ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# លទ្ធផលអង្កេតភពផែនដី

# នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៥

## (ខេត្តកំពង់ចាម និង ខេត្តត្បូងឃ្មុំ)

រៀបចំដោយៈ

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

ខែមីនា  ឆ្នាំ២០២៦

# របាយការណ៍
# លទ្ធផលអង្កេតកពផែនដី
# នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៥
## (ខេត្តកំពង់ចាម និង ខេត្តត្បូងឃ្មុំ)

វិទ្យាស្ថានជាតិស្ថិតិ
ក្រសួងផែនការ

ខែមីនា ឆ្នាំ២០២៦

# និមិត្តសញ្ញា
# ក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា
( Cambodia GEO )

# បុព្វកថា

របាយការណ៍លទ្ធផលអង្កេតភពផែនដី នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៥ គឺជាសមិទ្ធផលថ្មីមួយទៀតដែលវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការសម្រេចបាននៅក្នុងអាណត្តិទី៧ របស់រាជរដ្ឋាភិបាលកម្ពុជា។ របាយការណ៍នេះ បានសិក្សាលើខេត្តចំនួន២ ដែលស្ថិតនៅតំបន់ទំនាបកណ្តាលរួមមាន ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ បន្ទាប់ពីស្ថានភាពឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ស្ទើរតែលែងមានឥទ្ធិពលទៅហើយ។ អង្កេតភពផែនដី ឆ្នាំ២០២៥ គឺជាអង្កេតលើកទី៧ ដែលបានអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បន្ទាប់ពីប្រទេសកម្ពុជាបានចូលជាសមាជិកទី១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីនៅឆ្នាំ២០១៧។

អង្កេតភពផែនដី ឆ្នាំ២០២៥ បានប្រមូលទិន្នន័យ និងសូចនាករសំខាន់ៗមួយចំនួនរួមមាន ស្ថានភាពលក្ខណៈប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ទំនាបកណ្តាលនៃខេត្តគោលដៅចំនួន២ គឺ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។ វិធីសាស្ត្រនៃការប្រមូលទិន្នន័យនៃអង្កេតនេះ ត្រូវបានធ្វើឡើងតាមរយៈ ការសម្ភាសប្រធានភូមិ និងមេគ្រួសារនៅក្នុងខេត្តគោលដៅ ខណៈដែលប្រទេសកម្ពុជាពុំទាន់មានផ្កាយរណប និងពុំទាន់មានប្រទេសណាមួយបានផ្តល់នូវទិន្នន័យ តាមរយៈផ្កាយរណបនៅឡើយ។

របាយការណ៍លទ្ធផលអង្កេតភពផែនដី ឆ្នាំ២០២៥ គឺជាប្រភពទិន្នន័យសំខាន់ៗសម្រាប់អ្នកធ្វើគោលនយោបាយ ក្នុងការរៀបចំធ្វើផែនការ និងគោលនយោបាយពាក់ព័ន្ធនឹងការតាមដានត្រួតពិនិត្យលក្ខណៈប្រជាសាស្ត្រ បរិស្ថាន ការពារគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងមានវិធានការសមស្របសម្រាប់ដោះស្រាយបញ្ហាដែលបានរកឃើញទាំងអស់នេះ បន្ថែមពីលើទិន្នន័យដែលបានមកពីប្រភពដទៃទៀត ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល អ្នកស្រាវជ្រាវ និងអ្នកវិភាគនានា ក៏អាចទទួលបាននូវអត្ថប្រយោជន៍ពីរបាយការណ៍នេះផងដែរ តាមរយៈការសិក្សាស្វែងយល់អំពីលក្ខណៈប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅក្នុងខេត្តគោលដៅទាំងពីរខាងលើ។

តាងនាមក្រសួងផែនការ ខ្ញុំសូមគោរពថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុតចំពោះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់ការគាំទ្រយ៉ាងពេញទំហឹង ជំរុញឱ្យការងារនេះសម្រេចបានលទ្ធផលគួរជាទីមោទនៈ។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះថ្នាក់ដឹកនាំ មន្ត្រីជំនាញនៃវិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីដែលចុះស្រង់ទិន្នន័យតាមខេត្តគោលដៅទាំង២ ដែលខិតខំព្យាយាមបំពេញភារកិច្ចយ៉ាងសកម្ម និងហ្មត់ចត់ រហូតដល់ការងារនេះសម្រេចបានភាពជោគជ័យ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគ្រប់ក្រសួង ស្ថាប័នជាតិ អន្តរជាតិនានា អ្នកសិក្សាស្រាវជ្រាវ និងសាធារណជននឹងទទួលបានអត្ថប្រយោជន៍ពីរបាយការណ៍នេះ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មីនា ឆ្នាំ២០២៦

រដ្ឋមន្ត្រី

ប៊ិន ត្រាឈៃ

# អារម្ភកថា

របាយការណ៍លទ្ធផលនៃអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៥នេះ គឺជារបាយការណ៍ទី៧ ដែលផលិតដោយក្រុមការងារនៃក្រុមសង្កេតការណ៍ភពផែនដី ដែលស្ថិតនៅក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ ចាប់តាំងពីប្រទេសកម្ពុជា បានចូលជាសមាជិកទី១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីនៅឆ្នាំ២០១៧ រួចមក គម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជា បានអនុវត្តសកម្មភាពការងារចាប់តាំងពីឆ្នាំ២០១៩ រហូតមកដល់ឆ្នាំ២០២៤ ក្រុមការងារនៃក្រុមសង្កេតការណ៍ភពផែនដីនៃវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានផលិតចេញនូវរបាយការណ៍លទ្ធផលស្តីពីអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាបានចំនួន៦ដងរួចមកហើយ ដោយផ្អែកលើការចុះស្រង់ទិន្នន័យជាក់ស្តែងនៅតាមបណ្តាខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងទិន្នន័យដែលបានផលិតដោយក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន និងទិន្នន័យដែលបានពីការចែករំលែកតាមរយៈផ្កាយរណបដែលផ្តោតទៅលើផ្ទៃដីគ្របដណ្តប់។ ទិន្នន័យដែលបានចុះស្រង់នៅតាមបណ្តាខេត្តចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ មានខេត្តចំនួន៥ ដែលជាប់បឹងទន្លេសាប គឺខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ។ នៅក្នុងឆ្នាំ២០២២កន្លងទៅ បានចុះស្រង់ទិន្នន័យនៅក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ។ នៅក្នុងឆ្នាំ២០២៣ គឺបានចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពត និងខេត្តកែប។ នៅក្នុងឆ្នាំ២០២៤ បានចុះស្រង់ទិន្នន័យនៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង។ នៅក្នុងឆ្នាំ២០២៥ គឺបានចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ នៅក្នុងការអនុវត្តគម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៥។ ថវិកាសម្រាប់អនុវត្តគម្រោងខាងលើនេះ គឺបានមកពីការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈថវិកាកម្មវិធីប្រចាំឆ្នាំរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

គោលបំណងចម្បងនៃអង្កេតនេះ គឺដើម្បីប្រមូលនូវសូចនាករសំខាន់ៗទាក់ទងនឹងប្រជាសាស្ត្របរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ តាមរយៈការសម្ភាសមេភូមិ និងមេគ្រួសារ នៅក្នុងភូមិមួយចំនួនដែលបានជ្រើសរើសធ្វើការសម្ភាស និងការប្រមូលទិន្នន័យពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធដែលបានផលិត ជំនួសឱ្យការទទួលបានទិន្នន័យពីផ្កាយរណប និងឧបករណ៍ថតរូបភាពផ្សេងៗដែលថតពីលើអាកាស ខណៈដែលបច្ចុប្បន្នការប្រមូលទិន្នន័យបែបនេះ នូវពុំទាន់មានលទ្ធភាពធ្វើទៅបាន។ លទ្ធផលអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៥នេះ រួមមានរបាយការណ៍លទ្ធផលអង្កេតជាឯកសារសៀវភៅបោះពុម្ព និងឯកសារជាអេឡិចត្រូនិក ហើយក៏បានដាក់ចូលនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការផងដែរ។ របាយការណ៍អង្កេតភពផែនដី គឺជារង្វាស់វាស់វែងនូវការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ផងដែរ តាមរយៈរបកគំហើញដែលបានរកឃើញ ពីព្រោះថាបើសិនជា ភពផែនដីបានជួបប្រទះនូវគ្រោះមហន្តរាយច្រើននោះ គឺជាហេតុផលដែលនាំឱ្យការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ មិនអាចសម្រេចបានឡើយ។

ខ្ញុំសូមគោរពថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តម ប៊ិន ត្រាឈៃ រដ្ឋមន្ត្រីក្រសួងផែនការ** ដែលបានជួយគាំទ្រ ជំរុញ និងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ក្នុងការអនុវត្តការងារស្ថិតិប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ខ្ញុំសូមគោរពថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន អតីតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ដែលបានផ្តល់អនុសាសន៍ល្អៗ និងជំរុញលើកទឹកចិត្តដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានចូលរួមនៅក្នុងការអនុវត្តគម្រោងរហូតទទួលបានជោគជ័យ។

ខ្ញុំសូមគោរពថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តម រិន ធីរៈ ទីប្រឹក្សាផ្ទាល់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជារដ្ឋលេខាធិការក្រសួងផែនការ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិស្ថិតិ និង **លោកជំទាវ ហង់ លីណា** អតីតប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងបច្ចុប្បន្នជារដ្ឋលេខាធិការក្រសួងផែនការ ដែលបានយកចិត្តទុកដាក់ និងបានណែនាំដល់មន្ត្រីចុះស្រង់ទិន្នន័យ និងកែច្នៃទិន្នន័យឱ្យមានគុណភាពល្អ។ ខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះ **លោកបណ្ឌិត ម៉េខ គីមហ៊ី** អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ និងជាប្រធានក្រុមការងារដឹកនាំគម្រោងអង្កេតភពផែនដី និងលោកប្រធានមន្ទីរផែនការខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ដែលបានសហការល្អនៅក្នុងអំឡុងពេលចុះស្រង់ទិន្នន័យនៅក្នុងខេត្តទាំង២ខាងលើ រហូតទទួលបានជោគជ័យ។

តាងនាមឱ្យវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ខ្ញុំសូមបង្ហាញជូននូវរបាយការណ៍លទ្ធផលនៃអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ ដែលជាសមិទ្ធផលថ្មីមួយទៀតរបស់វិទ្យាស្ថានជាតិស្ថិតិជូនដល់ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូរអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកប្រើប្រាស់ទិន្នន័យដទៃទៀត និងសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះតម្រូវការលទ្ធផលនៃទិន្នន័យជាឯកសារសៀវភៅបោះពុម្ព និងឯកសារជាអេឡិចត្រូនិក ដែលប្រមូលបានពីការធ្វើអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៥នេះ ពីគ្រប់មជ្ឈដ្ឋាននៃអ្នកប្រើប្រាស់ទិន្នន័យទាំងឡាយ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦

**នាយកវិទ្យាស្ថានជាតិស្ថិតិ**

**ទ្រី ឫទ្ធា**

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍លទ្ធផលនៃអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៥ សម្រាប់ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំនេះ នឹងមិនអាចដំណើការទៅបានឡើយ បើគ្មានការចូលរួមវិភាគទាន និងការលះបង់របស់មន្ត្រីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពីស្ថាប័នពាក់ព័ន្ធមួយចំនួនមានជាអាទិ៍ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧតុនិយម អាជ្ញាធរមីនកម្ពុជា និងអាជ្ញាធរជាតិគ្រប់គ្រងគ្រោះមហន្តរាយទនោះ។

ក្រុមការងារនឹងមិនអាចសម្រេចសមិទ្ធផលមួយនេះបានឡើយ បើគ្មានការផ្តល់លទ្ធភាពទាំងឱកាសសន្តិភាព និងការគាំទ្រផ្នែកថវិកាជាតិសម្រាប់ដំណើរការការងារនេះ ជាពិសេសក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រកបដោយសក្តានុពលខ្លាំងក្លា និងមានចក្ខុវិស័យប្រកបដោយគតិបណ្ឌិត។

ជាការពិតណាស់ ដោយសារមានការណែនាំ និងចង្អុលបង្ហាញពីថ្នាក់ដឹកនាំនៃក្រសួងផែនការកន្លងមករួមមាន **ឯកឧត្តម ប៊ិន ត្រឈៃ រដ្ឋមន្ត្រីក្រសួងផែនការ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន អតីតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ឯកឧត្តម រិន ធីរះ ទីប្រឹក្សាផ្ទាល់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជារដ្ឋលេខាធិការក្រសួងផែនការ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិស្ថិតិ លោកជំទាវ **ហាង់ លីណា** អតីតប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងបច្ចុប្បន្នជារដ្ឋលេខាធិការ**នៃក្រសួងផែនការ ឯកឧត្តម ទ្រី ឬទ្ធា នាយកវិទ្យាស្ថានជាតិស្ថិតិ** និងឯកឧត្តម លោកជំទាវ ដែលជាថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃក្រសួងផែនការបច្ចុប្បន្ន ព្រមទាំងលោកប្រធានមន្ទីរផែនការខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ និងមន្ត្រីពាក់ព័ន្ធដទៃទៀត ទើបក្រុមការងារបានបញ្ចប់របាយការណ៍នេះ ប្រកបដោយជោគជ័យទៅតាមផែនការដូចដែលបានគ្រោងទុក។

តាងនាមឱ្យក្រុមការងារកសាងរបាយការណ៍នេះ ខ្ញុំសូមគោរពសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរដល់ **ឯកឧត្តម ប៊ិន ត្រឈៃ រដ្ឋមន្ត្រីក្រសួងផែនការ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន អតីតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ឯកឧត្តម រិន ធីរះ ទីប្រឹក្សាផ្ទាល់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជារដ្ឋលេខាធិការក្រសួងផែនការ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិស្ថិតិ លោកជំទាវ **ហាង់ លីណា** អតីតប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងបច្ចុប្បន្នជារដ្ឋលេខាធិការ

**នៃក្រសួងផែនការ ឯកឧត្តម ទ្រី ចន្ធា នាយកវិទ្យាស្ថានជាតិស្ថិតិ** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការផ្តល់អនុសាសន៍ ក៏ដូចជាត្រួតពិនិត្យកែលម្អរបាយការណ៍នេះឱ្យកាន់តែប្រសើរ និងថ្នាក់ដឹកនាំអង្គភាពជំនាញ និងអ្នកបច្ចេកទេសទាំងអស់ក្នុងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ព្រមទាំងមន្ត្រីជំនាញរបស់មន្ទីរផែនការខេត្តទាំងពីរ ដែលបានចូលរួមការងារខាងលើ រហូតទទួលបានជោគជ័យគួរជាទីគាប់ចិត្ត។

ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណដល់វត្តមានចូលរួម និងផ្តល់គំនិតយោបល់ល្អៗពីសមាជិកក្រុមការងារ ក៏ដូចជាអនុសាសន៍ពីសំណាក់ស្ថាប័នពាក់ព័ន្ធផ្សេងៗ ដែលបានលះបង់ទាំងពេលវេលា កម្លាំងកាយ និងបញ្ញាទាំងអស់ ពិតជាមានតម្លៃសម្រាប់ជំរុញឱ្យរបាយការណ៍នេះ បានលេចចេញជារូបរាង និងទទួលបានផ្លែផ្កាឡើង។

តាងនាមឱ្យក្រុមការងារកសាងរបាយការណ៍ខាងលើនេះ អនុញ្ញាតឱ្យខ្ញុំសូមគោរពជូនពរដល់សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ជួបប្រទះនូវពុទ្ធពរទាំង៥ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦

**អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ**
**ទទួលបន្ទុកអនុវត្តគម្រោងអង្កេតភពផែនដី**

**បណ្ឌិត ម៉េង គីមហ៊ា**

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| CDB | Commune Database<br>ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ |
| COVID-19 | Coronavirus Disease 2019<br>ជំងឺឆ្លងវីរុសកូរ៉ូណា ២០១៩ |
| CSPro | Census and Survey Processing System<br>ប្រព័ន្ធកែច្នៃជំរឿន និងអង្កេត |
| GDP | Gross Domestic Products<br>ផលិតផលក្នុងស្រុកសរុប |
| GEO | Group on Earth Observations<br>ក្រុមសង្កេតការណ៍ភពផែនដី |
| KAP3 | Third Study on Understanding Public Perceptions of Climate Change in Cambodia: Knowledge, Attitudes, and Practices<br>ការសិក្សាលើកទី៣ស្តីអំពីការស្វែងយល់លើការយល់ដឹងជាសាធារណៈនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា: ការយល់ដឹង, អាកប្បកិរិយា និងការអនុវត្ត |
| P-Value | Probability Value<br>តម្លៃប្រូបាប៊ីលីតេ |
| PM2.5 | Fine particulate matter less than 2.5 µm in diameter<br>កម្រិតខ្យល់ល្អកម្រិតល្អិតតិចជាង២,៥ µm នៅក្នុងដាយ៉ាម៉ែត្រ |
| NASA | National Aeronautics and Space Administration<br>រដ្ឋបាលអវកាស និងអវកាសនាវាវិជ្ជាជាតិ |
| NMVOCs | Non methane volatile organic compounds (NMVOC)<br>សមាធាតុសរីរាង្គងាយប្រែប្រួលប្រភេទមិនមែនមេតាន |
| ROC | Receiver Operating Curves |
| SDGs | Sustainable Development Goals<br>គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| UI | Uncertainty Interval<br>ចន្លោះពីចំនួន..ដល់ |
| UN | United Nations<br>អង្គការសហប្រជាជាតិ |
| UNFCCC | United Nations Framework Convention on Climate Change<br>អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |

| | | |
|---|---|---|
| UNTAC | United Nations Transitional Authority of Cambodia<br>អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា |
| WHO | World Health Organization<br>អង្គការសុខភាពពិភពលោក |
| WWI | World War I<br>សង្គ្រាមលោកលើកទី១ |
| WWII | World War II<br>សង្គ្រាមលោកលើកទី២ |

# មាតិកា

ទំព័រ


និមិត្តសញ្ញាក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា....................i
បុព្វកថា....................ii
អារម្ភកថា....................v
សេចក្តីថ្លែងអំណរគុណ....................vi

**ជំពូក ១ សេចក្តីផ្តើម**....................១

១.១ សេចក្តីផ្តើម....................១
១.២ គោលបំណង....................២
១.៣ វិធីសាស្ត្រប្រមូលទិន្នន័យ....................២
១.៤ ការកែច្នៃទិន្នន័យ....................៣
១.៥ វិសាលភាព....................៤
១.៦ សារៈប្រយោជន៍....................៤

**ជំពូក ២ ស្ថានភាពទូទៅ**....................៥

២.១ ស្ថានភាពទូទៅផ្អែកលើទិន្នន័យទី២....................៥
២.១.១ ប្រជាសាស្ត្រ....................៥
២.១.២ ទីប្រជុំជន គ្រួសារ អគារ និងលំនៅឋាន....................៤៤
២.១.៣ បរិស្ថាន ទឹកស្អាត និងបង្គន់អនាម័យ....................៥៦
២.១.៤ ស្ថានភាពគ្រោះមហន្តរាយ....................៩១
២.១.៥ ការប្រែប្រួលអាកាសធាតុ....................១៣៧
២.១.៦ ការព្យាករណ៍ទិន្នផលស្រូវ បរិមាណផលស្រូវ ចំណូលជាមធ្យមសម្រាប់មនុស្ស និងផលិតផលក្នុងស្រុកសរុប ដោយប្រើប្រាស់ម៉ូដែល Linear Relation or Regression Analysis Model....................១៥៤
២.២. ស្ថានភាពទូទៅផ្អែកលើទិន្នន័យទី៣ (ផ្កាយរណប)....................១៧៤
២.២.១ ផ្ទៃដីគ្របដណ្តប់....................១៧៤

**ជំពូក ៣ ការវិភាគលទ្ធផលផ្អែកលើទិន្នន័យទី១**....................១៨២

៣.១ លទ្ធផលផ្អែកលើទិន្នន័យទី១....................១៨២
៣.១.១ លទ្ធផលពីការសម្ភាសន៍មេភូមិ....................១៨២
៣.១.២ លទ្ធផលពីការសម្ភាសន៍មេគ្រួសារ....................១៨៨

**ជំពូក ៤ របកគំហើញ និង សន្និដ្ឋាន** ............ ២២២
៤.១ របកគំហើញ ............ ២២២
៤.១.១ របកគំហើញផ្អែកលើទិន្នន័យទី១ ............ ២២២
៤.១.២ របកគំហើញផ្អែកលើទិន្នន័យទី២ ............ ២២៥
៤.១.៣ របកគំហើញផ្អែកលើទិន្នន័យទី៣ (ផ្កាយរណប) ............ ២៣០
៤.២ សន្និដ្ឋាន ............ ២៣០
**ឯកសារយោង** ............ ២៣២
**ឧបសម្ព័ន្ធ** ............ ២៣៧

# បញ្ជីតារាង


| តារាងលេខ | ចំណងជើងតារាង | ទំព័រ |
|---|---|---|
| តារាង១ | បញ្ជីភូមិគោលដៅសម្រាប់ធ្វើការសម្ភាសន៍ស្រង់ទិន្នន័យនៅក្នុង ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ៣ |
| តារាង២ | ចំនួនមេភូមិតាមក្រុមអាយុ និងភេទ | ៧ |
| តារាង៣ | តារាងសង្ខេបអាយុមេភូមិតាមលទ្ធផលដែលបានពី Box and Whisker Plot ពីឆ្នាំ២០២០ដល់ ២០២៥ | ៧ |
| តារាង៤ | ចំនួនប្រជាជន គ្រួសារធ្វើការងារតាមវិស័យសេដ្ឋកិច្ច និងចំនួនគ្រួសារដែលប្រើប្រាស់ទឹក អគ្គិសនី និងបង្គន់អនាម័យនៅក្នុងភូមិ | ៩ |
| តារាង៥ | ចំនួនមេគ្រួសារ បែងចែកតាមក្រុមអាយុ | ១៥ |
| តារាង៦ | ទិន្នន័យសង្ខេបអាយុមេគ្រួសារទាំងពីរភេទតាមលទ្ធផលដែលបាន ពី Box and Whisker Plot ពីឆ្នាំ២០២០ដល់ ២០២៥ | ១៥ |
| តារាង៧ | តារាងសង្ខេបអាយុមេគ្រួសារតាមភេទតាមលទ្ធផលដែលបាន ពី Box and Whisker Plot ឆ្នាំ២០២៥ | ១៧ |
| តារាង៨ | ចំនួនគ្រួសារ និងសមាជិកគ្រួសារឆ្នាំ២០២៥ | ១៨ |
| តារាង៩ | ចំនួនសមាជិគ្រួសារបែងតាមក្រុមអាយុនិងភេទមេគ្រួសារ | ១៩ |
| តារាង១០ | ចំនួនសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកឆ្នាំ២០២៥ | |
| តារាង១១ | ចំនួនសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកបែងចែកតាមភេទ និងក្រុមអាយុរបស់មេគ្រួសារឆ្នាំ២០២៥ | ២១ |
| តារាង១២ | ចំនួនសមាជិកបានធ្វើការងារតាមផ្នែកនៃការងារ | ២៤ |
| តារាង១៣ | ចំនួនសមាជិកគ្រួសារបានធ្វើការងារតាមផ្នែកនៃការងារបែងចែកតាមភេទ និងក្រុមអាយុមេគ្រួសារ | ២៦ |
| តារាង១៤ | មុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារ | ២៧ |
| តារាង១៥. | មុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារទាំងពីរភេទ បែងចែកតាមភេទ និងក្រុមអាយុនៃមេគ្រួសារ | ២៩ |
| តារាង១៦ | មុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារភេទប្រុស បែងចែកតាមភេទ និងក្រុមអាយុនៃមេគ្រួសារ | ៣០ |
| តារាង១៧ | មុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារភេទស្រី បែងចែកតាមភេទ និងក្រុមអាយុនៃមេគ្រួសារ | ៣១ |
| តារាង១៨ | សមាជិកគ្រួសារដែលបានធ្វើការងារតាមវិស័យសេដ្ឋកិច្ចតាមក្រុមអាយុនៃភេទមេគ្រួសារ | ៣២ |
| តារាង១៩ | ភាគរយសមាជិកគ្រួសារដែលបានធ្វើការងារតាមវិស័យសេដ្ឋកិច្ចតាមក្រុមអាយុនៃភេទមេគ្រួសារ | ៣៣ |

| តារាងលេខ | ចំណងជើងតារាង | ទំព័រ |
|---|---|---|
| តារាង២០ | ការប្រើប្រាស់បង្គន់ ការប្រមូលសំរាម និងផលប៉ះពាល់បរិស្ថាន | ៣៦ |
| តារាង២១ | ចំនួនមេគ្រួសារដែលបានទទួលព័ត៌មានគ្រោះមហន្តរាយ | ៣៨ |
| តារាង២២ | ភាគរយនៃមេគ្រួសារតាមក្រុមអាយុដែលបានទទួលព័ត៌មានគ្រោះមហន្តរាយបែងចែកភេទនៃមេគ្រួសារ | ៣៩ |
| តារាង២៣ | ចំនួនគ្រួសារដែលទទួលរងគ្រោះមហន្តរាយតាមភេទនៃមេគ្រួសារ | ៤១ |
| តារាង២៤ | ចំនួនទឹកប្រាក់ដែលបាត់បង់តាមប្រភេទនៃគ្រោះមហន្តរាយ | ៤៤ |
| តារាង២៥ | ទិន្នន័យអថេរសម្រាប់ Run Logistics Regression | ៤៥ |
| តារាង២៦ | តារាងលទ្ធផលនៃការ Run Logistic Regression Model | ៤៦ |
| តារាង២៧ | តារាងលទ្ធផលនៃការព្យាករណ៍ផលប៉ះពាល់ដោយគ្រោះមហន្តរាយដោយប្រើប្រាស់ Logistic Regression Model | ៤៧ |
| តារាង២៨ | តារាងពិនិត្យភាពត្រឹមត្រូវកំណត់យកម្រិត(Threshold)ស្មើនឹង 0.3 | ៤៩ |
| តារាង២៩ | តារាងភាគរយនៃភាពត្រឹមត្រូវតាមកម្រិត (Threshold) | ៤៩ |
| តារាង៣០ | តារាងលទ្ធផល True Positive Rate (TPR) និង False Positive Rate តាមកម្រិត (Threshold) | ៥០ |
| តារាង៣១ | ចំនួនគ្រួសារដែលបានសម្ភាសន៍ទាក់ទងលក្ខណៈអាកាសធាតុ | ៥៤ |
| តារាង៣២ | ភាគរយគ្រួសារដែលបានសម្ភាសន៍ទាក់ទងលក្ខណៈអាកាសធាតុ | ៥៥ |
| តារាង៣៣ | ចំនួនគ្រួសារដែលរំពឹងទុកដែលអាចនឹងបានឆ្លើយទាក់ទងលក្ខណៈអាកាសធាតុ | ៥៥ |
| តារាង៣៤ | លទ្ធផល Chi Square ($X^2$) Test ទាក់ទងលក្ខណៈអាកាសធាតុ | ៥៦ |
| តារាង៣៥ | Table of chi-squared distribution | ៥៧ |
| តារាង៣៦ | ចំនួនប្រជាជនពិភពលោក ១៩៩៥ ២០២៤ ២០៥៤ និង២១០០ | ៦០ |
| តារាង៣៧ | ចំនួនប្រជាជនតាមបណ្តាខេត្តស្ថិតនៅក្នុងតំបន់ទំនាបកណ្តាល | ៦៦ |
| តារាង៣៨ | ចំនួនប្រជាជននិងចំនួនគ្រួសារសរុប ពីឆ្នាំ ១៩៩៨ ដល់ ២០៣៥ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ គិតជានាក់ | ៦៨ |
| តារាង៣៩ | ចំនួនជនអន្តោប្រវេសន៍អន្តរជាតិពីឆ្នាំ ១៩៧០ ដល់ ២០២០ | ៧៩ |
| តារាង៤០ | ប្រទេសចំនួន១០ដែលបានទទួលនិងផ្ញើប្រាក់ដោយសមាជិកគ្រួសារជាជនអន្តោប្រវេសន៍នៅក្រៅប្រទេស (២០១៩ដល់២០២២) គិតជាប៊ីលានដុល្លារ | ៨២ |
| តារាង៤១ | អ្នកមានការងារធ្វើ អ្នកគ្មានការងារធ្វើ និងអសកម្មជនសេដ្ឋកិច្ចដែលមានអាយុ៧ឆ្នាំឡើង | ៩៣ |
| តារាង៤២ | ចំនួនអ្នកចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច | ៩៦ |

| តារាងលេខ | ចំណងជើងតារាង | ទំព័រ |
|---|---|---|
| តារាង៤៣ | ចំនួនប្រជាជននៅតំបន់ទីប្រជុំជន | ១០២ |
| តារាង៤៤ | ចំនួនអគារ គ្រួសារ និង ចំនួនគ្រួសារដែលមានផ្ទះផ្ទាល់ខ្លួន | ១០៣ |
| តារាង៤៥ | ចំនួនគ្រួសារដែលកាន់កាប់តាមប្រភេទលំនៅដ្ឋាន | ១០៥ |
| តារាង៤៦ | ចំនួនផ្ទះបែងចែកតាមប្រភេទឆ្នាំ២០២១ | ១០៨ |
| តារាង៤៧ | ទិន្នន័យគុណភាពខ្យល់សាធារណៈស្ដីពី $PM_{2.5}$ ក្នុងរាជធានីភ្នំពេញពីឆ្នាំ ២០១៧ ដល់ ២០១៩ | ១១៤ |
| តារាង៤៨ | គុណភាពខ្យល់សាធារណៈឆ្នាំ២០១៩ (កម្រិតមធ្យមប្រចាំឆ្នាំ) | ១១៥ |
| តារាង៤៩ | ចំនួនគ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថានឆ្នាំ២០២១ ខេត្តកំពង់ចាម និង ខេត្តត្បូងឃ្មុំ | ១២៣ |
| តារាង៥០ | បរិមាណការប្រមូលសំណល់រឹងទីក្រុង ការចោលសំរាមខុសច្បាប់ និងការកែច្នៃឡើងវិញ ឆ្នាំ២០១៥ តាមតំបន់ | ១៣០ |
| តារាង៥១ | បរិមាណការប្រមូលសំណល់រឹងទីក្រុង ការចោលសំរាមខុសច្បាប់ និងការកែច្នៃឡើងវិញ ឆ្នាំ២០១៥ តាមខេត្តក្នុងតំបន់ទំនាបកណ្ដាល | ១៣១ |
| តារាង៥២ | ចំនួនផ្ទៃដីតំបន់ការពារធម្មជាតិ | ១៣៤ |
| តារាង៥៣ | ចំនួនគ្រួសារតាមទីតាំងប្រភពទឹកដែលយកមកប្រើប្រាស់ | ១៤១ |
| តារាង៥៤ | ចំនួនគ្រួសារដែលមានទឹកស្អាតប្រើប្រាស់ | ១៤១ |
| តារាង៥៥ | ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | ១៤៤ |
| តារាង៥៦ | ចំនួនអ្នកស្លាប់ដោយសារអគ្គីភ័យ ខ្យល់កន្ត្រាក់ និងរន្ទះបាញ់ | ១៥៨ |
| តារាង៥៧ | ចំនួនអ្នករងរបួសដោយសារអគ្គីភ័យ ខ្យល់កន្ត្រាក់ និងរន្ទះបាញ់ | ១៦០ |
| តារាង៥៨ | ទិន្នន័យរងផលប៉ះពាល់ និងខូចខាតដោយជំនន់ទឹកភ្លៀង និងទឹកជំនន់ទន្លេមេគង្គឆ្នាំ២០២៥ | ១៦២ |
| តារាង៥៩ | ការប៉ះពាល់ និងខូចខាតដោយសារគ្រោះរាំងស្ងួតឆ្នាំ២០២៥ | ១៦៨ |
| តារាង៦០ | ស្ថានភាពរងគ្រោះដោយការបាក់ច្រាំងទន្លេ ស្ទឹងឆ្នាំ២០២៥ | ១៦៩ |
| តារាង៦១ | ស្ថានភាពរងគ្រោះដោយសារខ្យល់កន្ត្រាក់ឆ្នាំ២០២៥ ទូទាំងប្រទេស | ១៧១ |
| តារាង៦២ | ការខាតបង់ផ្នែកសេដ្ឋកិច្ចបែងចែកតាមវិស័យ ឆ្នាំ២០០៩ | ១៧៣ |
| តារាង៦៣ | ស្ថានភាពរងគ្រោះដោយសាររន្ទះបាញ់ទូទាំងប្រទេស | ១៧៥ |
| តារាង៦៤ | ស្ថានភាពរងគ្រោះដោយសារអគ្គីភ័យទូទាំងប្រទេស | ១៧៦ |
| តារាង៦៥ | ស្ថានភាពកូវីដ១៩ ក្នុងឆ្នាំ២០២៥ | ១៨៣ |
| តារាង៦៦ | ស្ថានភាពគ្រោះជំងឺផ្ដាសាយបក្សី H1N1 | ១៨៤ |
| តារាង៦៧ | ស្ថានភាពជំងឺគ្រុនឈាម | ១៨៥ |
| តារាង៦៨ | ចំនួនប្រជាជន និង ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១ | ១៨៨ |
| តារាង៦៩ | ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី២ | ១៩៤ |

| តារាងលេខ | ចំណងជើងតារាង | ទំព័រ |
|---|---|---|
| តារាង៧០ | ផលប៉ះពាល់ដល់វិស័យសង្គមកិច្ច | ១៩៩ |
| តារាង៧១ | ផលប៉ះពាល់ដល់វិស័យអប់រំ | ២០០ |
| តារាង៧២ | ផលប៉ះពាល់ដល់វិស័យហេដ្ឋារចនាសម្ព័ន្ធ | ២០១ |
| តារាង៧៣ | សីតុណ្ហភាពអប្បបរមា (អប្បបរមា អតិបរមា និងមធ្យមភាគ) ពីឆ្នាំ២០០៣ ដល់ ២០២៥ | ២១០ |
| តារាង៧៤ | សីតុណ្ហភាពអតិបរមា (អប្បបរមា អតិបរមា និងមធ្យមភាគ) ពីឆ្នាំ២០០៣ដល់ ២០២៥ | ២១១ |
| តារាង៧៥ | កម្ពស់ទឹកអតិបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២៥ គិតជាម៉ែត្រ | ២១៣ |
| តារាង៧៦ | កម្ពស់ទឹកអប្បបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២៥ គិតជាម៉ែត្រ | ២១៥ |
| តារាង៧៧ | កំណត់អថេរឯករាជ្យ និងអថេរមិនឯករាជ្យសម្រាប់ព្យាករណ៍ទិន្នផលស្រូវ | ២២២ |
| តារាង៧៨ | ការព្យាករណ៍ទិន្នផលស្រូវពីឆ្នាំ២០២៦ ដល់ ២០៣៥ | ២២៣ |
| តារាង៧៩ | កំណត់អថេរឯករាជ្យ និងអថេរមិនឯករាជ្យសម្រាប់ព្យាករណ៍បរិមាណផលស្រូវ | ២២៤ |
| តារាង៨០ | ការព្យាករណ៍បរិមាណផលស្រូវពីឆ្នាំ២០២៦ ដល់ ២០៣៥ | ២២៦ |
| តារាង៨១ | កំណត់អថេរឯករាជ្យ និងអថេរមិនឯករាជ្យសម្រាប់ព្យាករណ៍ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ (GDP Per Capita) | ២២៨ |
| តារាង៨២ | ការព្យាករណ៍ចំណូលសម្រាប់មនុស្សម្នាក់ (GDP Per Capita) ពីឆ្នាំ២០២៦ ដល់ ២០៣៥ | ២៣០ |
| តារាង៨៣ | កំណត់អថេរឯករាជ្យ និងអថេរមិនឯករាជ្យសម្រាប់ព្យាករណ៍ GDP | ២៣១ |
| តារាង៨៤ | ការព្យាករណ៍ផលិតផលសរុប (GDP) ពីឆ្នាំ២០២៦ ដល់ ២០៣៥ | ២៣៣ |
| តារាង៨៥ | លទ្ធផលព្យាករណ៍ពីឆ្នាំ២០២៥ ដល់២០៣៥ ផ្អែកលើ Multiple Linear Regression Model | ២៣៤ |

# បញ្ជីក្រាហ្វិក


| ក្រាហ្វិកលេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|
| ក្រាហ្វិក១ | ភាគរយមេភូមិតាមភេទ | ៦ |
| ក្រាហ្វិក២ | ភាគរយមេភូមិដែលបានសម្ភាសន៍បែងចែកតាមខេត្ត និងភេទ | ៦ |
| ក្រាហ្វិក៣ | អាយុមេភូមិដែលបានសម្ភាសន៍បង្ហាញតាម Box and Whisker Plot | ៨ |
| ក្រាហ្វិក៤ | អាយុមេភូមិដែលបានសម្ភាសន៍ជា Median, Mean, First Quartile និង Third Quartile | ៨ |
| ក្រាហ្វិក៥ | ភាគរយគ្រួសារដែលមានទឹកស្អាត បង្គន់អនាម័យ និងអគ្គិសនីប្រើប្រាស់នៅក្នុងផ្ទះ | ១០ |
| ក្រាហ្វិក៦ | ភាគរយចំនួនសមាជិកក្នុងភូមិបានធ្វើការងារតាមវិស័យសេដ្ឋកិច្ច | ១០ |
| ក្រាហ្វិក៧ | ចំនួនគ្រួសារដែលរងផលប៉ះពាល់ដោយសារការបង្ហូរទឹកកខ្វក់ និងការចាក់សំរាមឆ្នាំ២០២៥ | ១១ |
| ក្រាហ្វិក៨ | ភាគរយនៃប្រភពព័ត៌មានគ្រោះមហន្តរាយដែលមេភូមិបានទទួលឆ្នាំ ២០២៥ | ១១ |
| ក្រាហ្វិក៩ | ចំនួនគ្រួសារដែលរងគ្រោះដោយសារខ្យល់ព្យុះ និង គ្រោះរាំងស្ងួត | ១២ |
| ក្រាហ្វិក១០ | ការខូចខាតដោយសារគ្រោះមហន្តរាយនៅក្នុងភូមិគិតជាទឹកប្រាក់ US$ | ១២ |
| ក្រាហ្វិក១១ | ការប្រែប្រួលអាកាសធាតុ និង គ្រោះរាំងស្ងួត | ១៣ |
| ក្រាហ្វិក១២ | ភាគរយនៃមេគ្រួសារដែលបានសម្ភាសន៍ | ១៤ |
| ក្រាហ្វិក១៣ | ភាគរយនៃមេគ្រួសារតាមក្រុមអាយុដែលបានសម្ភាសន៍ | ១៤ |
| ក្រាហ្វិក១៤ | អាយុមេគ្រួសារទាំងពីរភេទដែលបានសម្ភាសន៍បង្ហាញតាម Box and Whisker Plot | ១៦ |
| ក្រាហ្វិក១៥ | អាយុមេគ្រួសារតាមភេទដែលបានសម្ភាសន៍ឆ្នាំ២០២៥ បង្ហាញតាម Box and Whisker Plot | ១៧ |
| ក្រាហ្វិក១៦ | ទំហំគ្រួសារគិតជាមធ្យម | ១៨ |
| ក្រាហ្វិក១៧ | ភាគរយសមាជិកចំណាកស្រុក | ២០ |
| ក្រាហ្វិក១៨ | ចំនួនសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកទៅតាមបណ្តាខេត្ត | ២២ |
| ក្រាហ្វិក១៩ | ចំនួនសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកទៅក្រៅប្រទេស | ២២ |
| ក្រាហ្វិក២០ | មូលហេតុដែលធ្វើចំណាកស្រុកក្នុងប្រទេស | ២៣ |
| ក្រាហ្វិក២១ | មូលហេតុស្វែងរកការងារធ្វើសម្រាប់ចំណាកស្រុកក្រៅប្រទេសបែងចែកតាមភេទ | ២៣ |

| ក្រាហ្វិកលេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|
| ក្រាហ្វិក២២ | ភាគរយសមាជិកគ្រួសារដែលបានធ្វើការងារតាមផ្នែកនៃការងារទាំងពីរភេទ | ២៤ |
| ក្រាហ្វិក២៣ | ភាគរយសមាជិកគ្រួសារដែលបានធ្វើការងារតាមផ្នែកនៃការងារ | ២៥ |
| ក្រាហ្វិក២៤ | ភាគរយនៃមុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារទាំងពីរភេទ និងមេគ្រួសារទាំងពីរភេទ | ២៧ |
| ក្រាហ្វិក២៥ | ភាគរយនៃមុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារភេទប្រុស និងមេគ្រួសារទាំងពីរភេទ | ២៨ |
| ក្រាហ្វិក២៦ | ភាគរយនៃមុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារភេទស្រី និងមេគ្រួសារទាំងពីរភេទ | ២៨ |
| ក្រាហ្វិក២៧ | ភាគរយសមាជិកគ្រួសារដែលធ្វើការតាមវិស័យសេដ្ឋកិច្ចសម្រាប់មេគ្រួសារទាំងពីរភេទ | ៣៤ |
| ក្រាហ្វិក២៨ | ភាគរយសមាជិកគ្រួសារដែលធ្វើការតាមវិស័យសេដ្ឋកិច្ចសម្រាប់មេគ្រួសារជាបុរស | ៣៤ |
| ក្រាហ្វិក២៩ | ភាគរយសមាជិកគ្រួសារដែលធ្វើការតាមវិស័យសេដ្ឋកិច្ចសម្រាប់មេគ្រួសារជាស្ត្រី | ៣៥ |
| ក្រាហ្វិក៣០ | ភាគរយគ្រួសារដែលមានបង្គន់ប្រើប្រាស់ សេវាប្រមូលសំរាមទីតាំងប្រមូលសំរាម និងផលប៉ះពាល់បរិស្ថាន | ៣៦ |
| ក្រាហ្វិក៣១ | ចំនួន/ភាគារយគ្រួសារទទួលព័ត៌មានគ្រោះមហន្តរាយ | ៣៧ |
| ក្រាហ្វិក៣២ | ភាគរយមេគ្រួសារទាក់ទងការទទួលព័ត៌មានគ្រោះមហន្តរាយ | ៣៩ |
| ក្រាហ្វិក៣៣ | ចំនួនមេគ្រួសារដែលបានទទួលព័ត៌មានគ្រោះមហន្តរាយតាមប្រភពនៃព័ត៌មាន | ៤០ |
| ក្រាហ្វិក៣៤ | ភាគរយគ្រួសារដែលបានទទួលរងគ្រោះដោយសារគ្រោះមហន្តរាយ | ៤១ |
| ក្រាហ្វិក៣៥ | ភាគរយគ្រួសារដែលបានទទួលរងគ្រោះដោយគ្រោះមហន្តរាយតាមភេទមេគ្រួសារ | ៤២ |
| ក្រាហ្វិក៣៦ | ចំនួនគ្រោះមហន្តរាយដែលគ្រួសារបានទទួលរងគ្រោះ | ៤៣ |
| ក្រាហ្វិក៣៧ | ចំនួនគ្រួសារដែលទទួលរងគ្រោះតាមប្រភេទនៃគ្រោះមហន្តរាយ | ៤៣ |
| ក្រាហ្វិក៣៨ | ចំនួនទឹកប្រាក់ដែលបាត់បង់ដោយសារគ្រោះមហន្តរាយ | ៤៤ |
| ក្រាហ្វិក៣៩ | ភាគរយផលប៉ះពាល់លើគ្រួសារនីមួយៗដោយសារគ្រោះមហន្តរាយតាមការព្យាករណ៍ Logistic Regression Model | ៤៨ |
| ក្រាហ្វិក៤០ | ROC Curve | ៥១ |

| ក្រាហ្វិកលេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|
| ក្រាហ្វិក៤១ | ស្ថានភាពទឹកភ្លៀងតាមការសម្ភាសន៍មេគ្រួសារ | ៥១ |
| ក្រាហ្វិក៤២ | ស្ថានភាពអាកាសធាតុតាមការសម្ភាសន៍មេគ្រួសារ | ៥២ |
| ក្រាហ្វិក៤៣ | ស្ថានភាពអាកាសធាតុតាមការសម្ភាសន៍មេគ្រួសារឆ្នាំ២០២២ ដល់ ២០២៥ | ៥៣ |
| ក្រាហ្វិក៤៤ | លទ្ធផល Chi-square ($X^2$) ធៀបជាមួយ Chi-square ($X^2$) នៅក្នុងតារាង | ៥៨ |
| ក្រាហ្វិក៤៥ | និន្នាការចំនួនប្រជាជនពិភពលោកពីឆ្នាំ១៩៦០ ដល់ ឆ្នាំ២០៥០ | ៥៩ |
| ក្រាហ្វិក៤៦ | និន្នាការចំនួនប្រជាជនសរុបទូទាំងប្រទេសកម្ពុជា | ៦៤ |
| ក្រាហ្វិក៤៧ | និន្នាការចំនួនប្រជាជនតាមតំបន់ក្នុងប្រទេសកម្ពុជា | ៦៥ |
| ក្រាហ្វិក៤៨ | ចំនួនប្រជាជនតាមបណ្តាខេត្តស្ថិតនៅក្នុងតំបន់ទំនាបកណ្តាល | ៦៦ |
| ក្រាហ្វិក៤៩ | និន្នាការចំនួនប្រជាជនសម្រាប់ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ៦៧ |
| ក្រាហ្វិក៥០ | ដង់ស៊ីតេប្រជាជនបែងចែកតាមពិភពលោក តំបន់ និងកម្ពុជា | ៦៩ |
| ក្រាហ្វិក៥១ | ដង់ស៊ីតេប្រជាជនពិភពលោក និងកម្ពុជា | ៧០ |
| ក្រាហ្វិក៥២ | ដង់ស៊ីតេប្រជាជនសម្រាប់ ពិភពលោក កម្ពុជា ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ៧១ |
| ក្រាហ្វិក៥៣ | ចំនួនជនអន្តោប្រវេសន៍អន្តរជាតិឆ្នាំ២០២៣ | ៧៨ |
| ក្រាហ្វិក៥៤ | ចំនួនជនអន្តោប្រវេសន៍ចេញពីប្រទេសមួយទៅប្រទេសមួយទៀត | ៨០ |
| ក្រាហ្វិក៥៥ | ចំនួនជនអន្តោប្រវេសន៍ដែលរស់នៅខុសពីលំនៅដ្ឋានរបស់ខ្លួនឆ្នាំ២០២២ | ៨០ |
| ក្រាហ្វិក៥៦ | ចំនួនទឹកប្រាក់ដែលបានផ្ញើទៅក្រុមគ្រួសារដែលរស់នៅក្នុងប្រទេស | ៨១ |
| ក្រាហ្វិក៥៧ | ការផ្លាស់ប្តូរទីលំនៅពីមុនទូទាំងប្រទេស | ៨៤ |
| ក្រាហ្វិក៥៨ | ការផ្លាស់ប្តូរទីលំនៅតាមតំបន់ទូទាំងប្រទេស | ៨៥ |
| ក្រាហ្វិក៥៩ | ការផ្លាស់ប្តូរទីលំនៅតាមតំបន់ឆ្នាំ ២០១៩ | ៨៦ |
| ក្រាហ្វិក៦០ | ការផ្លាស់ប្តូរទីលំនៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ៨៧ |
| ក្រាហ្វិក៦១ | មូលហេតុនៃការផ្លាស់ប្តូរទីលំនៅសម្រាប់ទូទាំងប្រទេស | ៨៨ |
| ក្រាហ្វិក៦២ | មូលហេតុនៃការផ្លាស់ប្តូរទីលំនៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ៨៩ |
| ក្រាហ្វិក៦៣ | ផលិតផលក្នុងស្រុកសរុប (GDP) | ៩១ |
| ក្រាហ្វិក៦៤ | ចំណូលសម្រាប់មនុស្សម្នាក់គិតជាមធ្យម (GDP Per Capita) | ៩២ |
| ក្រាហ្វិក៦៥ | អត្រាអ្នកមានការងារធ្វើ អ្នកគ្មានការងារធ្វើ និងអសកម្មជនសេដ្ឋកិច្ចដែលមានអាយុ៧ឆ្នាំឡើង | ៩៤ |

| ក្រាហ្វិកលេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
| --- | --- | --- |
| ក្រាហ្វិក៦៦ | ភាគរយអ្នកគ្មានការងារធ្វើសម្រាប់ទូទាំងប្រទេស តំបន់ទំនាបកណ្តាល និងតាមបណ្តាខេត្តនៅក្នុងតំបន់ទំនាបកណ្តាល | ៩៤ |
| ក្រាហ្វិក៦៧ | ភាគរយការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ច | ៩៥ |
| ក្រាហ្វិក៦៨ | និន្នាការចំនួនប្រជាជនសរុប និងចំនួនប្រជាជនរស់នៅទីប្រជុំជនទូទាំងពិភពលោក | ៩៨ |
| ក្រាហ្វិក៦៩ | ភាគរយចំនួនប្រជាជនរស់នៅទីប្រជុំជននៅលើពិភពលោក និងចំនួនប្រជាជនរស់នៅទីប្រជុំជនកម្ពុជា | ១០០ |
| ក្រាហ្វិក៧០ | ភាគរយចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជន | ១០១ |
| ក្រាហ្វិក៧១ | ចំនួនគ្រួសារ និងអគារ | ១០៣ |
| ក្រាហ្វិក៧២ | ភាគរយគ្រួសារដែលមានផ្ទះផ្ទាល់ខ្លួនធៀបគ្រួសារសរុប | ១០៤ |
| ក្រាហ្វិក៧៣ | ភាគរយគ្រួសារដែលកាន់កាប់តាមប្រភេទលំនៅដ្ឋាន | ១០៥ |
| ក្រាហ្វិក៧៤ | ចំនួនផ្ទះ និង ចំនួនគ្រួសារឆ្នាំ២០២១ | ១០៧ |
| ក្រាហ្វិក៧៥ | ភាគរយតាមប្រភេទផ្ទះឆ្នាំ២០២១ | ១០៨ |
| ក្រាហ្វិក៧៦ | ការយល់ដឹងអំពីការផ្លាស់ប្តូរក្នុងបរិស្ថានធម្មជាតិ | ១១២ |
| ក្រាហ្វិក៧៧ | និន្នាការសកលនៅក្នុងការប្រើប្រាស់ឥន្ធនៈស្អាត និងបច្ចេកវិទ្យា | ១១៣ |
| ក្រាហ្វិក៧៨ | ប្រភពដែលរួមចំណែកឲ្យមានបំភាយ $PM_{2.5}$ នៅកម្ពុជា | ១១៦ |
| ក្រាហ្វិក៧៩ | ប្រភពដែលរួមចំណែកឲ្យមានបំភាយ NOx នៅកម្ពុជា | ១១៧ |
| ក្រាហ្វិក៨០ | ប្រភពដែលរួមចំណែកឲ្យមានបំភាយ $SO_2$ នៅកម្ពុជា | ១១៨ |
| ក្រាហ្វិក៨១ | ប្រភពដែលរួមចំណែកឲ្យមានបំភាយ $CH_4$នៅកម្ពុជា | ១១៩ |
| ក្រាហ្វិក៨២ | ប្រភពដែលរួមចំណែកឲ្យមានបំភាយ CO នៅកម្ពុជា | ១២០ |
| ក្រាហ្វិក៨៣ | ប្រភពដែលរួមចំណែកឲ្យមានបំភាយ NMVOCs នៅកម្ពុជា | ១២១ |
| ក្រាហ្វិក៨៤ | ការយល់ដឹងអំពីការផ្លាស់ប្តូរអាកាសធាតុតាមតំបន់ | ១២៣ |
| ក្រាហ្វិក៨៥ | ភាគរយគ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | ១២៤ |
| ក្រាហ្វិក៨៦ | សមត្ថភាពប្រព្រឹត្តិកម្មសំណល់រាវ-ទឹកកខ្វក់ | ១២៦ |
| ក្រាហ្វិក៨៧ | បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលបានចាក់នៅទីលានប្រចាំឆ្នាំនៅទូទាំងប្រទេស | ១២៧ |
| ក្រាហ្វិក៨៨ | បរិមាណសំណល់រឹងនៅរាជធានីភ្នំពេញ | ១២៧ |
| ក្រាហ្វិក៨៩ | ភាគរយបរិមាណសំណល់រឹងនៅរាជធានីភ្នំពេញ | ១២៨ |
| ក្រាហ្វិក៩០ | ភាគរយបរិមាណសំណល់រឹងទីក្រុងតាមតំបន់ | ១២៩ |

| ក្រាហ្វិក លេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
| --- | --- | --- |
| ក្រាហ្វិក៩១ | ភាគរយបរិមាណសំណល់រឹងទីក្រុងតាមរាជធានីខេត្តក្នុងតំបន់ទំនាបកណ្ដាល | ១៣០ |
| ក្រាហ្វិក៩២ | ភាគរយការផ្ដល់សេវា ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្រុង ស្រុក ទាំង១៨៥ទូទាំងប្រទេស | ១៣១ |
| ក្រាហ្វិក៩៣ | តំបន់ការពារ | ១៣២ |
| ក្រាហ្វិក៩៤ | ភាគរយតាមប្រភេទតំបន់ការពារធម្មជាតិ | ១៣៥ |
| ក្រាហ្វិក៩៥ | ប្រភេទព្រៃឈើ | ១៣៦ |
| ក្រាហ្វិក៩៦ | ការប្រែប្រួលគម្របព្រៃឈើ | ១៣៦ |
| ក្រាហ្វិក៩៧ | តំបន់វាលភក់ | ១៣៧ |
| ក្រាហ្វិក៩៨ | ភាគរយគ្រួសារ តាមទីតាំងប្រភពទឹកទទួលទាន | ១៤០ |
| ក្រាហ្វិក៩៩ | ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់ | ១៤២ |
| ក្រាហ្វិក១០០ | បរិមាណទឹកកខ្វក់បញ្ចេញពីរាជធានីភ្នំពេញ | ១៤៣ |
| ក្រាហ្វិក១០១ | ភាគរយចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | ១៤៤ |
| ក្រាហ្វិក១០២ | ចំនួនគ្រោះមហន្តរាយដែលបានកើតឡើង តាមទ្វីប និងប្រទេសចំនួន១១ដែលទទួលរងគ្រោះមហន្តរាយធ្ងន់ធ្ងរ | ១៤៧ |
| ក្រាហ្វិក១០៣ | ប្រភេទគ្រោះមហន្តរាយដែលបានកើតឡើង | ១៤៨ |
| ក្រាហ្វិក១០៤ | ប្រភេទនៃគ្រោះមហន្តរាយ | ១៤៩ |
| ក្រាហ្វិក១០៥ | ចំនួនអ្នកស្លាប់ដោយសារគ្រោះមហន្តរាយ | ១៥០ |
| ក្រាហ្វិក១០៦ | ភាគរយអ្នកស្លាប់តាមប្រភេទគ្រោះមហន្តរាយ | ១៥១ |
| ក្រាហ្វិក១០៧ | ចំនួនប្រជាជនដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយ | ១៥៣ |
| ក្រាហ្វិក១០៨ | ការខាតបង់ផ្នែកសេដ្ឋកិច្ចដោយសារគ្រោះមហន្តរាយ | ១៥៥ |
| ក្រាហ្វិក១០៩ | ភាគរយនៃការខាតបង់ផ្នែកសេដ្ឋកិច្ចតាមប្រភេទគ្រោះមហន្តរាយ | ១៥៧ |
| ក្រាហ្វិក១១០ | ចំនួនអ្នកស្លាប់ដោយសារអគ្គីភ័យ ខ្យល់កន្ត្រាក់ និងរន្ទះបាញ់ | ១៥៩ |
| ក្រាហ្វិក១១១ | ចំនួនអ្នករងរបួសដោយសារអគ្គីភ័យ ខ្យល់កន្ត្រាក់ និងរន្ទះបាញ់ | ១៦០ |
| ក្រាហ្វិក១១២ | ភាគរយនៃភូមិដែលងាយរងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងរយៈពេល៥ឆ្នាំចុងក្រោយមុនធ្វើជំរឿនកសិកម្ម | ១៦១ |
| ក្រាហ្វិក១១៣ | ចំនួនស្រុក/ខណ្ឌ និង ឃុំ/សង្កាត់ ដែលរងផលប៉ះពាល់ដោយសារជំនន់ទឹកភ្លៀង និងទឹកទន្លេមេគង្គ | ១៦៤ |
| ក្រាហ្វិក១១៤ | ផលប៉ះពាល់ និងខូចខាតលើវិស័យសង្គមកិច្ចដោយទឹកជំនន់ | ១៦៤ |
| ក្រាហ្វិក១១៥ | ផលប៉ះពាល់ និងខូចខាតលើវិស័យផលិតកម្ម ដោយទឹកជំនន់ | ១៦៥ |

| ក្រាហ្វិកលេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|
| ក្រាហ្វិក១១៦ | ផលប៉ះពាល់ និងខូចខាតលើហេដ្ឋារចនាសម្ព័ន្ធ ដោយទឹកជំនន់ | ១៦៥ |
| ក្រាហ្វិក១១៧ | ផលប៉ះពាល់ និងខូចខាតលើវិស័យសង្គមកិច្ចដោយទឹកជំនន់ឆ្នាំ២០២៥ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ១៦៦ |
| ក្រាហ្វិក១១៨ | ផលប៉ះពាល់ និងខូចខាតលើវិស័យផលិតកម្ម ដោយទឹកជំនន់ឆ្នាំ ២០២៥ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ១៦៦ |
| ក្រាហ្វិក១១៩ | ផលប៉ះពាល់ និងខូចខាតលើហេដ្ឋារចនាសម្ព័ន្ធ ដោយទឹកជំនន់ឆ្នាំ ២០២៥ នៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ | ១៦៧ |
| ក្រាហ្វិក១២០ | ការប៉ះពាល់ និងអន្តរាគមន៍ដោយសារគ្រោះរាំងស្ងួត | ១៦៨ |
| ក្រាហ្វិក១២១ | ចំនួនគ្រួសារ និងផ្ទៃដីដែលរងផលប៉ះពាល់ដោយសារគ្រោះរាំងស្ងួត | ១៦៩ |
| ក្រាហ្វិក១២២ | ស្ថានភាពរងគ្រោះដោយការបាក់ច្រាំងទន្លេ ស្ទឹង | ១៧០ |
| ក្រាហ្វិក១២៣ | ច្រាំងទន្លេដែលបានបាក់ស្រុត | ១៧០ |
| ក្រាហ្វិក១២៤ | ស្ថានភាពរងគ្រោះដោយសារខ្យល់កន្ត្រាក់ | ១៧១ |
| ក្រាហ្វិក១២៥ | ភាគរយនៃការខាតបង់ផ្នែកសេដ្ឋកិច្ចបែងចែកតាមវិស័យ ឆ្នាំ២០០៩ | ១៧៤ |
| ក្រាហ្វិក១២៦ | ស្ថានភាពរងគ្រោះដោយសាររន្ទះបាញ់ | ១៧៥ |
| ក្រាហ្វិក១២៧ | ស្ថានភាពរងគ្រោះដោយសារអគ្គិភ័យ | ១៧៧ |
| ក្រាហ្វិក១២៨ | ចំនួនអ្នកឆ្លងកូវីដ១៩ | ១៧៨ |
| ក្រាហ្វិក១២៩ | ស្ថានភាពជំងឺកូវីដ១៩ទូទាំងពិភពលោក | ១៧៩ |
| ក្រាហ្វិក១៣០ | ស្ថានភាពនៃចាក់វ៉ាក់សាំងជំងឺកូវីដ១៩ទូទាំងពិភពលោក | ១៨០ |
| ក្រាហ្វិក១៣១ | ស្ថានភាពជំងឺកូវីដ១៩នៅកម្ពុជា | ១៨១ |
| ក្រាហ្វិក១៣២ | ស្ថានភាពចាក់វ៉ាក់សាំងជំងឺកូវីដ១៩នៅកម្ពុជា និងពិភពលោក | ១៨២ |
| ក្រាហ្វិក១៣៣ | ស្ថានភាពកូវីដ១៩ ២០២៥ | ១៨៣ |
| ក្រាហ្វិក១៣៤ | ស្ថានភាពគ្រោះជំងឺផ្តាសាយបក្សី H1N1 | ១៨៤ |
| ក្រាហ្វិក១៣៥ | ស្ថានភាពជំងឺគ្រុនឈាម | ១៨៥ |
| ក្រាហ្វិក១៣៦ | ទស្សនវិស័យសកលរយៈពេលខ្លី និងរយៈពេលវែង | ១៨៦ |
| ក្រាហ្វិក១៣៧ | ស្ថានភាពហានិភ័យសកលលោកបច្ចុប្បន្ន | ១៨៧ |
| ក្រាហ្វិក១៣៨ | ចំនួនអ្នកស្លាប់ និង រងរបួសក្នុងសង្គ្រាមលោកលើកទី១ និងលើកទី២ | ១៨៨ |
| ក្រាហ្វិក១៣៩ | ចំនួនប្រជាជនសរុបក្នុងអំឡុងពេល WWI | ១៩០ |
| ក្រាហ្វិក១៤០ | ចំនួនអ្នកស្លាប់ និងទាហានរងរបួសសរុបក្នុងអំឡុងពេល WWI | ១៩១ |
| ក្រាហ្វិក១៤១ | ភាគរយចំនួនអ្នកស្លាប់តាមចំណាត់ថ្នាក់ក្នុង WWI | ១៩២ |
| ក្រាហ្វិក១៤២ | ភាគរយចំនួនទាហានសម្រាប់ក្រុម Entente Powers ក្នុង WWI | ១៩២ |

| ក្រាហ្វិកលេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|
| ក្រាហ្វិក១៤៣ | ភាគរយចំនួនទាហានសម្រាប់ក្រុម Central Powers ក្នុង WWI | ១៩៣ |
| ក្រាហ្វិក១៤៤ | ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី២ | ១៩៥ |
| ក្រាហ្វិក១៤៥ | ចំនួនគ្រាប់មីន និងអាវុធជាតិផ្ទុះដែលបានកម្ទេច | ១៩៦ |
| ក្រាហ្វិក១៤៦ | ចំនួនជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ | ១៩៧ |
| ក្រាហ្វិក១៤៧ | ប្រភេទជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ | ១៩៧ |
| ក្រាហ្វិក១៤៨ | ចំនួនជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ពីឆ្នាំ១៩៩២ - ២០២៣ តាមរាជធានី ខេត្ត | ១៩៨ |
| ក្រាហ្វិក១៤៩ | ចំនួនអ្នកស្លាប់ របួស និងរងផ្សែងពុល | ២០០ |
| ក្រាហ្វិក១៥០ | ចំនួនសាលារៀនបានបិទទ្វារ និងប៉ះពាល់ដល់គ្រូបង្រៀន | ២០១ |
| ក្រាហ្វិក១៥១ | ផលប៉ះពាល់ដល់វិស័យហេដ្ឋារចនាសម្ព័ន្ធ | ២០២ |
| ក្រាហ្វិក១៥២ | ការយល់ដឹងអំពីអត្ថន័យការប្រែប្រួលអាកាសធាតុ និង អាកាសធាតុសកលនៅកម្ពុជា | ២០៥ |
| ក្រាហ្វិក១៥៣ | ការយល់ដឹងអំពីស្ថានភាពអាកាសធាតុតាមប្រភេទ និងតាមតំបន់នៅកម្ពុជា | ២០៦ |
| ក្រាហ្វិក១៥៤ | កត្តាចម្បងដែលនាំឱ្យមានការប្រែប្រួលអាកាសធាតុនៅកម្ពុជា | ២០៧ |
| ក្រាហ្វិក១៥៥ | ការបំភាយឧស្ម័នផ្ទះកញ្ចក់តាមវិស័យ | ២០៨ |
| ក្រាហ្វិក១៥៦ | កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ | ២០៩ |
| ក្រាហ្វិក១៥៧ | ចំនួនថ្ងៃមានភ្លៀងក្នុងមួយឆ្នាំ | ២១០ |
| ក្រាហ្វិក១៥៨ | សីតុណ្ហភាពអប្បបរមា | ២១១ |
| ក្រាហ្វិក១៥៩ | សីតុណ្ហភាពអតិបរមា | ២១២ |
| ក្រាហ្វិក១៦០ | ស្ថានភាពកម្ពស់ទឹកអតិបរមានៅទន្លេមេគង្គ | ២១៣ |
| ក្រាហ្វិក១៦១ | កម្ពស់ទឹកអតិបរមាប្រចាំឆ្នាំតាមស្ថានីយ៍ | ២១៤ |
| ក្រាហ្វិក១៦២ | ស្ថានភាពកម្ពស់ទឹកអប្បរមានៅទន្លេមេគង្គ | ២១៥ |
| ក្រាហ្វិក១៦៣ | កម្ពស់ទឹកអប្បបរមាប្រចាំឆ្នាំតាមស្ថានីយ៍ | ២១៦ |
| ក្រាហ្វិក១៦៤ | កម្ពស់ទឹកអប្បបរមា អតិបរមា | ២១៦ |
| ក្រាហ្វិក១៦៥ | និន្នាការសីតុណ្ហភាពអតិបរមា និងអប្បបរមា | ២១៨ |
| ក្រាហ្វិក១៦៦ | និន្នាការកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំ | ២១៩ |
| ក្រាហ្វិក១៦៧ | និន្នាការកម្ពស់ទឹកអតិបរមា និងអប្បរមា | ២២០ |
| ក្រាហ្វិក១៦៨ | និន្នាការទិន្នផលស្រូវ | ២២១ |
| ក្រាហ្វិក១៦៩ | ស្ថានភាពផលិតផលក្នុងស្រុកសរុប (GDP) | ២៣១ |

| ក្រាហ្វិក លេខ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|
| ក្រាហ្វិក១៧០ | ផ្ទៃដីគ្របដណ្តប់ (Land Cover) ប្រទេសកម្ពុជា | ២៣៩ |
| ក្រាហ្វិក១៧១ | ផ្ទៃដីគ្របដណ្តប់ (Land Cover) ខេត្តកំពង់ចាម | ២៤៤ |
| ក្រាហ្វិក១៧២ | ផ្ទៃដីគ្របដណ្តប់ (Land Cover) ខេត្តត្បូងឃ្មុំ | ២៤៩ |
| ក្រាហ្វិក១៧៣ | ប្រៀបធៀបភាគរយផ្ទៃដីគ្របដណ្តប់ (Land Cover) ប្រទេសកម្ពុជា និង ប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួន | ២៥៤ |

# បញ្ជីផែនទី



| ផែនទីលេខ | ចំណងជើងផែនទី | ទំព័រ |
|---|---|---|
| ផែនទី១ | ផែនទីបង្ហាញតាមប្រទេសនៃការព្យាករណ៍ចំនួនប្រជាជនដែលអាចកើនឡើងដល់ចំណុចកំពូលត្រឹមឆ្នាំ២០២៤ ពីឆ្នាំ២០២៥ដល់២០៥៤ និងពីឆ្នាំ២០៥៤ឡើងទៅ | ៦១ |
| ផែនទី២ | បង្ហាញអំពីផែនទីប្រទេសកម្ពុជា និងរូបភាពប្រជាជនដែលជាយុវវ័យនៅទូទាំងប្រទេស | ៦៣ |
| ផែនទី៣ | ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ១៩៩៨ | ៧៣ |
| ផែនទី៤ | ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ២០០៨ | ៧៣ |
| ផែនទី៥ | ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ ២០១៩ | ៧៤ |
| ផែនទី៦ | ដង់ស៊ីតេប្រជាជនតាមក្រុង ស្រុក ខេត្តកំពង់ចាម ឆ្នាំ១៩៩៨ ២០០៨ និង ២០១៩ | ៧៥ |
| ផែនទី៧ | ដង់ស៊ីតេប្រជាជនតាមក្រុង ស្រុក ខេត្តត្បូងឃ្មុំ ឆ្នាំ១៩៩៨ ២០០៨ និង ២០១៩ | ៧៧ |
| ផែនទី៨ | ផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជាឆ្នាំ ២០២៤ | ២៣៥ |
| ផែនទី៩. | ផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជាគ្របដណ្ដប់ដោយផ្ទៃទឹក (Water) ឆ្នាំ ២០២៤ | ២៣៦ |
| ផែនទី១០ | ផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជាគ្របដណ្ដប់ដោយព្រៃឈើ (Tree) ឆ្នាំ ២០២៤ | ២៣៦ |
| ផែនទី១១ | ផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជាគ្របដណ្ដប់ដោយ ទឹកជំនន់ដំណាំ (Flood Vegetation) ឆ្នាំ ២០២៤ | ២៣៧ |
| ផែនទី១២ | ផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជាគ្របដណ្ដប់ដោយដំណាំ (Crop) | ២៣៧ |
| ផែនទី១៣ | ផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជាគ្របដណ្ដប់ដោយអគារ ឬ សំណង់ផ្សេងៗ (Built) | ២៣៨ |
| ផែនទី១៤. | ផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជាគ្របដណ្ដប់ដោយវាលស្មៅ (Rangeland) | ២៣៨ |
| ផែនទី១៥ | ផ្ទៃដីគ្របដណ្ដប់ខេត្តកំពង់ចាមឆ្នាំ ២០២៤ | ២៤០ |
| ផែនទី១៦ | ផ្ទៃដីគ្របដណ្ដប់ដោយទឹក ខេត្តកំពង់ចាមឆ្នាំ ២០២៤ | ២៤០ |
| ផែនទី១៧ | ផ្ទៃដីគ្របដណ្ដប់ខេត្តកំពង់ចាមគ្របដណ្ដប់ដោយព្រៃឈើឆ្នាំ ២០២៤ | ២៤១ |
| ផែនទី១៨ | ផ្ទៃដីគ្របដណ្ដប់ខេត្តកំពង់ចាមគ្របដណ្ដប់ដោយទឹកជំនន់ឆ្នាំ ២០២៤ | ២៤១ |
| ផែនទី១៩ | ផ្ទៃដីគ្របដណ្ដប់ខេត្តកំពង់ចាមគ្របដណ្ដប់ដោយដំណាំឆ្នាំ ២០២៤ | ២៤២ |
| ផែនទី២០ | ផ្ទៃដីគ្របដណ្ដប់ខេត្តកំពង់ចាមគ្របដណ្ដប់ដោយអគារឆ្នាំ ២០២៤ | ២៤២ |
| ផែនទី២១ | ផ្ទៃដីគ្របដណ្ដប់ខេត្តកំពង់ចាមគ្របដណ្ដប់ដោយវាលស្មៅឆ្នាំ ២០២៤ | ២៤៣ |

| ផែនទីលេខ | ចំណងជើងផែនទី | ទំព័រ |
|---|---|---|
| ផែនទី២២ | ផ្ទៃដីគ្របដណ្តប់ខេត្តត្បូងឃ្មុំឆ្នាំ២០២៤ | ២៤៥ |
| ផែនទី២៣ | ផ្ទៃដីគ្របដណ្តប់ដោយទឹក ខេត្តត្បូងឃ្មុំឆ្នាំ២០២៤ | ២៤៥ |
| ផែនទី២៤ | ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤ | ២៤៦ |
| ផែនទី២៥ | ផ្ទៃដីគ្របដណ្តប់ដោយទឹកជំនន់ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤ | ២៤៦ |
| ផែនទី២៦ | ផ្ទៃដីគ្របដណ្តប់ដោយដំណាំ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤ | ២៤៧ |
| ផែនទី២៧ | ផ្ទៃដីគ្របដណ្តប់ដោយអគារ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤ | ២៤៧ |
| ផែនទី២៨ | ផ្ទៃដីគ្របដណ្តប់ដោយដីទំនេរ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤ | ២៣៨ |
| ផែនទី២៩ | ផ្ទៃដីគ្របដណ្តប់ដោយវាលស្មៅ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤ | ២៣៨ |
| ផែនទី៣០ | ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួន ឆ្នាំ២០២៤ | ២៥០ |
| ផែនទី៣១ | ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដោយផ្ទៃទឹកសាប ឆ្នាំ២០២៤ | ២៥០ |
| ផែនទី៣២ | ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដោយព្រៃឈើ ឆ្នាំ២០២៤ | ២៥១ |
| ផែនទី៣៣ | ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដោយទឹកជំនន់ ឆ្នាំ២០២៤ | ២៥១ |
| ផែនទី៣៤ | ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដោយដំណាំ ឆ្នាំ២០២៤ | ២៥២ |
| ផែនទី៣៥ | ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដោយអគារ ឆ្នាំ២០២៤ | ២៥២ |
| ផែនទី៣៦ | ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដីទំនេរ ឆ្នាំ២០២៤ | ២៥៣ |
| ផែនទី៣៧ | ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដោយវាលស្មៅ ឆ្នាំ២០២៤ | ២៥៣ |

# បញ្ជីឧបសម្ព័ន្ធ


| ឧបសម្ព័ន្ធ | ចំណងជើងឧបសម្ព័ន្ធ | ទំព័រ |
|---|---|---|
| ឧបសម្ព័ន្ធ១ | បញ្ជីសំណួរការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ សម្រាប់អនុវត្តគម្រោងការងារក្រុមសង្កេតការណ៍ភពផែនដី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២៥ (សម្រាប់មេភូមិ) | ២៧២ |
| ឧបសម្ព័ន្ធ២ | បញ្ជីសំណួរការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ សម្រាប់អនុវត្តគម្រោងការងារក្រុមសង្កេតការណ៍ភពផែនដី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២៥ (សម្រាប់មេគ្រួសារ) | ២៧៦ |
| ឧបសម្ព័ន្ធ៣ | ការព្យាករណ៍គ្រួសារដែលអាចរងគ្រោះដោយគ្រោះមហន្តរាយដែលអាចខាតប់បង់ថវិកាលើសពី៥៥៥ដុល្លារឡើងតាមម៉ដែល Logistics Regression Model (ផ្អែកតាមទិន្នន័យទី១) | ២៨៣ |
| ឧបសម្ព័ន្ធ៤ | Table of Chi-squared distribution | ២៨៨ |

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺត្រូវបាននាយកលេខាធិការនៃលេខាធិការដ្ឋានក្រុមសង្កេតការណ៍ភពផែនដីប្រកាសជាផ្លូវការចូលជាសមាជិកទី១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីនៅក្នុងអំឡុងពេលកិច្ចប្រជុំពិភាក្សាលើកទី១៤ ដែលបានប្រារព្ធធ្វើពីថ្ងៃទី២៥ ដល់ ២៦ ខែតុលា ឆ្នាំ២០១៧ នៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ដែលមានវត្តមាន **ឯកឧត្តម ជុំ ប៊ុនរ៉ុង** ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនសហរដ្ឋអាមេរិកតំណាងឲ្យប្រទេសកម្ពុជា ព្រមទាំងមានការចូលរួមពីលេខាទី១របស់ស្ថានទូត និងមន្ត្រីជាន់ខ្ពស់របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ តាមរយៈសំណើរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០១៧ ទៅនាយកលេខាធិការនៃលេខាធិការដ្ឋានក្រុមសង្កេតការណ៍ភពផែនដី (GEO) ដែលមានទីស្នាក់ការនៅទីក្រុងហ្សឺណែវប្រទេសស្វីស។ បន្ទាប់ពីបានចូលជាសមាជិកក្រុមសង្កេតការណ៍ភពផែនដីជាផ្លូវការរួចមក អង្គភាពក្រុមសង្កេតការណ៍ភពផែនដីស្ថិតក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបានបង្កើតឡើង ដើម្បីងាយស្រួលធ្វើកិច្ចការងារផ្សេងៗជាមួយអគ្គលេខាធិការដ្ឋានក្រុមសង្កេតភពផែនដី ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុងហ្សឺណែវប្រទេសស្វីស។ ការងារសំខាន់របស់ប្រទេសជាសមាជិកក្រុមសង្កេតការភពផែនដីគឺសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ និងវិភាគទិន្នន័យដែលប្រមូលដោយផ្ទាល់តាមរយៈការសម្ភាសន៍នៅតាមតំបន់គោលដៅដែលត្រូវបានសិក្សាស្រាវជ្រាវ និងបានតាមរយៈផ្កាយរណប ឬ ឧបករណ៍ផ្សេងៗ ដែលថតរូបភាពពីលើអាកាស សម្រាប់ធ្វើការតាមដានត្រួតពិនិត្យលើផលប៉ះពាល់បរិស្ថានគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងតាមដាននូវការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជាផងដែរ។ បច្ចុប្បន្ននេះ អង្គភាពក្រុមសង្កេតការណ៍ភពផែនដីស្ថិតក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនេះ បានរៀបចំជាក្រុមការងារមួយសម្រាប់អនុវត្តគម្រោងថវិកាកម្មវិធី និងសកម្មភាពដូចដែលបានអនុវត្តកន្លងទៅស្របតាមការកែប្រែរចនាសម្ព័ន្ធរបស់វិទ្យាស្ថានជាតិស្ថិតិជាគ្រឹះស្ថានរដ្ឋបាលសាធារណៈ។ ចំពោះប្រទេសកម្ពុជាយើងការប្រមូលទិន្នន័យពីផ្កាយរណបពុំអាចធ្វើទៅបានទេ ដោយសារពុំទាន់មានផ្កាយរណប ឬ ឧបករណ៍ថតពីលើអាកាសនោះទេ ឬ ទទួលបានការចែករំលែកទិន្នន័យពីផ្កាយរណបពីបណ្តាប្រទេសផ្សេងទៀតនោះទេ។ ហេតុដូច្នេះជំនួសការប្រមូលទិន្នន័យត្រូវបានធ្វើតាមរយៈការសម្ភាសន៍មេភូមិ និង មេគ្រួសារដែលរស់នៅក្នុងតំបន់គោលដៅដែលត្រូវសិក្សានោះវិញ។ សម្រាប់ការអនុវត្តការងារជំហានទី១ នៅឆ្នាំ ២០១៩ អង្គភាពក្រុមសង្កេតការណ៍ភពផែនដី បានអនុវត្តគម្រោងសកម្មភាពការងារដែលបានផ្តោត

ទៅលើខេត្ត៥នៅជាប់បឹងទន្លេសាបរួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ ដោយប្រើប្រាស់ថវិការាជរដ្ឋាភិបាលកម្ពុជាតាមរយៈថវិកាកម្មវិធី របស់ក្រសួងផែនការដែលមានចំនួនកំណត់។ នៅក្នុងការអនុវត្តការងារជំហានទី២ ឆ្នាំ២០២០ គឺបានចុះស្រង់ទិន្នន័យអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជា នៅក្នុងតំបន់ខ្ពង់រាបនៅក្នុងខេត្ត៣ រួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលគម្រោងត្រូវអនុវត្តចំនួន៥ខេត្តដូចឆ្នាំ២០១៩ ដែរ តែដោយសារបញ្ហាជំងឺឆ្លងកូវីដ ១៩ ត្រូវបានរាជរដ្ឋាភិបាលឲ្យកាត់សកម្មភាព ៥០ភាគរយ។នៅក្នុងឆ្នាំ ២០២១ នេះរាជរដ្ឋាភិបាលបានកាត់ថវិកាគ្រប់គម្រោងទាំងអស់ ៣៧,៥% លើគម្រោងដែលបានកាត់ ៥០% ប៉ុន្តែសកម្មភាពចុះស្រង់ទិន្នន័យនៅក្នុងខេត្តចំនួន២ ដែលស្ថិតនៅក្នុងតំបន់ខ្ពង់រាបគឺ ខេត្តកំពង់ធំ និងខេត្តសៀមរាបពុំទាន់បានអនុវត្តនៅឆ្នាំ ២០២០ ហើយបានបន្តអនុវត្តនៅក្នុងឆ្នាំ២០២១ វិញ។ នៅក្នុងឆ្នាំ ២០២២ ដោយសារថវិកាកម្មវិធីអនុវត្តគម្រោង សម្រាប់ការចុះស្រង់ទិន្នន័យនៅតំបន់ឆ្នេរសមុទ្រមានកម្រិត គឺត្រូវបានអនុវត្តបានតែ២ខេត្តប៉ុណ្ណោះ គឺនៅក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ ហើយនៅក្នុងឆ្នាំ២០២៣ គឺបានអនុវត្តការចុះប្រមូលទិន្នន័យនៅក្នុងខេត្តកំពត និងខេត្តកែប។ តាមរយៈការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២៤ គម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជា គឺបានចុះប្រមូលទិន្នន័យនៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង ខណៈដែលក្នុងឆ្នាំ២០២៥ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ត្រូវបានអនុវត្តសកម្មភាពដូចគ្នានេះដែរ។

## ១.២ គោលបំណង

គោលបំណងសំខាន់នៃការអនុវត្តគម្រោងអង្កេតភពផែនដីឆ្នាំ២០២៥នេះ គឺការកសាងប្រព័ន្ធទិន្នន័យស្ថិតិដែលទាក់ទងផ្នែកបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុសម្រាប់តំបន់វាលទំនាបនៅក្នុងខេត្តចំនួន២គឺខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ដើម្បីចូលរួមតាមដានលើការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## ១.៣ វិធីសាស្ត្រប្រមូលទិន្នន័យ

ទិន្នន័យសម្រាប់ធ្វើការវិភាគនេះ គឺបានមកពីការប្រមូលទិន្នន័យបីប្រភេទ គឺទិន្នន័យទី១ ទិន្នន័យទី២ និងទិន្នន័យដែលបានពីផ្កាយរណប។ វិធីសាស្ត្រនៃការប្រមូលទិន្នន័យទី១ គឺត្រូវបានប្រមូលតាមរយៈការធ្វើសម្ភាសន៍មេភូមិ និងមេគ្រួសារនៅក្នុងភូមិគោលដៅនៃខេត្តទាំង ២គឺខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ដែលស្ថិតនៅតំបន់វាលទំនាប។ កម្រងសំណួរសម្រាប់សម្ភាសន៍មានពីរ គឺកម្រងសំណួរទី១ គឺសម្រាប់សម្ភាសន៍មេភូមិ និងកម្រងសំណួរទី២ គឺសម្រាប់សម្ភាសន៍មេគ្រួសារ។ ភូមិគោលដៅដែលមានចំនួន១០ភូមិ និងចំនួនមេគ្រួសារ ៦០០នាក់ ស្ថិតនៅក្នុងខេត្ត២នៅក្នុងតំបន់ទំនាបកណ្តាលគឺត្រូវបានធ្វើសម្ភាសន៍។ ទិន្នន័យទី២ គឺត្រូវបានប្រមូលពីក្រសួងបរិស្ថាន ក្រសួងធនធានទឹក និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មន្ទីរផែនការខេត្តកំពង់ចាម និងមន្ទីរផែនការខេត្តត្បូងឃ្មុំ ព្រមទាំងទិន្នន័យផ្សេងៗទៀត ពីស្ថាប័នដែលមានការពាក់ព័ន្ធដទៃទៀត

ដែលបានផលិតចេញជារបាយការណ៍ផ្ទាល់របស់ស្ថាប័ន ដែលពាក់ព័ន្ធនឹងសូចនាករខាងលើ និងទិន្នន័យដែលទទួលបានពីផ្កាយរណបតាមដែលអាចធ្វើបាន។

**តារាង ១. បញ្ជីភូមិគោលដៅសម្រាប់ធ្វើការសម្ភាសន៍ស្រង់ទិន្នន័យ នៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ**

| ល.រ | ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនគ្រួសារសរុបក្នុងភូមិ | ចំនួនគ្រួសារត្រូវសម្ភាសន៍ |
|---|---|---|---|---|---|---|
| 1 | កំពង់ចាម | បាធាយ | បាធាយ | បាធាយ | 1,097 | 60 |
| 2 | កំពង់ចាម | បាធាយ | បាធាយ | ស្វាយពក | 305 | 60 |
| 3 | កំពង់ចាម | បាធាយ | បាធាយ | ស្រះព្រីង | 620 | 60 |
| 4 | កំពង់ចាម | បាធាយ | បាធាយ | ទួល | 1,077 | 90 |
| 5 | កំពង់ចាម | បាធាយ | ផ្អាវ | បឹងត្រស់ | 182 | 35 |
| 6 | កំពង់ចាម | បាធាយ | ផ្អាវ | សំរោង | 214 | 60 |
| 7 | កំពង់ចាម | បាធាយ | ផ្អាវ | ផ្អាវ | 706 | 60 |
| 8 | ត្បូងឃ្មុំ | ត្បូងឃ្មុំ | ដីរោទ៍ទី២ | ទួលវិហារ | 869 | 70 |
| 9 | ត្បូងឃ្មុំ | ត្បូងឃ្មុំ | ដីគរ | ដីគរ | 126 | 35 |
| 10 | ត្បូងឃ្មុំ | ត្បូងឃ្មុំ | ដីគរ | សាមគ្គី | 205 | 70 |
| **សរុប** | | | | | **5,401** | **600** |

## ១.៤ ការកែច្នៃទិន្នន័យ

ទិន្នន័យដែលបានមកពីការធ្វើសម្ភាសន៍តាមរយៈមេភូមិ និងមេគ្រួសារនៅតាមភូមិគោលដៅនៅក្នុងខេត្តទាំង២ ដែលស្ថិតនៅក្នុងតំបន់វាលទំនាប គឺត្រូវបានវាយបញ្ចូលទៅក្នុងកុំព្យូទ័រដោយប្រើប្រាស់កម្មវិធី CSPro 8.0 សម្រាប់ការត្រួតពិនិត្យកំហុស និងការទាញទិន្នន័យផលិតជាតារាងសម្រាប់ធ្វើការវិភាគក្នុងការសរសេររបាយការណ៍វិភាគលទ្ធផលចុងក្រោយផងដែរ។ ចំពោះកម្មវិធី Microsoft Excel គឺត្រូវបានប្រើប្រាស់សម្រាប់ការធ្វើក្រាហ្វិក និងការគណនាផ្សេងៗ។ កម្មវិធី Microsoft Word គឺសម្រាប់សរសេររបាយការណ៍វិភាគទិន្នន័យ និងបោះពុម្ពជាឯកសារចុងក្រោយ។

## ១.៥ វិសាលភាព

របាយការណ៍នេះ បានសិក្សាស្រាវជ្រាវអំពីស្ថានភាពប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម បរិស្ថាន ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗក្រៅពីគ្រោះមហន្តរាយធម្មជាតិ ដែលរួមមាន គ្រោះថ្នាក់អគ្គីភ័យ និងជំងឺឆ្លង។ វិសាលភាពនៃការសិក្សាស្រាវជ្រាវចំណុចខាងលើ គឺគ្របដណ្តប់លើស្ថានភាពទូទៅរបស់សកលលោក គ្របខណ្ឌថ្នាក់ជាតិសម្រាប់

ទូទាំងប្រទេសកម្ពុជា និងថ្នាក់ក្រោមជាតិផ្តោតទៅលើខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ តាមគម្រោងផែនការអនុវត្តប្រចាំឆ្នាំ។ ចំពោះខេត្តដទៃទៀត នឹងសិក្សាពេលបន្តបន្ទាប់ទៀត។

## ១.៦ សារៈប្រយោជន៍

របាយការណ៍វិភាគទិន្នន័យដែលប្រមូលបាននេះ គឺមានសារៈសំខាន់ដល់អ្នកសិក្សាស្រាវជ្រាវ អ្នកធ្វើផែនការ និងអ្នករៀបចំគោលនយោបាយផ្សេងៗ ជាពិសេសរាជរដ្ឋាភិបាលមានទិន្នន័យបន្ថែមទៀតសម្រាប់រៀបចំគោលនយោបាយ ដែលទាក់ទងទៅនឹងការត្រួតពិនិត្យតាមដានការប្រែប្រួលនៃលក្ខណៈប្រជាសាស្ត្រ បរិស្ថានគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុតាមតំបន់នីមួយៗនៅក្នុងប្រទេសកម្ពុជា និងមានវិធានការបង្ការនូវហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងដោយសារគ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុជាដើម។

## ១.៧ ដំណើរការនៃការអនុវត្តគម្រោង



# ជំពូក ២
# លទ្ធផលនៃការវិភាគទិន្នន័យផ្អែកលើទិន្នន័យទី១

## ២.១ លទ្ធផលផ្អែកលើទិន្នន័យទី១

លទ្ធផលរបាយការណ៍អង្កេតភពផែនដី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៥នេះ គឺបានវិភាគចេញពីប្រភពទិន្នន័យ៣ប្រភេទគឺ៖(១) ទិន្នន័យទី១ ដែលជាទិន្នន័យដែលបានចុះសម្ភាសន៍ផ្ទាល់នៅក្នុងភូមិមួយចំនួននៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ (២) ទិន្នន័យទី២ ដែលជាទិន្នន័យដែលផលិតដោយក្រសួងស្ថាប័នជាតិនិងអន្តរជាតិ និង (៣)ទិន្នន័យដែលបានពីផ្កាយរណប Satellite Sentinel-2 របស់អង្គការ NASA។ លទ្ធផលនៃទិន្នន័យទី១ គឺបានសម្ភាសន៍មេភូមិចំនួន ១២នាក់ និងមេគ្រួសារចំនួន៦០០នាក់ ដែលមានបញ្ជីសំណួរពីរដាច់ដោយឡែកពីគ្នា ហើយបានធ្វើការវិភាគលម្អិតដូចខាងក្រោម។

### ២.១.១ លទ្ធផលពីការសម្ភាសន៍មេភូមិ

នៅក្នុងការចុះសម្ភាសន៍ស្រង់ទិន្នន័យជាក់ស្តែងនៅក្នុងខេត្តកំពង់ចាម និង ខេត្តត្បូងឃ្មុំ សម្រាប់តំបន់ទំនាបកណ្តាល បានប្រើប្រាស់តារាងបញ្ជីសំណួរ ១ ដែលផ្តោតលើសូចនាករមួយចំនួននៅក្នុងភូមិរួមមាន៖

- ប្រជាសាស្ត្រ និងការងារ
- ស្ថានភាពបរិស្ថាន
- ស្ថានភាពគ្រោះមហន្តរាយ
- ការប្រែប្រួលអាកាសធាតុ។

#### ក.ស្ថានភាពទូទៅ

នៅក្នុងភូមិចំនួនទាំង ១០ ដែលបានសម្ភាសន៍មេភូមិ គឺមេភូមិភេទប្រុសមានរហូត៩នាក់ ស្មើនឹង៩០% និងភេទស្រីមានតែម្នាក់ប៉ុណ្ណោះគឺស្មើនឹង១០% ក្នុងចំណោមមេភូមិទាំង១០រូប។ ក្រាហ្វិក១ បង្ហាញអំពីភាគរយមេភូមិទៅតាមភេទ ដែលបានសម្ភាសន៍នៅតាមភូមិគោលដៅដែលបានកំណត់ស្ថិតនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។ ក្រាហ្វិក២ បង្ហាញអំពីភាគរយមេភូមបែងចែកតាមខេត្ត និងតាមភេទ។

ក្រាហ្វិក ១. ភាគរយមេភូមិតាមភេទ




ក្រាហ្វិក ២. ភាគរយមេភូមិដែលបានសម្ភាសន៍បែងចែកតាមខេត្ត និងភេទ



នៅក្នុងតារាង ២ បានបង្ហាញថា មេភូមិភាគច្រើនជាបុរសដែលស្ថិតនៅក្នុងក្រុមអាយុចាប់ពី៦០ឆ្នាំឡើង មាន៧នាក់ ក្នុងនោះស្រី១នាក់ ខណៈដែលមេភូមិដែលស្ថិតនៅក្នុងក្រុមអាយុ៤០ដល់៥៩ ឆ្នាំ មាន៣នាក់ គឺសុទ្ធតែបុរស និងមេភូមិដែលស្ថិតនៅក្នុងក្រុមអាយុ១៥ដល់៣៩ ឆ្នាំពុំមានទេ។

**តារាង ២. ចំនួនមេភូមិតាមក្រុមអាយុ និងភេទ**

| ក្រុមអាយុ | ភេទ | | |
|---|---|---|---|
| | ប្រុស | ស្រី | សរុប |
| **សរុប** | **9** | **1** | **10** |
| 15-39 | 0 | 0 | 0 |
| 40-59 | 3 | 0 | 3 |
| 60+ | 6 | 1 | 7 |

តារាង ៣ ខាងក្រោមបង្ហាញថា អាយុមេភូមិអប្បបរមាពីឆ្នាំ២០២០ ដល់២០២៥ គឺចាប់ពី ៣៦ ដល់៥៤ឆ្នាំ និង អាយុអតិបរមាមានចំនួនចាប់ពី៧១ឆ្នាំ ដល់៧៧ឆ្នាំ ខណៈដែលអាយុកណ្តាល (មេដ្យានអាយុ) ពីឆ្នាំ ២០២០ ដល់២០២៥ គឺចាប់ពី ៤៧ ដល់៦៧,៥ឆ្នាំនិងអាយុមធ្យមចាប់ពី ៥១,៧១ ដល់ ៦៤,៥ឆ្នាំ ក្នុងឆ្នាំដូចគ្នានេះដែរ។ ទិន្នន័យលម្អិតសម្រាប់បណ្តាឆ្នាំផ្សេងៗទៀត មាននៅក្នុងតារាងខាងក្រោម។ នៅក្នុងក្រាហ្វិក២ បង្ហាញថាឆ្នាំ២០២៥ មានចំនួន២៥% នៃមេភូមិដែលមានអាយុក្រោម៥៧,៧៥ឆ្នាំ និង២៥%នៃចំនួនមេភូមិដែលអាយុ ៧២ឆ្នាំឡើង ខណៈដែល៥០%នៃចំនួនមេភូមិស្ថិតនៅចន្លោះអាយុចាប់ពី ៥៧,៧៥ ដល់ ៧២ឆ្នាំ។ មេដ្យានអាយុមេភូមិគឺ ៦៤ឆ្នាំ មានន័យថា៥០% នៃអាយុមេភូមិដែលចាស់ជាងមានអាយុច្រើនជាង៦៤ឆ្នាំ និង៥០%តិចជាង ៦៤ឆ្នាំ ខណៈដែលអាយុមធ្យមមានចំនួន ៦៤,៥ឆ្នាំ នៅក្នុងឆ្នាំដូចគ្នានេះដែរ។ ទិន្នន័យលម្អិតសម្រាប់បណ្តាឆ្នាំផ្សេងៗទៀត មាននៅក្នុងក្រាហ្វិកខាងក្រោម។

**តារាង ៣. តារាងសង្ខេបអាយុមេភូមិតាមលទ្ធផលដែលបាន**
**ពី Box and Whisker Plot ពីឆ្នាំ២០២០ដល់ ២០២៥**

| អាយុគិតជាឆ្នាំ | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|
| Minimum | 47.00 | 37.00 | 48.00 | 47.00 | 36.00 | 54.00 |
| Maximum | 74.00 | 77.00 | 73.00 | 71.00 | 74.00 | 75.00 |
| Median (Q2) | 60.00 | 47.00 | 57.50 | 63.00 | 67.50 | 64.00 |
| Mean | 60.67 | 51.71 | 58.90 | 61.30 | 63.44 | 64.50 |
| First Quartile (Q1) | 55.00 | 41.00 | 52.00 | 55.50 | 58.50 | 57.75 |
| Third Quartile (Q3) | 68.00 | 59.50 | 66.25 | 67.50 | 70.75 | 72.00 |
| Interquartile Range (IQR) | 13.00 | 18.50 | 14.25 | 12.00 | 12.25 | 14.25 |
| Range | 27.00 | 40.00 | 25.00 | 24.00 | 38.00 | 21.00 |
| Lower outlier | 35.50 | 13.25 | 30.63 | 37.50 | 40.13 | 36.38 |
| Upper outlier | 87.50 | 87.25 | 87.63 | 85.50 | 89.13 | 93.38 |

ក្រាហ្វិក ៣. អាយុមេភូមិដែលបានសម្ភាសន៍បង្ហាញតាម Box and Whisker Plot




ក្រាហ្វិក ៤. អាយុមេភូមិដែលបានសម្ភាសន៍ជា Median, Mean, First Quartile និង Third Quartile



## ខ.ស្ថានភាពប្រជាសាស្ត្រ និងគ្រួសារ

តារាង ៤ បង្ហាញថាចំនួនគ្រួសារ និងចំនួនប្រជាជនឆ្នាំ២០២៤ និងឆ្នាំ២០២៥ មានប្រហាក់ប្រហែលគ្នា តែចំនួនគ្រួសារនៃប្រជាជនដែលរស់នៅក្នុងភូមិមានការកើនឡើងបន្តិច។ ការកើនឡើងនេះ ប្រហែលមកពីចំណូលស្រុក និងចំនួនប្រជាជនកើនឡើងបន្តិចក៏អាចបណ្តាលមកពីកំណើនធម្មជាតិ និងចំណូលស្រុកផងដែរ។ ភាគរយនៃគ្រួសារដែលមានទឹកស្អាតប្រើប្រាស់មានប្រហែល ៧៤% នៅឆ្នាំ២០២៤ និង ៧៨% នៅឆ្នាំ២០២៥ ខណៈដែលគ្រួសារដែលមានអគ្គិសនីប្រើប្រាស់នៅក្នុងភូមិមាន៧៨%នៅឆ្នាំ ២០២៣ និង៨៤% នៅឆ្នាំ២០២៤។ ភាគរយគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់នៅឆ្នាំ ២០២៤ មាន ៨៦% និង ៩១% នៅឆ្នាំ២០២៥។

**តារាង ៤. ចំនួនប្រជាជន គ្រួសារធ្វើការងារតាមវិស័យសេដ្ឋកិច្ច និងចំនួនគ្រួសារដែលប្រើប្រាស់ទឹក អគ្គិសនី និងបង្គន់អនាម័យនៅក្នុងភូមិ**

| អធិប្បាយ | 2024 | 2025 |
|---|---|---|
| ចំនួនប្រជាជន | 29,285 | 29,552 |
| ចំនួនគ្រួសារ | 5,335 | 5,420 |
| ចំនួនគ្រួសារមានទឹកស្អាតប្រើប្រាស់ | 3,955 | 4,238 |
| ចំនួនគ្រួសារមានអគ្គិសនីប្រើប្រាស់ | 4,180 | 4,564 |
| ចំនួនគ្រួសារមានបង្គន់ | 4,598 | 4,911 |
| ភាគរយអ្នកធ្វើការវិស័យកសិកម្ម | 56 | 54 |
| ភាគរយអ្នកធ្វើការវិស័យឧស្សាហកម្ម | 30 | 31 |
| ភាគរយអ្នកធ្វើការវិស័យសេវាកម្ម | 14 | 15 |

ក្រាហ្វិក ៥ បង្ហាញភាគរយគ្រួសារដែលមានទឹកស្អាត បង្គន់អនាម័យ និងអគ្គិសនីប្រើប្រាស់នៅក្នុងផ្ទះ។ ភាគរយគ្រួសារដែលមានទឹកស្អាតប្រើប្រាស់នៅឆ្នាំ២០២៤ មាន ៧៤% បានកើនឡើងដល់ ៧៨%នៅឆ្នាំ ២០២៥ ខណៈដែលភាគរយនៃចំនួនគ្រួសារដែលមានអគ្គិសនីប្រើប្រាស់មានចំនួន ៧៨%នៅឆ្នាំ២០២៤ នឹងបានកើនឡើងដល់៨៤% នៅឆ្នាំ២០២៥។ ចំពោះបង្គន់អនាម័យវិញ ភាគរយគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់មានចំនួនប្រហែល ៨៦% នៅឆ្នាំ ២០២៣ បានកើនឡើងដល់៩១% នៅឆ្នាំ២០២៤។ ក្រាហ្វិក ៦ បង្ហាញអំពីភាគរយសមាជិកធ្វើការតាមវិស័យសេដ្ឋកិច្ច។

**ក្រាហ្វិក៥. ភាគរយគ្រួសារដែលមានទឹកស្អាត បង្គន់អនាម័យ និងអគ្គិសនីប្រើប្រាស់នៅក្នុងផ្ទះ**




ភាគរយសមាជិកគ្រួសារនៅក្នុងភូមិ ដែលបានធ្វើការងារនៅក្នុងវិស័យកសិកម្មឆ្នាំ២០២៣ មានចំនួន ៥៦% វិស័យឧស្សាហកម្ម ៣០% និងវិស័យសេវាកម្ម ១៤% ខណៈដែលនៅឆ្នាំ២០២៤ ភាគរយសមាជិកគ្រួសារដែលបានធ្វើការងារក្នុងវិស័យកសិកម្មថយចុះបន្តិចមកត្រឹម៥៤% វិស័យឧស្សាហកម្មកើនបន្តិចមាន ៣១% និងវិស័យសេវាកម្មកើនតិចតួចមាន ១៥% (ដូចក្នុងក្រាហ្វិក ៦)។

**ក្រាហ្វិក៦. ភាគរយចំនួនសមាជិកក្នុងភូមិបានធ្វើការងារតាមវិស័យសេដ្ឋកិច្ច**



## គ. បរិស្ថាន

ចំនួនគ្រួសារដែលរងផលប៉ះពាល់ការបង្ហូរទឹកកខ្វក់មានចំនួន១០ គ្រួសារ ស្មើនឹង០,២% ក្នុងចំណោមគ្រួសារជាង៥ពាន់ និង រងផលប៉ះពាល់ដោយការចាក់សំរាមមានចំនួន ៥៤គ្រួសារ ស្មើនឹង ១% ក្នុងចំណោមគ្រួសារដូចខាងលើដែរ។

**ក្រាហ្វិក៧. ចំនួនគ្រួសារដែលរងផលប៉ះពាល់ដោយសារការបង្ហូរទឹកកខ្វក់ និងការចាក់សំរាមឆ្នាំ២០២៥**




## ឃ.ស្ថានភាពគ្រោះមហន្តរាយ

ក្រាហ្វិក ៨ បង្ហាញថា ប្រភពព័ត៌មានគ្រោះមហន្តរាយដែលមេភូមិទទួលបានពីព័ត៌មានផ្សេងៗ មាន៨០% ទូរទស្សន៍ ៧០% អាជ្ញាធរ និង សារតាមទូរស័ព្ទមានចំនួនដូចគ្នាគឺ ៦០% ការជូនដំណឹងតាមទូរស័ព្ទផ្ទាល់៥០% និងតាមវិទ្យុមានតែ៣០%។

**ក្រាហ្វិក៨. ភាគរយនៃប្រភពព័ត៌មានគ្រោះមហន្តរាយដែលមេភូមិបានទទួលឆ្នាំ២០២៥**



ក្នុងចំណោមភូមិទាំង១០ នៃខេត្តទាំងពីរខាងលើ មានខូចខាតដោយសារខ្យល់ព្យុះខូចខាតផ្ទះ៥ខ្នង និង ៨៩៦គ្រួសាររងគ្រោះដោយសារគ្រោះរាំងស្ងួត (ក្រាហ្វិក៨)។ ទឹកប្រាក់សរុប ២២.៨០០ដុល្លារ ដែលបានប៉ាន់ស្មានរងគ្រោះដោយគ្រោះមហន្តរាយទាំងពីរនេះ ដែលក្នុងនោះ គ្រោះមហន្តរាយខ្យល់មានទឹកប្រាក់១.០០០ ដុល្លារ និង គ្រោះរាំងស្ងួតមានទឹកប្រាក់ ២១.៨០០ ដុល្លារ (ក្រាហ្វិក១០)។

**ក្រាហ្វិក៩. ចំនួនគ្រួសារដែលរងគ្រោះដោយសារខ្យល់ព្យុះ និង គ្រោះរាំងស្ងួត**




**ក្រាហ្វិក១០. ការខូចខាតដោយសារគ្រោះមហន្តរាយនៅក្នុងភូមិគិតជាទឹកប្រាក់ US$**



### ង. ស្ថានភាពការប្រែប្រួលអាកាសធាតុ

ក្រាហ្វិក ១១ បង្ហាញថា តាមការផ្តល់ចម្លើយពីមេភូមិដែលបានសម្ភាសន៍បានឆ្លើយថា មានរហូតដល់ ១០០%អាកាសធាតុមានការប្រែប្រួលខ្លាំងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ មាន៩០%ទឹកភ្លៀងមិនទៀងទាត់ និង ៧០%មានគ្រោះរាំងស្ងួត (ក្រាហ្វិក១០)។

**ក្រាហ្វិក១១. ការប្រែប្រួលអាកាសធាតុ និង គ្រោះរាំងស្ងួត**




## ២.១.២ លទ្ធផលពីការសម្ភាសន៍មេគ្រួសារ

នៅក្នុងការចុះសម្ភាសន៍ស្រង់ទិន្នន័យជាក់ស្តែងត្រូវប្រើប្រាស់តារាងសំណួរ២ ដែលសម្ភាសន៍ទៅលើមេគ្រួសារចំនួន៦០០នាក់ នៅក្នុងចំណោម១០ភូមិ។ សូចនាករសំខាន់នៅក្នុងការសម្ភាសន៍ គឺផ្តោតទៅលើស្ថានភាពរស់នៅរបស់គ្រួសារ ការប្រើទឹកស្អាត បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុដែលទទួលរងផលប៉ះពាល់នៅក្នុងកម្រិតគ្រួសារ។ លទ្ធផលដែលបានសម្ភាសន៍មេគ្រួសារមានដូចខាងក្រោម។

### ក.ស្ថានភាពប្រជាសាស្រ្ត

### ក១.ស្ថានភាពមេគ្រួសារ

តាមរយៈការចុះស្រង់ទិន្នន័យតាមគ្រួសារបានបង្ហាញថា មេគ្រួសារភាគច្រើនជាបុរសដែលមានរហូតដល់៧៤% និងស្ត្រីមាន២៦% ក្នុងចំណោមមេគ្រួសារទាំង៦០០ គ្រួសារ។ មេគ្រួសារភាគ

ច្រើនទាំងបុរសនិងស្ត្រីគឺស្ថិតនៅក្នុងក្រុមអាយុពី៤០ទៅ៥៩ឆ្នាំ មានភាគរយច្រើនជាងក្នុងនោះបុរសជាមេគ្រួសារមាន៥១% និងស្ត្រីជាមេគ្រួសារមានចំនួន៦០% ខណៈដែលមេគ្រួសារទាំងពីរភេទស្ថិតក្នុងក្រុមអាយុ១៥ដល់៣៩ឆ្នាំ និង៦០ឆ្នាំឡើង តិចជាង៣០%។

**ក្រាហ្វិក១២. ភាគរយនៃមេគ្រួសារដែលបានសម្ភាសន៍**




**ក្រាហ្វិក១៣. ភាគរយនៃមេគ្រួសារតាមក្រុមអាយុដែលបានសម្ភាសន៍**



**តារាង ៥. ចំនួនមេគ្រួសារ បែងចែកតាមក្រុមអាយុ**

| ក្រុមអាយុ | ភេទនៃមេគ្រួសារ | | |
|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ |
| ១៥ ដល់ ៣៩ឆ្នាំ | 97 | 20 | 117 |
| ៤០ ដល់ ៥៩ឆ្នាំ | 234 | 79 | 313 |
| ៦០ឆ្នាំ ឡើង | 115 | 55 | 170 |
| **សរុប** | **446** | **154** | **600** |

អាយុមេគ្រួសារដែលបានសម្ភាសន៍ពីឆ្នាំ២០២០ ដល់២០២៥ បានបង្ហាញថាអាយុមេគ្រួសារដែលទាបបំផុតស្ថិតនៅចន្លោះពី២០ ដល់ ២៤ឆ្នាំ ក្នុងនោះឆ្នាំ២០២៥ អាយុមេគ្រួសារទាបបំផុតគឺ២៣ឆ្នាំ ទាបជាងឆ្នាំ២០២៤ ដែលមានអាយុ២៤ឆ្នាំ។ អាយុមេគ្រួសារខ្ពស់បំផុតស្ថិតចន្លោះពី ៨១ដល់៩៧ ឆ្នាំ តាមបណ្តាឆ្នាំដូចគ្នា។ ទិន្នន័យនេះ បានបង្ហាញថាគ្រួសារខ្លះបានធ្វើចំណាកស្រុកទៅធ្វើការខេត្ត ក្រៅប្រទេសទុកចាស់ៗនៅផ្ទះ សម្រាប់មើលថែទាំផ្ទះសម្បែង។ អាយុមេដ្ឋាន (អាយុកណ្តាល) នៃមេគ្រួសារ នៅចន្លោះពី ៤៤ ដល់ ៥២ឆ្នាំ មានន័យថាមេគ្រួសារ៥០% ដែលមានអាយុខ្ពស់ជាងអាយុមេដ្យាន និង ៥០% មានអាយុតិចជាងអាយុមេដ្យាន។ នៅក្នុង First Quartile (Q1) តាមបណ្តាឆ្នាំស្ថិតនៅចន្លោះពី ៣៥ ដល់ ៤២ឆ្នាំ មានន័យថា មេគ្រួសារ ២៥% មានអាយុទាបជាងអាយុដែលមាននៅក្នុង First Quartile (Q1) និង Third Quartile (Q3) បង្ហាញពីចន្លោះ ៥៥ ដល់ ៦០ឆ្នាំ មានន័យថាមេគ្រួសារ២៥% មានអាយុខ្ពស់ជាងអាយុដែលមាននៅក្នុង Third Quartile (Q3) (តារាង៦ និង ក្រាហ្វិក ១៤) ។

**តារាង ៦. ទិន្នន័យសង្ខេបអាយុមេគ្រួសារទាំងពីរភេទតាមលទ្ធផលដែលបាន ពី Box and Whisker Plot ពីឆ្នាំ២០២០ដល់ ២០២៥**

| អាយុមេគ្រួសារទាំងពីរភេទ(ឆ្នាំ) | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|
| Minimum | 21 | 20 | 20 | 21 | 24 | 23 |
| Maximum | 97 | 85 | 81 | 90 | 93 | 91 |
| Median(Q2) | 45 | 44 | 50 | 46 | 51 | 52 |
| Mean | 46.5 | 45.4 | 49.1 | 48.1 | 50.7 | 51.5 |
| First Quartile(Q1) | 36 | 35 | 40 | 36 | 40 | 42 |
| Third Quartile(Q3) | 56 | 55 | 59 | 58 | 60 | 60 |
| Interquartile Range (IQR) | 20 | 20 | 19 | 22 | 20 | 18 |
| Range | 76 | 65 | 61 | 69 | 69 | 68 |
| Lower outlier | 5 | 5 | 12 | 4 | 10 | 15 |
| Upper outlier | 86 | 85 | 88 | 91 | 90 | 88 |

**ក្រាហ្វិក ១៤. អាយុមេគ្រួសារទាំងពីរភេទដែលបានសម្ភាសន៍បង្ហាញតាម Box and Whisker Plot**




អាយុមេគ្រួសារបែងចែកតាមភេទនៅឆ្នាំ ២០២៥ បានបង្ហាញថា អាយុមេគ្រួសារភេទប្រុសទាបបំផុតមាន ២៣ឆ្នាំ និង ខ្ពស់បំផុត ៩១ឆ្នាំ ខណៈដែលមេគ្រួសារភេទ្រសីមាន២៥ឆ្នាំ និងអាយុខ្ពស់បំផុតមានចំនួន ៨១ឆ្នាំ។ អាយុជាមធ្យមនៃមេគ្រួសារជាបុរសគឺ ៥០,៦ឆ្នាំ និងមេគ្រួសារជាស្រីមានអាយុមធ្យម ៥៤,៣ឆ្នាំ។ មេគ្រួសារជាបុរស ៥០% មានអាយុលើស៥១ឆ្នាំ និង៥០% មានអាយុក្រោម៥១ឆ្នាំ ខណៈមេគ្រួសារជាស្ត្រី៥០% មានអាយុលើសពី៥៥ឆ្នាំ និង៥០% មានអាយុក្រោម៥៥ឆ្នាំ។ មេគ្រួសារភេទប្រុស ២៥% មានអាយុក្រោម៤១ឆ្នាំចុះ និង មេគ្រួសារជាស្រីមាន២៥% មានអាយុក្រោម ៤៦ឆ្នាំចុះ ខណៈដែលមេគ្រួសារភេទប្រុស២៥% មានអាយុលើសពី៦០ឆ្នាំឡើង និង២៥%នៃមេគ្រួសារភេទស្រីដែលមានអាយុលើសពី៦៤ឆ្នាំឡើង។ មេគ្រួសារភេទប្រុសដែលស្ថិតចន្លោះអាយុចាប់ពី ៤១ ដល់ ៦០ឆ្នាំ មាន៥០% និងមេគ្រួសារភេទស្រីដែលស្ថិតនៅចន្លោះអាយុចាប់ពី ៤៦ ដល់ ៦៤ឆ្នាំ មាន៥០%។ Interquartile Range (IQR) គឺផលដករវាង Third Quartile (Q3) និង First Quartile (Q1) សម្រាប់មេគ្រួសារជាបុរសស្មើនឹង ១៩ឆ្នាំ និង សម្រាប់មេគ្រួសារជាស្ត្រីស្មើនឹង១៨ឆ្នាំ។ ទិន្នន័យនេះបង្ហាញថា សម្រាប់មេគ្រួសារជាបុរស ភាពខុសគ្នារវាង Q3=៦០ឆ្នាំ និង Q1=៤១ឆ្នាំ មានចំនួន១៩ឆ្នាំ និង សម្រាប់ស្ត្រីជាមេគ្រួសារភាពខុសគ្នារវាង Q3=៦៤ឆ្នាំ និង Q1=៤៦ឆ្នាំ មានចំនួន១៨ឆ្នាំ។ ទិន្នន័យ Lower outlier គឺ១៣ សម្រាប់បុរសមេគ្រួសារ និងស្ត្រីមេគ្រួសារ១៩ និង Upper outlier គឺ៨៩ សម្រាប់បុរសមេគ្រួសារ និងស្ត្រីមេគ្រួសារ៩១ ជាទិន្នន័យដែលមិនត្រូវបានយកពិចារណាទេ (តារាង៧ និងក្រាហ្វិក១៥)។

### តារាង ៧. តារាងសង្ខេបអាយុមេគ្រួសារតាមភេទតាមលទ្ធផលដែលបាន ពី Box and Whisker Plot ឆ្នាំ២០២៥

| អាយុមេគ្រួសារ | ប្រុស | ស្រី | ទាំងពីរភេទ |
|---|---|---|---|
| Minimum | 23 | 25 | 23 |
| Maximum | 91 | 81 | 91 |
| Median(Q2) | 51 | 55 | 52 |
| Mean | 50.6 | 54.3 | 51.5 |
| First Quartile(Q1) | 41 | 46 | 42 |
| Third Quartile(Q3) | 60 | 64 | 60 |
| Interquartile Range (IQR) | 19 | 18 | 18 |
| Range | 68 | 56 | 68 |
| Lower outlier | 13 | 19 | 15 |
| Upper outlier | 89 | 91 | 88 |

*Note: Lower outliers= Q1-1.5*IQR; Upper outliers= Q3-1.5*IQR*

### ក្រាហ្វិក ១៥. អាយុមេគ្រួសារតាមភេទដែលបានសម្ភាសន៍ឆ្នាំ២០២៥ បង្ហាញតាម Box and Whisker Plot



## ក២.ទំហំគ្រួសារ និងសមាជិកក្នុងគ្រួសារ

តាមរយៈការធ្វើសម្ភាន៍មេគ្រួសារចាប់តាំងពីឆ្នាំ២០២០ ដល់ ឆ្នាំ២០២៥ បានបង្ហាញទំហំគ្រួសារជាមធ្យមក្នុងគ្រួសារស្ថិតនៅចន្លោះ៤,៥នាក់ ដល់ ៤,៨នាក់ ក្នុងនោះឆ្នាំ២០២៥ មានទំហំសមាជិកគ្រួសារជាមធ្យម ៤,៧នាក់ (ក្រាហ្វិក១៦)។

**ក្រាហ្វិក១៦. ទំហំគ្រួសារគិតជាមធ្យម**




ចំនួនសមាជិកក្នុងគ្រួសារភេទប្រុសមានចំនួន១,៣៩៨ នាក់ ស្មើនឹង៤៩% និងសមាជិកគ្រួសារភេទប្រុសមានចំនួន១,៤៤៦នាក់ ស្មើនឹង៥១% តាមរយៈការសម្ភាសន៍មេគ្រួសារ៦០០នាក់ នៅក្នុងឆ្នាំ២០២៥ តាមភូមិគោលដៅដែលបានកំណត់នៅក្នុងអង្កេតនេះ (តារាង៨)។

**តារាង ៨. ចំនួនគ្រួសារ និងសមាជិកគ្រួសារឆ្នាំ២០២៥**

| ភេទ | ចំនួនគ្រួសារ | ចំនួនសមាជិកអចិន្ត្រៃយ៍ | ភាគរយ (%) |
|---|---|---|---|
| **ទាំងពីរភេទ** | 600 | 2,844 | 100 |
| ប្រុស | 446 | 1,398 | 49 |
| ស្រី | 154 | 1,446 | 51 |

សមាជិកគ្រួសារដែលមានបុរសជាមេគ្រួសារមានចំនួន២.៨៤៤នាក់ ច្រើនជាងមេគ្រួសារជាស្ត្រីដែលមានចំនួន៧០០នាក់។ នៅក្នុងក្រុមអាយុបុរសជាមេគ្រួសារពី៤០ ដល់ ៥៩ឆ្នាំ មានចំនួនសមាជិក១.១៦៨នាក់ ច្រើនជាង ខណៈដែលបុរសជាមេគ្រួសារក្នុងក្រុមអាយុ ១៥ ដល់ ៣៩ឆ្នាំមានចំនួនសមាជិកគ្រួសារ ៤៣២នាក់ និង បុរសជាមេគ្រួសារក្នុងក្រុមអាយុ៦០ឆ្នាំ ឡើង មានចំនួនសមាជិកគ្រួសារ ៥៤៤នាក់។ ចំពោះស្ត្រីជាមេគ្រួសារដែលស្ថិតនៅចន្លោះអាយុពី ៤០ ដល់ ៥៩ឆ្នាំ មានចំនួនសមាជិកចំនួន ៣៥៨នាក់ ខណៈដែលស្ត្រីជាមេគ្រួសារស្ថិតនៅចន្លោះអាយុពី១៥ដល់៣៩ឆ្នាំ មានសមាជិកគ្រួសារចំនួន៨៣នាក់ និងមេគ្រួសារជាស្ត្រីដែលមានអាយុចាប់ពី៦០ឆ្នាំឡើង មានសមាជិកគ្រួសារចំនួន២៥៩នាក់។ ចំនួនសមាជិកគ្រួសារទាំងនេះ ក្នុងចំណោមសមាជិកសរុប ២.៨៤៤នាក់ នៃចំនួនគ្រួសារសរុប៦០០ គ្រួសារ (តារាង៩)។

**តារាង ៩. ចំនួនសមាជិកគ្រួសារបែងតាមក្រុមអាយុនិងភេទមេគ្រួសារ**

| ក្រុមអាយុ | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|
| **ទាំងពីរភេទ** | | | |
| **សរុប** | **2,844** | **1,398** | **1,446** |
| 15-39 | 515 | 252 | 263 |
| 40-59 | 1,526 | 753 | 773 |
| 60+ | 803 | 393 | 410 |
| **ប្រុស** | | | |
| **សរុប** | **2,144** | **1,079** | **1,065** |
| 15-39 | 432 | 217 | 215 |
| 40-59 | 1,168 | 587 | 581 |
| 60+ | 544 | 275 | 269 |
| **ស្រី** | | | |
| **សរុប** | **700** | **319** | **381** |
| 15-39 | 83 | 35 | 48 |
| 40-59 | 358 | 166 | 192 |
| 60+ | 259 | 118 | 141 |

## ក៣.ចំណាកស្រុក

សមាជិកគ្រួសារបានធ្វើចំណាកស្រុកសរុបមានចំនួន៣២៦នាក់ ក្នុងនោះចំណាកស្រុកក្នុងប្រទេសមានចំនួន២៨៣នាក់ ស្មើនឹង៨៧% និងចំណាកស្រុកក្រៅប្រទេសមាន៤៣នាក់ ស្មើនឹង១៣%។ សមាជិកចំណាកស្រុកភាគច្រើន ជាបុរសមានចំនួន១៦១នាក់ចំណាកស្រុកក្នុងប្រទេស និងក្រៅប្រទេសមានចំនួន ៣០នាក់ ខណៈចំណាកស្រុកជាស្ត្រីមានចំនួន១២២នាក់ នៅក្នុងប្រទេស និងនៅក្រៅប្រទេសមានចំនួន១៣នាក់ (ក្រាហ្វិក១៧ និងតារាង១០)។

**ក្រាហ្វិក១៧. ភាគរយសមាជិកចំណាកស្រុក**




**តារាង ១០. ចំនួនសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកឆ្នាំ២០២៥**

| ភេទ | សមាជិកគ្រួសារចំណាកស្រុកសរុប | សមាជិកចំណាកស្រុកក្នុងប្រទេស | សមាជិកចំណាកស្រុកក្រៅប្រទេស |
|---|---|---|---|
| **ទាំងពីរភេទ** | **326** | **283** | **43** |
| ប្រុស | 191 | 161 | 30 |
| ស្រី | 135 | 122 | 13 |

ចំនួនសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកក្នុងប្រទេសមានចំនួនច្រើនជាង សមាជិកដែលបានធ្វើចំណាកស្រុកទៅក្រៅប្រទេស។ ក្រុមអាយុមេគ្រួសារដែលមានអាយុចាប់ពី៤០ដល់៥៩ឆ្នាំ មានចំនួនសមាជិកចំណាកស្រុកច្រើនជាង ចំនួនសមាជិកដែលស្ថិតនៅក្នុងក្រុមអាយុ ១៥ដល់៣៩ឆ្នាំ និង អាយុ៦០ឡើង (តារាង១១)។

### តារាង ១១. ចំនួនសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុក បែងចែកតាមភេទ និងក្រុមអាយុរបស់មេគ្រួសារឆ្នាំ២០២៥

| ភេទមេគ្រួសារ | ចំណាកស្រុកសរុប | | | ចំណាកស្រុកក្នុងប្រទេស | | | ចំណាកស្រុកក្រៅប្រទេស | | |
|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| **ប្រុស** | | | | | | | | | |
| **សរុប** | **138** | **107** | **245** | **119** | **97** | **216** | **19** | **10** | **29** |
| 15-39 | 16 | 14 | 30 | 14 | 14 | 28 | 2 | 0 | 2 |
| 40-59 | 78 | 67 | 145 | 65 | 58 | 123 | 13 | 9 | 22 |
| 60+ | 44 | 26 | 70 | 40 | 25 | 65 | 4 | 1 | 5 |
| **ស្រី** | | | | | | | | | |
| សរុប | 53 | 28 | 81 | 42 | 25 | 67 | 11 | 3 | 14 |
| 15-39 | 3 | 2 | 5 | 2 | 2 | 4 | 1 | 0 | 1 |
| 40-59 | 25 | 13 | 38 | 18 | 12 | 30 | 7 | 1 | 8 |
| 60+ | 25 | 13 | 38 | 22 | 11 | 33 | 3 | 2 | 5 |
| **ទាំងពីរភេទ** | | | | | | | | | |
| **សរុប** | **191** | **135** | **326** | **161** | **122** | **283** | **30** | **13** | **43** |
| 15-39 | 19 | 16 | 35 | 16 | 16 | 32 | 3 | 0 | 3 |
| 40-59 | 103 | 80 | 183 | 83 | 70 | 153 | 20 | 10 | 30 |
| 60+ | 69 | 39 | 108 | 62 | 36 | 98 | 7 | 3 | 10 |

តាមការសម្ភាសន៍មេគ្រួសារបានបង្ហាញថា សមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកពីភូមិកំណើតរបស់គាត់ទៅតាមបណ្ដារាជធានី ខេត្តនៅក្នុងប្រទេសកម្ពុជា។ តាមទិន្នន័យបង្ហាញថា ប្រជាជនចំណាកស្រុកបានមកធ្វើការនៅរាជធានីភ្នំពេញមានចំនួនច្រើនជាងគេស្មើនឹង៧១% នៃចំណាកស្រុកក្នុងស្រុកសរុប ខណៈខេត្តមួយចំនួនពុំមានចំណាកស្រុកមកខេត្តផ្សេងដូចជា ខេត្តបាត់ដំបង កំពង់ឆ្នាំង ព្រៃវែង ឧត្តរមានជ័យ កែប និងខេត្តប៉ៃលិនជាដើម។ ចំពោះចំណាកស្រុកទៅក្រៅប្រទេសគឺមានតែវៀតណាម ថៃ កូរ៉េ និងប្រទេសជប៉ុន ដែលក្នុងនោះចំណាកស្រុកទៅប្រទេសថៃមានចំនួនច្រើនជាងគេ បន្ទាប់មកប្រទេសកូរ៉េ ប្រទេសជប៉ុន និងប្រទេសវៀតណាម តាមលំដាប់រៀង (ក្រាហ្វិក ១៨ និងក្រាហ្វិក ១៩) ខាងក្រោម។

## ក្រាហ្វិក១៨. ចំនួនសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកទៅតាមបណ្តាខេត្ត




## ក្រាហ្វិក១៩. ចំនួនសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកទៅក្រៅប្រទេស



មូលហេតុចម្បង ដែលសមាជិកគ្រួសារបានធ្វើចំណាកស្រុកក្នុងប្រទេស គឺមានតែមូលហេតុ ៣ប៉ុណ្ណោះដែលមានដូចជាការស្វែងរកការងារធ្វើ ការសិក្សា និងប្តូរកន្លែងការងារ។ ក្នុងចំណោមមូលហេតុទាំង៣នេះគឺ មូលហេតុស្វែងរកការងារធ្វើមានចំនួនច្រើនជាងគេ ឈរលំដាប់ទី១ បន្ទាប់ការសិក្សា និងចុងក្រោយប្តូរកន្លែងការងារ ខណៈដែលមូលហេតុចំណាកស្រុកក្រៅប្រទេសមានតែមូលហេតុស្វែងរកការងារធ្វើតែប៉ុណ្ណោះ (ក្រាហ្វិក២០ និងក្រាហ្វិក២១)។

**ក្រាហ្វិក២០. មូលហេតុដែលធ្វើចំណាកស្រុកក្នុងប្រទេស**




**ក្រាហ្វិក២១ មូលហេតុស្វែងរកការងារធ្វើសម្រាប់ចំណាកស្រុកក្រៅប្រទេសបែងចែកតាមភេទ**



## ខ. ផ្នែកការងារ មុខរបរ និងការងារតាមវិស័យសេដ្ឋកិច្ច

### ខ១.ផ្នែកការងារ

សមាជិកគ្រួសារទាំងពីរភេទសរុប ដែលបានធ្វើការងារតាមផ្នែកនៃការងារសរុបមានចំនួន ១.៥៤២នាក់ ក្នុងនោះសមាជិកគ្រួសារដែលធ្វើការផ្នែកក្រុមហ៊ុនឯកជនខ្មែរមានចំនួនច្រើនជាងគេគឺ ១.២៤៤នាក់ ស្មើនឹង ៨០,៦៧% ក្រុមហ៊ុនឯកជនបរទេសមាន ២៥១នាក់ ស្មើនឹង១៦,២៨% ធ្វើការផ្នែករដ្ឋាភិបាលមានចំនួន៤០នាក់ស្មើនឹង២,៥៩% ជួយគ្រួសារមាន ៥នាក់ ស្មើនឹង០,៣២% និង ផ្នែកការងារស្វ័យតមានចំនួន២នាក់ ស្មើនឹង០,១៣% (តារាង១២ និងក្រាហ្វិក២៤)។ ភាគរយសមាជិកគ្រួសារ ដែលបានធ្វើការងារតាមផ្នែកនៃការងារបែងចែកតាមភេទ មានបង្ហាញក្នុងក្រាហ្វិក ២២ ដូចខាងក្រោម។

**តារាង ១២. ចំនួនសមាជិកបានធ្វើការងារតាមផ្នែកនៃការងារ**

| ភេទ | រដ្ឋាភិបាល | ស្វយ័ត | ក្រុមហ៊ុន ឯកជនខ្មែរ | ក្រុមហ៊ុន ឯកជនបរទេស | ជួយគ្រួសារ | សរុប |
|---|---|---|---|---|---|---|
| **ទាំងពីរភេទ** | 40 | 2 | 1,244 | 251 | 5 | 1,542 |
| ប្រុស | 28 | 0 | 708 | 89 | 3 | 828 |
| ស្រី | 12 | 2 | 536 | 162 | 2 | 714 |

**ក្រាហ្វិក២២. ភាគរយសមាជិកគ្រួសារដែលបានធ្វើការងារតាមផ្នែកនៃការងារទាំងពីរភេទ**



ក្រាហ្វិក២៣. ភាគរយសមាជិកគ្រួសារដែលបានធ្វើការងារតាមផ្នែកនៃការងារ




ចំនួនសមាជិកគ្រួសារ ដែលបានធ្វើការងារតាមផ្នែកនៃការងារបែងចែកតាមភេទនិងក្រុមអាយុមេគ្រួសារ គឺសមាជិកគ្រួសារដែលបានធ្វើការងារក្រុមហ៊ុនឯកជនខ្មែរមានចំនួនច្រើនជាងគេស្ថិតក្នុងមេគ្រួសារដែលមានក្រុមអាយុ ៤០ ដល់ ៥៩ឆ្នាំ និង៦០ឆ្នាំឡើង ខណៈដែលមេគ្រួសារ មានអាយុចន្លោះពី១៥ ដល់ ៣៩ឆ្នាំ មានចំនួនតិចជាងគេសម្រាប់មេគ្រួសារទាំងពីរភេទ។ ចំពោះមេគ្រួសារជាបុរសដែលស្ថិតនៅក្នុងក្រុមពី៤០ ដល់ ៥៩ឆ្នាំ និង ៦០ឆ្នាំឡើង មានសមាជិកធ្វើការច្រើនជាងមេគ្រួសារជាស្ត្រីដែលស្ថិតក្នុងក្រុមអាយុដូចគ្នានេះដែរ និងក្រុមអាយុដែលមានមេគ្រួសារជាបុរសដែលស្ថិតនៅក្នុងក្រុមអាយុចាប់ពី ១៥ ដល់ ៣៩ឆ្នាំ ក៏មានសមាជិកធ្វើការច្រើនជាងសមាជិកដែលមានមេគ្រួសារជាស្ត្រីក្នុងក្រុមអាយុដូចគ្នានេះដែរ (តារាង១៣)។

## តារាង ១៣. ចំនួនសមាជិកគ្រួសារបានធ្វើការងារតាមផ្នែកនៃការងារបែងចែកតាមភេទ និងក្រុមអាយុមេគ្រួសារ

| ភេទមេគ្រួសារ | រដ្ឋាភិបាល | ស្វយ័ត | ក្រុមហ៊ុនឯកជនខ្មែរ | ក្រុមហ៊ុនឯកជនបរទេស | ជួយគ្រួសារ | សរុប |
|---|---|---|---|---|---|---|
| **ទាំងពីរភេទ** | | | | | | |
| **សរុប** | **40** | **2** | **1244** | **251** | **5** | **1,542** |
| 15-39 | 3 | 0 | 195 | 33 | 0 | 231 |
| 40-59 | 25 | 0 | 683 | 127 | 4 | 839 |
| 60+ | 12 | 2 | 366 | 91 | 1 | 472 |
| **ប្រុស** | | | | | | |
| **សរុប** | **30** | **2** | **948** | **179** | **3** | **1,162** |
| 15-39 | 2 | 0 | 168 | 25 | 0 | 195 |
| 40-59 | 18 | 0 | 526 | 95 | 3 | 642 |
| 60+ | 10 | 2 | 254 | 59 | 0 | 325 |
| **ស្រី** | | | | | | |
| **សរុប** | **10** | **0** | **296** | **72** | **2** | **380** |
| 15-39 | 1 | 0 | 27 | 8 | 0 | 36 |
| 40-59 | 7 | 0 | 157 | 32 | 1 | 197 |
| 60+ | 2 | 0 | 112 | 32 | 1 | 147 |

### ខ២.មុខរបរ

ចំនួនសមាជិកទាំងពីរភេទដែលមានមុខរបរចម្បងៗសរុបចំនួន១,៥៤២នាក់ ក្នុងចំណោម ៦០០គ្រួសារ ដែលបានសម្ភាសន៍ ដែលក្នុងនោះជាកសិករដាំស្រូវ ដាំដំណាំ នេសាទ និងចិញ្ចឹមសត្វ មានចំនួនរហូតដល់៥៩៩នាក់ ស្មើនឹង ៣៩% កម្មករទទួលប្រាក់ខែមានចំនួន៣៩០នាក់ ស្មើនឹង ២៥% និងជាសន្តិសុខមានចំនួន៣៨២នាក់ ស្មើនឹង ២៥% ហើយក្រៅពីនោះមានមុខរបរផ្សេងៗមានចំនួន២៥២នាក់ស្មើនឹង១១% ក្នុងចំណោមអ្នកមានមុខរបរចម្បង ១,៥៤២នាក់។ ចំពោះសមាជិកភេទប្រុសដែលមានមុខរបរ ជាកសិករ ដាំស្រូវ ដាំដំណាំ នេសាទ និងចិញ្ចឹមសត្វ មានចំនួនរហូតដល់ ៣៤០នាក់ ស្មើនឹង ៤១% កម្មករទទួលប្រាក់ខែមានចំនួន១៨៦នាក់ ស្មើនឹង២២% សន្តិសុខមានចំនួន១៧១នាក់ ស្មើនឹង ២១% និងមុខរបរផ្សេងៗមានចំនួន ១៣២នាក់ ស្មើនឹង១៦% ក្នុងចំណោម

សមាជិកគ្រួសារភេទប្រុសសរុបចំនួន៨២៩នាក់។ ទន្ទឹមនឹងនេះផងដែរ សមាជិកភេទស្រីដែលមានមុខរបរ ជាកសិករ ដាំស្រូវ ដាំដំណាំ នេសាទ និងចិញ្ចឹមសត្វ មានចំនួនរហូតដល់២៥៩នាក់ ស្មើនឹង ៣៦% សន្តិសុខមានចំនួន២១១នាក់ ស្មើនឹង ៣០% កម្មករទទួលប្រាក់ខែមានចំនួន២០៤នាក់ ស្មើនឹង២៩% និងមុខរបរផ្សេងៗ មានចំនួន៣៩នាក់ ស្មើនឹង៥%។ ទិន្នន័យនេះ សម្រាប់សមាជិកគ្រួសារដែលមានមេគ្រួសារទាំងពីរភេទ។

**តារាង១៤. មុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារ**

| មុខរបរចម្បង | ប្រុស | ស្រី | ទាំងពីរភេទ |
|---|---|---|---|
| **សរុប** | **829** | **713** | **1,542** |
| កម្មករទទួលប្រាក់ខែ | 186 | 204 | 390 |
| កម្មករទទួលប្រាក់ឈ្នួលប្រចាំថ្ងៃ | 39 | 9 | 48 |
| បុគ្គលិកឯកជន | 33 | 17 | 50 |
| បុគ្គលិករដ្ឋាភិបាល | 31 | 12 | 43 |
| កសិករដាំស្រូវ ដាំដំណាំ នេសាទ និងចិញ្ចឹមសត្វ | 340 | 259 | 599 |
| កាត់សក់ | 4 | 0 | 4 |
| សំណង់ | 3 | 0 | 3 |
| ជួសជុលនាឡិការនិងវិទ្យុ | 16 | 0 | 16 |
| ជួសជុលម៉ូតូ | 6 | 1 | 7 |
| សន្តិសុខ | 171 | 211 | 382 |

**ក្រាហ្វិក២៤. ភាគរយនៃមុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារទាំងពីរភេទ និងមេគ្រួសារទាំងពីរភេទ**



ក្រាហ្វិក២៥. ភាគរយនៃមុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារភេទប្រុស និងមេគ្រួសារទាំងពីរភេទ




ក្រាហ្វិក២៦. ភាគរយនៃមុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារភេទស្រី និងមេគ្រួសារទាំងពីរភេទ



## តារាង ១៥. មុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារទាំងពីរភេទ បែងចែកតាមភេទ និងក្រុមអាយុនៃមេគ្រួសារ

| ភេទមេគ្រួសារ | មុខរបរចម្បង | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | កម្មករទទួលប្រាក់ខែ | កម្មករទទួលប្រាក់ឈ្នួលប្រចាំថ្ងៃ | បុគ្គលិកឯកជន | បុគ្គលិករដ្ឋាភិបាល | កសិករដាំស្រូវនិងដាំដំណាំ | នេសាទ | ចិញ្ចឹមសត្វ | កសិករដាំដំណាំ | កាត់សក់ | មេការសំណង់ | ជាងជួសជុលវិទ្យុនិងនាឡិការ | ជាងជួសជុលម៉ូតូ | សន្តិសុខ |
| **ទាំងពីរភេទ** | | | | | | | | | | | | | | |
| សរុប | **1,542** | **390** | **48** | **50** | **43** | **518** | **50** | **19** | **12** | **4** | **3** | **16** | **7** | **382** |
| 15-39 | 231 | 63 | 8 | 7 | 3 | 62 | 4 | 0 | 2 | 1 | 1 | 4 | 0 | 76 |
| 40-59 | 839 | 195 | 26 | 25 | 26 | 287 | 35 | 12 | 8 | 2 | 1 | 8 | 3 | 211 |
| 60+ | 472 | 132 | 14 | 18 | 14 | 169 | 11 | 7 | 2 | 1 | 1 | 4 | 4 | 95 |
| **ប្រុស** | | | | | | | | | | | | | | |
| សរុប | **1,162** | **260** | **31** | **35** | **33** | **429** | **46** | **13** | **8** | **4** | **3** | **14** | **6** | **280** |
| 15-39 | 195 | 47 | 5 | 7 | 2 | 55 | 4 | 0 | 2 | 1 | 1 | 4 | 0 | 67 |
| 40-59 | 642 | 130 | 20 | 14 | 19 | 237 | 32 | 6 | 6 | 2 | 1 | 7 | 3 | 165 |
| 60+ | 325 | 83 | 6 | 14 | 12 | 137 | 10 | 7 | 0 | 1 | 1 | 3 | 3 | 48 |
| **ស្រី** | | | | | | | | | | | | | | |
| សរុប | **380** | **130** | **17** | **15** | **10** | **89** | **4** | **6** | **4** | **0** | **0** | **2** | **1** | **102** |
| 15-39 | 36 | 16 | 3 | 0 | 1 | 7 | 0 | 0 | 0 | 0 | 0 | 0 | 0 | 9 |
| 40-59 | 197 | 65 | 6 | 11 | 7 | 50 | 3 | 6 | 2 | 0 | 0 | 1 | 0 | 46 |
| 60+ | 147 | 49 | 8 | 4 | 2 | 32 | 1 | 0 | 2 | 0 | 0 | 1 | 1 | 47 |

# តារាង ១៦ មុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារភេទប្រុស បែងចែកតាមភេទ និងក្រុមអាយុនៃមេគ្រួសារ

| ភេទមេគ្រួសារ | មុខរបរចម្បង | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | កម្មការទទួលប្រាក់ខែ | កម្មករទទួលប្រាក់ឈ្នួលប្រចាំថ្ងៃ | បុគ្គលិកឯកជន | បុគ្គលិករដ្ឋាភិបាល | កសិករដាំស្រូវនិងដាំដំណាំ | នេសាទ | ចិញ្ចឹមសត្វ | កសិករដាំដំណាំ | កាត់សក់ | មេការសំណង់ | ជាងជួសជុលវិទ្យុនិងនាឡិការ | ជាងជួសជុលម៉ូតូ | សន្តិសុខ |
| **ទាំងពីរភេទ** | | | | | | | | | | | | | | 
| **សរុប** | **829** | **186** | **39** | **33** | **31** | **288** | **36** | **12** | **4** | **4** | **3** | **16** | **6** | **171** |
| 15-39 | 129 | 27 | 8 | 4 | 3 | 38 | 3 | 0 | 1 | 1 | 1 | 4 | 0 | 39 |
| 40-59 | 449 | 96 | 21 | 17 | 17 | 158 | 26 | 8 | 2 | 2 | 1 | 8 | 2 | 91 |
| 60+ | 251 | 63 | 10 | 12 | 11 | 92 | 7 | 4 | 1 | 1 | 1 | 4 | 4 | 41 |
| **ប្រុស** | | | | | | | | | | | | | | 
| **សរុប** | **641** | **115** | **25** | **22** | **27** | **252** | **34** | **8** | **2** | **4** | **3** | **14** | **5** | **130** |
| 15-39 | 109 | 20 | 5 | 4 | 2 | 33 | 3 | 0 | 1 | 1 | 1 | 4 | 0 | 35 |
| 40-59 | 350 | 56 | 16 | 8 | 15 | 138 | 25 | 4 | 1 | 2 | 1 | 7 | 2 | 75 |
| 60+ | 182 | 39 | 4 | 10 | 10 | 81 | 6 | 4 | 0 | 1 | 1 | 3 | 3 | 20 |
| **ស្រី** | | | | | | | | | | | | | | 
| **សរុប** | **188** | **71** | **14** | **11** | **4** | **36** | **2** | **4** | **2** | **0** | **0** | **2** | **1** | **41** |
| 15-39 | 20 | 7 | 3 | 0 | 1 | 5 | 0 | 0 | 0 | 0 | 0 | 0 | 0 | 4 |
| 40-59 | 99 | 40 | 5 | 9 | 2 | 20 | 1 | 4 | 1 | 0 | 0 | 1 | 0 | 16 |
| 60+ | 69 | 24 | 6 | 2 | 1 | 11 | 1 | 0 | 1 | 0 | 0 | 1 | 1 | 21 |

## តារាង ១៧ មុខរបរចម្បងៗរបស់សមាជិកក្នុងគ្រួសារភេទស្រី បែងចែកតាមភេទ និងក្រុមអាយុនៃមេគ្រួសារ

| ភេទមេគ្រួសារ | មុខរបរចម្បង | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | កម្មករទទួលប្រាក់ខែ | កម្មករទទួលប្រាក់ឈ្នួលប្រចាំថ្ងៃ | បុគ្គលិកឯកជន | បុគ្គលិករដ្ឋាភិបាល | កសិករដាំស្រូវនិងដាំដំណាំ | នេសាទ | ចិញ្ចឹមសត្វ | កសិករដាំដំណាំ | កាត់សក់ | មេការសំណង់ | ជាងជួសជុលវិទ្យុនិងនាឡិការ | ជាងជួសជុលម៉ូតូ | សន្តិសុខ |
| **ទាំងពីរភេទ** | | | | | | | | | | | | | | |
| **សរុប** | **713** | **204** | **9** | **17** | **12** | **230** | **14** | **7** | **8** | **0** | **0** | **0** | **1** | **211** |
| 15-39 | 102 | 36 | 0 | 3 | 0 | 24 | 1 | 0 | 1 | 0 | 0 | 0 | 0 | 37 |
| 40-59 | 390 | 99 | 5 | 8 | 9 | 129 | 9 | 4 | 6 | 0 | 0 | 0 | 1 | 120 |
| 60+ | 221 | 69 | 4 | 6 | 3 | 77 | 4 | 3 | 1 | 0 | 0 | 0 | 0 | 54 |
| **ប្រុស** | | | | | | | | | | | | | | |
| **សរុប** | **521** | **145** | **6** | **13** | **6** | **177** | **12** | **5** | **6** | **0** | **0** | **0** | **1** | **150** |
| 15-39 | 86 | 27 | 0 | 3 | 0 | 22 | 1 | 0 | 1 | 0 | 0 | 0 | 0 | 32 |
| 40-59 | 292 | 74 | 4 | 6 | 4 | 99 | 7 | 2 | 5 | 0 | 0 | 0 | 1 | 90 |
| 60+ | 143 | 44 | 2 | 4 | 2 | 56 | 4 | 3 | 0 | 0 | 0 | 0 | 0 | 28 |
| **ស្រី** | | | | | | | | | | | | | | |
| **សរុប** | **192** | **59** | **3** | **4** | **6** | **53** | **2** | **2** | **2** | **0** | **0** | **0** | **0** | **61** |
| 15-39 | 16 | 9 | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 5 |
| 40-59 | 98 | 25 | 1 | 2 | 5 | 30 | 2 | 2 | 1 | 0 | 0 | 0 | 0 | 30 |
| 60+ | 78 | 25 | 2 | 2 | 1 | 21 | 0 | 0 | 1 | 0 | 0 | 0 | 0 | 26 |

## ១២.ការងារតាមវិស័យសេដ្ឋកិច្ច

ចំនួនសមាជិកទាំងអស់ដែលបានចូលរួមធ្វើការងារតាមវិស័យសេដ្ឋកិច្ចមានចំនួន ១.៥៤២នាក់ ក្នុងនោះសមាជិកដែលចូលរួមធ្វើការងារក្នុងវិស័យកសិកម្មមានចំនួន៥៩១នាក់ ស្មើនឹង៤០% វិស័យឧស្សាហកម្មមានចំនួន៣៩៣នាក់ ស្មើនឹង២៥,៥% និងវិស័យសេវាកម្មមានចំនួន៥៥៨នាក់ ស្មើនឹង៣៤,៧%។ ចំពោះការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យកសិកម្មមានបុរសចំនួន៣៣៧នាក់ ស្មើនឹង៤០,៧% ស្ត្រីមានចំនួន២៥៤នាក់ ស្មើនឹង៣៥,៦% វិស័យឧស្សាហកម្មមានបុរសមានចំនួន១៩១នាក់ ស្មើនឹង២៣,០% ស្ត្រីមានចំនួន២០២នាក់ ស្មើនឹង២៨,៣% និងវិស័យសេវាកម្មមានបុរសចូលរួមចំនួន៣០១នាក់ ស្មើនឹង៣៦,៣% និងស្ត្រីមានចំនួន២៥៧នាក់ស្មើនឹង៣៦,០% (តារាង១៨ និងតារាង១៩)។

**តារាង ១៨. សមាជិកគ្រួសារដែលបានធ្វើការងារតាមវិស័យសេដ្ឋកិច្ចតាមក្រុមអាយុនៃភេទមេគ្រួសារ**

| ភេទមេគ្រួសារ | កសិកម្ម | | | ឧស្សាហកម្ម | | | សេវាកម្ម | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ |
| **ទាំងពីរភេទ** | | | | | | | | | | | | |
| **សរុប** | **337** | **254** | **591** | **191** | **202** | **393** | **301** | **257** | **558** | **829** | **713** | **1,542** |
| 15-39 | 41 | 25 | 66 | 27 | 35 | 62 | 61 | 42 | 103 | 129 | 102 | 231 |
| 40-59 | 193 | 144 | 337 | 102 | 98 | 200 | 154 | 148 | 302 | 449 | 390 | 839 |
| 60+ | 103 | 85 | 188 | 62 | 69 | 131 | 86 | 67 | 153 | 251 | 221 | 472 |
| **ប្រុស** | | | | | | | | | | | | |
| **សរុប** | **295** | **196** | **491** | **120** | **145** | **265** | **226** | **180** | **406** | **641** | **521** | **1,162** |
| 15-39 | 36 | 23 | 59 | 20 | 26 | 46 | 53 | 37 | 90 | 109 | 86 | 195 |
| 40-59 | 168 | 110 | 278 | 62 | 74 | 136 | 120 | 108 | 228 | 350 | 292 | 642 |
| 60+ | 91 | 63 | 154 | 38 | 45 | 83 | 53 | 35 | 88 | 182 | 143 | 325 |
| **ស្រី** | | | | | | | | | | | | |
| **សរុប** | **42** | **58** | **100** | **71** | **57** | **128** | **75** | **77** | **152** | **188** | **192** | **380** |
| 15-39 | 5 | 2 | 7 | 7 | 9 | 16 | 8 | 5 | 13 | 20 | 16 | 36 |
| 40-59 | 25 | 34 | 59 | 40 | 24 | 64 | 34 | 40 | 74 | 99 | 98 | 197 |
| 60+ | 12 | 22 | 34 | 24 | 24 | 48 | 33 | 32 | 65 | 69 | 78 | 147 |

តារាង ១៩. ភាគរយសមាជិកគ្រួសារដែលបានធ្វើការងារតាមវិស័យសេដ្ឋកិច្ចតាមក្រុមអាយុនៃភេទមេគ្រួសារ

| ភេទមេគ្រួសារ | កសិកម្ម | | | ឧស្សាហកម្ម | | | សេវាកម្ម | | |
|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ |
| ទាំងពីរភេទ | | | | | | | | | |
| **សរុប** | **40.7** | **35.6** | **40.0** | **23.0** | **28.3** | **25.2** | **36.3** | **36.0** | **34.7** |
| 15-39 | 31.8 | 24.5 | 28.6 | 20.9 | 34.3 | 26.8 | 47.3 | 41.2 | 44.6 |
| 40-59 | 43.0 | 36.9 | 40.2 | 22.7 | 25.1 | 23.8 | 34.3 | 37.9 | 36.0 |
| 60+ | 41.0 | 38.5 | 39.8 | 24.7 | 31.2 | 27.8 | 34.3 | 30.3 | 32.4 |
| បុរស | | | | | | | | | |
| **សរុប** | **46.0** | **37.6** | **42.3** | **18.7** | **27.8** | **22.8** | **35.3** | **34.5** | **34.9** |
| 15-39 | 33.0 | 26.7 | 30.3 | 18.3 | 30.2 | 23.6 | 48.6 | 43.0 | 46.2 |
| 40-59 | 48.0 | 37.7 | 43.3 | 17.7 | 25.3 | 21.2 | 34.3 | 37.0 | 35.5 |
| 60+ | 50.0 | 44.1 | 47.4 | 20.9 | 31.5 | 25.5 | 29.1 | 24.5 | 27.1 |
| ស្ត្រី | | | | | | | | | |
| **សរុប** | **22.3** | **30.2** | **26.3** | **37.8** | **29.7** | **33.7** | **39.9** | **40.1** | **40.0** |
| 15-39 | 25.0 | 12.5 | 19.4 | 35.0 | 56.3 | 44.4 | 40.0 | 31.3 | 36.1 |
| 40-59 | 25.3 | 34.7 | 29.9 | 40.4 | 24.5 | 32.5 | 34.3 | 40.8 | 37.6 |
| 60+ | 17.4 | 28.2 | 23.1 | 34.8 | 30.8 | 32.7 | 47.8 | 41.0 | 44.2 |

មេគ្រួសារទាំងពីរភេទមានភាគរយសមាជិកគ្រួសារភេទប្រុស ដែលបានធ្វើការនៅក្នុងវិស័យកសិកម្មមាន៤១% វិស័យឧស្សាហកម្ម២៣% និងធ្វើការក្នុងវិស័យសេវាកម្មមាន៣៦% ខណៈដែលភាគរយសមាជិកគ្រួសារភេទស្រីធ្វើការក្នុងវិស័យកសិកម្មមាន៣៦% វិស័យឧស្សាហកម្មមាន២៨% និងធ្វើការក្នុងវិស័យសេវាកម្មមានចំនួន៣៦%។ ចំពោះសមាជិកទាំងពីរភេទសម្រាប់មេគ្រួសារទាំងពីរភេទភាគរយសមាជិកគ្រួសារភេទស្រីធ្វើការក្នុងវិស័យកសិកម្មមាន៤០% វិស័យឧស្សាហកម្មមាន២៥% និងធ្វើការក្នុងវិស័យសេវាកម្មមានចំនួន៣៥%។ បន្ថែមពីនេះទៀត ភាគរយសមាជិកគ្រួសារប្រុស ស្រីនិងសមាជិកទាំងពីរភេទដែលធ្វើការក្នុងវិស័យសេដ្ឋកិច្ច ហើយមានមេគ្រួសារជាបុរសនិងមេគ្រួសារជាស្ត្រីមានលម្អិតនៅក្នុងក្រាហ្វិក២៧និងក្រាហ្វិក២៨ ដូចខាងក្រោម។

ក្រាហ្វិក២៧. ភាគរយសមាជិកគ្រួសារដែលធ្វើការតាមវិស័យសេដ្ឋកិច្ច
សម្រាប់មេគ្រួសារទាំងពីរភេទ




ក្រាហ្វិក២៨. ភាគរយសមាជិកគ្រួសារដែលធ្វើការតាមវិស័យសេដ្ឋកិច្ចសម្រាប់មេគ្រួសារជាបុរស



ក្រាហ្វិក២៩. ភាគរយសមាជិកគ្រួសារដែលធ្វើការតាមវិស័យសេដ្ឋកិច្ចសម្រាប់មេគ្រួសារជាស្ត្រី




**<u>គ. បរិស្ថាន</u>**

ស្ថានភាពគ្រួសារប្រើប្រាស់បង្គន់អនាម័យនៅឆ្នាំ២០២៤ មានប្រហែលគ្រួសារ៨៩,៨% និងឆ្នាំ២០២៥ មាន៩០,២% ខណៈដែលសេវាប្រមូលសំរាមមានគ្រួសារ១៧,៥% នៅឆ្នាំ២០២៤ និង ១៨,២% នៅឆ្នាំ២០២៥ ប៉ុន្តែទីតាំងចាក់សំរាមនៅជុំវិញបរិវេណផ្ទះមានប្រហែល៨៦% សម្រាប់ឆ្នាំ ២០២៤ និងឆ្នាំ២០២៥ និងទីតាំងចាក់សំរាមនៅក្នុងភូមិមាន៦,៥% មានភាគរយប្រហាក់ប្រហែលគ្នាសម្រាប់ឆ្នាំទាំងពីរដូចខាងលើនេះដែរ។ ចំពោះផលប៉ះពាល់ដោយសារការចាក់សំរាមឆ្នាំ២០២៥ មានប្រហែលគ្រួសារ៨% ថយចុះបន្តិចពីឆ្នាំ២០២៤ ដែលមានចំនួនច្រើនជាង៨%បន្តិច។ ភាគរយគ្រួសារដែលផលប៉ះពាល់ដោយសារការបាញ់ថ្នាំពុលមាន១២,៥% មានភាគរយប្រហែលគ្នាទាំងនៅឆ្នាំ២០២៤ និងឆ្នាំ២០២៥។ ការប្រើប្រាស់ជីគីមីមានគ្រួសារជាង១០%ទាំងឆ្នាំ២០២៤ និង ២០២៥ ខណៈដែលផលប៉ះពាល់ដោយសារមូលហេតុផ្សេងៗ មានចំនួនជាង៥%នៅឆ្នាំ២០២៤ និងឆ្នាំ២០២៥ មានចំនួនប្រហែលគ្នា។

## តារាង ២០. ការប្រើប្រាស់បង្គន់ ការប្រមូលសំរាម និងផលប៉ះពាល់បរិស្ថាន

| អធិប្បាយ | គ្រួសារសរុប | ចំនួនគ្រួសារ | | ភាគរយ | |
|---|---|---|---|---|---|
| | | 2024 | 2025 | 2024 | 2025 |
| មានបង្គន់ | 600 | 539 | 541 | 89.8 | 90.2 |
| សេវាប្រមូលសំរាម | 600 | 105 | 109 | 17.5 | 18.2 |
| មានទីតាំងចាក់សំរាមក្នុងភូមិ | 600 | 39 | 40 | 6.5 | 6.7 |
| ទីតាំងចាក់សំរាមជុំវិញផ្ទះ | 600 | 518 | 521 | 86.3 | 86.8 |
| ប៉ះពាល់ដោយការចាក់សំរាម | 600 | 49 | 47 | 8.2 | 7.8 |
| ប៉ះពាល់បរិស្ថានដោយសាររោងចក្រ | 600 | 5 | 4 | 0.8 | 0.7 |
| ប៉ះពាល់ដោយការបង្ហូរទឹកកខ្វក់ចូលបឹងស្ទឹងទន្លេធម្មជាតិ | 600 | 6 | 12 | 1.0 | 2.0 |
| ការបាញ់ថ្នាំពុល | 600 | 75 | 75 | 12.5 | 12.5 |
| ការប្រើប្រាស់ជីគីមី | 600 | 65 | 63 | 10.8 | 10.5 |
| កាប់បំផ្លាញព្រៃឈើ | 600 | 8 | 8 | 1.3 | 1.3 |
| កាប់បំផ្លាញព្រៃលិចទឹក | 600 | 12 | 7 | 2.0 | 1.2 |

## ក្រាហ្វិក៣០. ភាគរយគ្រួសារដែលមានបង្គន់ប្រើប្រាស់ សេវាប្រមូលសំរាម ទីតាំងប្រមូលសំរាម និងផលប៉ះពាល់បរិស្ថាន



## ឃ. គ្រោះមហន្តរាយ

### ឃ១. ការទទួលព័ត៌មានទាក់ទងគ្រោះមហន្តរាយ

តាមចម្លើយមេគ្រួសារទាំង៦០០នាក់ ដែលបានសម្ភាសន៍ឆ្នាំ២០២៥ បានបង្ហាញថា ចំនួនមេគ្រួសារ៥៣១នាក់ ស្មើនឹង៨៩% បានឆ្លើយថាទទួលបាននូវព័ត៌មានគ្រោះមហន្តរាយ និង មេគ្រួសារចំនួន៦៩គ្រួសារស្មើនឹង១២% មិនបានទទួលព័ត៌មានគ្រោះមហន្តរាយ (ក្រាហ្វិក៣១)។

**ក្រាហ្វិក៣១. ចំនួន/ភាគរយគ្រួសារទទួលព័ត៌មានគ្រោះមហន្តរាយ**




ចំនួនមេគ្រួសារទាំងពីរភេទដែលបានទទួលព័ត៌មានគ្រោះមហន្តរាយមានចំនួន៥៣១នាក់ និងមិនបានទទួលព័ត៌មាន ៦៩នាក់ ឆ្នាំ២០២៥ ក្នុងនោះមេគ្រួសារជាបុរសបានទទួលព័ត៌មានចំនួន៤០៣នាក់ និងមិនបានទទួលព័ត៌មានចំនួន៤៣នាក់ និងមេគ្រួសារជាស្ត្រីបានទទួលព័ត៌មានគ្រោះមហន្តរាយមានចំនួន១២៨នាក់ និងមិនបានទទួលព័ត៌មានចំនួន២៦នាក់។ ភាគច្រើនមេគ្រួសារដែលស្ថិតនៅក្នុងក្រុមអាយុចាប់ពី៤០ដល់៥៩ឆ្នាំ ដែលបានទទួលព័ត៌មានគ្រោះមហន្តរាយច្រើនជាងមេគ្រួសារដែលស្ថិតនៅក្រុមអាយុផ្សេងទៀត។ នៅក្នុងក្រុមអាយុនេះ សម្រាប់មេគ្រួសារទាំងពីរភេទដែលទទួលបានព័ត៌មានគ្រោះមហន្តរាយមានចំនួន២៨០នាក់ ក្នុងចំណោមមេគ្រួសារដែលទទួលព័ត៌មាន៥៣១នាក់ និងចំពោះមេគ្រួសារជាបុរសមានចំនួន២១២ ក្នុងចំណោមបុរសដែលជាមេ

គ្រួសារដែលបានទទួលព័ត៌មានគ្រោះមហន្តរាយមានចំនួន៤០៣នាក់ ខណៈដែលមេគ្រួសារជាស្ត្រីមានចំនួន៦៨នាក់ក្នុងចំណោមមេគ្រួសារជាស្ត្រីសរុបចំនួន ១២៨នាក់។

**តារាង ២១. ចំនួនមេគ្រួសារដែលបានទទួលព័ត៌មានគ្រោះមហន្តរាយ បែងចែកតាមភេទមេគ្រួសារ**

| ភេទមេគ្រួសារ | សរុប | បាន | មិនបាន |
|---|---|---|---|
| **ទាំងពីរភេទ** | | | |
| **សរុប** | **600** | **531** | **69** |
| 15-39 | 117 | 102 | 15 |
| 40-59 | 313 | 280 | 33 |
| 60+ | 170 | 149 | 21 |
| **ប្រុស** | | | |
| **សរុប** | **446** | **403** | **43** |
| 15-39 | 97 | 87 | 10 |
| 40-59 | 234 | 212 | 22 |
| 60+ | 115 | 104 | 11 |
| **ស្រី** | | | |
| **សរុប** | **154** | **128** | **26** |
| 15-39 | 20 | 15 | 5 |
| 40-59 | 79 | 68 | 11 |
| 60+ | 55 | 45 | 10 |

ភាគរយមេគ្រួសារទាំងពីរភេទដែលទទួលបានព័ត៌មានសរុបមាន៨៩% ក្នុងនោះមេគ្រួសារដែលស្ថិតនៅក្នុងក្រុមអាយុ ៤០ដល់៥៩ឆ្នាំ មាន ៨៩% ខណៈដែលមេគ្រួសារដែលស្ថិតនៅក្នុងក្រុមអាយុ១៥ដល់៣៩ឆ្នាំ មានចំនួន៨៧% និងមេគ្រួសារដែលមានអាយុ៦០ឆ្នាំឡើងមានចំនួន ៨៨%។ ចំពោះភាគរយមេគ្រួសារជាបុរសដែលទទួលព័ត៌មានគ្រោះមហន្តរាយសរុបមាន៩០% និងភាគរយមេគ្រួសារស្ថិតតាមក្រុមអាយុមាន៩០% ប្រហាក់ប្រហែលគ្នា ខណៈដែលមេគ្រួសារជាស្ត្រីសរុបដែលទទួលព័ត៌មានគ្រោះមហន្តរាយមានចំនួន ៨៣% និងមេគ្រួសារស្ថិតតាមក្រុមអាយុដែលទទួលព័ត៌មានគ្រោះមហន្តរាយមានចំនួនជាង៨០% ដូចគ្នាដែរ លើកលែងតែមេគ្រួសារដែលស្ថិតក្នុងក្រុមអាយុ១៥ដល់៣៩ឆ្នាំ ដែលទទួលបានព័ត៌មានគ្រោះមហន្តរាយមានតិចជាង៨០% (តារាង២២ និងក្រាហ្វិក ៣៣)។

### តារាង ២២. ភាគរយនៃមេគ្រួសារតាមក្រុមអាយុដែលបានទទួលព័ត៌មានគ្រោះមហន្តរាយបែងចែកភេទនៃមេគ្រួសារ

| ភេទមេគ្រួសារ | សរុប | បាន | មិនបាន |
|---|---|---|---|
| ទាំងពីរភេទ | | | |
| សរុប | 100% | 89% | 12% |
| 15-39 | 100% | 87% | 13% |
| 40-59 | 100% | 89% | 11% |
| 60+ | 100% | 88% | 12% |
| ប្រុស | | | |
| សរុប | 100% | 90% | 10% |
| 15-39 | 100% | 90% | 10% |
| 40-59 | 100% | 91% | 9% |
| 60+ | 100% | 90% | 10% |
| ស្រី | | | |
| សរុប | 100% | 83% | 17% |
| 15-39 | 100% | 75% | 25% |
| 40-59 | 100% | 86% | 14% |
| 60+ | 100% | 82% | 18% |

### ក្រាហ្វិក ៣២. ភាគរយមេគ្រួសារទាក់ទងការទទួលព័ត៌មានគ្រោះមហន្តរាយ



ចំនួនមេគ្រួសារដែលទទួលព័ត៌មានគ្រោះមហន្តរាយសរុបមានចំនួន ៥៣១នាក់ គ្រប់ប្រភពព័ត៌មានគ្រោះមហន្តរាយដែលមេគ្រួសារទាំងនោះទទួលបាន ដោយសួរសំណួរដាច់ឡែកៗនៃប្រភពព័ត៌មានដែលទទួលបាន។ តាមលទ្ធផលបង្ហាញថា ចំនួនមេគ្រួសារដែលទទួលព័ត៌មានពីប្រភពផ្សេងមានរហូតដល់៤៦៥នាក់ (៨៨%) ក្នុងចំណោមមេគ្រួសារ៥៣៨ មានចំនួនច្រើនជាងគេ ខណៈដែលព័ត៌មានដែលទទួលបានតាមសារទូរសព្ទមានមេគ្រួសាតែ៤១នាក់ (៨%) ប៉ុណ្ណោះ ដែលមានចំនួនទាបជាងគេ។ ចំនួនមេគ្រួសារដែលទទួលបានព័ត៌មានតាមអាជ្ញាធរមាន១៦២នាក់(៣១%) តាមរយៈវិទ្យុមាន១២០នាក់(២៣%) តាមរយៈទូរសព្ទមាន១០២នាក់(១៩%) និងតាមរយៈសារតាមទូរស័ព្ទ៥៨នាក់ (១១%) តាមលំដាប់រៀង។ ទិន្នន័យខាងលើនេះ ត្រូវបានសួរមេគ្រួសារជាប្រភេទសំណួរដាច់ឡែកនៃប្រភពព័ត៌មានគ្រោះមហន្តរាយ។

**ក្រាហ្វិក ៣៣. ចំនួនមេគ្រួសារដែលបានទទួលព័ត៌មានគ្រោះមហន្តរាយតាមប្រភពនៃព័ត៌មាន**




## ឃ២. គ្រួសារដែលរងគ្រោះដោយសារគ្រោះមហន្តរាយ

ចំនួនមេគ្រួសារសរុប៦០០ នាក់ ដែលបានសម្ភាសន៍ មានចំនួនមេគ្រួសារទាំងពីរភេទចំនួន ១៧៦នាក់ ស្មើនឹង ២៩% ឆ្លើយថាបានទទួលគ្រោះមហន្តរាយដោយធម្មជាតិ និងមេគ្រួសារដែលមានចំនួន ៤២៤នាក់ ស្មើនឹង ៧១% មិនទទួលគ្រោះមហន្តរាយដោយធម្មជាតិទេ (ក្រាហ្វិក៣៥)។

### ក្រាហ្វិក ៣៥. ភាគរយគ្រួសារដែលបានទទួលរងគ្រោះដោយសារគ្រោះមហន្តរាយ




ចំនួនគ្រួសារដែលទទួលរងគ្រោះមហន្តរាយសរុបមានចំនួន១៧៦ គ្រួសារ ក្នុងចំណោម ៦០០ គ្រួសារ ក្នុងនោះមាន១៤១គ្រួសារ ស្មើនឹង៨០% ដែលរងគ្រោះមហន្តរាយមានមេគ្រួសារជាបុរស និង ៣៥គ្រួសារ ស្មើនឹង២០% ដែលទទួលរងគ្រោះមហន្តរាយមានមេគ្រួសារជាស្ត្រី (តារាង២៣ និង ក្រាហ្វិក ៣៦)។

### តារាង២៣. ចំនួនគ្រួសារដែលទទួលរងគ្រោះមហន្តរាយតាមភេទនៃមេគ្រួសារ

| ក្រុមអាយុ | ភេទ | | |
|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី |
| **សរុប** | **176** | **141** | **35** |
| 15-39 | 28 | 25 | 3 |
| 40-59 | 94 | 75 | 19 |
| 60+ | 54 | 41 | 13 |

ក្រាហ្វិក ៣៥. ភាគរយគ្រួសារដែលបានទទួលរងគ្រោះដោយគ្រោះមហន្តរាយតាមភេទមេគ្រួសារ




ចំនួនគ្រួសារដែលទទួលរងគ្រោះមហន្តរាយសរុបមានចំនួន១៧៦គ្រួសារ ក្នុងចំណោម ៦០០គ្រួសារ ដែលក្នុងនោះចំនួនគ្រួសារដែលទទួលរងគ្រោះមហន្តរាយតែមួយគត់មានចំនួន ១៦៧ គ្រួសារ និង ចំនួន៩គ្រួសារ ទទួលរងគ្រោះមហន្តរាយចំនួនពីរ។ ចំនួនគ្រួសារដែលទទួលរងគ្រោះ គ្រោះមហន្តរាយនៅឆ្នាំ២០២៥ មានគ្រោះរាំងស្ងួតមានចំនួន ១៦០គ្រួសារ ទទួលរងគ្រោះ ដោយសារព្យុះមាន២២ គ្រួសារ និង គ្រោះទឹកជំនន់មានចំនួនគ្រួសារ ក្នុងចំណោមគ្រួសារសរុប ដែលទទួលរងគ្រោះមហន្តរាយទាំងបីនេះ មានចំនួន៩គ្រួសារ ទទួលរងគ្រោះមហន្តរាយចំនួនពីរក្នុង ចំណោមគ្រោះមហន្តរាយទាំងបីនេះ (ក្រាហ្វិក៣៧ និងក្រាហ្វិក៣៨)។

ក្រាហ្វិក ៣៦. ចំនួនគ្រោះមហន្តរាយដែលគ្រួសារបានទទួលរងគ្រោះ




ក្រាហ្វិក ៣៧. ចំនួនគ្រួសារដែលទទួលរងគ្រោះតាមប្រភេទនៃគ្រោះមហន្តរាយ



ចំនួនទឹកប្រាក់សរុបដែលបានបាត់បង់ដោយសារគ្រោះមហន្តរាយសរុបមានចំនួន ៩៧.៦២២ ដុល្លារ ក្នុងនោះទឹកប្រាក់ដែលបាត់បង់ដោយសារព្យុះមានចំនួន១.៣៦៥ដុល្លារ ស្មើនឹង១,៤% ទឹកជំនន់ ២.៤០០ ដុល្លារ ស្មើនឹង ២,៥% និងគ្រោះរាំងស្ងួតមានចំនួន៩៣.៨៥៧ដុល្លារ ស្មើនឹង៩៦,១% នៃទឹកប្រាក់សរុបដែលបានបាត់បង់ដោយសារគ្រោះមហន្តរាយសរុប (តារាង២៤ និងក្រាហ្វិក៣៩)។

**តារាង២៤. ចំនួនទឹកប្រាក់ដែលបាត់បង់តាមប្រភេទនៃគ្រោះមហន្តរាយ**

| វិស័យ | ទឹកប្រាក់ដែលបាត់បង់ (គិតជាដុល្លារ) |
|---|---|
| ព្យុះ | 1,365 |
| ទឹកជំនន់ | 2,400 |
| រាំងស្ងួត | 93,857 |
| **សរុប** | **$97,622** |

**ក្រាហ្វិក ៣៨. ចំនួនទឹកប្រាក់ដែលបាត់បង់ដោយសារគ្រោះមហន្តរាយ**



## ឃ៣. ការព្យាករណ៍គ្រួសាររងផលប៉ះពាល់ដោយគ្រោះមហន្តរាយ
### តាម Logistic Regression Model

នៅក្នុងម៉ូដែល Logistic Regression គេច្រើនប្រើនៅក្នុងផ្នែកវិទ្យាសាស្រ្ត ឬ នៅក្នុងផ្នែកសុខាភិបាលដូចជាការពិនិត្យលើលទ្ធផលនៃអ្នកជំងឺបេះដូង ដែលអាចកើតឡើងបណ្តាលមកពីការជក់បារី ឬមូលហេតុផ្សេងៗជាដើម។ ក្រោយពេលគេបានប្រមូលទិន្នន័យអំពីអ្នកជក់បារីតាមអាយុ ភេទ និងកត់ត្រាពីអ្នកជំងឺទាំងនេះរួចប្រើម៉ូដែល Logistic Regression ដើម្បីឲ្យដឹងមូលហេតុកាន់តែច្បាស់សម្រាប់ធ្វើគោលនយោបាយ ឬការសម្រេចចិត្តផ្សេងៗ។ នៅក្នុងម៉ូដែលនេះ អាចឲ្យយើងធ្វើការធ្វើព្យាករណ៍អំពីភាគរយដែលអាចកើតឡើងដោយប្រៀបធៀបនឹងស្ថានភាពជាក់ស្តែង។

នៅក្នុងរបាយការណ៍នេះ គឺចង់បង្ហាញអំពីការព្យាករណ៍នៃគ្រួសារដែលអាចរងគ្រោះមហន្តរាយដោយគ្រោះមហន្តរាយធម្មជាតិដែលរួមមានដូចជា ខ្យល់កន្ត្រាក់/ព្យុះ គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត មានផលប៉ះពាល់ដូចម្តេចដែរ ដែលផ្អែកទិន្នន័យដែលប្រមូលបានពីមេគ្រួសារចំនួន ៦០០នាក់ ស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាមឆ្នាំ២០២៥កន្លងមក តាម Logistic Regression Model ដោយជ្រើសរើសយកចំនួនគ្រួសារសរុបដែលទទួលរងគ្រោះមហន្តរាយមានចំនួន ១៧៦ គ្រួសារ តែប៉ុណ្ណោះ សម្រាប់ម៉ូដែលនេះ។ នៅក្នុងការកំណត់ផលប៉ះពាល់គឺយើងកំណត់ថាគ្រួសារដែលខូចខាតសម្ភារៈ ឬទ្រព្យសម្បត្តិដែលមានទឹកប្រាក់ចាប់ពី៥៥៥ ដុល្លារ ឡើងទៅត្រូវបានកំណត់ថារងផលប៉ះពាល់ធ្ងន់ធ្ងរសំគាល់លេខកូដ១ តែផ្ទុយទៅវិញបើទឹកប្រាក់តិចជាង ៥៥៥ ដុល្លារត្រូវបានកំណត់ថាមិនរងផលប៉ះពាល់ធ្ងន់ធ្ងរទេសំគាល់លេខកូដ០។ ចំនួនទឹកប្រាក់ ៥៥៥ ដុល្លារនេះ ជាទឹកប្រាក់ដែលគ្រួសារបានខូចខាតសម្ភារៈ ឬ ទ្រព្យសម្បត្តិដែលគិតជាមធ្យមក្នុងចំណោមគ្រួសារទាំង១៧៦គ្រួសារ ដែលទទួលរងគ្រោះមហន្តរាយ។

រូបមន្តសម្រាប់ព្យាករណ៍ តាម Logistic Regression Model គឺ:

$$P\ (y = 1|x_1, \ldots\ldots, x_n) = \frac{1}{1+e^{-(b_1 \cdot x_1 + \cdots + b_k \cdot x_k + a)}}$$

តាមរយៈរូបមន្តខាងលើ យើងបានកំណត់អថេរឯករាជ្យ និងអថេរមិនឯករាជ្យដូចខាងក្រោម៖

(១) គ្រួសារដែលរងផលប៉ះពាល់ជាអថេរមិនឯករាជ្យ (Dependent Variable)

(២) ភេទ, អាយុ, ប្រភពទទួលព័ត៌មានគ្រោះមហន្តរាយ, ព្យុះ, ទឹកជំនន់ និង គ្រោះរាំងស្ងួត ជាអថេរមិនឯករាជ្យ (Independent Variable)។

### តារាង ២៥. ទិន្នន័យអថេរសម្រាប់ Run Logistics Regression

| ល.រ | ភេទ | អាយុ | ប្រភពទទួលព័ត៌មានគ្រោះមហន្តរាយ | ព្យុះ | ទឹកជំនន់ | គ្រោះរាំងស្ងួត | ផលប៉ះពាល់ |
|---|---|---|---|---|---|---|---|
| 1 | 1 | 32 | 0 | 1 | 0 | 0 | 1 |
| 2 | 1 | 55 | 0 | 0 | 0 | 1 | 1 |
| 3 | 1 | 53 | 1 | 0 | 0 | 1 | 0 |
| 4 | 1 | 35 | 1 | 0 | 0 | 1 | 0 |
| 5 | 1 | 65 | 1 | 0 | 1 | 1 | 1 |
| ... | ... | ... | ... | ... | ... | ... | ... |
| 172 | 1 | 47 | 1 | 1 | 0 | 0 | 0 |
| 173 | 1 | 37 | 1 | 1 | 0 | 0 | 0 |
| 174 | 1 | 50 | 1 | 1 | 0 | 0 | 0 |
| 175 | 1 | 45 | 1 | 1 | 0 | 0 | 0 |
| 176 | 0 | 51 | 1 | 1 | 0 | 0 | 0 |

*បញ្ជាក់៖ (ភេទប្រុស=1 ស្រី=0), (បានទទួលព័ត៌មានគ្រោះមហន្តរាយ=1 ពុំបានទទួលបានព័ត៌មាន=0), (ទទួលរងគ្រោះដោយសារព្យុះ=1, មិនទទួលរងដោយសារព្យុះ=0), (ទទួលរងគ្រោះដោយសារទឹកជំនន់=1, មិនទទួលរងដោយសារទឹកជំនន់=0,), (ទទួលរងគ្រោះរាំងស្ងួត=1, មិនទទួលរងគ្រោះរាំងស្ងួត=0)។*

*សំគាល់៖ ទិន្នន័យលម្អិតមាននៅក្នុងឧបសម្ព័ន្ធ។*

ផ្អែកតាមការ Run Logistics Regression Model ដោយប្រើប្រាស់ទិន្នន័យខាងលើ យើងទទួលបានលទ្ធផលដូចខាងក្រោម៖

### តារាង ២៦. តារាងលទ្ធផលនៃការ Run Logistic Regression Model

| Items | Coefficients | Standard Error | P-value | Odd Ratio | Lower 95% | Upper 95% | Lower 95% | Upper 95% |
|---|---|---|---|---|---|---|---|---|
| Intercept | -2.55965 | 1.464983 | 0.080599 | 0.077332 | 0.004379 | 1.365694 | 0.00437887 | 1.365694335 |
| Sex | 0.48166 | 0.456402 | 0.291269 | 1.61876 | 0.661747 | 3.959793 | 0.66174734 | 3.959793326 |
| Age | 0.006307 | 0.014907 | 0.672242 | 1.006327 | 0.97735 | 1.036162 | 0.9773503 | 1.036161975 |
| Dis_Info | 0.060582 | 0.633427 | 0.923805 | 1.062455 | 0.306999 | 3.676919 | 0.30699886 | 3.676919421 |
| Storm | -0.07547 | 0.80168 | 0.925001 | 0.92731 | 0.192679 | 4.462889 | 0.19267889 | 4.462889485 |
| Flooding | 2.090496 | 1.511581 | 0.166669 | 8.08893 | 0.418053 | 156.5133 | 0.41805264 | 156.5132747 |
| Drying | 1.006422 | 1.072383 | 0.347992 | 2.735795 | 0.334402 | 22.38193 | 0.33440244 | 22.38193286 |

ឧទាហរណ៍ យើងចង់ធ្វើការព្យាករណ៍លើគ្រួសារមួយ ដែលមានមេគ្រួសារមានអាយុ ៤៥ឆ្នាំ ភេទស្រី បានទទួលព័ត៌មានអំពីគ្រោះមហន្តរាយដែលកើតឡើងក្នុងតំបន់របស់គាត់ ហើយបានទទួលរងគ្រោះដោយសារព្យុះ ទឹកជំនន់ និងគ្រោះរាំងស្ងួត។ ការខូចខាតបើគិតជាទឹកប្រាក់ ស្មើនឹង ២០០០ ដុល្លារ។ តើគ្រួសារគាត់អាចនឹងរងផលប៉ះពាល់ប៉ុន្មានភាគរយ?។

$$\mathbf{P}\ (\boldsymbol{y} = \mathbf{1}|\boldsymbol{x}_{\mathbf{1}}, \ldots\ldots, \boldsymbol{x}_{\boldsymbol{n}}) = \frac{\mathbf{1}}{\mathbf{1}+\boldsymbol{e}^{-(\boldsymbol{b}_{\mathbf{1}}.\boldsymbol{x}_{\mathbf{1}}+\boldsymbol{b}_{\mathbf{2}}.\boldsymbol{x}_{\mathbf{2}}+\boldsymbol{b}_{\mathbf{3}}.\boldsymbol{x}_{\mathbf{3}}+\boldsymbol{b}_{\mathbf{4}}.\boldsymbol{x}_{\mathbf{4}}+\boldsymbol{b}_{\mathbf{5}}.\boldsymbol{x}_{\mathbf{5}}+\boldsymbol{b}_{\mathbf{6}}.\boldsymbol{x}_{\mathbf{6}}+\boldsymbol{a})}}$$

P: Prediction Impact

$X_1$= Sex, $X_2$= Age, $X_3$= Disaster Information, $X_4$ =Storm, $X_5$ =Flood, $X_6$ =Drought

a : constant

$$\text{P (impact)} = \frac{1}{1+e^{-(-2.55965+0*0.48166+45*0.006307+1*\ 0.060582+1*(-0.07547)+1*2.090496+1*1.006422)}} = 0.69129 \approx 69\%$$

តាមទិន្នន័យនេះបង្ហាញថា ៦៩% នៃគ្រួសារ ដែលមានមេគ្រួសារអាយុ៤៥ឆ្នាំ ភេទប្រុស ហើយបានទទួលព័ត៌មានគ្រោះមហន្តរាយ និងរងផលប៉ះពាល់ដោយខ្យល់ព្យុះ ទឹកជំនន់ និងគ្រោះរាំងស្ងួត។ ដូច្នេះយើងអាចវាយតម្លៃបានថា គ្រួសារខាងលើនេះរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយខាងលើនេះ ខ្លាំងដែរ។

តាមលទ្ធផលនៃការព្យាករណ៍តាមរយៈការ Run Logistic Regression Model បង្ហាញថា ភាគរយនៃផលប៉ះពាល់ដោយសារគ្រោះមហន្តរាយទៅលើគ្រួសារនីមួយៗ មានកម្រិតទាបបំផុត (អប្បបរមា) មាន៨% អតិបរមាមាន៨២% និងគិតជាមធ្យមមាន៣១% នៃគ្រួសារសរុបទាំង១៧៦ គ្រួសារ ដែលបានសម្ភាសន៍ (ក្រាហ្វិក ៤០)។

**តារាង ២៧. តារាងលទ្ធផលនៃការព្យាករណ៍ផលប៉ះពាល់ដោយគ្រោះមហន្តរាយ ដោយប្រើប្រាស់** Logistic Regression Model

| ល.រ | ភេទ | អាយុ | ប្រភពទទួលព័ត៌មានគ្រោះមហន្តរាយ | ព្យុះ | ទឹកជំនន់ | គ្រោះរាំងស្ងួត | ផលប៉ះពាល់ | ព្យាករណ៍ (%) |
|---|---|---|---|---|---|---|---|---|
| 1 | 1 | 32 | 0 | 1 | 0 | 0 | 1 | 12% |
| 2 | 1 | 55 | 0 | 0 | 0 | 1 | 1 | 33% |
| 3 | 1 | 53 | 1 | 0 | 0 | 1 | 0 | 34% |
| 4 | 1 | 35 | 1 | 0 | 0 | 1 | 0 | 31% |
| 5 | 1 | 65 | 1 | 0 | 1 | 1 | 1 | 82% |
| ... | ... | ... | ... | ... | ... | ... | ... | ... |
| 172 | 1 | 47 | 1 | 1 | 0 | 0 | 0 | 14% |

| ល.រ | ភេទ | អាយុ | ប្រភពទទួលព័ត៌មានគ្រោះមហន្តរាយ | ព្យុះ | ទឹកជំនន់ | គ្រោះរាំងស្ងួត | ផលប៉ះពាល់ | ព្យាករណ៍ (%) |
|---|---|---|---|---|---|---|---|---|
| 173 | 1 | 37 | 1 | 1 | 0 | 0 | 0 | 13% |
| 174 | 1 | 50 | 1 | 1 | 0 | 0 | 0 | 14% |
| 175 | 1 | 45 | 1 | 1 | 0 | 0 | 0 | 14% |
| 176 | 0 | 51 | 1 | 1 | 0 | 0 | 0 | 10% |

**ក្រាហ្វិក ៣៩. ភាគរយផលប៉ះពាល់លើគ្រួសារនីមួយៗដោយសារគ្រោះមហន្តរាយ តាមការព្យាករណ៍ Logistic Regression Model**




តារាង២៨ បង្ហាញអំពីការកម្រិតនៃភាពត្រឹមត្រូវរវាងការព្យាករណ៍តាម Logistic Regression Model និងទិន្នន័យជាក់ស្តែង ដើម្បីកំណត់យកកម្រិត(Threshold) ដែលមានភាពត្រឹមត្រូវខ្ពស់ជាងគេ ភាគច្រើនគេយក ០,៥ ស្មើនឹង៥០%។ ផ្អែកតាមទិន្នន័យជាក់ស្តែង និងការព្យាករណ៍តាមម៉ូដែល កម្រិត (Threshold) ដែលមានភាពត្រឹមត្រូវខ្ពស់ជាងគេ គឺកម្រិត (Threshold) ស្មើនឹង០,៣ ដែលមានភាពត្រឹមត្រូវ ៤៧% រវាងទិន្នន័យដែលយើងធ្វើការព្យាករណ៍តាមម៉ូដែល និងទិន្នន័យដែលប្រមូលបានជាក់ស្តែង។ ទិន្នន័យលម្អិតមានបង្ហាញក្នុងតារាង ២៨ខាងក្រោម។

តារាង ២៨. តារាងពិនិត្យភាពត្រឹមត្រូវកំណត់យកកម្រិត(Threshold) ស្មើនឹង0.3

| | | ព្យាករណ៍ (Prediction) | | គ្រួសារសរុប (Total) | ភាពត្រឹមត្រូវ (Correct) |
|---|---|---|---|---|---|
| | | 0 | 1 | | |
| ជាក់ស្តែង (Actual) | 0 | 38 | 84 | 122 | 31% |
| | 1 | 9 | 45 | 54 | 83% |
| | | | | 176 | 47% |

តារាង ២៩. តារាងភាគរយនៃភាពត្រឹមត្រូវតាមកម្រិត (Threshold)

| កម្រិត (Threshold) | ភាពត្រឹមត្រូវសរុប (Correct) | ព្យាករណ៍ពិត និង ជាក់ស្តែងពិត (True positive) | ព្យាករណ៍មិនពិត និង ជាក់ស្តែងមិនពិត (True Negative) | ព្យាករណ៍ពិត និង ជាក់ស្តែងមិនពិត (False Positive) | ព្យាករណ៍មិនពិត និង ជាក់ស្តែងពិត (Fales Negative) |
|---|---|---|---|---|---|
| 0.1 | 31% | 53 | 2 | 120 | 1 |
| 0.2 | 36% | 52 | 12 | 110 | 2 |
| 0.3 | 47% | 45 | 38 | 84 | 9 |
| 0.4 | 70% | 2 | 121 | 1 | 52 |
| 0.5 | 70% | 2 | 121 | 1 | 52 |
| 0.6 | 70% | 2 | 122 | 0 | 52 |
| 0.7 | 70% | 1 | 122 | 0 | 53 |
| 0.8 | 70% | 1 | 122 | 0 | 53 |
| 0.9 | 69% | 0 | 122 | 0 | 54 |
| 1.0 | 69% | 0 | 122 | 0 | 54 |

ក្រាហ្វិក ៤១ បង្ហាញអំពីអត្រាគ្រួសារ ដែលអាចរងផលប៉ះពាល់ពិតវិជ្ជមាន (True Positive Rate) និងអត្រាគ្រួសារដែលអាចរងផលប៉ះពាល់មិនពិតវិជ្ជមាន (False Positive Rate)។ True Positive Rate (TPR) គឺជាអត្រាដែលកើតឡើងពិតប្រាកដជាក់ស្តែងផ្អែកលើទិន្នន័យដែលប្រមូលបាន ត្រូវគ្នាជាមួយនឹង ការព្យាករណ៍តាម Logistic Regression Model ដែលនៅក្នុងទិន្នន័យបង្ហាញអំពីចំនួនគ្រួសារដែលរងគ្រោះដោយសារគ្រោះមហន្តរាយ។ False Positive Rate(FPR) គឺជាអត្រាដែលគ្រួសារមិនទទួលរងគ្រោះដោយសារគ្រោះមហន្តរាយតាមទិន្នន័យ ដែលប្រមូលបានជាក់ស្តែងត្រូវគ្នាជាមួយនឹង ការព្យាករណ៍តាម Logistic Regression Model ដែលនៅក្នុងទិន្នន័យបង្ហាញអំពីចំនួនគ្រួសារដែលមិនទទួលរងគ្រោះដោយសារគ្រោះមហន្តរាយ។

រូបមន្តសម្រាប់គណនា True Positives Rate (TPR) និង False Positives Rate (FPR) ដូចខាងក្រោម៖

$$\text{True Positives Rate (TPR)} = \frac{True\ Positives}{True\ Positives + False\ Negative}$$

$$\text{False Positives Rate (FPR)} = \frac{False\ Positives}{False\ Positives + True\ Negative}$$

ផ្អែកលើកម្រិត (Threshold) ស្មើនឹង០,៣ ដែលសមស្របរវាងទិន្នន័យជាក់ស្តែង និង ការព្យាករណ៍តាមម៉ូដែលខាងលើ ដែលមានភាពត្រឹមត្រូវសរុប៤៧%។ នៅក្នុងកម្រិត (Threshold) ស្មើនឹង០,៣ បានបង្ហាញថាមានចំនួន ៥៤គ្រួសារ ស្មើនឹង៨៣% គឺគ្រួសារដែលទទួលរងផលប៉ះពាល់ និង៣៨គ្រួសារ ស្មើនឹង៣១% គ្រួសារដែលមិនទទួលរងផលប៉ះពាល់។ កម្រិត (Threshold) ខ្លះមានភាពត្រឹមត្រូវខ្ពស់ តែរបាយទិន្នន័យនៅក្នុងការ True Positive, True Negative, False Positive, និង False Negative មានទិន្នន័យតិចតួច មិនអាចសមស្របនឹងទិន្នន័យដែលយើងបានព្យាករណ៍តាមម៉ូដែល ដូចបង្ហាញជូនក្នុងតារាង ២៩ ខាងលើ។

**តារាង ៣០. តារាងលទ្ធផល True Positive Rate (TPR)**
**និង False Positive Rate តាមកម្រិត (Threshold)**

| Threshold | True Positive Rate (TPR) | False Positive Rate (FPR) |
|---|---|---|
| 0 | 1 | 1 |
| 0.1 | 0.98148148 | 0.983606557 |
| 0.2 | 0.96296296 | 0.901639344 |
| 0.3 | 0.83333333 | 0.688524590 |
| 0.4 | 0.03703704 | 0.008196721 |
| 0.5 | 0.03703704 | 0.008196721 |
| 0.6 | 0.03703704 | 0 |
| 0.7 | 0.01851852 | 0 |
| 0.8 | 0.01851852 | 0 |
| 0.9 | 0 | 0 |

ក្រាហ្វិក ៤១ បង្ហាញអំពីស្ថានភាព True Positives Rate (TPR) និង False Positives Rate (FPR) តាមកម្រិត (Threshold)។ ចំណុចពណ៌ក្រហមជាចំណុចដែលយើងកំណត់កម្រិត (Threshold) ស្មើនឹង០,៣ មាន True Positives Rate (TPR) ស្មើនឹង ០,៨៣ និង False Positives Rate (FPR) ស្មើនឹង ០,៦៩។ នៅក្នុងចំណុចពណ៌ក្រហមនេះ មានន័យថា ៨៣%នៃគ្រួសារនីមួយៗ គឺត្រឹមត្រូវដែលត្រូវបានកំណត់ថាជាគ្រួសារទទួលរងផលប៉ះពាល់រវាងការព្យាករណ៍តាមម៉ូដែល និងទិន្នន័យជាក់ស្តែង និង ១៧% នៃគ្រួសារនីមួយៗដែលព្យាករណ៍មិនរងផលប៉ះពាល់តែជាក់ស្តែងរងផលប៉ះពាល់។

ក្រាហ្វិក ៤០. ROC Curve




## ង. ការប្រែប្រួលអាកាសធាតុ

### ង១. ទឹកភ្លៀង

តាមរយៈការសម្ភាសន៍មេគ្រួសារទាំង៦០០នាក់ នៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ បានឲ្យដឹងថា មេគ្រួសារដែលឆ្លើយថាស្ថានភាពទឹកភ្លៀងទៀតទាត់មានចំនួន៤១នាក់ (៧%) មិនទៀងទាត់ មានចំនួន ៥០៦នាក់ (៨៤%) និងមិនប្រាកដមានចំនួន៥៣នាក់ (៩%)។

ក្រាហ្វិក ៤១. ស្ថានភាពទឹកភ្លៀងតាមការសម្ភាសន៍មេគ្រួសារ



### ង២. អាកាសធាតុ

### ង២.១ ស្ថានភាពអាកាសធាតុតាមរយៈការសម្ភាសន៍មេគ្រួសារ

តាមរយៈការសម្ភាសន៍មេគ្រួសារទាំង៦០០នាក់ នៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ បានឲ្យដឹងថា មេគ្រួសារដែលឆ្លើយថាស្ថានភាពអាកាសធាតុក្ដៅខ្លាំងមានចំនួន៥០៩នាក់ (៨៥%) ក្ដៅល្មមមានចំនួន៦៨នាក់ (១១%) និងអាកាសធាតុត្រជាក់ខ្លាំងមានចំនួន២៣នាក់ (៤%)។ ទិន្នន័យលម្អិតមាននៅក្នុងក្រាហ្វិក ៤៣។

**ក្រាហ្វិក ៤២. ស្ថានភាពអាកាសធាតុតាមការសម្ភាសន៍មេគ្រួសារ**




### ង២.២ ស្ថានភាពអាកាសធាតុឆ្នាំ២០២២ និងឆ្នាំ២០២៥ តាមរយៈការសម្ភាសន៍មេគ្រួសារ

ស្ថានភាពអាកាសធាតុពីឆ្នាំ២០២២ ដល់ ឆ្នាំ២០២៥ តាមចម្លើយរបស់មេគ្រួសារដែលបានសម្ភាសន៍៦០០ គ្រួសារដូចគ្នា ប៉ុន្តែទីតាំងខេត្តខុសៗគ្នា។ នៅឆ្នាំ២០២២ មាន៤៨%នៃមេគ្រួសារដែលបានឆ្លើយថាអាកាសធាតុក្ដៅខ្លាំង ហើយបានកើនឡើងរហូតដល់៨៥%នៅឆ្នាំ២០២៥ ខណៈដែលនៅឆ្នាំ២០២៣ មាន៦០% និងឆ្នាំ២០២៤ មាន៧៥% ខ្ពស់ជាងឆ្នាំ២០២២ ផងដែរ។ តាមទិន្នន័យនេះ បានបង្ហាញថា អាកាសធាតុមានការឡើងកម្ដៅខ្លាំង បើយោងតាមចម្លើយមេគ្រួសារដែលបានកត់សំគាល់ពីមួយឆ្នាំទៅមួយឆ្នាំ បើទោះបីពួកគាត់ពុំមានឧបករណ៍សម្រាប់វាស់ស្ទង់ក៏ដោយ (ក្រាហ្វិក ៤៤)។

ក្រាហ្វិក ៤៣. ស្ថានភាពអាកាសធាតុតាមការសម្ភាសន៍មេគ្រួសារឆ្នាំ២០២២ ដល់ ២០២៥




**ង២.៣ គណនា Chi-Square ($X^2$ )Test ទាក់ទងអាកាសធាតុ**

ស្ថានភាពអាកាសធាតុដែលទទួលបានចម្លើយពីមេគ្រួសារទាំង៦០០នាក់ តាមបណ្ដាឆ្នាំនីមួយៗ ត្រូវបានប្រើប្រាស់ Chi-Square ($X^2$)Test សម្រាប់ប្រៀបធៀបតាមបណ្ដាឆ្នាំ ដើម្បីឲ្យដឹងច្បាស់ថា ទិន្នន័យតាមបណ្ដាឆ្នាំទាក់ទងនឹងអាកាសធាតុមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬ ក៏ខុសគ្នាយ៉ាងណា? ផ្អែកតាមការសម្ភាសន៍។ ក្រាហ្វិក៤៤ ខាងលើ បានបង្ហាញអំពីភាគរយតាមបណ្ដាឆ្នាំទាក់ទងអាកាសធាតុក្ដៅរួចហើយ។

រូបមន្តសម្រាប់គណនា Chi-Square ($X^2$) មានដូចខាងក្រោម៖

$$X^2 = \sum_{k=1}^{n} \frac{(O_k - E_k)^2}{E_k}$$

ដែល $X^2$: Chi Square Test

$O$ : ចំនួនគ្រួសារដែលបានឆ្លើយ(Observed frequency)

$E$ : ចំនួនគ្រួសារដែលរំពឹងទុកបានឆ្លើយ(Expected frequency)

$k$ : 1,2,3,4…n

ចំពោះរូបមន្ត Degree of Freedom មានដូចខាងក្រោម៖

**Degree of Freedom = (p-1)*(q-1)**

ដែល $p$ : ចំនួនជួរ (Row)

$q$ : ចំនួនកូឡោន (column)

តារាង ២៨ បង្ហាញអំពីទិន្នន័យ ដែលមេគ្រួសារបានផ្តល់ចម្លើយពីឆ្នាំ២០២២ ដល់២០២៥ តាមភូមិគោលដៅដែលបានជ្រើសរើសម្ភាសន៍។ នៅឆ្នាំ២០២២ ភូមិគោលដៅសម្ភាសន៍ស្ថិតនៅក្នុងខេត្តព្រះសីហនុ និងខេត្តកោះកុង និងនៅក្នុងឆ្នាំ២០២៣ ភូមិគោលដៅសម្ភាសន៍ស្ថិតនៅក្នុងខេត្តកំពត និងខេត្តកែប ខណៈដែលនៅឆ្នាំ២០២៤ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ត្រូវបានកំណត់គោលដៅសម្ភាសន៍តាមភូមិដែលបានជ្រើសរើសមួយចំនួន និងនៅឆ្នាំ២០២៥ បានកំណត់យកខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ត្រូវបានអនុវត្តវិធីសាស្រ្តដូចគ្នានេះដែរ។ តារាង ២៨ បង្ហាញអំពីទិន្នន័យដែលមេគ្រួសារបានផ្តល់ចម្លើយដល់មន្ត្រីសម្ភាសន៍ដែលហៅថា Observed Frequency និង តារាង៣០ បង្ហាញអំពីចំនួនគ្រួសារដែលរំពឹងទុកថាបានឆ្លើយ (Expected frequency)។

តារាង៣១ បង្ហាញអំពី ភាគរយទាក់ទងលក្ខណៈអាកាសធាតុ តាមបណ្តាឆ្នាំនីមួយៗ ដោយផ្អែកទៅលើការសម្ភាសន៍មេគ្រួសារទាំង៦០០នាក់តាមបណ្តាឆ្នាំនីមួយៗ។

**តារាង ៣១. ចំនួនគ្រួសារដែលបានសម្ភាសន៍ទាក់ទងលក្ខណៈអាកាសធាតុ**

| លក្ខណៈអាកាសធាតុ | ចំនួនគ្រួសារដែលបានឆ្លើយ (Observed Frequency) | | | | |
|---|---|---|---|---|---|
| | 2022 | 2023 | 2024 | 2025 | សរុប |
| ក្តៅខ្លាំង | 288 | 358 | 448 | 509 | 1,603 |
| ក្តៅល្មម | 290 | 200 | 110 | 68 | 668 |
| ត្រជាក់ល្មម | 7 | 16 | 36 | 0 | 59 |
| ត្រជាក់ខ្លាំង | 15 | 26 | 6 | 23 | 70 |
| **សរុប** | **600** | **600** | **600** | **600** | **2,400** |

**តារាង ៣២. ភាគរយគ្រួសារដែលបានសម្ភាសន៍ទាក់ទងលក្ខណៈអាកាសធាតុ**

| លក្ខណៈអាកាសធាតុ | %គ្រួសារដែលបានឆ្លើយ | | | | |
|---|---|---|---|---|---|
| | 2022 | 2023 | 2024 | 2025 | សរុប |
| ក្ដៅខ្លាំង | 48% | 60% | 75% | 85% | 67% |
| ក្ដៅល្មម | 48% | 33% | 18% | 11% | 28% |
| ត្រជាក់ល្មម | 1% | 3% | 6% | 0% | 2% |
| ត្រជាក់ខ្លាំង | 3% | 4% | 1% | 4% | 3% |
| **សរុប** | **100%** | **100%** | **100%** | **100%** | **100%** |

នៅក្នុងការគណនា ចំនួនគ្រួសារដែលរំពឹងទុកថាអាចនឹងបានឆ្លើយ (Expected frequency) ត្រូវបានកំណត់រូបមន្តដូចខាងក្រោម៖

$$f(i,j) = \frac{\text{RowSum}(i) \cdot \text{ColumnSum}(j)}{N}$$

ដែល RowSum (i) : ផលបូកសរុបតាមជួរ (i)

ColumnSum (j) : ផលបូកសរុបតាមកូឡោន (j)

N : ចំនួនសរុប

ផ្អែកតាមរូបមន្តខាងលើ យើងបានលទ្ធផលដូចតារាងខាងក្រោម៖

**តារាង ៣៣. ចំនួនគ្រួសារដែលរំពឹងទុកដែលអាចនឹងបានឆ្លើយទាក់ទងលក្ខណៈអាកាសធាតុ**

| លក្ខណៈអាកាសធាតុ | ចំនួនគ្រួសារដែលរំពឹងទុកថាបានឆ្លើយ (Expected frequency) | | | | |
|---|---|---|---|---|---|
| | 2022 | 2023 | 2024 | 2025 | សរុប |
| ក្ដៅខ្លាំង | 401 | 401 | 401 | 401 | 1,603 |
| ក្ដៅល្មម | 167 | 167 | 167 | 167 | 668 |
| ត្រជាក់ល្មម | 15 | 15 | 15 | 15 | 59 |
| ត្រជាក់ខ្លាំង | 18 | 18 | 18 | 18 | 70 |
| **សរុប** | **600** | **600** | **600** | **600** | **2,400** |

តាមរូបមន្តនៃការគណនា Chi sqaure ($X^2$) និង Degree of Freedom ត្រូវបានអនុវត្តដូចខាងក្រោម៖

ក. គណនា Chi sqaure ($X^2$)

$$X^2 = \frac{(288-401)^2}{401} + \frac{(358-401)^2}{401} + \frac{(448-401)^2}{401} + \frac{(509-401)^2}{401} + \frac{(290-167^2}{167} + \frac{(200-167)^2}{167} + \frac{(110-167)^2}{167} + \frac{(68-167)^2}{167} + \frac{(7-15)^2}{15} + \frac{(16-15)^2}{15} + \frac{(36-15)^2}{15} + \frac{(0-15)^2}{15} + \frac{(15-18)^2}{18} + \frac{(26-18)^2}{18} + \frac{(6-18)^2}{18} + \frac{(23-18)^2}{18} = 309.66$$

$X^2$= 309.66

ខ. គណនា Degree of Freedom (df)

df = (4-1)*(4-1) =3*3 =9

**ដូច្នេះ** Chi Square ($X^2$) =309.66 **និង** df = 9 ។

ម្យ៉ាងវិញទៀត យើងអាចគណនានៅក្នុង Microsoft Excel ដែលបានបង្ហាញលទ្ធផលដូចមាននៅក្នុងតារាង៣៤ ខាងក្រោម។

**តារាង ៣៤. លទ្ធផល Chi Square ($X^2$) Test ទាក់ទងលក្ខណៈអាកាសធាតុ**

| លក្ខណៈអាកាសធាតុ | លទ្ធផល Chi Square ($X^2$) | | | | |
|---|---|---|---|---|---|
| | 2022 | 2023 | 2024 | 2025 | សរុប Chi Square ($X^2$) |
| ក្តៅខ្លាំង | 31.72 | 4.56 | 5.57 | 29.24 | 71.09 |
| ក្តៅល្មម | 90.59 | 6.52 | 19.46 | 58.69 | 175.26 |
| ត្រជាក់ល្មម | 4.07 | 0.11 | 30.61 | 14.75 | 49.54 |
| ត្រជាក់ខ្លាំង | 0.36 | 4.13 | 7.56 | 1.73 | 13.77 |
| **សរុប** | **126.74** | **15.32** | **63.20** | **104.41** | **309.66** |

តារាង ៣៥ បង្ហាញអំពី Chi-square ($X^2$) distribution ទៅតាមចំនួននៃ Degree of Freedom (df) ចាប់ពី១ ដល់ ១០០ និង Significance level Alpha ចាប់ពី ០,៩៩៥ ដល់ ០,០០១ សម្រាប់ធ្វើការប្រៀបធៀបជាមួយនឹង Chi Square ($X^2$) ដែលបានគណនាខាងលើរួចហើយ។ នៅក្នុងតារាង៣២ ខាងក្រោមបានបង្ហាញថាសម្រាប់ Significance level Alpha ស្មើនឹង ០.០៥ និង Degree of Freedom (df) ស្មើនឹង៩ មាន Chi Square ($X^2$) ស្មើនឹង ១៦,៩១៩។ តាមលទ្ធផល Chi Square ($X^2$) ដែល

បានគណនាស្មើនឹង៣០៩,៦៦ ធំជាង Chi Square ($X^2$) នៅក្នុងតារាងដែលស្មើនឹង១៦,៩១៩។ ដូច្នេះ យើងត្រូវ Reject $H_0$ មានន័យថាទិន្នន័យណាដែលមានចំនួនច្រើន គឺច្រើនដាច់តែម្តង នៅក្នុងនោះទិន្នន័យដែលបានបង្ហាញថាអាកាសធាតុក្តៅខ្លាំងនៅឆ្នាំ២០២៥ មានចំនួនមេគ្រួសារ៥០៩នាក់ (៨៥%) នៃមេគ្រួសារសរុបទាំង៦០០នាក់ ជាចំនួនដែលច្រើនជាងគេ និងអាចសន្និដ្ឋានថាអាកាសធាតុនៅក្នុងឆ្នាំ២០២៥ មានកម្តៅខ្លាំងជាងឆ្នាំផ្សេងៗទៀត ផ្អែកតាមលទ្ធផលនៃការគណនា Chi Square ($X^2$) ដូចបានរៀបរាប់ខាងលើ ។

**តារាង ៣៥. Table of chi-squared distribution**

| Degrees of freedom | Significance level Alpha | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | **0.995** | **0.975** | **0.2** | **0.1** | **0.05** | **0.025** | **0.02** | **0.01** | **0.005** | **0.002** | **0.001** |
| **1** | 0 | 0.001 | 1.642 | 2.706 | 3.841 | 5.024 | 5.412 | 6.635 | 7.879 | 9.55 | 10.828 |
| **2** | 0.01 | 0.051 | 3.219 | 4.605 | 5.991 | 7.378 | 7.824 | 9.21 | 10.597 | 12.429 | 13.816 |
| **3** | 0.072 | 0.216 | 4.642 | 6.251 | 7.815 | 9.348 | 9.837 | 11.345 | 12.838 | 14.796 | 16.266 |
| **4** | 0.207 | 0.484 | 5.989 | 7.779 | 9.488 | 11.143 | 11.668 | 13.277 | 14.86 | 16.924 | 18.467 |
| **5** | 0.412 | 0.831 | 7.289 | 9.236 | 11.07 | 12.833 | 13.388 | 15.086 | 16.75 | 18.907 | 20.515 |
| **6** | 0.676 | 1.237 | 8.558 | 10.645 | 12.592 | 14.449 | 15.033 | 16.812 | 18.548 | 20.791 | 22.458 |
| **7** | 0.989 | 1.69 | 9.803 | 12.017 | 14.067 | 16.013 | 16.622 | 18.475 | 20.278 | 22.601 | 24.322 |
| **8** | 1.344 | 2.18 | 11.03 | 13.362 | 15.507 | 17.535 | 18.168 | 20.09 | 21.955 | 24.352 | 26.124 |
| **9** | 1.735 | 2.7 | 12.242 | 14.684 | **16.919** | 19.023 | 19.679 | 21.666 | 23.589 | 26.056 | 27.877 |
| **10** | 2.156 | 3.247 | 13.442 | 15.987 | 18.307 | 20.483 | 21.161 | 23.209 | 25.188 | 27.722 | 29.588 |
| **............** | ......... | ............ | ............ | ............ | ............ | ............ | ............ | ............ | ............ | ............ | ............ |
| **60** | 35.534 | 40.482 | 68.972 | 74.397 | 79.082 | 83.298 | 84.58 | 88.379 | 91.952 | 96.404 | 99.607 |
| **70** | 43.275 | 48.758 | 79.715 | 85.527 | 90.531 | 95.023 | 96.388 | 100.425 | 104.215 | 108.929 | 112.317 |
| **80** | 51.172 | 57.153 | 90.405 | 96.578 | 101.879 | 106.629 | 108.069 | 112.329 | 116.321 | 121.28 | 124.839 |
| **90** | 59.196 | 65.647 | 101.054 | 107.565 | 113.145 | 118.136 | 119.648 | 124.116 | 128.299 | 133.489 | 137.208 |
| **100** | 67.328 | 74.222 | 111.667 | 118.498 | 124.342 | 129.561 | 131.142 | 135.807 | 140.169 | 145.577 | 149.449 |

ប្រភព៖ JAY L. DEVORE, *Probability and Statistics for Engineering and the Sciences, Sixth Edition,* JAY L. DEVORE, 2004.

ក្រាហ្វិក ៨៤. លទ្ធផល Chi-square ($X^2$) ធៀបជាមួយ Chi-square ($X^2$) នៅក្នុងតារាង




វិធីសាស្ត្រមួយទៀតយើងអាចគណនារក P-value តាម CHISQ.DIST.RT($X^2$,df) នៅក្នុង Microsoft Excel ផ្អែកលើលទ្ធផល Chi-square ($X^2$) ដែលបានគណនារួច យើងបានលទ្ធផលដូចខាងក្រោម៖

$X^2$=309.66 ; df=9

P-value = CHISQ.DIST.RT(309.66,9) = **2.32202E-61** ≈ **0.0000**

លទ្ធផល **P-value = 2.32202E-61 < 0.05**។

ដូច្នេះ ផ្អែកតាមលទ្ធផលខាងលើបានបង្ហាញថា P-value ដែលគណនាបានស្មើនឹង 2.32202E-61 ≈ 0.0000 តូចជាង 0,០៥ (៥%) បញ្ជាក់ថា មានសារៈសំខាន់ខាងស្ថិតិ (Statistical Significance) គឺមានន័យថាតម្លៃលេខខុសគ្នាដាច់តែម្តងតាមបណ្តាឆ្នាំនីមួយៗ។ ប្រសិនបើ តម្លៃលេខណាធំគឺធំដាច់តែម្តង តម្លៃលេខណាតូចគឺតូចដាច់តែម្តង។ នៅក្នុងនោះ ចំនួនមេគ្រួសារ៥០៩នាក់ (៨៥%) នៃមេគ្រួសារសរុបទាំង៦០០នាក់ ដែលបានឆ្លើយថាឆ្នាំ២០២៥ មានអាកាសធាតុក្តៅខ្លាំងជាចំនួនដែលច្រើនជាងគេ។ ជាការសន្និដ្ឋានថា អាកាសធាតុនៅក្នុងឆ្នាំ២០២៥ មានកម្តៅខ្លាំងជាងឆ្នាំផ្សេងៗទៀត ផ្អែកតាមលទ្ធផលនៃការគណនា Chi Square ($X^2$) ដូចបានរៀបរាប់ខាងលើ។

# ជំពូក ៣

# ស្ថានភាពទូទៅ

## ៣.១ ស្ថានភាពទូទៅផ្អែកលើទិន្នន័យទី២

### ៣.១.១ ប្រជាសាស្ត្រ

ប្រជាសាស្ត្រ គឺសំដៅដល់ចរិតលក្ខណៈរបស់ប្រជាជន រួមមាន រចនាសម្ព័ន្ធអាយុ ចំណាកស្រុក ការចូលរួមកម្លាំងពលកម្មក្នុងវិស័យសេដ្ឋកិច្ច ការអប់រំ លទ្ធភាពបង្កើតកូន និងការប្រើប្រាស់សម្ភារៈនៅក្នុងគ្រួសារជាដើម។ ការអភិវឌ្ឍប្រទេសក៏ជាផ្នែកមួយដែលធ្វើឲ្យមានបម្រែបម្រួលប្រជាសាស្ត្រផងដែរ។

#### ក. និន្នាការចំនួនប្រជាជនពិភពលោក

ក្រាហ្វិក៤៥ . បង្ហាញអំពីចំនួននិន្នាការចំនួនប្រជាជនពិភពលោកពីឆ្នាំ១៩៦០ ដល់ឆ្នាំ ២០៥០។ តាមនិន្នាការនេះ បានបង្ហាញថា ប្រជាជនទូទាំងពិភពលោកនឹងកើនឡើងជាងពីរដង កើនឡើងពីចំនួន ២.៩៩៦ លាននាក់ នៅឆ្នាំ១៩៦០ ដល់ចំនួន៧.៨៥១ លាននាក់ឆ្នាំ ២០២០ និងបានបន្តកើនឡើងជាង៣ដង នៅឆ្នាំ២០៥០ ដែលមានចំនួន ៩.៦៤៤ លាននាក់ តាមការព្យាករណ៍សម្រាប់ចំនួនប្រជាជននៅថ្ងៃទី១ ខែកក្កដា អង្គការសហប្រជាជាតិ។ ការកើនឡើងចំនួនប្រជាជននឹងមានផលប៉ះពាល់យ៉ាងច្រើនដល់ការប្រើប្រាស់នូវធនធានធម្មជាតិ ផលប៉ះពាល់បរិស្ថាន ផលប៉ះពាល់សន្តិសុខស្បៀង និងជះឥទ្ធិពលដល់សេដ្ឋកិច្ចផងដែរ ប្រសិនបើមិនបានគ្រប់គ្រងឲ្យបានត្រឹមត្រូវ។

**ក្រាហ្វិក៤៥. និន្នាការចំនួនប្រជាជនពិភពលោកពីឆ្នាំ១៩៦០ ដល់ ឆ្នាំ២០៥០**




ប្រភព៖ United Nations, Department of Economic and Social Affairs, Population Division (2024). World Population Prospects 2024, Online, Edition.
Note: Total Population, as of 1 July

តារាង៣៦. បង្ហាញអំពីចំនួនប្រជាជនពិភពលោកបែងចែកតាមតំបន់នៃ ឆ្នាំ ១៩៩៥ ឆ្នាំ២០២៤ ឆ្នាំ២០៥៤ និងឆ្នាំ២១០០។ ក្នុងចំណោមតំបន់ទាំងអស់ ចំនួនប្រជាជនដែលស្ថិតនៅតំបន់អាស៊ីប៉ែកខាងកើត និងអាស៊ីអាគ្នេយ៍ មានចំនួនប្រជាជនច្រើនជាងគេនៅឆ្នាំ១៩៩៥ និងឆ្នាំ២០២៤ ហើយចំនួនប្រជាជននឹងធ្លាក់ចុះនៅឆ្នាំ២០៥៤ និងឆ្នាំ២១០០ ខណៈតំបន់ផ្សេងនៅលើពិភពលោកមានចំនួនកើនឡើងពីឆ្នាំ២០៥៤ ដល់ឆ្នាំ២១០០។ យោងតាមការព្យាករណ៍របស់អង្គការសហប្រជាជាតិប្រជាជនពិភពលោកឆ្នាំ២០២៤ មានចំនួន ៨.១២៦.៩៦៤ ពាន់នាក់ និងនៅឆ្នាំ២១០០ នឹងអាចកើនឡើងដល់ ១០.១៨៦.៦០៨នាក់ គិតត្រឹមថ្ងៃទី១ ខែកក្កដានៃឆ្នាំដែលបានរៀបរាប់ខាងលើ។ ការកើនឡើងចំនួនប្រជាជនវាអាចធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ច សង្គមកិច្ច សន្តិសុខស្បៀង និងបរិស្ថានជាដើម។

### តារាង៣៦. ចំនួនប្រជាជនពិភពលោក ១៩៩៥ ២០២៤ ២០៥៤ និង២១០០

| Region | Population (in thousands) | | | |
|---|---|---|---|---|
| | 1995 | 2024 | 2054 | 2100 |
| **World** | **5,717,157** | **8,126,964** | **9,796,364** | **10,186,608** |
| Sub-Saharan Africa | 565,364 | 1,227,720 | 2,209,061 | 3,344,728 |
| Northern Africa and Western Asia | 323,292 | 576,973 | 816,036 | 986,573 |
| Central and Southern Asia | 1,377,757 | 2,134,994 | 2,658,654 | 2,643,211 |
| Eastern and South-Eastern Asia | 1,917,861 | 2,350,719 | 2,198,280 | 1,456,234 |
| Latin America and the Caribbean | 478,329 | 661,207 | 730,775 | 615,305 |
| Oceania (excluding Australia and New Zealand) | 7,153 | 14,050 | 20,008 | 23,985 |
| Europe and Northern America Australia and New Zealand | 1,047,401 | 1,161,300 | 1,163,549 | 1,116,569 |

*ប្រភព៖ United Nations, Population Division, Department of Economic and Social Affairs, World Population Prospects 2024, Summary of Results, New York, 2024.*

ផែនទី១. ផែនទីបង្ហាញតាមប្រទេសនៃការព្យាករណ៍ចំនួនប្រជាជនដែលអាចកើនឡើងដល់ចំណុចកំពូលត្រឹមឆ្នាំ២០២៤ ពីឆ្នាំ២០២៥ដល់២០៥៤ និងពីឆ្នាំ២០៥៤ឡើងទៅ តាងដោយពណ៌នីមួយដែលមានពណ៌ទឹកក្រូច ពណ៌ទឹកសមុទ្រ ពណ៌ស្វាយ និងពណ៌ប្រផេះ។ ពណ៌ទឹកក្រូចតំណាងប្រទេសដែលមានចំនួនប្រជាជនកើនឡើងខ្ពស់នៅឆ្នាំ២០២៤ ក្នុងនោះប្រទេសកម្ពុជាយើងស្ថិតនៅក្នុងតំបន់ប្រជាជនដែលកើនឡើងខ្ពស់បំផុតនៅឆ្នាំ២០២៤ ហើយបន្ទាប់មកមានចំនួនធ្លាក់ចុះ។ ពណ៌ទឹកសមុទ្រតំណាងប្រទេសដែលមានចំនួនប្រជាជនកើនឡើងខ្ពស់ពីឆ្នាំ២០២៥ ដល់២០៥៤ ហើយព៌ណស្វាយតំណាងប្រទេស ដែលនឹងមានចំនួនប្រជាជនកើនឡើងខ្ពស់ ចាប់ពីឆ្នាំ២០៥៤ ឡើងទៅ និងពណ៌ប្រផេះតំណាងប្រទេស ដែលមិនបានផ្តល់ទិន្នន័យប្រជាជនទៅអង្គការសហប្រជាជាតិដោយសារសង្គ្រាម ឬ ហេតុផលផ្សេងៗ។

**ផែនទី១. ផែនទីបង្ហាញតាមប្រទេសនៃការព្យាករណ៍ចំនួនប្រជាជនដែលអាចកើនឡើងដល់ ចំណុចកំពូលត្រឹមឆ្នាំ២០២៤ ពីឆ្នាំ២០២៥ដល់២០៥៤ និងពីឆ្នាំ២០៥៤ឡើងទៅ**




*ប្រភព៖ United Nations, Population Division, Department of Economic and Social Affairs, World Population Prospects 2024, Summary of Results, New York, 2024.*

## ខ. និន្នាការចំនួនប្រជាជនកម្ពុជា

ចំនួនប្រជាជនសរុបនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានបង្ហាញតាមរយៈការធ្វើជំរឿនប្រជាជនឆ្នាំ១៩៦២ មានចំនួន៥,៧ លាននាក់ បានកើនឡើងដល់ចំនួន ១១,៤ លាននាក់ ផ្អែកតាមការធ្វើជំរឿនប្រជាជនឆ្នាំ១៩៩៨ រយៈពេល៣៦ឆ្នាំនេះប្រជាជនកម្ពុជា បានកើនឡើងជាង២ដងស្មើនឹងចំនួន៧,៧ លាននាក់ ។ ចំនួនប្រជាជនក្នុងរយៈពេល១០ឆ្នាំ គិតចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០៨ មានការកើនឡើងប្រហែលចំនួន ២លាននាក់ (៩,៥%) ហើយក្នុងរយៈពេល ១១ឆ្នាំ គិតចាប់ពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០១៩ កើនឡើងចំនួន ១,៩លាននាក់ (១៤,១%) នឹងត្រូវបានគេរំពឹងទុកថានៅឆ្នាំ ២០៣៥ ចំនួនប្រជាជនកម្ពុជាអាចកើនដល់ ១៩,៨លាននាក់។

ស្ថានភាពប្រជាជនកម្ពុជា មានការកើនឡើងពីចំនួន ១១លាននាក់ ក្នុងឆ្នាំ ១៩៩៨ ដល់ជិត ១៦លាននាក់ នៅក្នុងឆ្នាំ២០១៧ ហើយកំពុងមានបម្រែបម្រួលប្រជាសាស្ត្រមួយល្អប្រសើរដល់ការអភិវឌ្ឍន៍ប្រទេស ដោយសាររចនាសម្ព័ន្ធអាយុរបស់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលភាគលាភប្រជាសាស្ត្រដ៏មានសក្តានុពលសេដ្ឋកិច្ច ដែលមានចំនួនច្រើនលើសលប់នៃប្រជាជនក្នុងវ័យធ្វើការងារខណៈដែលប្រទេសមួយចំនួននៅលើពិភពលោក ចំនួនប្រជាជនស្ថិតនៅក្នុងវ័យធ្វើការងារមាននិន្នាការថយចុះ តែចំនួនអ្នកនៅដែលស្ថិតនៅក្នុងបន្ទុកមានការកើនឡើងវិញ។

ម្យ៉ាងវិញទៀត នៅក្នុងរយៈពេល២៥ឆ្នាំនេះ ប្រទេសកម្ពុជាបានទទួលនូវការរីកចម្រើនគួរឲ្យកត់សំគាល់ក្នុងការធានាលទ្ធភាពទទួលបានសុខភាពបន្តពូជសម្រាប់ស្ត្រី យុវវ័យ និងគូស្វាមីភរិយាផងដែរ (ព្រឹត្តិបត្រព័ត៌មាន អគ្គលេខាធិការប្រជាជន និងការអភិវឌ្ឍន៍ឆ្នាំ២០២០)។ បើទោះបីជាស្ថានភាពប្រជាជនកម្ពុជា ដែលកំពុងស្ថិតក្នុងផលលាភប្រជាសាស្ត្រល្អប្រសើរក្តី ក៏ការកើនឡើងចំនួនប្រជាជនអាចមានផលប៉ះពាល់ដល់ធនធានធម្មជាតិ បរិស្ថាន ការងារ និងសន្តិសុខស្បៀង។ លើសពីនេះទៀត តម្រូវលំនៅដ្ឋានបន្ថែម និងសេវាសង្គមផ្សេង។ ម្យ៉ាងវិញទៀត ប្រសិនបើប្រជាជនដែលស្ថិតក្នុងវ័យផលិត ឬម្យ៉ាងទៀតអាចនិយាយថាជាផលលាភប្រជាសាស្ត្រនោះមិនមានការងារធ្វើ ឬការប្រព្រឹត្តិនូវអំពើមិនល្អក៏អាចជះឥទ្ធិពលដល់សង្គមជាតិធ្ងន់ធ្ងរផងដែរ។

សរុបមក ស្ថានភាពនៃបម្រែបម្រួលប្រជាជនកម្ពុជា កំពុងស្ថិតក្នុងដំណាក់កាលភាគលាភប្រជាសាស្ត្រដ៏មានសក្តានុពលសេដ្ឋកិច្ច ប្រសិនបើការការរៀបក្រុមមនុស្សដែលស្ថិតក្នុងវិស័យផលិតបានល្អប្រសើរ។ តែផ្ទុយទៅវិញ ប្រសិនបើការការរៀបចំក្រុមមនុស្សដែលស្ថិតក្នុងវិស័យផលិតមិនបានល្អនឹងបាត់ឱកាសនេះ ហើយក្រុមមនុស្សនេះក៏អាចធ្វើអំពើមិនគប្បីប្រសិនបើការគ្រប់គ្រងមិនបានល្អ។

**ផែនទីទី២. បង្ហាញអំពីផែនទីប្រទេសកម្ពុជា និងរូបភាពប្រជាជនដែលជាយុវវ័យនៅទូទាំងប្រទេស**



ក្រាហ្វិក៤៦. បង្ហាញអំពី និន្នាការនៃការកើនឡើងពីចំនួនប្រជាជនអំឡុងពេលការធ្វើជំរឿនឆ្នាំ ១៩៦២ មានចំនួនប្រជាជន ៥,១ លាននាក់ បានកើនឡើង ១១,៤លាននាក់ នៅពេលធ្វើជំរឿនឆ្នាំ ១៩៩៨ បានកើនឡើងដល់ពេល ១៣,៤លាននាក់ នៅពេលធ្វើជំរឿនឆ្នាំ ២០០៨ និង ១៥,៣ លាននាក់ ផ្អែកតាមលទ្ធផលជំរឿនឆ្នាំ ២០១៩ ហើយរំពឹងថានឹងកើនឡើងដល់ ១៩,៨លាននាក់ នៅឆ្នាំ២០៣៥។

## ក្រាហ្វិក៤៦. និន្នាការចំនួនប្រជាជនសរុបទូទាំងប្រទេសកម្ពុជា




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩*

*២. ទិន្នន័យឆ្នាំ ១៩៩៦ ផ្អែកលើទិន្នន័យអង្កេតប្រជាសាស្ត្រឆ្នាំ ១៩៩៦*

*៣. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*

*៤. ទិន្នន័យឆ្នាំ ២០២៥, ២០៣០ និង ២០៣៥ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០២០ ដោយប្រើប្រាស់ទិន្នន័យជំរឿនប្រជាជនឆ្នាំ ២០១៩*

*៥. ទិន្នន័យឆ្នាំ ២០២៤ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០២៤ ។*

ចំនួនប្រជាជនកម្ពុជាក្នុងរយៈពេល៣៦ឆ្នាំ ពីឆ្នាំ១៩៦២ ដល់១៩៩៨ បានកើនឡើង ៥,៧ លាននាក់ ស្មើនឹង ៥០% នៃចំនួនប្រជាជនឆ្នាំ១៩៦២។ នៅក្នុងរយៈពេល ១០ ឆ្នាំពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៨ បានកើនឡើងចំនួន ២ លាននាក់ ស្មើនឹង ១៧,៥% នៃចំនួនប្រជាជនឆ្នាំ ២០០៨។ នៅក្នុងរយៈពេល ១១ឆ្នាំ ពីឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៩ បានកើនឡើងចំនួន១,៩ លាននាក់ ស្មើនឹង ១៤,២%នៃចំនួនប្រជាជនឆ្នាំ២០០៨។ នៅក្នុងរយៈ ៥៧ ឆ្នាំ គិតពីឆ្នាំ១៩៦២ ដល់ ឆ្នាំ២០១៩ ចំនួនប្រជាជនបានកើនឡើងជិត ៣ដង នៃចំនួនប្រជាជនទូទាំងប្រទេស ឆ្នាំ១៩៦២។ នៅឆ្នាំ២០៥០ តាមការធ្វើចំណោលប្រជាជនឆ្នាំ២០២០ ដោយផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ២០១៩ អាចនឹងកើនឡើងដល់ ២១,៧ លាននាក់។

## ១១. និន្នាការចំនួនប្រជាជនកម្ពុជាតាមតំបន់

ប្រទេសកម្ពុជាបានបែងចែកសណ្ឋានដីចំនួន ៤តំបន់ រួមមាន ទី១. តំបន់ទំនាបកណ្តាល ទី២. តំបន់ទន្លេសាប ទី៣. តំបន់ឆ្នេរសមុទ្រ និងទី៤. តំបន់ខ្ពង់រាប និងភ្នំ។ ទំហំផ្ទៃដីនៃតំបន់ទាំង៤ នោះគឺតំបន់ខ្ពង់រាបនិងភ្នំ មានទំហំផ្ទៃដីចំនួន ៦៨.០៦១ គីឡូម៉ែត្រការ៉េ ធំជាងគេស្ថិតក្នុងលំដាប់ទី១ បន្ទាប់មកតំបន់ទន្លេសាបមានទំហំផ្ទៃដីចំនួន ៦៧.៦៦៨ គីឡូម៉ែត្រការ៉េ ស្ថិតក្នុងលំដាប់ទី២ តំបន់ទំនាបកណ្តាលមានទំហំផ្ទៃដីចំនួន ២៥.០៦៩គីឡូម៉ែត្រការ៉េ ស្ថិតក្នុងលំដាប់ទី៣ និងតំបន់ឆ្នេរសមុទ្រមានទំហំផ្ទៃដីចំនួន ១៧.២៣៧គីឡូម៉ែត្រការ៉េ ស្ថិតក្នុងលំដាប់ទី៤។តំបន់ដែលមានភាគរយចំនួនប្រជាជនរស់នៅច្រើនជាងគេតំបន់ទំនាបកណ្តាល និង តិចជាងគេគឺតំបន់ឆ្នេរសមុទ្រ។ ចំនួនប្រជាជននៅក្នុងតំបន់ទំនាបកណ្តាលមានចំនួនប្រហែល ៥,៩លាននាក់ នៅឆ្នាំ១៩៩៨ នឹងកើនដល់ ៩,៧ លាននាក់ នៅឆ្នាំ ២០៣៥ ខណៈដែលចំនួនក្នុងតំបន់ទន្លេសាបមានចំនួនប្រហែល ៣,៥លាននាក់នៅឆ្នាំ ១៩៩៨ នឹងកើនដល់ ៦,២ លាននាក់ នៅឆ្នាំ ២០៣៥ តំបន់ខ្ពង់រាប និងភ្នំមានចំនួនប្រហែល ១,២លាននាក់នៅឆ្នាំ ១៩៩៨ នឹងកើនដល់ ២,៥ លាននាក់ នៅឆ្នាំ ២០៣៥ និង តំបន់ឆ្នេរសមុទ្រមានចំនួនប្រហែល ៨៤៤ ពាន់ នាក់នៅឆ្នាំ១៩៩៨ នឹងកើនដល់ ១,៤ លាននាក់ នៅឆ្នាំ ២០៣៥។ ក្រាហ្វិក៤៧ បង្ហាញអំពីនិន្នាការចំនួនប្រជាជនតាមតំបន់ក្នុងប្រទេសកម្ពុជា។

**ក្រាហ្វិក៤៧. និន្នាការចំនួនប្រជាជនតាមតំបន់ក្នុងប្រទេសកម្ពុជា**




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ១៩៩៦ ផ្អែកលើទិន្នន័យអង្កេតប្រជាសាស្ត្រឆ្នាំ ១៩៩៦*
*៣. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៤. ទិន្នន័យឆ្នាំ ២០២០ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០២០ ដោយប្រើប្រាស់ទិន្នន័យជំរឿនប្រជាជនឆ្នាំ ២០១៩។*

ផ្អែកតាមទិន្នន័យជំរឿនប្រជាជនកន្លងមក ចំនួនប្រជាជននៅក្នុងតំបន់ទំនាបកណ្តាល គឺបានកើនឡើងពីចំនួន៥,៩លាននាក់ នៅឆ្នាំ១៩៩៨ កើនដល់ចំនួន៧,៦លាននាក់ នៅឆ្នាំ២០១៩ ខណៈដែលខេត្តកំពង់ចាមបានថយចុះជាងពីរម៉ឺននាក់ និងខេត្តត្បូងឃ្មុំបានកើនឡើងពីជាងប្រាំបួនម៉ឺននាក់ ពីឆ្នាំ១៩៩៨ ដល់ ២០១៩។ ការថយចុះនៅខេត្តកំពង់ចាមអាចប្រជាជនទៅរស់នៅខេត្តត្បូងឃ្មុំ ដោយសារខេត្តទាំង២នេះ ពីមុនជាខេត្តតែមួយតែប៉ុណ្ណោះ។ ចំពោះខេត្តផ្សេងទៀតដែលស្ថិតនៅក្នុងតំបន់ទំនាបកណ្តាលមាននៅក្នុងតារាង ៣៧ និងក្រាហ្វិក៤៩ ខាងក្រោម។

**តារាង៣៧. ចំនួនប្រជាជនតាមបណ្តាខេត្តស្ថិតនៅក្នុងតំបន់ទំនាបកណ្តាល**

| ខេត្ត | 1998 | 2008 | 2019 |
|---|---|---|---|
| កំពង់ចាម | 924,808 | 961,888 | 899,791 |
| កណ្តាល | 1,075,125 | 1,265,280 | 1,201,581 |
| រាជធានីភ្នំពេញ | 999,804 | 1,327,615 | 2,281,377 |
| ព្រៃវែង | 946,042 | 947,372 | 1,057,720 |
| ស្វាយរៀង | 478,252 | 482,788 | 525,497 |
| តាកែវ | 790,168 | 844,906 | 900,914 |
| ត្បូងឃ្មុំ | 684,106 | 718,104 | 776,841 |
| **សរុប** | **5,898,305** | **6,547,953** | **7,643,721** |

**ក្រាហ្វិក៤៨. ចំនួនប្រជាជនតាមបណ្តាខេត្តស្ថិតនៅក្នុងតំបន់ទំនាបកណ្តាល (ពាន់នាក់)**



## ១២. និន្នាការចំនួនប្រជាជនខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ជាខេត្តដែលស្ថិតក្នុងតំបន់ទំនាបកណ្តាល។ ខេត្តកំពង់ចាមមានផ្ទៃដីសរុបប្រហែល៤.៥៤៩ គីឡូម៉ែត្រការ៉េ និងមានចំនួនប្រជាជននៅឆ្នាំ ២០១៩ ប្រហែល ៨៨៧.១២១នាក់។ ខេត្តត្បូងឃ្មុំមានផ្ទៃដីចំនួន ៤.៩២៨ គីឡូម៉ែត្រការ៉េ និងមានចំនួនប្រជាជននៅឆ្នាំ ២០១៩ ប្រហែល ៧៦៣.៧៣៥នាក់ ផ្អែករបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។ ក្រាហ្វិក ៥០ បង្ហាញពីនិន្នាការចំនួនប្រជាជនខេត្តកំពង់ចាមនិង ខេត្តត្បូងឃ្មុំពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០៣៥។ ចំនួនប្រជាជន ខេត្តកំពង់ចាមនៅឆ្នាំ១៩៩៨ មានចំនួន ៩២៤.៨០៨នាក់ បានកើនដល់ ១.១៥០.៨៨៨ នាក់ នៅឆ្នាំ២០៣៥ និងខេត្តត្បូងឃ្មុំនៅឆ្នាំ១៩៩៨ មានចំនួនប្រជាជន៦៨៤.១០៦នាក់ បានកើនដល់ ១.០០១.០២៣នាក់ នៅឆ្នាំ២០៣៥។

**ក្រាហ្វិក ៤៩. និន្នាការចំនួនប្រជាជនសម្រាប់ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ**




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៣. ទិន្នន័យឆ្នាំ ២០២៥, ២០៣០ និង ២០៣៥ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០២០ ដោយប្រើប្រាស់ទិន្នន័យជំរឿនប្រជាជនឆ្នាំ ២០១៩។*

## តារាង ៣៨. ចំនួនប្រជាជននិងចំនួនគ្រួសារសរុប ពីឆ្នាំ ១៩៩៨ ដល់ ២០៣៥ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ គិតជានាក់

| ឆ្នាំ | ចំនួនប្រជាជន | | ចំនួនគ្រួសារ | |
|---|---|---|---|---|
| | កំពង់ចាម | ត្បូងឃ្មុំ | កំពង់ចាម | ត្បូងឃ្មុំ |
| 1962 | 440,541 | 379,223 | 80,098 | 68,950 |
| 1998 | 924,808 | 684,106 | 179,521 | 133,320 |
| 2008 | 961,888 | 718,104 | 214,762 | 154,696 |
| 2019 | 899,791 | 776,841 | 217,197 | 178,942 |
| 2020 | 945,259 | 816,096 | 239,747 | 207,311 |
| 2021 | 959,954 | 828,783 | 264,638 | 240,176 |
| 2022 | 974,490 | 841,333 | 292,113 | 278,253 |
| 2023 | 988,846 | 853,727 | 322,441 | 322,365 |
| 2024 | 1,003,012 | 865,958 | 355,917 | 373,471 |
| 2025 | 1,016,981 | 878,018 | 392,869 | 432,680 |
| 2026 | 1,030,773 | 889,926 | 433,658 | 501,274 |
| 2027 | 1,044,397 | 901,688 | 478,681 | 580,744 |
| 2028 | 1,057,825 | 913,281 | 528,378 | 672,812 |
| 2029 | 1,071,018 | 924,671 | 583,236 | 779,475 |
| 2030 | 1,083,934 | 935,822 | 643,788 | 903,049 |
| 2031 | 1,097,005 | 948,513 | 710,628 | 915,296 |
| 2032 | 1,110,235 | 961,377 | 784,406 | 927,709 |
| 2033 | 1,123,624 | 974,414 | 865,845 | 940,290 |
| 2034 | 1,137,174 | 987,629 | 955,739 | 953,042 |
| 2035 | 1,150,888 | 1,001,023 | 1,054,965 | 965,967 |

*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩។*
*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣។*
*៣. ទិន្នន័យឆ្នាំ ២០២០ និង ២០៣៥ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០២០។*

*សំគាល់៖ ផ្អែកតាមជំរឿនប្រជាជនឆ្នាំ១៩៦២ ខេត្តកំពង់ចាមរួមបញ្ចូលនឹងខេត្តត្បូងឃ្មុំមានចំនួន ៨១៩.៧៦៤នាក់ ក្នុងនោះខេត្តកំពង់ចាម(ថ្មី) មានចំនួនប្រជាជនប្រហែល ៤៤០.៥៤១នាក់ និងខេត្តត្បូងឃ្មុំ (ថ្មី)មានចំនួន ៣៧.៩២២៣នាក់។*

## គ. ដង់ស៊ីតេប្រជាជន

### គ១. ដង់ស៊ីតេប្រជាជនពិភពលោក

ដង់ស៊ីតេប្រជាជនគឺជាសូចនាករមួយយ៉ាងសំខាន់ សម្រាប់ពិនិត្យមើលនូវរបាយប្រជាជន ដែលរស់នៅលើផ្ទៃដីតាមប្រទេស តំបន់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់ ។ ក្រាហ្វិក ៥ បានបង្ហាញថាដង់ស៊ីតេប្រជាជនពិភពលោកបានកើនឡើងពី ចំនួន២៤នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ កើនឡើង ៦០នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ពីឆ្នាំ១៩៦២ ទៅឆ្នាំ២០១៩។ ដង់ស៊ីតេប្រជាជនកម្ពុជា បានកើនឡើងពី ៣២នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ដល់ ៨៧នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ពីឆ្នាំ១៩៦២ ដល់ឆ្នាំ២០១៩។ ដង់ស៊ីតេចំនួនប្រជាជននៅតំបន់អាស៊ីកណ្តាលប៉ែកខាងត្បូងមានដង់ស៊ីតេខ្ពស់ជាងគេគឺនៅឆ្នាំ២០១៩មានចំនួន ១៩៧ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ និងខ្ពស់ជាងតំបន់អាស៊ីអាគ្នេយ៍ ដែលមានដង់ស៊ីតេចំនួន ១៤៤ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ខណៈដែលដង់ស៊ីនៅតំបន់អូសេអានី មានចំនួនតិចជាងគេគឺ ២៤នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ នៅឆ្នាំ២០១៩ដូចគ្នាដែរ។

**ក្រាហ្វិក ៥០. ដង់ស៊ីតេប្រជាជនបែងចែកតាមពិភពលោក តំបន់ និងកម្ពុជា**



ក្រាហ្វិក ៥១. ដង់ស៊ីតេប្រជាជនពិភពលោក និងកម្ពុជា (នាក់/គម$^{២}$)




ប្រភព៖ United Nations, Department of Economic and Social Affairs, Population Division (2024). World Population Prospects 2024, Online, Edition.

Note: Total Population, as of 1 July

## គ២. ដង់ស៊ីតេប្រជាជនកម្ពុជា

ដង់ស៊ីតេប្រជាជនកម្ពុជានៅឆ្នាំ១៩៦២ មានចំនួន៣២នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ផ្អែកលើលទ្ធផលនៃការធ្វើជំរឿនប្រជាជនឆ្នាំ១៩៦២ នឹងបានកើនឡើងដល់ ៨៧នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ផ្អែកលើលទ្ធផលនៃការធ្វើជំរឿនប្រជាជនឆ្នាំ២០១៩ នឹងអាចនកើឡើងដល់ ១១១នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ នៅឆ្នាំ២០៣៥ យោងតាមលទ្ធផលនៃការធ្វើចំណោលប្រជាជនឆ្នាំ២០២០។ ចំណែកឯខេត្តកំពង់ចាមនៅឆ្នាំ១៩៦២ មានដង់ស៊ីតេ៩៧នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ បានកើនឡើង២១១នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅឆ្នាំ២០០៨ នឹងបានធ្លាក់ចុះមកត្រឹម ១៩៥នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ នៅឆ្នាំ២០១៩ នឹងបានកើនដល់២៥៣ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅឆ្នាំ២០៣៥ ខណៈដែលខេត្តត្បូងឃ្មុំនៅឆ្នាំ១៩៦២ មានដង់ស៊ីតេ ៧៧នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ បានកើនឡើង១៥៥នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅឆ្នាំ២០១៩ នឹងបន្តកើនឡើងដល់ ២០៣នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ នៅឆ្នាំ២០៣៥។ ទិន្នន័យលំអិតដូចមាននៅក្នុងក្រាហ្វិក៥៣ដូចខាងក្រោម។

## ក្រាហ្វិក ៥២. ដង់ស៊ីតេប្រជាជនសម្រាប់ ពិភពលោក កម្ពុជា ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ




នៅក្នុងផែនទីខាងក្រោម បង្ហាញអំពីដង់ស៊ីតេប្រជាជននៅលើផែនទីនៅក្នុងប្រទេសកម្ពុជា នៅឆ្នាំ១៩៩៨ ឆ្នាំ២០០៨ និងឆ្នាំ២០១៩ ដើម្បីយល់ដឹងកាន់តែច្បាស់អំពីចលនាប្រជាជនតាមបណ្តារាជធានី ខេត្ត។

ដង់ស៊ីតេចំនួនប្រជាជនទូទាំងប្រទេសនៅឆ្នាំ១៩៩៨ មានដង់ស៊ីតេចំនួន ៦៤នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ហើយបានកើនឡើង ៧៥ ក្នុងមួយគីឡូម៉ែត្រការ៉េ និង កើនឡើងដល់ ៨៧នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅឆ្នាំ២០១៩ ។ នៅឆ្នាំ១៩៩៨ រាជធានីភ្នំពេញ និងខេត្តកណ្តាលមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេស្ថិតនៅចន្លោះពី ៣០២ ទៅ១.៤៧២ នាក់/១គម$^2$។ ខេត្តកំពង់ចាម ព្រៃវែង ស្វាយរៀង តាកែវ និង ខេត្តព្រះសីហនុមានដង់ស៊ីតេប្រជាជនចន្លោះពី ១៣១ ទៅ៣០១ នាក់/១គម$^2$ ស្ថិតនៅលំដាប់លេខ២។ ខេត្តត្បូងឃ្មុំ កំពង់ឆ្នាំង កំពង់ស្ពឺ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពត និងខេត្តកែបមានដង់ស៊ីតេចន្លោះពី ៤២ ទៅ១៣០នាក់/១គម$^2$ ស្ថិតនៅលំដាប់លេខ៣។ ខេត្តក្រចេះ កំពង់ធំ ពោធិ៍សាត់ និងខេត្តប៉ៃលិន មានដង់ស៊ីតេប្រជាជនស្ថិតនៅចន្លោះពី ១៤ ទៅ៤១ នាក់/១គម$^2$ ស្ថិតនៅលំដាប់លេខ៤។ ខេត្តកោះកុង ឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរីមានដង់ស៊ីតេប្រជាជនស្ថិតនៅចន្លោះពី ២ ទៅ១៣ នាក់/១គម$^2$ ស្ថិតនៅលំដាប់លេខ៥ ជាខេត្តដែលមានដង់ស៊ីតេប្រជាជនទាបជាងគេបំផុត។

នៅឆ្នាំ ២០០៨ ដង់ស៊ីតេប្រជាជននៅរាជធានីភ្នំពេញ មានដង់ស៊ីតេប្រជាជនច្រើនជាងគេស្ថិតនៅចន្លោះពី ៣៨៤ ទៅ ២១១២ នាក់/១គម$^{២}$ ស្ថិតនៅលំដាប់លេខ១។ ខេត្តកណ្តាល កំពង់ចាម ព្រៃវែង និង ខេត្តតាកែវ មានដង់ស៊ីតេប្រជាជនចន្លោះពី ១៦៤ ទៅ៣៨៣ នាក់/១គម$^{២}$ ស្ថិតនៅលំដាប់លេខ២។ ខេត្តត្បូងឃ្មុំ ស្វាយរៀង កំពង់ឆ្នាំង កំពង់ស្ពឺ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប ព្រះសីហនុ កំពត និងខេត្តកែប មានដង់ស៊ីតេចន្លោះពី ៤៧ ទៅ១៦៣នាក់/១គម$^{២}$ ស្ថិតនៅលំដាប់លេខ៣។ ខេត្តឧត្តរមានជ័យ ពោធិ៍សាត់ កំពង់ធំ និងខេត្តក្រចេះ មានដង់ស៊ីតេចន្លោះពី ១៥ ទៅ៤៦ នាក់/១គម$^{២}$ ស្ថិតនៅលំដាប់លេខ៤។ ខេត្តកោះកុង ព្រះវិហារ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី មានដង់ស៊ីតេប្រជាជនស្ថិតនៅចន្លោះពី ៤ ទៅ១៤ នាក់/១គម$^{២}$ ស្ថិតនៅលំដាប់លេខ៥ ជាខេត្តដែលមានដង់ស៊ីតេប្រជាជនទាបជាងគេបំផុត។

នៅឆ្នាំ ២០១៩ ដង់ស៊ីតេប្រជាជននៅរាជធានីភ្នំពេញ មានដង់ស៊ីតេប្រជាជនច្រើនជាងគេស្ថិតនៅចន្លោះពី ៣៧៧ ទៅ ៣១៣៦ នាក់/១គម$^{២}$ ស្ថិតនៅលំដាប់លេខ១។ ខេត្តកណ្តាល មានដង់ស៊ីតេប្រជាជនចន្លោះពី ២៥៣ ទៅ៣៧៦ នាក់/១គម$^{២}$ ស្ថិតនៅលំដាប់លេខ២។ ខេត្តកំពង់ចាម ព្រៃវែង ស្វាយរៀង និង ខេត្តតាកែវ មានដង់ស៊ីតេប្រជាជនចន្លោះពី ១៥៧ ទៅ ២៥២នាក់/១គម$^{២}$ ស្ថិតនៅលំដាប់លេខ៣។ ខេត្តត្បូងឃ្មុំ កំពង់ឆ្នាំង កំពង់ស្ពឺ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប ព្រះសីហនុ កំពត និង ខេត្តកែប មានដង់ស៊ីតេចន្លោះពី ៥០ ទៅ១៥៣នាក់/១គម$^{២}$ ស្ថិតនៅលំដាប់លេខ៤។ ខេត្តឧត្តរមានជ័យ កោះកុង ពោធិ៍សាត់ កំពង់ធំ ខេត្តក្រចេះ ព្រះវិហារ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី មានដង់ស៊ីតេប្រជាជនស្ថិតនៅចន្លោះពី ៦ ទៅ៤៩ នាក់/១គម$^{២}$ ស្ថិតនៅលំដាប់លេខ៥ ជាខេត្តដែលមានដង់ស៊ីតេប្រជាជនទាបជាងគេបំផុត។

## ផែនទី៣. ដង់ស៊ីតេប្រជាជនតាមរាជធានី ខេត្ត ឆ្នាំ១៩៩៨




ប្រភពៈ លទ្ធផលចុងក្រោយជំរឿនទូទៅនូវប្រជារាស្ត្រ ឆ្នាំ១៩៩៨

## ផែនទី៤. ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ២០០៨




ប្រភពៈ លទ្ធផលចុងក្រោយជំរឿនទូទៅនូវប្រជារាស្ត្រ ឆ្នាំ ២០០៨

### ផែនទី៥. ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ២០១៩




ប្រភព: របាយការណ៍ការជាតិស្ដីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩

ដង់ស៊ីតេប្រជាជនតាមបណ្ដាស្រុកនៃខេត្តកំពង់ចាមបានបង្ហាញថា នៅឆ្នាំ១៩៩៨ ដង់ស៊ីតេប្រជាជនដែលមានចំនួនខ្ពស់ជាងគេគឺក្រុងកំពង់ចាមស្ថិតនៅចន្លោះពី ៣៨០នាក់ ទៅ១៩៧៨នាក់/១គម² និងទាបជាងគេមាន២ស្រុកគឺស្រុកបាធាយ និងស្រុកស្ទឹងត្រង់ ដែលមានដង់ស៊ីតេប្រជាជនស្ថិតនៅចន្លោះពី ៩៩ដល់១៣៧នាក់/១គម²។ នៅឆ្នាំ២០០៨ ដង់ស៊ីតេប្រជាជនតាមបណ្ដាស្រុកនៃខេត្តកំពង់ចាម គឺក្រុងកំពង់ចាមមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេស្ថិតនៅចន្លោះពី ៣២៥ ដល់ ២០៦៣នាក់/១គម² និងទាបជាងគេគឺស្រុកស្ទឹងត្រង់មានដង់ស៊ីតេ១០៩នាក់/១គម²។ នៅឆ្នាំ២០១៩ ដង់ស៊ីតេប្រជាជន តាមបណ្ដាស្រុកនៃខេត្តកំពង់ចាមគឺក្រុងកំពង់ចាមមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេស្ថិតនៅចន្លោះពី ៣០២ ដល់ ១៦៧៣នាក់/១គម² និងទាបជាងគេគឺស្រុកស្ទឹងត្រង់មានដង់ស៊ីតប្រជាជន ៩៥នាក់/១គម²។ និន្នាការនៃដង់ស៊ីតេប្រជាជន ខេត្តកំពង់ចាមមាននិន្នាការថយចុះ ប្រហែលមកពីមានការធ្វើចំណាកស្រុកនៅក្នុងប្រទេស និងក្រៅប្រទេសកើតឡើង។ ជាពិសេសនោះ ប្រហែលជាការផ្លាស់ប្ដូរលំនៅឋានរបស់ប្រជាជនទៅរស់នៅខេត្តផ្សេងដែលមានលក្ខណៈសេដ្ឋកិច្ចប្រសើរជាងកន្លែងរស់នៅបច្ចុប្បន្ន។

## ផែនទីទី៦. ដង់ស៊ីតេប្រជាជនក្រុង ស្រុក ខេត្តកំពង់ចាម ឆ្នាំ១៩៩៨ ២០០៨ និង ២០១៩



ដង់ស៊ីតេប្រជាជនតាមបណ្តាស្រុកនៃខេត្តត្បូងឃ្មុំបានបង្ហាញថា នៅឆ្នាំ១៩៩៨ ដង់ស៊ីតេប្រជាជនដែលមានចំនួនខ្ពស់ជាងគេគឺក្រុងសួង និងស្រុកត្បូងឃ្មុំ ស្ថិតនៅចន្លោះពី ២៤៣នាក់ ទៅ ៣២០នាក់/១គម² និងទាបជាងគេគឺស្រុកដំបែរ ដែលមានដង់ស៊ីតេប្រជាជន៧១នាក់/១គម²។ នៅឆ្នាំ២០០៨ ដង់ស៊ីតេប្រជាជនតាមបណ្តាស្រុកនៃខេត្តត្បូងឃ្មុំ គឺក្រុងសួង និងស្រុកត្បូងឃ្មុំ មានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេស្ថិតនៅចន្លោះពី ២៣៨ ដល់ ៣២៧នាក់/១គម² និងទាបជាងគេគឺស្រុកមេមត់ដង់ស៊ីតេប្រជាជន ៩៧នាក់/១គម²។ នៅឆ្នាំ២០១៩ ដង់ស៊ីតេប្រជាជន តាមបណ្តាស្រុកនៃខេត្តត្បូងឃ្មុំគឺក្រុងសួង និងស្រុកត្បូងឃ្មុំ មានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេស្ថិតនៅចន្លោះពី ២៣៤ ដល់ ៣២០នាក់/១គម² និងទាបជាងគេគឺស្រុកមេមត់មានដង់ស៊ីតប្រជាជន ៩៩នាក់/១គម²។ និន្នាការនៃដង់ស៊ីតេប្រជាជនខេត្តត្បូងឃ្មុំមានលម្អិតនៅក្នុងផែនទី៧ ដូចខាងក្រោម។

## ផែនទី៧. ដង់ស៊ីតេប្រជាជនខេត្តត្បូងឃ្មុំ ឆ្នាំ១៩៩៨២០០៨ និង ២០១៩



## ឃ. ការបំលាស់ទីកន្លែងរស់នៅ

ការបំលាស់ទីកន្លែងរស់នៅរបស់មនុស្ស គឺបានកើតឡើងគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក។ ការផ្លាស់ប្តូរទីកន្លែងរស់នៅ គឺអាចផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងខេត្តដដែលឬ ពីប្រទេសមួយទៅប្រទេសមួយទៀត ដែលបណ្តាលមកពីហេតុផលផ្សេងៗដូចជាការស្វែងរកការងារធ្វើ គ្រោះធម្មជាតិ សង្គ្រាម ការប្រែប្រួលអាកាសធាតុដែលមិនអាចធ្វើការកសិកម្មបាន ឬហេតុផលផ្សេងៗទៀត។ សូចនាករការបំលាស់ទីកន្លែងរស់នៅ ឬចំណាកស្រុក ដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ គឺមានគោលបំណងចង់បង្ហាញអំពីស្ថានភាពនៃការបំលាស់ទីកន្លែងរស់នៅ ឬចំណាកស្រុករបស់ប្រជាជននៅលើពិភពលោក និងនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំផងដែរ។

### ឃ១. ស្ថានភាពបំលាស់ទីកន្លែងរស់នៅរបស់ប្រជាជនពិភពលោក

ប្រជាជននៅលើពិភពលោក គឺបានធ្វើចំណាកស្រុកទៅក្រៅប្រទេសមានចំនួនប្រហែល ១៨១ លាននាក់ ស្មើនឹងចំនួន ៣,៦% នៃចំនួនប្រជាជននៅលើពិភពលោក ផ្អែកតាមទិន្នន័យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកជនអន្តោរប្រវេសន៍នៅឆ្នាំ២០២០។ នៅក្នុងចំណោមប្រជាជនអន្តោរប្រវេសន៍ ២៨១ លាននាក់ មានចំនួនមនុស្សប្រុសចំនួនប្រហែល ១៤៦ លាននាក់ ស្មើនឹង ៣,៧%នៃចំនួនមនុស្សប្រុសសរុបលើពិភពលោក និងចំនួនមនុស្សស្រី ១៣៥លាននាក់ស្មើនឹង ៣,៥%នៃចំនួនមនុស្សស្រីសរុបលើពិភពលោក ។ ជនអន្តោប្រវេសន៍ជាកុមារមានចំនួន ២៨លាន ស្មើនឹង១,៤% នៃចំនួនកុមារពិភពលោកនៅក្នុងឆ្នាំ២០២០។ ជនអន្តោប្រវេសន៍ ដែលជាកម្មករមានចំនួន ១៦៩លាននាក់ នៅឆ្នាំ២០១៩ និងជនអន្តោរប្រវេសន៍ដែលស្លាប់និងបាត់បង់ជីវិតមានចំនួន ៨.៥០០ នាក់ នៅឆ្នាំ២០២៣។

**ក្រាហ្វិក ៥៣. ចំនួនជនអន្តោប្រវេសន៍អន្តរជាតិឆ្នាំ២០២៣**




សំគាល់៖ ជនអន្តោរប្រវេសន៍បាត់ខ្លួន និងស្លាប់មានចំនួន៨.៥០០ នាក់នៅឆ្នាំ២០២៣

ប្រភព៖ UN Migration, *World Migration Report 2024,* 2024, UN Migration.

តារាង៣៩ បង្ហាញអំពីជនអន្តោរប្រវេសន៍មានការកើនឡើងពីចំនួន ៨៤.៤៦០.១២៥ នាក់ ដល់ ២៨០.៥៩៨.១០៥នាក់ ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ២០២០ គឺបានកើនឡើងជាងបីដងប្រៀបធៀបរវាងឆ្នាំ២០២០ និងឆ្នាំ១៩៧០។ បើពិនិត្យមើលភាគរយជនអន្តោរប្រវេសន៍ឆ្នាំ១៩៧០ ស្មើនឹង២,៣% នៃចំនួនប្រជាជនពិភពលោក ហើយបានកើនឡើងដល់៣,៦% នៃចំនួនប្រជាជនពិភពលោកនៅឆ្នាំ ២០២០។ ទិន្នន័យលំអិតមាននៅក្នុងតារាង៤ ខាងក្រោម។

**តារាង ៣៩. ចំនួនជនអន្តោប្រវេសន៍អន្តរជាតិពីឆ្នាំ ១៩៧០ ដល់ ២០២០**

| Year | Number of international migrants | Migrants as a % of the world's population |
|---|---|---|
| 1970 | 84 460 125 | 2.3 |
| 1975 | 90 368 010 | 2.2 |
| 1980 | 101 983 149 | 2.3 |
| 1985 | 113 206 691 | 2.3 |
| 1990 | 152 986 157 | 2.9 |
| 1995 | 161 289 976 | 2.8 |
| 2000 | 173 230 585 | 2.8 |
| 2005 | 191 446 828 | 2.9 |
| 2010 | 220 983 187 | 3.2 |
| 2015 | 247 958 644 | 3.4 |
| 2020 | 280 598 105 | 3.6 |

ប្រភព៖ UN Migration, *World Migration Report 2024,* 2024, UN Migration.

ក្រាហ្វិក៥៤ បង្ហាញអំពីចំនួនជនអន្តោប្រវេសន៍ចេញពីប្រទេសមួយទៅប្រទេសមួយទៀតតាមច្រករបៀងផ្សេងៗ ដោយសារមូលហេតុសង្គ្រាម ស្វែងរកការងាធ្វើ ឬ ការធ្វើពាណិជ្ជកម្មជាដើម។ ប្រទេសម៉ិកសិកូបានចូលទៅប្រទេសអាមេរិកតាមច្រករបៀងមានចំនួនប្រហែលជិត ១១ លាននាក់ គឺជាចំនួនមួយដែលធំជាងគេ។ បន្ទាប់មកសាធារណៈរដ្ឋអារ៉ាប់ស៊ីរី ចូលទៅប្រទេសតួគីមានចំនួនជិត៤លាននាក់។ ច្រករបៀងសហព័ន្ធរុស្ស៊ី និងអ៊ុយក្រែន គឺចំនួនតូចៗ៣ជាច្រករបៀងតូច និងច្រករបៀងធំមានចំនួន៥ នៅលើពិភលោកដោយសារហេតុផលសង្គ្រាមឈ្លានពានរបស់ប្រទេសរុស្ស៊ីពីឆ្នាំ២០១៤ដល់២០២២។ ទិន្នន័យលំអិតមានបង្ហាញនៅក្នុងក្រាហ្វិកខាងក្រោម។

**ក្រាហ្វិក ៥៤. ចំនួនជនអន្តោប្រវេសន៍ចេញពីប្រទេសមួយទៅប្រទេសមួយទៀត**




ប្រភព៖ UN Migration, *World Migration Report 2024,* 2024, UN Migration

នៅក្នុងក្រាហ្វិក៥៥ បង្ហាញអំពីជនអន្តោរប្រវេសន៍ដែលកំពុងរស់នៅខុសពីលំនៅដ្ឋានរបស់គាត់នៅក្នុងឆ្នាំ២០២២ មានចំនួនសរុប១១៧លាននាក់។ នៅក្នុងចំណោមជនទាំងនោះ មានជនភៀសខ្លួនមានចំនួន៣៥,៣លាននាក់ អ្នកសុំសិទ្ធជ្រកកោនចំនួន៥,៤លាននាក់ អ្នកសុំសិទ្ធការពារជាពិសេសជនជាតិវេណេសូអេឡា និងអ្នករស់នៅគេចពីសង្គ្រាម ឬ អំពើហឹង្សាមានចំនួន ៦១,៥ លាននាក់ និងមូលហេតុដោយសារគ្រោះមហន្តរាយមានចំនួន៨,៧លាននាក់។

**ក្រាហ្វិក ៥៥. ចំនួនជនអន្តោប្រវេសន៍ដែលរស់នៅខុសពីលំនៅដ្ឋានរបស់ខ្លួនឆ្នាំ២០២២**




ប្រភព៖ UN Migration, *World Migration Report 2024,* 2024, UN Migration

ការផ្ញើប្រាក់ ឬ ជាវត្ថុ (Remittances) គឺជាថវិកា ឬ វត្ថុ ដែលមានតម្លៃទៅឲ្យក្រុមគ្រួសារ ឬ សហគមន៍ដែលរស់នៅក្នុងប្រទេសកំណើតរបស់ពួកគេ។ នៅក្នុងក្រាហ្វិក៥៦ បានបង្ហាញអំពីទឹកប្រាក់ ឬ វត្ថុដែលមានតម្លៃគិតជាទឹកប្រាក់ ដែលបានផ្ញើទៅក្រុមគ្រួសារ។ នៅក្នុងឆ្នាំ២០២២ ជនអន្តោប្រវេសន៍បានផ្ញើប្រាក់ប្រហែលចំនួន៨៣១ ពាន់លានដុល្លារ ច្រើនជាងឆ្នាំ២០២១ មានចំនួន ៧៩១ ពាន់លានដុល្លារ និងមានចំនួនច្រើនជាងឆ្នាំ២០២០ ខ្លាំង ដែលមានចំនួន ៧១៧ ពាន់លានដុល្លារ សម្រាប់ទូទាំងពិភពលោក។ ចំពោះប្រទេសដែលមានចំណូលទាប និងមធ្យមដែលបានផ្ញើ ឬ ផ្ទេរប្រាក់នៅឆ្នាំ២០២២ មានចំនួន ៦៤៧ ពាន់លានដុល្លារ ច្រើនជាងឆ្នាំ២០២១ ដែលមានចំនួន ៥៩៩ ពាន់លានដុល្លារ និងនៅឆ្នាំ ២០២០ ទាបជាងឆ្នាំ២០២១ ដែលមានចំនួន ៥៤០ពាន់លានដុលារ។ នៅឆ្នាំ២០១៩ ទឹកប្រាក់ដែលបានផ្ញើ ឬ ការផ្ទេរមានចំនួនច្រើជាងឆ្នាំ២០២០ ទាំងសកលលោក និងប្រទេស ដែលមានចំណូលទាប និងមធ្យម ដោយសារនៅឆ្នាំ២០២០ មានជំងឺកូវីដ១៩ រាតត្បាត។

**ក្រាហ្វិក ៥៦. ចំនួនទឹកប្រាក់ដែលបានផ្ញើទៅក្រុមគ្រួសារដែលរស់នៅក្នុងប្រទេស**




ប្រភព៖ UN Migration, *World Migration Report 2024,* 2024, UN Migration

នៅក្នុងតារាង ៤០ ខាងក្រោម បង្ហាញអំពីចំនួនប្រទេស១០ ដែលខ្ពស់ជាងគេបានផ្ញើ ឬ ទទួលប្រាក់ពីការផ្ទេរប្រាក់ពីឆ្នាំ ២០១០ ដល់២០២២។ នៅឆ្នាំ២០២២ ប្រទេសដែលបានទទួល

ប្រាក់ពីការផ្ទេរប្រាក់គឺប្រទេសឥណ្ឌាបានទទួលទឹកប្រាក់ប្រហែល១១១,២២ ពាន់លានដុល្លារ ហើយប្រទេសដែលស្ថិតក្នុងលំដាប់ទី២គឺម៉ិចស៊ិចកូ លំដាប់ទី៣ ប្រទេសចិន និងតិចជាងគេគឺប្រទេសអាល្លឺម៉ង់។ នៅឆ្នាំ២០២២នេះដែរ ចំពោះប្រទេសដែលបានផ្ទេរប្រាក់ទៅឲ្យក្រុមគ្រួសារ ឬសហគមន៍ច្រើនជាងគេគឺមានទឹកប្រាក់៧៩,១៥ ពាន់លានដុល្លារ ប្រទេសអារ៉ាប៊ីសាអូឌីតស្ថិតក្នុងលំដាប់លេខ២ ដែលមានទឹកប្រាក់ចំនួន៣៩,៣៥ពាន់លានដុល្លារ និងតិចជាងគេគឺប្រទេសកាតាដែលមានទឹកប្រាក់ចំនួន១២,២៩ ពាន់លានដុល្លារ នៅក្នុងចំណោមប្រទេសទាំង១០ ដែលបានរៀបរាប់។ ទិន្នន័យតាមបណ្ដាឆ្នាំ មានបង្ហាញជូននៅក្នុងតារាងខាងក្រោម។

តារាង ៤០. ប្រទេសចំនួន១០ដែលបានទទួលនិងផ្ញើប្រាក់ដោយសមាជិកគ្រួសារជាជនអន្តោប្រវេសន៍នៅក្រៅប្រទេស (២០១៩ដល់២០២២) គិតជាប៊ីលានដុល្លារ

(Top 10 countries receiving/sending international remittances (2010–2022) (current USD billion))

| Top countries receiving remittances | | | | | | | |
|---|---|---|---|---|---|---|---|
| 2010 | | 2015 | | 2020 | | 2022 | |
| India | 53.48 | India | 68.91 | India | 83.15 | India | 111.22 |
| China | 52.46 | China | 63.94 | China | 59.51 | Mexico | 61.10 |
| Mexico | 22.08 | Philippines (the) | 29.80 | Mexico | 42.88 | China | 51.00 |
| Philippines (the) | 21.56 | Mexico | 26.23 | Philippines (the) | 34.88 | Philippines (the) | 38.05 |
| France | 19.90 | France | 24.07 | Egypt | 29.60 | France | 30.04 |
| Nigeria | 19.75 | Nigeria | 20.63 | France | 28.82 | Pakistan | 29.87 |
| Germany | 12.79 | Pakistan | 19.31 | Pakistan | 26.09 | Egypt | 28.33 |
| Egypt | 12.45 | Egypt | 18.33 | Bangladesh | 21.75 | Bangladesh | 21.50 |
| Belgium | 10.99 | Germany | 15.57 | Germany | 19.32 | Nigeria | 20.13 |
| Bangladesh | 10.85 | Bangladesh | 15.30 | Nigeria | 17.21 | Germany | 19.29 |

| Top countries sending remittances | | | | | | | |
|---|---|---|---|---|---|---|---|
| 2010 | | 2015 | | 2020 | | 2022 | |
| United States | 50.53 | United States | 60.72 | United States | 66.54 | United States | 79.15 |
| Saudi Arabia | 27.07 | United Arab Emirates | 40.70 | United Arab Emirates | 43.35 | Saudi Arabia | 39.35 |
| Russian Federation | 21.45 | Saudi Arabia | 38.79 | Saudi Arabia | 34.60 | Switzerland | 31.91 |
| Switzerland | 18.51 | Switzerland | 26.03 | Switzerland | 29.64 | Germany | 25.60 |
| Germany | 14.68 | Russian Federation | 19.69 | Germany | 22.45 | China | 18.26 |
| Italy | 12.88 | Germany | 18.25 | China | 18.30 | Kuwait | 17.74 |
| France | 12.03 | Kuwait | 15.20 | Kuwait | 17.36 | Luxembourg | 15.51 |
| Kuwait | 11.86 | France | 12.79 | Russian Federation | 16.87 | Kingdom of the Netherlands (the) | 15.41 |
| Luxembourg | 10.66 | Qatar | 12.19 | France | 14.78 | France | 14.44 |
| United Arab Emirates | 10.57 | Luxembourg | 11.23 | Kingdom of the Netherlands (the) | 14.31 | Qatar | 12.29 |

## ឃ២. ការបំលាស់ទីកន្លែងរស់នៅរបស់ប្រទេសកម្ពុជា

សូចនាករការបំលាស់ទីកន្លែងរស់នៅ ដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ គឺមានគោលបំណងចង់បង្ហាញអំពីការបំលាស់ទីកន្លែងរស់នៅរបស់ប្រជាជន ដែលភាគច្រើនគឺការផ្លាស់ប្តូរទីកន្លែងរស់នៅដោយសារបញ្ហាសេដ្ឋកិច្ច និងមូលហេតុផ្សេងៗ។ ប្រជាជនកម្ពុជាភាគច្រើន គឺជាអ្នកប្រកបរបរកសិកម្ម តែដោយសារកំណើនប្រជាជន សំណង់លំនៅដ្ឋានមានការកើនឡើង ហើយផ្ទៃដីកសិកម្មត្រូវបានរួមតូច ដោយសារការអភិវឌ្ឍន៍ផ្នែកនគរូបនីយកម្ម ប្រជាជនដែលមានចំណេះដឹងតិចតួច ដែលចេះតែធ្វើការងារកសិកម្មហើយពុំមានផ្ទៃដីគ្រប់គ្រាន់សម្រាប់ធ្វើកសិកម្ម បានស្វែងរកទីកន្លែងរស់នៅថ្មី ដែលពួកគាត់គិតថាមានភាពប្រសើរជាងមុន ជាពិសេសនៅតំបន់ប៉ៃកព្យសាន ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តដទៃទៀត។ ខេត្តកំពង់ធំ និងខេត្តសៀមរាប កាលពីមុន គឺជាខេត្តសម្បូរព្រៃឈើ ត្រី និង ដីកសិកម្មទូលំទូលាយ ព្រមទាំងមានស្ថានភាពភូមិសាស្ត្រល្អ ដល់ប្រជាជនដែលចង់ប្រកបរបរកសិកម្មអាចរស់នៅបាន។ ដូច្នេះ ប្រជាជនភាគច្រើននៅតំបន់ទំនាបកណ្តាលបានផ្លាស់ប្តូរទីកន្លែងរស់នៅតំបន់ទាំងនោះ។ ការផ្លាស់ប្តូរទីកន្លែងរស់នៅ ឬ ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនកម្ពុជា គឺត្រូវបានកំណត់ជាដំណើរការនៃការផ្លាស់ប្តូរកន្លែងរស់នៅពីទីតាំភូមិសាស្ត្រមួយទៅទីតាំងភូមិសាស្ត្រមួយទៀត។ យោងតាមអនុសាសន៍របស់អង្គការសហប្រជាជាតិ បានឲ្យគ្រប់ប្រទេសទាំងអស់លើពិភពលោក បញ្ចូលសូចនាករនេះទៅក្នុងតារាងបញ្ជីសំណួរនៃការធ្វើជំរឿនប្រជាជន ដើម្បីសិក្សាអំពីចរិតលក្ខណៈនៃការផ្លាស់ប្តូរលំនៅដ្ឋាន។ ជាក់ស្តែងផងដែរ រាជរដ្ឋាភិបាលកម្ពុជាមានទិន្នន័យ សម្រាប់ការរៀបចំគោលនយោបាយជាតិទាក់ទងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងរកវិធីសាស្ត្រណាទប់ស្កាត់ការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជន តាមរយៈការអភិវឌ្ឍ និងបង្កើតការងារនៅក្នុងស្រុក ឬ នៅទីតាំងជិតលំនៅដ្ឋានរបស់ពួកគាត់តែម្តង ។ នៅឆ្នាំ១៩៩៨ ប្រជាជនទូទាំងប្រទេសមានការផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៣១ភាគរយ ហើយបានកើនឡើង ៣៥ភាគរយនៅឆ្នាំ២០០៤ ប៉ុន្តែនៅឆ្នាំ ២០០៨ បានធ្លាក់ចុះមកត្រឹម ២៦,៥ភាគរយ និងបានកើនឡើងវិញនៅឆ្នាំ២០១៣ មានចំនួន ២៨,៩ភាគរយ និងបានធ្លាក់ចុះមកត្រឹម ២១,៥ភាគរយ នៅឆ្នាំ២០១៩។ សូចនាករនេះ ប្រសិនបើពិនិត្យឲ្យស៊ីជម្រៅ វាមានទំនាក់ទំនងទៅការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងមូលដ្ឋានផ្ទាល់ ដូចជាការងារកសិកម្មដែលជាការងារជាប្រពៃណីរបស់ប្រជាជនកម្ពុជាភាគច្រើន ដែលពួកគាត់បានធ្វើរាប់ជំនាន់មកហើយ តែដោយសារដីកសិកម្មរួមតូច ពួកគាត់ត្រូវធ្វើចំណាកស្រុកទៅតំបន់ផ្សេង ជាពិសេសតំបន់ដែលសម្បូរព្រៃឈើ ដើម្បីធ្វើកសិកម្ម ពួកគាត់ត្រូវកាប់ព្រៃឈើ រានយកដី ដែលធ្វើឲ្យប៉ះពាល់បរិស្ថាន ប៉ះពាល់ដល់ជីវចម្រុះផ្សេងៗ គួបផ្សំនឹងការបាត់បង់ព្រៃឈើស្រាប់ផងនោះ បានធ្វើឲ្យព្រៃឈើមានការបាត់បង់បន្ថែមទៀត ដែលបណ្តាលឲ្យមានការប្រែប្រួលអាកាសធាតុ ទឹកជំនន់ គ្រោះរាំងស្ងួតជាដើម។

### ក្រាហ្វិក ៥៧. ការផ្លាស់ប្តូរទីលំនៅពីមុនទូទាំងប្រទេស




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជារាស្ត្រកម្ពុជា អង្កេតចន្លោះជំរឿន ឆ្នាំ២០០៤
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩។

ស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅដ្ឋានរបស់ប្រជាជនកម្ពុជាសរុបទូទាំងប្រទេស បានថយចុះពីជាង៣0% មកត្រឹម ២២% ពីឆ្នាំ១៩៩៨ដល់ឆ្នាំ ២០១៩។ ចំពោះនៅតាមតំបន់ទីប្រជុំជន ភាគរយនៃការផ្លាស់ប្តូរទីលំនៅក៏មាននិន្នាការថយចុះពី៦0% មកត្រឹម៣៥% ខណៈដែលតំបន់ជនបទបានថយចុះពី២៦% មកត្រឹម ១២% ពីឆ្នាំ១៩៩៨ដល់ឆ្នាំ២០១៩។ ទិន្នន័យលម្អិតមាននៅក្នុងក្រាហ្វិក ៥៨ខាងក្រោម។

### ក្រាហ្វិក ៥៨. ការផ្លាស់ប្តូរទីលំនៅតាមតំបន់ទូទាំងប្រទេស




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩។

ក្រាហ្វិក ៥៩ បង្ហាញពីនិន្នាការនៃការផ្លាស់ប្តូរទីកន្លែងរស់នៅខុសពីមុន ដែលបច្ចុប្បន្នគាត់កំពុងរស់នៅខេត្តដែលធ្វើជំរឿន។ ផ្អែកតាមទិន្នន័យជំរឿនទូទៅប្រជាជន នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ចំនួនអ្នកដែលមានលំនៅដ្ឋានខុសពីមណ្ឌលជំរឿន នៅក្នុងតំបន់ទំនាបកណ្តាលមានចំនួនប្រហែល ១.៧៩៤.២០១នាក់ (៥៤%) តំបន់ទន្លេសាប ៩០៤.៨០៧ នាក់ (២៧%) តំបន់ខ្ពង់រាប និងភ្នំ ៣៦៣.៧៤១នាក់ (១១%) តំបន់ឆ្នេរសមុទ្រ ២៧៤.៩២០នាក់ (៨%)។

## ក្រាហ្វិក ៥៩. ការផ្លាស់ប្តូរទីលំនៅតាមតំបន់ឆ្នាំ ២០១៩




ប្រភព: របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩។

ក្រាហ្វិក ៦០. បង្ហាញអំពីស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ឆ្នាំ១៩៩៨ ឆ្នាំ២០០៨ និងឆ្នាំ២០១៩។ ខេត្តកំពង់ចាមមានអ្នកដែលផ្លាស់ប្តូរទីលំនៅពីមុន ហើយកំពុងរស់នៅក្នុងខេត្តកំពង់ចាមមានចំនួន ១៩៩.៩៤៩នាក់ ស្មើនឹង២២%នៃប្រជាជនសរុប នៅឆ្នាំ ១៩៩៨ ហើយធ្លាក់ចុះនៅឆ្នាំ២០០៨ ដែលមានចំនួន១៣៣.៩១៧នាក់ ស្មើនឹង១៤% នៃប្រជាជនសរុប និងបន្តធ្លាក់ចុះនៅឆ្នាំ២០១៩ ដែលមានចំនួន ៨១.៦៦៨នាក់ ស្មើនឹង៩%។ ខេត្តត្បូងឃ្មុំមានអ្នកដែលផ្លាស់ប្តូរទីលំនៅពីមុន ហើយកំពុងរស់នៅក្នុងខេត្តខេត្តត្បូងឃ្មុំមានចំនួន ១៨៦.៧២៦នាក់ ស្មើនឹង២៧%នៃប្រជាជនសរុប ហើយបានធ្លាក់ចុះមកត្រឹមចំនួន ៩៨.៣១០នាក់ស្មើនឹង១៤% នៃប្រជាជនសរុបនៅឆ្នាំ២០០៨ និងបន្តធ្លាក់ចុះមកត្រឹមចំនួន ៨៣.៧០៤នាក់ ស្មើនឹង១៤%នៃប្រជាជនសរុបនៅឆ្នាំ២០១៩។

## ក្រាហ្វិក ៦០. ការផ្លាស់ប្តូរទីលំនៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩។

នៅក្នុងឆ្នាំ ១៩៩៨, ឆ្នាំ២០០៨ និង ឆ្នាំ២០១៩ មូលហេតុចម្បងនៃការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជនមានចំនួនច្រើនជាងគេ នៅក្នុងចំណោមមូលហេតុដទៃទៀតនៃការផ្លាស់ប្តូរលំនៅដ្ឋាន។ នៅឆ្នាំ១៩៩៨ មូលហេតុគ្រួសារផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៣៧,០ ភាគរយ បានកើនឡើងដល់ ៣៧,៩ភាគរយ នៅឆ្នាំ២០០៨ និងកើនឡើងដល់ ៣៨,៩ភាគរយ នៅឆ្នាំ២០១៩ ។ មូលហេតុរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ ២០១៩ មានចំនួនច្រើនជាង ឆ្នាំ ២០០៨ ចំនួន ៥,១ ភាគរយ ហើយមូលហេតុ កូនកំព្រាក៏មានចំនួនថយចុះពី ៥,៦ ភាគរយ នៅឆ្នាំ ២០០៨ ថយមកត្រឹម ០,២ ភាគរយ នៅឆ្នាំ ២០១៩។ មូលហេតុនៃការស្វែងរកការងារធ្វើបានធ្លាក់ចុះបន្តិចនៅឆ្នាំ ២០០៨ មានចំនួន ២១,៥ភាគរយ បានធ្លាក់ចុះមកត្រឹម ១៩,៦ ភាគរយនៅឆ្នាំ២០១៩ ខណៈនៅឆ្នាំ១៩៩៨ មានចំនួន ១៤,៥ ភាគរយ។ មូលហេតុផ្សេងៗ គឺបានបញ្ចូលនូវមូលហេតុផ្លាស់លំនៅដ្ឋានក្រៅពីមូលហេតុរៀបរាប់ខាងលើ នៅឆ្នាំ១៩៩៨ មានចំនួន ២៥ភាគរយ បានថយចុះមកត្រឹម១៣,៩ភាគរយនៅឆ្នាំ២០០៨ និងបន្តថយចុះមកត្រឹម៨,៦ភាគរយនៅឆ្នាំ២០១៩។

### ក្រាហ្វិក ៦១. មូលហេតុនៃការផ្លាស់ប្តូរទីលំនៅសម្រាប់ទូទាំងប្រទេស




ប្រភពៈ លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨, ឆ្នាំ២០០៨ និង ឆ្នាំ២០១៩

ក្រាហ្វិក ៦២ បានបង្ហាញថា មូលហេតុនៃការផ្លាសប្តូរទីលំនៅនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០១៩។ ខេត្តកំពង់ចាមនៅឆ្នាំ១៩៩៨ ដែលមានប្រជាជនចំនួន ១៩៩.៩៤៩នាក់បានធ្វើការផ្លាស់ប្តូរទីទីកន្លែងរស់នៅ ហើយបានមករស់នៅក្នុងខេត្តកំពង់ចាម ដោយសារមូលហេតុផ្សេងៗ។ ខេត្តកំពង់ចាមនៅក្នុងឆ្នាំ២០១៩មានប្រជាជនដែលបានផ្លាស់ប្តូរទីកន្លែងរស់នៅ ដោយសារមូលហេតុផ្សេង២មានចំនួន៨១.៦៦៨នាក់។ មូលហេតុដោយសារផ្លាស់ប្តូរទីកន្លែងការងារពីឆ្នាំ១៩៩៨ ដល់ ២០១៩ បានកើន២% ខណៈដែលមូលហេតុដោយសារការរៀបអាពាហ៍ពិពាហ៍មានបានឡើង២៣% និងគ្រួសារផ្លាស់ប្តូរលំនៅដ្ឋានបានថយចុះ៦% បើប្រៀបធៀបពីឆ្នាំ១៩៩៨ដល់ឆ្នាំ២០១៩។ ការផ្លាស់ប្តូរទីកន្លែងរស់នៅដោយសារមូលហេតុផ្សេងៗដែលរួមមានដូចជា មាតុភូមិនិវត្តន៍ គ្រោះមហន្តរាយ អសន្តិសុខ សួរសុខទុក្ខគ្រួសារពេលជំរឿន បាត់បង់ដីធ្លី បានថយចុះចំនួន១៤% ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០១៩ និងមូលហេតុដោយសារការស្វែងរកការងារធ្វើបានថយចុះ៦%។

ខេត្តត្បូងឃ្មុំចំនួនប្រជាជនផ្លាស់ប្តូរទីកន្លែងរស់នៅឆ្នាំ១៩៩៨ មានចំនួន និងឆ្នាំ២០១៩ មានចំនួន ៨៣.៧០៤នាក់។ មូលហេតុដោយសារប្តូរទីកន្លែងការងារបានកើនឡើង៥% ពីឆ្នាំ ១៩៩៨ ដល់២០១៩ ខណៈដែលមូលហេតុរៀបអាពាហ៍ពិពាហ៍បានកើន១៧% ជាងពាក់កណ្តាល និងគ្រួសារផ្លាស់ប្តូរលំនៅដ្ឋានកើនឡើង១១% បើប្រៀបធៀបពីឆ្នាំ១៩៩៨ដល់២០១៩។ ចំពោះមូលហេតុផ្សេងៗបានថយចុះ៣៧% ខណៈដែលមូលហេតុដោយសារការស្វែងរកការងារមិនមានការផ្លាស់ បើប្រៀបធៀបពីឆ្នាំ១៩៩៨ដល់២០១៩។

### ក្រាហ្វិក ៦២. មូលហេតុនៃការផ្លាស់ប្តូរទីលំនៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ



## ខ. ការងារ និងសេដ្ឋកិច្ច




ការងារ និងសេដ្ឋកិច្ច នឹងត្រូវបានលើកយកមកបង្ហាញអំពីសកម្មភាពពលកម្ម និងការងាររបស់ប្រជាជនកម្ពុជា ដែលជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំគោលនយោបាយសេដ្ឋកិច្ច និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្សេងៗ។ គោលបំណងសំខាន់គឺធ្វើចំណាត់ថ្នាក់ប្រជាជនទាក់ទងអ្នកមានការងារធ្វើ អត់ការងារធ្វើ ជនសកម្មសេដ្ឋកិច្ច និងជនអសកម្មសេដ្ឋកិច្ច។ អ្នកមានការងារធ្វើសំដៅអ្នកដែលបានធ្វើការងារចាប់ពី៦ខែ ឡើង ហើយផ្ទុយទៅវិញបើអ្នកធ្វើការងារតិចជាងនេះ និងកំពុងរកការងារធ្វើត្រូវបានចាត់ទុកអ្នកគ្មានការងារធ្វើ។ ជនសកម្មសេដ្ឋកិច្ច គឺជាចំនួនសរុបនៃជនមានការងារធ្វើ និងជនអត់ការងារធ្វើ ខណៈដែលជនអសកម្មសេដ្ឋកិច្ចគឺរាប់បញ្ចូលអ្នកធ្វើការជាមេផ្ទះ សិស្ស និស្សិត អ្នកនៅក្នុងបន្ទុក អ្នកទទួលប្រាក់ចំណូលផ្សេងៗជាដើម។ ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានឆ្លុះបញ្ចាំងតាមវិស័យនីមួយៗក្នុងនោះរួមមាន វិស័យកសិកម្ម ឧស្សាហកម្ម និងវិស័យសេវាកម្ម។

### ខ១. ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

ស្ថានភាពសេដ្ឋកិច្ចកម្ពុជា គឺបានឆ្លុះបញ្ចាំងតាមរយៈផលិតផលក្នុងស្រុកសរុប (GDP) និងចំណូលសម្រាប់មនុស្សម្នាក់ និងកត្តាផ្សេងៗទៀតដូចជាស្ថានភាពគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុជាដើម។ ផលិតផលក្នុងស្រុកសរុប (GDP) គឺមានការចូលរួមចំណែកពីវិស័យ

៣សំខាន់រួមមានវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ព្រមទាំងរួមបញ្ចូលពន្ធដារលើផលិតផលមួយចំនួនដែលរាជរដ្ឋាភិបាលត្រូវចេញជំនួស។ ក្រាហ្វិក ១៨ ផលិតផលក្នុងស្រុកសរុប (GDP) បានបង្ហាញថា បានកើនឡើងពីចំនួនប្រហែល២.២១៥ លានដុល្លារ កើនឡើងដល់ចំនួនប្រហែល៥១.៤០៤ លានដុល្លារ ពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០២៥។

**ក្រាហ្វិក ៦៣. ផលិតផលក្នុងស្រុកសរុប (GDP) គិតជាលានដុល្លារ**




ប្រភព៖ - វិទ្យាស្ថានជាតិស្ថិតិ (www.nis.gov.kh) 2025.
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ថវិកាសង្ខេបឆ្នាំ២០២៣
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ថវិកាសង្ខេបឆ្នាំ២០២៤
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ថវិកាសង្ខេបឆ្នាំ២០២៥

ក្រាហ្វិក ៦៤. បង្ហាញពីចំណូលសម្រាប់មនុស្សម្នាក់គិតជាមធ្យម (GDP Per Capita) គិតជាដុល្លារ។ ចំណូលសម្រាប់មនុស្សម្នាក់គិតជាមធ្យម (GDP Per Capita) គឺឆ្លុះបញ្ចាំងអំពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាពីឆ្នាំ ១៩៩៣ ដល់ ឆ្នាំ២០២៥។ និន្នាការជារួម ចំណូលសម្រាប់មនុស្សម្នាក់គិតជាមធ្យម គឺមានការកើនឡើងពី២៣៤ ដុល្លារនៅឆ្នាំ១៩៩៣ កើនឡើងដល់ ២.៩២៤ ដុល្លារសម្រាប់មនុស្សម្នាក់។ និន្នាការនេះ បានឆ្លុះបញ្ចាំងឲ្យឃើញថា ជីវភាពរបស់ប្រជាជនកម្ពុជាមានជីវភាពកាន់តែប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

ក្រាហ្វិក ៦៤. ចំណូលសម្រាប់មនុស្សម្នាក់គិតជាមធ្យម (GDP Per Capita) គិតជាដុល្លារ




ប្រភព៖ - វិទ្យាស្ថានជាតិស្ថិតិ (www.nis.gov.kh) 2025.
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ថវិកាសង្ខេបឆ្នាំ២០២៣
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ថវិកាសង្ខេបឆ្នាំ២០២៤
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ថវិកាសង្ខេបឆ្នាំ២០២៥

## ១២. ជនសកម្មសេដ្ឋកិច្ច និងអសកម្មជនសេដ្ឋកិច្ច

នៅក្នុងរបាយការណ៍នេះបង្ហាញជូននូវជនសកម្មសេដ្ឋកិច្ច និងអសកម្មជនសេដ្ឋកិច្ច ដែលមានអាយុ៧ឆ្នាំឡើង។ ជនសកម្មសេដ្ឋកិច្ច គឺសំដៅដល់ជនដែលអាយុចាប់ពី៧ឆ្នាំឡើង ដែលមានការងារធ្វើ និង គ្មានការងារធ្វើ។ ជនដែលមានការងារធ្វើសំដៅដល់ជនទាំងឡាយណា ដែលបានធ្វើការងារចាប់ពី៦ខែឡើងទៅ ក្នុងរយៈពេល១ឆ្នាំកន្លងទៅ នៅក្នុងវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។ ចំពោះជនដែលគ្មានការងារធ្វើ គឺសំដៅជនដែលបានធ្វើការងារតិចជាង៦ខែ និងជនដែលគ្មានការងារសោះ ហើយកំពុងស្វែងរកការងារ តែមិនមានការងារណាមួយដែលខ្លួនទទួលបានក្នុងរយៈពេលមួយឆ្នាំកន្លងទៅ។ អសកម្មជនសេដ្ឋកិច្ច គឺជាជនដែលធ្វើការងារផ្ទះ សិស្ស អ្នកនៅក្នុងបន្ទុក អ្នកទទួលការប្រាក់ និងជនប្រភេទផ្សេងៗដែលមិនមានសកម្មភាពសេដ្ឋកិច្ច។

តារាង ៣៨ បង្ហាញថា នៅទូទាំងប្រទេសចំនួនអ្នកមានការងារធ្វើនៅឆ្នាំ១៩៩៨ មាន៤,៨ លាននាក់ ស្មើនឹង ៥៣% បានកើនឡើងដល់៨,៦លាននាក់ ស្មើនឹង៦៤% ធៀបនឹងចំនួនប្រជជនសរុបដែលមានអាយុ៧ឆ្នាំឡើងតាមបណ្តាឆ្នាំ។ ចំពោះតំបន់ទំនាបកណ្តាលអ្នកមានការងារធ្វើនៅឆ្នាំ ១៩៩៨មានចំនួន២,៥លាននាក់ ស្មើនឹង៥៣% បានកើនដល់៤,៣លាននាក់ ស្មើនឹង៦៤% ខណៈ

ដែលខេត្តកំពង់ចាមអ្នកមានការងារធ្វើនៅឆ្នាំ១៩៩៨ មានចំនួន៤០៧ ពាន់នាក់ ស្មើនឹង៥៤% បានកើនដល់ ៤៩០ពាន់នាក់ ស្មើនឹង៦៣% នៅឆ្នាំ២០១៩ និងខេត្តត្បូងឃ្មុំអ្នកមានការងារធ្វើនៅឆ្នាំ១៩៩៨ មានចំនួន២៩០ពាន់នាក់ ស្មើនឹង៥៣% បានកើនដល់៤២១ពាន់នាក់ស្មើនឹង៦៣% នៅឆ្នាំ២០១៩។ នៅទូទាំងប្រទេសចំនួនអ្នកគ្មានការងាធ្វើនៅឆ្នាំ១៩៩៨ មានចំនួន២៧៣ពាន់នាក់ ស្មើនឹង៣% បានថយចុះមកត្រឹមចំនួន១២២ពាន់នាក់ស្មើនឹង០,៩% ខណៈដែលតំបន់ទំនាបកណ្តាលអ្នកគ្មានការងារធ្វើមានចំនួន១៣៩ ពាន់នាក់ស្មើនឹង២,៩% បានថយចុះមកត្រឹម៤៥ពាន់នាក់ស្មើនឹង០,៧% ។ នៅខេត្តកំពងចាមអ្នកគ្មានការងារធ្វើមានចំនួន១៤,៦ពាន់នាក់ ស្មើនឹង១,៩% នៅឆ្នាំ១៩៩៨ បានថយចុះមកត្រឹម៤,៧ ពាន់នាក់ស្មើនឹង០,៦%នៅឆ្នាំ២០១៩ និងខេត្តត្បូងឃ្មុំអ្នកគ្មានការងារធ្វើមានចំនួន១៦,៧ពាន់នាក់ស្មើនឹង៣% បានថយចុះមកត្រឹម៦,២ ពាន់នាក់ស្មើនឹង០,៩% បើប្រៀបធៀបនឹងចំនួនប្រជាជនសរុបដែលមានអាយុ៧ឆ្នាំឡើងតាមបណ្តាឆ្នាំនីមួយៗ។ នៅទូទាំងប្រទេសជនអសកម្មសេដ្ឋកិច្ចបានថយចុះពី៤៥% មកត្រឹម៣៥% ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០១៩ ខណៈដែលតំបន់ទំនាបកណ្តាលបានថយចុះពី៤៥% មកត្រឹម៣៦% ពីឆ្នាំដូចខាងលើដែរ។ នៅក្នុងខេត្តកំពង់ចាមជនអសកម្មសេដ្ឋកិច្ចបានថយចុះពី៤៤% មក៣៧% ពីឆ្នាំ១៩៩៨ដល់ឆ្នាំ២០១៩ ខណៈដែលខេត្តត្បូងឃ្មុំថយចុះពី៤៤% មកត្រឹម៣៥% ពីឆ្នាំ១៩៩៨ ដល់២០១៩ (តារាង ៤១ ក្រាហ្វិក ៦៥និងក្រាហ្វិក៦៦។

**តារាង ៤១. អ្នកមានការងារធ្វើ អ្នកគ្មានការងារធ្វើ និងអសកម្មជនសេដ្ឋកិច្ចដែលមានអាយុ៧ឆ្នាំឡើង**

| កម្ពុជា/តំបន់/ខេត្ត | ឆ្នាំ | អ្នកមានការងារធ្វើ | អ្នកគ្មានការងារធ្វើ | ជនអសកម្មសេដ្ឋកិច្ច | សរុប |
|---|---|---|---|---|---|
| កម្ពុជា | 1998 | 4,844,696 | 273,183 | 4,107,742 | 9,225,621 |
| | 2008 | 6,933,612 | 118,152 | 4,383,352 | 11,435,116 |
| | 2019 | 8,623,431 | 121,743 | 4,742,417 | 13,487,591 |
| ទំនាបកណ្តាល | 1998 | 2,533,456 | 139,303 | 2,151,216 | 4,823,975 |
| | 2008 | 3,419,607 | 68,297 | 2,178,422 | 5,666,326 |
| | 2019 | 4,271,502 | 45,652 | 2,371,976 | 6,689,130 |
| កំពង់ចាម | 1998 | 406,824 | 14,553 | 332,097 | 753,474 |
| | 2008 | 500,050 | 4,786 | 314,588 | 819,424 |
| | 2019 | 490,382 | 4,689 | 287,218 | 782,289 |
| ត្បូងឃ្មុំ | 1998 | 290,904 | 16,668 | 243,127 | 550,699 |
| | 2008 | 383,125 | 4,606 | 221,984 | 609,715 |
| | 2019 | 420,784 | 6,187 | 241,823 | 668,794 |

## ក្រាហ្វិក ៦៥. អត្រាអ្នកមានការងារធ្វើ អ្នកគ្មានការងារធ្វើ និងអសកម្មជនសេដ្ឋកិច្ច ដែលមានអាយុ៧ឆ្នាំឡើង




## ក្រាហ្វិក ៦៦. ភាគរយអ្នកគ្មានការងារធ្វើសម្រាប់ទូទាំងប្រទេស តំបន់ទំនាបកណ្ដាល និងតាមបណ្ដាខេត្តនៅក្នុងតំបន់ទំនាបកណ្ដាល




ប្រភព: លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨, ឆ្នាំ២០០៨ និង ឆ្នាំ២០១៩។

## ១៤.ការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ច

ក្រាហ្វិក ៦៧ បង្ហាញអំពីការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ច។ និន្នាការជារួម ការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យកសិកម្មនៅទូទាំងប្រទេសមានចំនួន៧៧,២% នៅឆ្នាំ១៩៩៨ បានធ្លាក់មកត្រឹម៥៤% នៅឆ្នាំ២០១៩ ខណៈដែលវិស័យឧស្សាហកម្មបានកើនឡើងពីចំនួន ៤,៤% កើនដល់ ១៨,៨% និងវិស័សេវាកម្មក៏មាននិន្នាការកើនឡើងផងដែរ ពី១៨,៤% កើនដល់ ២៦,៥% ពីឆ្នាំ១៩៩៨ ទៅឆ្នាំ២០១៩។ តំបន់ទំនាបកណ្តាល ការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យកសិកម្មមានចំនួន ៧៤,៤% នៅឆ្នាំ១៩៩៨ បានធ្លាក់មកត្រឹម ៤៥,៣% នៅឆ្នាំ២០១៩ ខណៈដែលវិស័យឧស្សាហកម្មមានការកើនឡើងពី ៥,៩% កើនដល់ ២២,៧% និងវិស័យសេវាកម្មបានកើនឡើងពី១៩,៧% កើនដល់៣២% ពីឆ្នាំ១៩៩៨ ទៅឆ្នាំ២០១៩។ ខេត្តកំពង់ចាម ការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យកិសិកម្មមានចំនួន៨៤% នៅឆ្នាំ១៩៩៨ បានធ្លាក់ចុះមកត្រឹម ៦៤%នៅឆ្នាំ២០១៩ ខណៈដែលវិស័យឧស្សាហកម្មមានការកើនឡើងពី៣% កើនដល់ ១៧% និងវិស័យសេវាកម្មបានកើនឡើងពី១៣% កើនដល់១៩% ពីឆ្នាំ១៩៩៨ ទៅឆ្នាំ២០១៩។ ខេត្តត្បូងឃ្មុំ ការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យកសិកម្មមានចំនួន៨៧% នៅឆ្នាំ១៩៩៨ បានធ្លាក់មកត្រឹម ៧៨% នៅឆ្នាំ២០១៩ ខណៈដែលវិស័យឧស្សាហកម្មមានការកើនឡើងពី ២% កើនដល់ ៥% និងវិស័យសេវាកម្មបានកើនឡើងពី១១% កើនដល់១៧%ពីឆ្នាំ១៩៩៨ ទៅឆ្នាំ២០១៩។

**ក្រាហ្វិក ៦៧. ភាគរយការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ច**




ប្រភព: លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្រ្តរបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨, ឆ្នាំ២០០៨ និង ២០១៩។

ក្រាហ្វិក៦៧ខាងលើ បានបង្ហាញអំពី ភាគរយនៃការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យសេដ្ឋកិច្ចសម្រាប់ទូទាំងប្រទេស តំបន់ទំនាបកណ្តាល ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំពីឆ្នាំ១៩៩៨ ដល់២០១៩។ តារាង ៤២ បង្ហាញអំពីចំនួនអ្នកចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចនៅទូទាំងប្រទេស តំបន់ទំនាបកណ្តាល និងខេត្តទាំង៧ ដែលស្ថិតនៅក្នុងតំបន់ទំនាបកណ្តាលក្នុងនោះមានខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំផងដែរ។ ទិន្នន័យលំអិតមានដូចតារាងខាងក្រោម។

**តារាង ៤២. ចំនួនអ្នកចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច**

| រាជធានីខេត្ត | វិស័យកសិកម្ម | | | វិស័យឧស្សាហកម្ម | | | វិស័យសេវាកម្ម | | |
|---|---|---|---|---|---|---|---|---|---|
| | 1998 | 2008 | 2019 | 1998 | 2008 | 2019 | 1998 | 2008 | 2019 |
| កម្ពុជា | 3,769,956 | 5,027,359 | 4,729,657 | 216,248 | 597,008 | 1,629,370 | 897,418 | 1,335,013 | 2,295,740 |
| តំបន់វាលទំនាប | 1,898,482 | 2,267,276 | 1,938,747 | 150,279 | 411,791 | 971,914 | 501,915 | 754,400 | 1,369,039 |
| កំពង់ចាម | 343,155 | 403,903 | 317,185 | 13,220 | 24,514 | 81,905 | 50,467 | 73,515 | 93,294 |
| កណ្តាល | 351,716 | 413,111 | 279,153 | 29,287 | 128,800 | 219,357 | 78,335 | 129,027 | 189,623 |
| ភ្នំពេញ | 37,023 | 34,357 | 56,136 | 87,615 | 210,257 | 389,756 | 255,122 | 401,218 | 805,400 |
| ព្រៃវែង | 404,209 | 457,949 | 464,751 | 5,725 | 12,188 | 49,650 | 37,884 | 46,169 | 71,979 |
| ស្វាយរៀង | 198,986 | 231,076 | 179,148 | 1,859 | 10,209 | 80,649 | 19,231 | 28,411 | 52,191 |
| តាកែវ | 310,551 | 388,868 | 314,304 | 6,040 | 16,761 | 128,109 | 28,260 | 38,433 | 85,293 |
| ត្បូងឃ្មុំ | 252,842 | 338,012 | 328,070 | 6,533 | 9,062 | 22,488 | 32,616 | 37,627 | 71,259 |

ប្រភព: លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨, ឆ្នាំ២០០៨ និង ២០១៩។

សរុបសេចក្តីមក ភាគរយនៃនិន្នាការរួមនៃការចូលរួមកម្លាំងពលកម្មក្នុងវិស័យកសិកម្មបានថយចុះ ហើយវិស័យឧស្សាហកម្ម និងសេវាកម្មមានការកើនឡើង។ ទាំងនេះឆ្លុះបញ្ចាំងឲ្យឃើញថា វិស័យកសិកម្មបានថយចុះអាចបណ្តាលមកពីហេតុផលជាច្រើន ដែលក្នុងនោះអាចទាក់ទងហេតុផលនៃគ្រោះរាំងស្ងួត ការប្រែប្រួលអាកាសធាតុ និងតម្លៃកសិផលមានតម្លៃទាបជាដើម។ លើសពីនេះទៀត ផ្ទៃដីកសិកម្មមួយចំនួនបានបង្វែរជាដីលំនៅឋានដោយសារអត្រាកំណើនប្រជាជន និងដីសាងសង់សំណង់សម្រាប់បំរើវិស័យឧស្សាហកម្ម និងសេវាកម្ម។

ការកើនឡើងឡើងនៃវិស័យឧស្សាហកម្ម និងសេវាកម្ម អាចធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន ប្រសិនបើការគ្រប់គ្រងបរិស្ថានមិនបានហ្មត់ចត់ទេនោះ។

## ៣.១.២ ទីប្រជុំជន គ្រួសារ អគារ និងលំនៅដ្ឋាន



## គ. ទីប្រជុំជន

### គ១. និន្នាការប្រជាជនពិភពលោកដែលរស់នៅទីប្រជុំជន

តំបន់ទីប្រជុំជន ការបង្កើតបានជាតំបន់ទីប្រជុំជនមួយដោយការប្រមូលផ្តុំទីប្រជុំជនតូចៗ ដែលមានទីតាំងជាប់គ្នា គឺសំដៅលើលំនៅដ្ឋានដែលមានប្រជាជនរស់នៅ និងមានដង់ស៊ីតេប្រជាជនខ្ពស់ និងមានការកសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ តំបន់ទីប្រជុំជនត្រូវបានបង្កើតតាមរយៈការធ្វើនគរូបនីយកម្ម និងត្រូវបានចាត់តាមចំណាត់ថ្នាក់មានដូចជាទីក្រុង ទីប្រជុំជន និងតំបន់ជាយក្រុង។ ការកំណត់និយមន័យនៃតំបន់ទីប្រជុំជនក៏ត្រូវបានកំណត់និយមន័យខុសៗគ្នា ទៅតាមស្ថានភាពប្រជាសាស្ត្រ និង លក្ខណៈសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ។ ចំនួនប្រជាជនជាង ៤,៤ពាន់លាននាក់ ដែលកំពុងរស់នៅក្នុងតំបន់ទីប្រជុំជន ស្មើនឹង ៥៦,៥៨%[1]ក្នុងឆ្នាំ២០២១។ ក្រាហ្វិក ២៥ បង្ហាញអំពីនិន្នាការចំនួនប្រជាជនសរុប និងចំនួនប្រជាជនរស់នៅទីប្រជុំជនទូទាំងពិភពលោក ពីឆ្នាំ២០០០ ដល់ ២០៣៥។ តាមនិន្នាការនេះ បានបង្ហាញថា ចំនួនប្រជាជនដែលរស់នៅទីប្រជុំជននឹងកើនឡើង ពី ៣ ពាន់លាននាក់ នៅឆ្នាំ២០០០ កើនដល់ជាង៥ ពាន់លាននាក់ ស្មើនឹង ៦៣% នៃចំនួនប្រជាជនសរុបទូទាំងពិភពលោកនៅឆ្នាំ២០៣៥ ខាងមុខ (ក្រាហ្វិក៦៨)។

**ក្រាហ្វិក ៦៨. និន្នាការចំនួនប្រជាជនសរុប និងចំនួនប្រជាជនរស់នៅទីប្រជុំជន ទូទាំងពិភពលោក (គិតជាពាន់នាក់)**




ប្រភព÷ United Nations, Department of Economic and Social Affairs, Population Division (2022*). World Population Prospects 2022*, Online Edition

[1] © 2010-2022 Macrotrends LLC*, World Urban Population 1960-2022* , [website], 2022, https://www.macrotrends.net/countries/WLD/world/urban-population, (accessed 12 January 2022).

## ក២. និន្នាការប្រជាជនកម្ពុជាដែលរស់នៅទីប្រជុំជន

ការកើនឡើងនូវនគរូបនីយកម្ម នៅលើពិភពលោកបានធ្វើឲ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងសម្រាប់ពិភពលោកនិងតាមប្រទេសនីមួយៗ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានកែសម្រួលតំបន់រដ្ឋបាលជាញឹកញាប់ ចាប់តាំងពីឆ្នាំ ១៩៩៨ មកទល់បច្ចុប្បន្ន។ ការកែសម្រួលតំបន់រដ្ឋបាលនេះ ក៏ជាកត្តាមួយដែលធ្វើឲ្យមានការកើនឡើងនូវតំបន់ទីប្រជុំជន ដោយសារតំបន់មួយចំនួនក្លាយជាក្រុង ដែលគោលដៅសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគ្រប់ផ្នែក និងលំនៅដ្ឋានទៀតផង។ ដូច្នេះផ្ទៃដីស្រែមួយចំនួនត្រូវបានបង្វែរមុខងារពីដីកសិកម្មទៅជាដីសម្រាប់ការសាងសង់នៅពេលអនាគត។ កន្លងមកការកំណត់តំបន់ទីប្រជុំជនពុំមាននិយមន័យច្បាស់លាស់នៅឡើយទេ ។ នៅឆ្នាំ១៩៩៨ ទីប្រឹក្សាជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ បានកំណត់ស្រុកដែលស្ថិតក្នុងទីរួមខេត្តជាទីប្រជុំជន ។ នៅឆ្នាំ ២០០៤ ជំនាញការរបស់មូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជននៅឆ្នាំ២០០៤ បានកំណត់និយមន័យទីប្រជុំជនដោយកំណត់យក ៣ លក្ខខណ្ឌគឺ៖

១) ចំនួនប្រជាជនទាបបំផុតចាប់ពី ២.០០០ នាក់ឡើង ក្នុងមួយឃុំ

២) ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េចាប់ពី ២០០នាក់ ឡើង

៣) ភាគរយបុរសធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ

នៅឆ្នាំ២០១១ និយមន័យលក្ខខណ្ឌទីប្រជុំជនបានកែសម្រួលនៅលក្ខខណ្ឌទី៣ គឺ ភាគរយបុរសធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ ទៅជាភាគរយប្រជាជនទាំងពីរភេទធ្វើការនៅក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ ហើយលក្ខខណ្ឌទី១ និង លក្ខខណ្ឌទី២គឺរក្សានៅដដែល។ លក្ខខណ្ឌដែលបានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០១១ រួមមាន៖

១) ចំនួនប្រជាជនទាបបំផុតចាប់ពី ២.០០០ នាក់ឡើង ក្នុងមួយឃុំ

២) ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េចាប់ពី ២០០នាក់ ឡើង

៣) ភាគរយចំនួនប្រជាជនទាំងពីរភេទធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ

ក្រាហ្វិក ៦៩ បង្ហាញថា ភាគរយចំនួនប្រជាជនរស់នៅទីប្រជុំជននៅលើពិភពលោក និងចំនួនប្រជាជនរស់នៅទីប្រជុំជនកម្ពុជា។ ភាគរយចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជននៅទូទាំងពិភពលោកនៅឆ្នាំ២០១៩ មានចំនួន ៥៥,៧% និងភាគរយចំនួនប្រជាជនរស់នៅទីប្រជុំជនមានចំនួន ៣៩,៤%។ បើប្រៀបធៀបភាគរយចំនួនប្រជាជនដែលរស់នៅទីប្រជុំជនទូទាំងពិភពលោក និងភាគរយចំនួនប្រជាជនដែលរស់នៅទីប្រជុំជនសម្រាប់ប្រទេសកម្ពុជាគឺ ភាគរយចំនួនប្រជាជនដែលរស់នៅទីប្រជុំជនទូទាំងពិភពលោក មានចំនួនភាគរយខ្ពស់ជាងភាគរយប្រជាជនដែលរស់នៅទីប្រជុំជន

របស់កម្ពុជាចំនួនប្រហែល១៦% ក្នុងឆ្នាំដូចគ្នា។ នៅឆ្នាំ ២០៣៥ ភាគរយប្រជាជនរស់នៅទីប្រជាជនសម្រាប់ពិភពលោកនឹងកើនដល់៦៣% ខណៈដែលកម្ពុជាអាចកើនដល់៤៤% (ក្រាហ្វិក៦៩)។

**ក្រាហ្វិក ៦៩. ភាគរយចំនួនប្រជាជនរស់នៅទីប្រជុំជននៅលើពិភពលោក និងចំនួនប្រជាជនរស់នៅទីប្រជុំជនកម្ពុជា**




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣
- របាយការណ៍ការជាតិស្ដីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩
- United Nations, Department of Economic and Social Affairs, Population Division (2022). World Population Prospects 2022, Online Edition.
- Population Projection in Cambodia 2020.

នៅក្នុងក្រាហ្វិក ៧០. បង្ហាញអំពីភាគរយនៃចំនួនប្រជាជន ដែលរស់នៅតំបន់ទីប្រជុំជន។ និន្នាការជារួមគឺមានការកើនឡើង ជាក់ស្តែងចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជនបានកើនឡើងពី ១៦ ភាគរយនៅឆ្នាំ១៩៩៨ កើនដល់ ៣៩ ភាគរយ នៅឆ្នាំ២០១៩ សម្រាប់នៅទូទាំងប្រទេសកម្ពុជា។ តំបន់ទីប្រជុំជនសម្រាប់តំបន់ទំនាបកណ្តាលដែលមានរួមបញ្ចូលខេត្តទាំង៧ មានការកើនឡើងពី២២% កើនដល់ ៤៩%ពីឆ្នាំ១៩៩៨ ដល់២០១៩ ខណៈដែលរាជធានីភ្នំពេញត្រូវបានចាត់ទុកជាតំបន់ទីប្រជុំជន១០០% មិនដូចនៅឆ្នាំ១៩៩៨ និង២០០៨ នោះទេ។ តំបន់ទីប្រជុំជននៅក្នុងខេត្តកំពង់ចាមមានចំនួន៨% កើនដល់១៥% ពីឆ្នាំ១៩៩៨ ទៅ ឆ្នាំ២០១៩ ខណៈដែលខេត្តត្បូងឃ្មុំបានកើនឡើងពី ៧% កើនដើល់៩% ពីឆ្នាំ១៩៩៨ ដល់២០១៩។ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំមុនជំរឿនឆ្នាំ២០១៩ ជាខេត្តតែមួយ។ ខេត្តកណ្តាលក៏មានកើនឡើងតំបន់ទីប្រជុំជនជិតប្រាំដងបើប្រៀបធៀបឆ្នាំ១៩៩៨ និងឆ្នាំ២០១៩។ កត្តាសំខាន់ៗនៃការកើនឡើងនៃភាគរយចំនួនប្រជាជនដោយសារកត្តាមួយចំនួនគឺកំណើន ប្រជាជន ការអភិវឌ្ឍន៍នគរូបនីយកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងការផ្លាស់ប្តូរតំបន់រដ្ឋបាល។ ម្យ៉ាងទៀត ប្រជាជនបានមករស់នៅទីប្រជុំជនដើម្បីស្វែងរកការងារធ្វើ ដែលពួកគាត់គិតថាមានលក្ខណៈល្អប្រសើរជាងកន្លែងជនបទ (ក្រាហ្វិក៧០ និងតារាង៤៣) ។

**ក្រាហ្វិក ៧០. ភាគរយចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជន**




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩។

## តារាង ៤៣. ចំនួនប្រជាជននៅតំបន់ទីប្រជុំជន

| រាជធានីខេត្ត | ចំនួនប្រជាជននៅតំបន់ទីប្រជុំជន | | | %ប្រជាជនតំបន់ទីប្រជុំជន | | |
|---|---|---|---|---|---|---|
| | 1998 | 2008 | 2019 | 1998 | 2008 | 2019 |
| **កម្ពុជា** | **1,795,575** | **2,614,027** | **6,135,194** | **15.7** | **19.5** | **39.4** |
| កំពង់ចាម | 72,959 | 98,969 | 133,632 | 7.9 | 10.3 | 14.9 |
| កណ្ដាល | 146,047 | 195,898 | 780,977 | 13.6 | 15.5 | 65.0 |
| ភ្នំពេញ | 950,373 | 1,242,992 | 2,281,377 | 95.1 | 93.6 | 100.0 |
| ព្រៃវែង | 35,304 | 33,079 | 62,563 | 3.7 | 3.5 | 5.9 |
| ស្វាយរៀង | 16,991 | 17,029 | 157,012 | 3.6 | 3.5 | 29.9 |
| តាកែវ | 13,659 | 14,456 | 286,540 | 1.7 | 1.7 | 31.8 |
| ត្បូងឃ្មុំ | 44,604 | 19,273 | 67,946 | 6.5 | 2.7 | 8.7 |
| **តំបន់ទំនាបកណ្ដាល** | **1,279,937** | **1,621,696** | **3,770,047** | **21.7** | **24.8** | **49.3** |

ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ការជាតិស្ដីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩។

## ខ. គ្រួសារ និងអគារ

សូចនាករចំនួនគ្រួសារ គឺជាសូចនាករមួយមានសារៈសំខាន់ណាស់ទាក់ទងទៅនឹងការផ្ដល់សេវាផ្សេងៗដូចជាអគ្គិសនី ទឹកស្អាត បង្គន់អនាម័យ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។ ចំនួនគ្រួសារសរុបទូទាំងប្រទេសនៅឆ្នាំ ១៩៩៨ មានចំនួន ២,១៨ លានគ្រួសារ ហើយបានកើនឡើងរហូតដល់ ៣,៥៥ លានគ្រួសារ នៅឆ្នាំ២០១៩ សម្រាប់ទូទាំងប្រទេស ខណៈដែលចំនួនអគារនៅឆ្នាំ ១៩៩៨ មានចំនួន ២,១៨ លានអគារ បានកើនដល់ ៣,៥៩លានអគារ នៅឆ្នាំ២០១៩ និងចំនួនគ្រួសារដែលមានផ្ទះផ្ទាល់ខ្លួនមានចំនួន២,០៦ លានគ្រួសារ នៅឆ្នាំ១៩៩៨ បានកើនដល់ចំនួន៣,២២ លានគ្រួសារនៅឆ្នាំ២០១៩ ។ តំបន់ទំនាបកណ្ដាលមានចំនួនអគារ១,១៤ លានអគារ នៅឆ្នាំ១៩៩៨ បានកើនដល់ចំនួន១,៧៩លានអគារ នៅឆ្នាំ២០១៩ ខណៈដែលចំនួនគ្រួសារមានចំនួន ១,១៤លានគ្រួសារនៅឆ្នាំ១៩៩៨ បានកើនដល់ ១,៧៧ លានគ្រួសារនៅឆ្នាំ២០១៩។ ខេត្តកំពង់ចាមមានចំនួនអគារចំនួន ១៨០ ពាន់អគារនៅឆ្នាំ១៩៩៨ បានកើនដល់ ២១៩ពាន់អគារនៅឆ្នាំ២០១៩ ខណៈដែលចំនួនគ្រួសារមានចំនួន១៨០ ពាន់គ្រួសារ នៅឆ្នាំ១៩៩៨ បានកើនដល់ ២១៧ ពាន់គ្រួសារនៅឆ្នាំ២០១៩ និង ចំនួនគ្រួសារដែលមានផ្ទះផ្ទាល់ខ្លួនមានចំនួន ១៦៨ ពាន់គ្រួសារ នៅឆ្នាំ១៩៩៨ បានកើនដល់ចំនួន ២០៦ ពាន់គ្រួសារនៅឆ្នាំ២០១៩។ ខេត្តត្បូងឃ្មុំមានចំនួនអគារចំនួន ១៣៣ ពាន់អគារនៅឆ្នាំ១៩៩៨ បានកើនដល់ ១៨០ពាន់អគារនៅឆ្នាំ២០១៩ ខណៈដែលចំនួនគ្រួសារមានចំនួន១៣៣ ពាន់គ្រួសារ នៅឆ្នាំ ១៩៩៨ បានកើនដល់ ១៧៩ ពាន់គ្រួសារនៅឆ្នាំ២០១៩ និង ចំនួនគ្រួសារដែលមានផ្ទះផ្ទាល់ខ្លួនមានចំនួន ១២២ ពាន់គ្រួសារ នៅឆ្នាំ១៩៩៨ បានកើនដល់ចំនួន ១៦៦ ពាន់គ្រួសារនៅឆ្នាំ២០១៩។ ទិន្នន័យលំអិតមានដូចតារាង៤៤ ក្រាហ្វិក៧១ និងក្រាហ្វិក៧២ ដូចខាងក្រោម។

## តារាង ៤៤. ចំនួនអគារ គ្រួសារ និង ចំនួនគ្រួសារដែលមានផ្ទះផ្ទាល់ខ្លួន

| រាជធានីខេត្ត | 1998 | | | 2008 | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|
| | ចំនួនអគារ | ចំនួនគ្រួសារ | ចំនួនគ្រួសារមានផ្ទះផ្ទាល់ខ្លួន | ចំនួនអគារ | ចំនួនសារ | ចំនួនគ្រួសារមានផ្ទះផ្ទាល់ខ្លួន | ចំនួនអគារ | ចំនួនគ្រួសារ | ចំនួនគ្រួសារមានផ្ទះផ្ទាល់ខ្លួន |
| កម្ពុជា | 2,188,663 | 2,188,663 | 2,060,579 | 2,841,897 | 2,841,897 | 2,598,010 | 3,593,943 | 3,553,021 | 3,222,952 |
| កំពង់ចាម | 179,521 | 179,521 | 167,977 | 214,762 | 214,762 | 199,025 | 218,929 | 217,197 | 206,371 |
| កណ្ដាល | 206,189 | 206,189 | 195,659 | 258,393 | 258,393 | 239,450 | 268,163 | 265,803 | 249,585 |
| ភ្នំពេញ | 173,678 | 173,678 | 140,560 | 260,468 | 260,468 | 183,384 | 514,655 | 499,299 | 334,212 |
| ព្រៃវែង | 194,185 | 194,185 | 189,088 | 227,137 | 227,137 | 219,424 | 268,012 | 266,934 | 260,466 |
| ស្វាយរៀង | 98,244 | 98,244 | 96,305 | 115,253 | 115,253 | 111,924 | 132,961 | 132,492 | 129,208 |
| តាកែវ | 155,030 | 155,030 | 151,725 | 184,215 | 184,215 | 180,010 | 209,583 | 208,698 | 204,823 |
| ត្បូងឃ្មុំ | 133,320 | 133,320 | 121,531 | 154,696 | 154,696 | 140,673 | 180,306 | 178,942 | 165,941 |
| តំបន់ទំនាបកណ្ដាល | 1,140,167 | 1,140,167 | 1,062,845 | 1,414,924 | 1,414,924 | 1,273,890 | 1,792,609 | 1,769,365 | 1,550,606 |

ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ការជាតិស្ដីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩។

## ក្រាហ្វិក ៧១. ចំនួនគ្រួសារ និងអគារ




ប្រភព: - របាយការណ៍លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- របាយការណ៍លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ការជាតិស្ដីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩។

ក្រាហ្វិក ៧២. ភាគរយគ្រួសារដែលមានផ្ទះផ្ទាល់ខ្លួនធៀបគ្រួសារសរុប




## គ. លំនៅដ្ឋាន

ក្រាហ្វិក ៧៣ បានបង្ហាញអំពីភាគរយគ្រួសារដែលកាន់កាប់តាមប្រភេទលំនៅដ្ឋានសម្រាប់ទូទាំងប្រទេស តំបន់ទំនាបកណ្តាល និងខេត្តទាំង៧ ដែលស្ថិតក្នុងតំបន់ទំនាបកណ្តាល។ តាមក្រាហ្វិកខាងក្រោមបានបង្ហាញឲ្យឃើញថានៅឆ្នាំ១៩៩៨ គ្រួសារជាង ៩០% មានផ្ទះផ្ទាល់ខ្លួន ទាំងទូទាំងប្រទេស តំបន់ទំនាបកណ្តាល និងខេត្ត៦ ដែលស្ថិតនៅក្នុងតំបន់ទំនាបកណ្តាលលើកលែងតែរាជធានីភ្នំពេញមានភាគរយលើស៨០% បន្តិចនៅឆ្នាំ១៩៩៨ និងនៅឆ្នាំ២០០៨ ធ្លាក់ចុះមកត្រឹម ៧០% ហើយនៅឆ្នាំ២០១៩ បានធ្លាក់ចុះមកត្រឹម ៦៧% ខណៈដែលគ្រួសារដែលរស់នៅផ្ទះជួលបានកើនឡើងពី១០% កើនដល់ជាង២០% ពីឆ្នាំ១៩៩៨ ទៅឆ្នាំ ២០០៨ ហើយបន្តកើនឡើងដល់ ៣០% នៅឆ្នាំ២០១៩។

## ក្រាហ្វិក ៧៣. ភាគរយគ្រួសារដែលកាន់កាប់តាមប្រភេទលំនៅដ្ឋាន




ប្រភព: - របាយការណ៍លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- របាយការណ៍លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩។

តារាង ៤៥. បង្ហាញអំពីចំនួនគ្រួសារដែលកាន់កាប់តាមប្រភេទលំនៅដ្ឋានឆ្នាំ១៩៩៨ ឆ្នាំ ២០០៨ និងឆ្នាំ២០១៩ សម្រាប់ទូទាំងប្រទេស តំបន់ទំនាបកណ្ដាល និងខេត្តទាំង៧នៅក្នុងតំបន់ទំនាបកណ្ដាល។

# តារាង ៤៥. ចំនួនគ្រួសារដែលកាន់កាប់តាមប្រភេទលំនៅដ្ឋាន

| រាជធានី ខេត្ត | 1998 | | | | | 2008 | | | | | 2019 | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនគ្រួសារសរុប | ផ្ទះផ្ទាល់ខ្លួន | ផ្ទះជួល | ផ្ទះជួលមិនបង់ថ្លៃ | ផ្សេងៗ | ចំនួនគ្រួសារសរុប | ផ្ទះផ្ទាល់ខ្លួន | ផ្ទះជួល | ផ្ទះជួលមិនបង់ថ្លៃ | ផ្សេងៗ | ចំនួនគ្រួសារសរុប | ផ្ទះផ្ទាល់ខ្លួន | ផ្ទះជួល | ផ្ទះជួលមិនបង់ថ្លៃ | ផ្សេងៗ |
| **កម្ពុជា** | **2,188,663** | **2,060,579** | **34,103** | **55,050** | **12,354** | **2,841,897** | **2,598,010** | **114,113** | **96,086** | **9,428** | **3,553,021** | **3,222,952** | **221,809** | **99,301** | **8,959** |
| កំពង់ចាម | 179,521 | 167,977 | 903 | 7,625 | 1,933 | 214,762 | 199,025 | 2,554 | 10,961 | 1,210 | 217,197 | 206,371 | 2,520 | 7,788 | 518 |
| កណ្តាល | 206,189 | 195,659 | 1,183 | 5,542 | 973 | 258,393 | 239,450 | 5,375 | 9,462 | 742 | 265,803 | 249,585 | 8,958 | 6,920 | 340 |
| ភ្នំពេញ | 173,678 | 140,560 | 19,346 | 6,321 | 1,531 | 260,468 | 183,384 | 60,308 | 5,932 | 973 | 499,299 | 334,212 | 153,827 | 10,377 | 883 |
| ព្រៃវែង | 194,185 | 189,088 | 473 | 2,451 | 723 | 227,137 | 219,424 | 918 | 5,472 | 498 | 266,934 | 260,466 | 1,064 | 5,113 | 291 |
| ស្វាយរៀង | 98,244 | 96,305 | 274 | 845 | 372 | 115,253 | 111,924 | 694 | 1,821 | 319 | 132,492 | 129,208 | 1,146 | 1,896 | 242 |
| តាកែវ | 155,030 | 151,725 | 378 | 1,415 | 345 | 184,215 | 180,010 | 898 | 2,629 | 205 | 208,698 | 204,823 | 1,390 | 2,198 | 287 |
| ត្បូងឃ្មុំ | 133,320 | 121,531 | 672 | 8,915 | 1,595 | 154,696 | 140,673 | 1,246 | 11,553 | 892 | 178,942 | 165,941 | 1,940 | 9,800 | 1,261 |
| **តំបន់ទំនាបកណ្តាល** | **1,140,167** | **1,062,845** | **23,229** | **33,114** | **7,472** | **1,414,924** | **1,273,890** | **71,993** | **47,830** | **4,839** | **1,769,365** | **1,550,606** | **170,845** | **44,092** | **3,822** |

ប្រភព: - របាយការណ៍លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨
- របាយការណ៍លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍ការជាតិស្តីពីលទ្ធផលជំរឿនចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រឆ្នាំ២០១៩។

ក្រាហ្វិក៧៤ បង្ហាញអំពីភាគរយតាមប្រភេទផ្ទះនៅឆ្នាំ២០២១ដោយផ្អែកលើទិន្នន័យ មូលដ្ឋានសម្រាបទូទាំងប្រទេស តំបន់ទំនាបកណ្តាល ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។ ចំនួនផ្ទះសរុបទូទាំងប្រទេសមានចំនួន៣,៦លានផ្ទះ ស្មើនឹង៩៥% ធៀបនឹងចំនួនគ្រួសារសរុប៣,៧លានគ្រួសារ។ តំបន់ទំនាបកណ្តាលមានចំនួនផ្ទះសរុប១,៦លានផ្ទះ ស្មើនឹង៩២% ធៀបនឹងចំនួនគ្រួសារសរុបមានចំនួន១,៨លានគ្រួសារ។ ខេត្តកំពង់ចាមមានចំនួនផ្ទះសរុប២៣៧ ពាន់ផ្ទះ ស្មើនឹង៨៥% ធៀបនឹងចំនួនគ្រួសារសរុប២៨០ពាន់គ្រួសារ និងខេត្តត្បូងឃ្មុំមានចំនួនផ្ទះសរុប១៨៦ពាន់ផ្ទះ ស្មើនឹង៩៣% ធៀបនឹងចំនួនគ្រួសារសរុប១៩៩ពាន់គ្រួសារ (ក្រាហ្វិក៧៤)។

**ក្រាហ្វិក ៧៤. ចំនួនផ្ទះ និង ចំនួនគ្រួសារឆ្នាំ២០២១**




*សំគាល់៖ ការគណនាភាគរយខាងលើគឺចំនួនផ្ទះធៀបនឹងចំនួនគ្រួសារ*

នៅទូទាំងប្រទេសភាគរយផ្ទះប្រក់សង្កសី ឬ ហ្វីប្រូស៊ីម៉ង់មាន ៤៩% និងផ្ទះដំបូលប្រក់ក្បឿងមាន៣២% និងក្រៅពីនោះប្រភេទផ្ទះផ្សេងៗ ក្នុងចំណោមផ្ទះសរុប៣,៦លានផ្ទះ។ តំបន់ទំនាបកណ្តាលមានភាគរយផ្ទះប្រក់សង្កសី ឬ ហ្វីប្រូស៊ីម៉ង់មាន៣៩% និងផ្ទះដំបូលប្រក់ក្បឿងមាន៣៨% និងក្រៅពីនោះប្រភេទផ្ទះផ្សេងៗ ខណៈដែលខេត្តកំពង់ចាមប្រក់សង្កសី ឬ ហ្វីប្រូស៊ីម៉ង់មាន៣២% និងផ្ទះដំបូលប្រក់ក្បឿងមាន៥៦% និងក្រៅពីនោះប្រភេទផ្ទះផ្សេងៗ និងខេត្តត្បូងឃ្មុំប្រក់សង្កសី ឬ ហ្វីប្រូស៊ីម៉ង់មាន ៣៨% និងផ្ទះដំបូលប្រក់ក្បឿងមាន៤៨% និងក្រៅពីនោះប្រភេទផ្ទះផ្សេងៗ (តារាង ៤៦ និងក្រាហ្វិក៧៥)។

## តារាង ៤៦. ចំនួនផ្ទះបែងចែកតាមប្រភេទឆ្នាំ២០២១

| ប្រភេទផ្ទះ | កម្ពុជា | តំបន់ទំនាបកណ្ដាល | កំពង់ចាម | ត្បូងឃ្មុំ |
|---|---|---|---|---|
| ផ្ទះដំបូលប្រក់ស្លឹកស្បូវ | 38,549 | 8,134 | 2,194 | 608 |
| ផ្ទះដំបូលប្រក់ស័ង្កសីហ្វីប្រូស៊ីម៉ង់ | 1,771,240 | 635,285 | 74,873 | 71,922 |
| ផ្ទះប្រក់សង្កសីតិចជាង២០សន្លឹក | 142,395 | 53,711 | 6,696 | 7,706 |
| ផ្ទះដំបូលប្រក់ក្បឿង | 1,143,185 | 620,257 | 132,768 | 88,184 |
| ផ្ទះថ្មមិនមែនបេតុង | 273,104 | 143,325 | 13,994 | 13,288 |
| ផ្ទះថ្មល្វែង | 215,370 | 172,741 | 5,798 | 3,809 |
| ផ្ទះភូមិគ្រឹះ(វីឡា) | 18,008 | 13,730 | 845 | 295 |
| **សរុប** | **3,601,851** | **1,647,183** | **237,168** | **185,812** |

## ក្រាហ្វិក ៧៥. ភាគរយតាមប្រភេទផ្ទះឆ្នាំ២០២១




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០២១។

### ៣.១.៣ បរិស្ថាន ទឹកស្អាត និង បង្គន់អនាម័យ



## ក. បរិស្ថាន

ដែលហៅថា បរិស្ថានគឺជាអ្វីៗដែលនៅជុំវិញខ្លួនយើង ដែលយើងមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយវា ហើយជីវិតយើងគ្រប់គ្នាទាំងអស់សុទ្ធតែត្រូវការបរិស្ថាន ដោយមិនអាចខ្វះបាន។ បរិស្ថានត្រូវបានបែងចែកជាបីប្រភេទគឺ បរិស្ថានធម្មជាតិ បរិស្ថានសង្គមវប្បធម៌ និង បរិស្ថានមនុស្ស[2]។

**១. បរិស្ថានធម្មជាតិ** (មានជីវិត និងឥតជីវិត ) គឺជាអ្វីៗដែលកើតមានឡើងដោយឯកឯង ក្រៅពីសកម្មភាពពលកម្ម ផលិតកម្មរបស់មនុស្សគឺវាកើតឡើងដោយធម្មជាតិខ្លួនឯងផ្ទាល់ ។ ម៉្យាងទៀតគឺរាល់សរីរាង្គដែលកើតឡើងដោយភាវៈធម្មជាតិដែលផ្សំបង្កើតឲ្យមានឡើង តួយ៉ាងធម្មជាតិគ្មានជីវិតមានដូចជា ទឹក ដី ភ្លើង ខ្យល់ ជាដើម។

**២. បរិស្ថានសង្គមវប្បធម៌** (មានជីវិត និងឥតជីវិត) គឺអ្វីៗដេលកើតមានជារូបរាងឡើងដោយផ្ទាល់ដៃ ពលកម្ម ផលិតកម្មប្រកបដោយការប៉ិនប្រសប់ និងការច្នៃប្រឌិតរបស់មនុស្ស ដើម្បីបម្រើសំណូមពរ និងតម្រូវការក្នុងជីវភាពរស់នៅរបស់មនុស្ស។ ដោយសមិទ្ធផលនៃបរិស្ថានសង្គមវប្បធម៌នេះបានញ៉ាំងឲ្យចាកផុតពីភាពចំណុះធម្មជាតិ និងដកខ្លួនឲ្យផុតពីស្ថានភាពជាសត្វ។ ប៉ុន្តែរាល់សមិទ្ធផលទាំងនេះ មនុស្សបានច្នៃបង្កើតឡើងដោយធ្វើការកែច្នៃធម្មជាតិ បើគ្មានបរិស្ថានធម្មជាតិគឺ មិនអាចមានបរិស្ថានសង្គមវប្បធម៌បានឡើយ។ តួយ៉ាងបរិស្ថានសង្គមវប្បធម៌មានជីវិតដូចជា អគារផ្សេងៗ ផ្លូវថ្នល់ ស្ពាន ក្រុង ភូមិ ស្រុក ប្រឡាយទឹកឧបករណ៍ផលិតកម្មជាដើម។ ចំណែកឯបរិស្ថានសង្គមវប្បធម៌ឥតជីវិតគឺ សកម្មភាពសង្គម ស្ថាប័ន ការគ្រប់គ្រង់ដឹកនាំសង្គម នយោបាយ សេដ្ឋកិច្ច ការអប់រំ សាសនា ប្រវត្តិសាស្ត្រ ការកម្សាន្តជាដើម។

**៣ . បរិស្ថានមនុស្ស** (មានជិវិត និងឥតជីវិត) គឺជាមនុស្សទូទៅ ដែលរស់នៅលើភពផែនដីទាំងអស់ ។ បរិស្ថានមនុស្សមានជីវិត : មនុស្សដែលកំពុងតែរស់រានមានជីវិតនៅសព្វថ្ងៃ គឺស្ថិតនៅក្នុងចំណោមភាវៈមានជីវិតទាំងអស់។ បរិស្ថានមនុស្សឥតជីវិត: គឺមនុស្សដែលបាត់បង់ជីវិតទៅហើយ ពោលគឺបុព្វបុរសជំនាន់ដើម និងមនុស្សជំនាន់ក្រោយ ដែលពុំទាន់មានកំណើតគឺស្ថិតនៅក្នុងភាវៈឥតជីវិត។

មនុស្សគ្រប់រូបយើងត្រូវរួមចំណែកដល់ការកសាង និងការពារបរិស្ថានដើម្បីឲ្យមានការអភិវឌ្ឍពីព្រោះបរិស្ថានជាភាវៈសម្រាប់ទ្រទ្រង់ភាវៈគ្មានជីវិត និងមានជីវិតហើយជាប្រភពធនធានធម្មជាតិ ដែលជាប្រភពនៃជីវិតព្រមទាំងវត្ថុធាតុដើម សម្រាប់ធ្វើការកែច្នៃបង្កើតភោគទ្រព្យនានាសម្រាប់បម្រើតម្រូវការរបស់មនុស្ស។ កន្លងមក បើមនុស្សគ្រាន់តែទាញផលពីធម្មជាតិ ដើម្បីបម្រើនូវតម្រូវការ ដែលចាំបាច់នៃជីវិតប្រចាំថ្ងៃរបស់ខ្លួន។ ដូច្នេះ ធនធានធម្មជាតិក៏ដូចជាបរិស្ថានធម្មជាតិគឺមិនទទួលរងនូវការវិនាសខូចខាតបាត់បង់តុល្យភាព ឬជះឥទ្ធិពលអាក្រក់ដល់ប្រព័ន្ធអេកូឡូស៊ីនៃ

---

[2] ចំណេះដឹងទូទៅ, *បរិស្ថាន ការអភិវឌ្ឍ* [website],27 September 2018. https://www.khsearch.com/qna/8284. (Accessed 21 August 2023).

ភពផែនដីនោះឡើយ។តែចំពោះមុខ ទោះបីបរិស្ថានធម្មជាតិ ឬភពផែនដីអាចបន្តពូជមនុស្សឲ្យរស់នៅបាន តែបរិស្ថានសព្វថ្ងៃមានការប្រែប្រួលគួរឲ្យព្រួយបារម្ភដូចជា ការកើនឡើងនៃកម្តៅព្រះអាទិត្យ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត រដូវមិនទៀងទាត់ បណ្តាលឲ្យមានគ្រោះទុរភិក្ស ហើយបញ្ជាក់ថាបរិស្ថាននៃភពផែនដីទទួលរង់នូវការខូចខាតដោយសារសកម្មភាពមនុស្ស ។ ដូចនេះយើងត្រូវតែយល់កិច្ចកសាង និងការពារបរិស្ថានជាភារកិច្ចរបស់យើងទាំងអស់គ្នា និងមនុស្សជាតិនៃសកលលោកទាំងមូល ជួយការពារគុណភាពបរិស្ថាន ស្រឡាញ់ខ្លួន ស្រឡាញ់ជីវិត ហើយបានរៀបចំអនាគត់ល្អសម្រាប់កូនចៅជំនាន់ក្រោយព្រមទាំងបានស្រឡាញ់មនុស្សជាតិទាំងមូលលើភពផែនដី ។

កត្តាមួយក្នុងចំណោមកត្តាផ្សេងទៀត ដែលបណ្តាលឲ្យមានប៉ះពាល់ដល់បរិស្ថានធ្ងន់ធ្ងនោះគឺកំណើនប្រជាជន។ នៅក្នុងពិភពលោកយើងនេះ តែងតែមានកំណើនប្រជាជនដូចគ្នា មិនថាប្រទេសជឿនលឿនឬកំពុងអភិវឌ្ឍន៍ឡើយ គ្រាន់តែប្រទេសជឿនលឿនមានកំណើនប្រជាជនទាបជាងប្រទេសកំពុងអភិវឌ្ឍន៍តែប៉ុណ្ណោះ ។ ជាទូទៅ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ដូចជា នៅទ្វីបអាព្រិចនិងអាស៊ីប្រជាជននៅតែកើនឡើងជានិច្ច ។ កាលណាប្រជាជននៅលើពិភពលោកចេះតែកើនឡើងៗ តម្រូវការអាហារ ទឹក ជម្រក សំលៀកបំពាក់ សេវាកម្មផ្សេងៗ និងការប្រើប្រាស់ធនធានរបស់ផែនដីក៏កាន់តែកើនឡើងដែរ។

## ក១. ការផ្លាស់ប្តូរក្នុងបរិស្ថានធម្មជាតិ

ការយល់ដឹងអំពីកម្រិតជីវភាពនៃការរស់នៅ និងប្រភពដែលអាចមានជាសំខាន់ គឺអាចត្រូវបានលើកដំឡើងជីវភាពរស់នៅរបស់ពួកគេនៅក្នុងមួយទសវត្សរ៍កន្លងទៅ ប៉ុន្តែដូចគ្នានេះដែរ គេមិនបាននិយាយអំពីការយល់ដឹងនៃការផ្លាស់ប្តូរបរិស្ថានធម្មជាតិនោះទេ។ ប្រជាជនកម្ពុជាប្រហែល ៣ភាគ៤ (៧៣%) ដែលបានយល់ឃើញថា មានការបាត់បង់ដើមឈើ និង ការបាត់បង់សត្វព្រៃនិងសត្វស្លាបមានចំនួន ៧១%នៃប្រជាជនកម្ពុជាដែលបានឆ្លើយតបតាមរយៈការសម្ភាសន៍។ ការបាត់បង់ព្រៃឈើនិងសត្វព្រៃទាំងពីរនេះ គឺប្រជាជនដែលរស់នៅជនបទបានឆ្លើយតបតាមរយៈការសាកសួររបស់អ្នកយកព័ត៌មានឬសម្ភាសន៍ពួកគាត់។ ប្រជាជនកម្ពុជាជិត២ភាគ៣ (៦៤%) បានឆ្លើយថាមានការបាត់បង់ប្រភេទត្រីនៅក្នុងមួយទសវត្សរ៍កន្លងទៅ។ អ្នកឆ្លើយប្រហែល៦៩% បានគិតថាមានការកើនឡើងនៃសត្វល្អិតដូចជារុយ និងមូសមានការកើនឡើងច្រើន។ ប្រជាជនកម្ពុជាភាគច្រើន (៦១%) យល់ឃើញថា ការពង្រាយសំរាម និងផ្លាស្ទិកមានការកើនឡើងនៅក្នុងទសវត្សរ៍កន្លងទៅនេះ ដែលភាគច្រើនអ្នករស់នៅតំបន់ទីប្រជុំជន (៦៧%) និងរាជធានីភ្នំពេញ (៧៩%)។ ការបំពុលខ្យល់មានការកើនឡើង៤២%នៃប្រជាជនកម្ពុជាដែលបានឆ្លើយ ជាពិសេសអ្នកដែលរស់នៅរាជធានីភ្នំពេញ (៦១% នៃអ្នកឆ្លើយដែលរស់នៅរាជធានី)។ តាមការសម្ភាសន៍ភ្នាក់ងារផ្សព្វផ្សាយ វិស័យឯកជន រដ្ឋាភិបាលបានបង្ហាញថាការបោះសំរាមនិងផ្លាស្ទិកចូលទៅក្នុងទន្លេមេគង្គបានធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹកនិងត្រី ដែលបង្ហាញអំពីការគ្រប់គ្រងនៅមានកម្រិត។ ប្រជាជនកម្ពុជា ៤៨% បានឆ្លើយថា មានសត្វល្អិតបំផ្លាញដំណាំកសិកម្មមានការកើនឡើង ក្នុងមួយទសវត្សរ៍កន្លងមក (ក្រាហ្វិក៧៦)។

## ក្រាហ្វិក ៧៦. ការយល់ដឹងអំពីការផ្លាស់ប្តូរក្នុងបរិស្ថានធម្មជាតិ




ប្រភព៖ The National Council for Sustainable Development, Ministry of Environment, *A Third Study on Understanding Public Perceptions of Climate Change in Cambodia, Phnom Penh,* The National Council for Sustainable Development, Ministry of Environment, 2020, p.26.

### ក២. គុណភាពខ្យល់

ការបំពុលខ្យល់ (Air Pollution) ទាំងក្នុង និងក្រៅ (បរិយាកាស) បង្កឡើងហានិភ័យចម្បងចំពោះសុខភាព។ ផ្លូវសំខាន់នៃការប៉ះពាល់ការបំពុលខ្យល់គឺតាមរយៈផ្លូវដង្ហើម។ ទោះយ៉ាងណាក៏ដោយផលប៉ះពាល់លើសុខភាពលើសពីជំងឺផ្លូវដង្ហើម ព្រោះសារធាតុបំពុលខ្យល់ខ្លះ អាចជ្រាបចូលទៅក្នុងចរន្តឈាមតាមរយៈសួត និងចរាចរពាសពេញរាងកាយទាំងមូលនាំឱ្យមានការរលាកជាប្រព័ន្ធ និងបង្កមហារីក។

ចង្ក្រានសាមញ្ញដែលប្រើជាមួយធ្យូង ធ្យូង កាកសំណល់ដំណាំ លាមក ប្រេងកាត ឬឈើ គឺជាប្រភពដ៏សំខាន់នៃការបំពុលខ្យល់ក្នុងផ្ទះ។ ការប៉ាន់ស្មានចុងក្រោយបង្ហាញថា ២,១ ពាន់លាន (UI: ១,៩ - ២,៥ ពាន់លានគ្រួសារ) មនុស្សនៅទូទាំងពិភពលោកនៅតែមានពឹងផ្អែកលើឥន្ធនៈចម្អិនអាហារ និងបច្ចេកវិទ្យាបំពុលទាំងនេះ ក្នុងឆ្នាំ២០២៣ស្មើនឹងជាងមួយភាគបួនបន្តិច (២៦%, UI: ២៣-៣០%) នៃចំនួនប្រជាជនពិភពលោក។ សមាមាត្រនៃប្រជាជនពិភពលោកដែលពឹងផ្អែកចម្បងលើការចម្អិនអាហារដោយប្រើឥន្ធនៈស្អាត និងបច្ចេកវិទ្យាបានកើនឡើងពី ៤៩% (UI: ៤៥–៥៣%) ក្នុងឆ្នាំ២០០០ ដល់ ៦៤% (UI: ៦០–៦៨%) ក្នុងឆ្នាំ២០១៥ និង ៧៤% (UI៖ ៧០–៧៧%) ក្នុងឆ្នាំ២០២៣ (ក្រាហ្វិក៧៧) ។ នៅក្រោមនិន្នាការបច្ចុប្បន្នពិភពលោកនឹងមិនអាចសម្រេចគោលដៅនៃរួមសម្រាប់ពិភពលោកនៅឆ្នាំ 2030។

## ក្រាហ្វិក ៧៧. និន្នាការសកលនៅក្នុងការប្រើប្រាស់ឥន្ធនៈស្អាត និងបច្ចេកវិទ្យា, ២០០០-២០២៣
(Global trends in the access to clean cooking fuels and technologies, 2000-2023)




ប្រភព៖ World Health Organization, *World health statistics 2025, Monitoring health for the SDGs, Sustainable Development Goals*, Geneva, World Health Organization, p.49.

គុណភាពខ្យល់ក្នុងប្រទេសកម្ពុជា រងផលប៉ះពាល់ដោយការបំពុលខ្យល់លាយឡំគ្នា និងមានប្រភពផ្សេងៗគ្នាជាច្រើន ដោយភាគច្រើនគឺបណ្តាលមកពីដំណើរការចំហេះ រួមទាំងយានយន្ត និង ដំណើរការឧស្សាហកម្ម ការដុតដីកសិកម្ម ការដុតសំណល់ ការផលិតឥដ្ឋ និងសកម្មភាពតាមផ្ទះ។ សារធាតុខ្យល់ពុលចម្បងជាកង្វល់នៅពេលវាស់វែងគុណភាពខ្យល់រួមមានដូចជា ភាគល្អិតនិចល (PM) អាស៊ូតអុកស៊ីត (នីទ្រិចអុកស៊ីត(NO) និងនីទ្រិចឌីអុកស៊ីត ($NO_2$)) ស្ពាន់ធ័រឌីអុកស៊ីត ($SO_2$) កាបូនម៉ូណូអុកស៊ីត (CO) និងអូហ្សូននៅកម្រិតផ្ទាល់ដី ($O_3$)។ អូហ្សូនកម្រិតផ្ទាល់ដី គឺពុំមែនបង្កឡើងដោយការបំភាយផ្ទាល់ដីនោះទេ ប៉ុន្តែត្រូវបានបង្កើតឡើងតាមរយៈពន្លឺព្រះអាទិត្យមានប្រតិកម្មជាមួយអាស៊ូតអុកស៊ីត និងសមាសធាតុអ៊ីដ្រូកាបូនក្នុងខ្យល់។ ជារឿយៗកំហាប់របស់វាមានកម្រិតខ្ពស់បំផុតនៅតំបន់ក្រោមខ្យល់ពីតំបន់ទីប្រជុំ ដោយក្នុងនោះយានយន្តបំភាយ NOx ។ សមាសធាតុសរីរាង្គងាយប្រែប្រួល (VOCs) ក៏ជាកង្វល់ផងដែរ ប៉ុន្តែមានកង្វះខាតទិន្នន័យក្នុងប្រទេសកម្ពុជា។

កម្រិតយភាគល្អិតនិចល និងសារធាតុបំពុលខ្យល់ដទៃទៀតត្រូវបានវាស់វែង ក្នុងខ្យល់សាធារណៈនៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តព្រះសីហនុ។ ការពិនិត្យតាមដានគុណភាពខ្យល់សាធារណៈសម្រាប់ឆ្នាំ២០១៩ (តារាង ៤៣) បង្ហាញកម្រិតកំហាប់នៃសារធាតុបំពុល

ខ្យល់ក្នុងរាជធានីភ្នំពេញ និងក្រុងធំៗដទៃទៀត។ ស្ថានីយ៍តាមដានជាច្រើនបង្ហាញពីកំហាប់ភាគល្អិតនិចល ($PM_{2.5}$) ខ្ពស់ជាងស្តង់ដារការបំភាយ (ឧណ្ណាលោម បាត់ដំបង) ឬ ក្រោមកម្រិតស្តង់ដារបន្តិច។ និន្នាការកម្រិត ($PM_{2.5}$) គិតជាមធ្យមនៅភ្នំពេញបង្ហាញការកើនឡើងចាប់ពីប្រមាណ១៤ µg/ម៣ ក្នុងឆ្នាំ២០១៧ ឡើងរហូតដល់ប្រមាណ ២០ µg/ម៣ ក្នុងឆ្នាំ២០១៩ ដែលជាការកើនឡើងជាង ៤០% (តារាង ៤៧) ។ អាទិភាពសំខាន់មួយគឺត្រូវបន្តត្រួតពិនិត្យតាមដានកម្រិត ($PM_{2.5}$) នៅទីតាំងផ្សេងៗក្នុងរាជធានីភ្នំពេញ។ កម្រិតរបស់ PM ទាំងនេះជាកង្វល់សម្រាប់សុខភាពសាធារណៈ និងជាកត្តាជម្រុញលើកទឹកចិត្តឲ្យមានសកម្មភាពផ្នែកគោលនយោបាយ។

តារាង ៤៧. ទិន្នន័យគុណភាពខ្យល់សាធារណៈស្តីពី $PM_{2.5}$ ក្នុងរាជធានីភ្នំពេញ ពីឆ្នាំ២០១៧ ដល់ ២០១៩

| | 2017 | 2018 | 2019 |
|---|---|---|---|
| $PM_{2.5}$ | 13.59 | 19.26 | 20.02 |

ប្រភព៖ ក្រសួងបរិស្ថាន នាយកដ្ឋានគុណភាពខ្យល់

នៅក្នុងខេត្តព្រះសីហនុ បានបង្ហាញឲ្យឃើញថា មានកម្រិតភាគល្អិតនិចលខ្ពស់ខ្លាំងក្នុងខ្យល់ ដែលទំនងជាបណ្តាលមកពីសកម្មភាពសាងសង់សំណង់ជាច្រើនបានធ្វើឡើងក្នុងឆ្នាំ២០១៩។ មានការរំពឹងទុកថាកម្រិតនេះនឹងទាបជាងមុនឆ្នាំ២០២០។

កំហាប់ $NO_2$ គឺស្ថិតនៅក្រោមគុណភាពខ្យល់ថ្នាក់ជាតិ។ ទោះយ៉ាងនេះក្តី គោលការណ៍ណែនាំរបស់ WHO សម្រាប់កម្រិតខ្យល់មធ្យមប្រចាំឆ្នាំរបស់ $NO_2$ គឺ ៤០ µg/ម៣ ។ កម្រិតនេះ នៅតែជាកង្វល់សម្រាប់សុខភាព។ កម្រិតគុណភាពខ្យល់នៃ $SO_2$, CO និងអូហ្សូន គឺសុទ្ធតែស្ថិតនៅក្រោមស្តង់ដារគុណភាពខ្យល់ មានន័យថាសារធាតុទាំងនេះពុំត្រូវបានចាត់ទុកថាស្ថិតនៅក្នុងកម្រិតបង្កឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈនៅឡើយ។ ទោះបីយ៉ាងនេះក្តី នេះពុំមែនមានន័យថាមិនមានផលប៉ះពាល់ជាអវិជ្ជមាននោះឡើយ ពោលគឺគ្រាន់តែមានន័យថា គឺឥទ្ធិពលនេះនឹងមានរយៈពេលវែងក្នុងទម្រង់ការកកើតមានជាតិអាស៊ីត ភាពកាត់ និងការខាតបង់ផលិតកម្មដំណាំ។

### តារាង ៤៨. គុណភាពខ្យល់សាធារណៈឆ្នាំ២០១៩ (កម្រិតមធ្យមប្រចាំឆ្នាំ)

| ទីតាំងស្ថានីយ៍ | $PM_{2.5}$ ($\mu g/m^3$) | $PM_{10}$ ($\mu g/m^3$) | $SO_2$ (PPB) | $NO_2$ (PPB) | CO (PPM) | $O_2$ (PPB) |
|---|---|---|---|---|---|---|
| ស្តង់ដារ | ២៥ µg/ម$^{៣}$/ឆ្នាំ | ៥០ µg/ម$^{៣}$/ឆ្នាំ | ១០០ µg/ម$^{៣}$/ឆ្នាំ | ១០០ µg/ម$^{៣}$/ឆ្នាំ | ២០ µg/ម$^{៣}$/ឆ្នាំ | ២០០ µg/ម$^{៣}$/ឆ្នាំ |
| ជ្រោយចង្វារ | ២២ | ២៦ | ១៣ | ៤០ | ១,៨ | ២២ |
| អូរឡាំពិក | ២២ | ២៦ | ១៣ | ៤០ | ១,៨ | ២២ |
| ឧណ្ណាលោម | ៣០ | ៦០ | ២៦ | ៣២ | 0.៩ | ៣២ |
| នាយកដ្ឋានបរិស្ថានរាជធានីភ្នំពេញ | ២៣ | ២៧ | ១៨ | ៧ | ០,៣៦ | ៦ |
| វត្តលង្កា | ២២ | ២៦ | ៣២ | ៤០ | ១,៥ | ២៧ |
| សួនក្តាន់ពីរ | ១៥ | ២២ | ២៩ | ៣១ | ២,១ | ៣០ |
| មន្ទីរបរិស្ថានខេត្តបាត់ដំបង | ២៥ | ៣២ | ១១ | ៧ | ០,៨៧ | ៦ |
| ឧទ្យានព្រះរាជដំណាក់ខេត្តសៀមរាប | ២៤ | ២៨ | ៧ | ២៣ | ០,៧៦ | ២៥ |
| មន្ទីរបរិស្ថានខេត្តកណ្តាល | ២១ | ២៤ | ២១ | ៣៨ | ០,៧៥ | ២៥ |
| មន្ទីរបរិស្ថានខេត្តព្រះសីហនុ | ៤៥ | ៩៤ | ៦ | ១៣ | ១,៨ | ១៨ |
| រង្វង់មូលតោពីរខេត្តព្រះសីហនុ | ២០ | ២៦ | ១១ | ៣៣ | ២៨ | ២៨ |

ប្រភព៖ ក្រសួងបរិស្ថាន នាយកដ្ឋានគុណភាពខ្យល់

### ក២.១ ប្រភពបំភាយសារធាតុពុលក្នុងបរិយាកាស

### ក២.១.១ ភាគល្អិតនិចល ( $PM_{2.5}$ )

ភាគល្អិត (PM) គឺជាល្បាយនៃសារធាតុសរីរាង្គ និងសារធាតុអសរីរាង្គ និងរឹង។ ជារឿយៗ PM ត្រូវបានរាយការណ៍ថាជា $PM_{10}$ (ភាគល្អិតដែលមានវិជ្ជមាត្រ១០មីក្រូម៉ែត្រ ឬ តិចជាងនេះ) និង $PM_{2.5}$ (< ២,៥មីក្រូម៉ែត្រ ឬ ហៅភាគល្អិតនិចល) ។ $PM_{2.5}$ អាចបន្តស្ថិតនៅក្នុងបរិយាកាសរយៈពេលយូរ ហើយរាយប៉ាយក្នុងរយៈចម្ងាយឆ្ងាយ។ PM មានទាំង PM ចម្បង និងPM បន្ទាប់បន្សំ ប៉ុន្តែសម្រាប់ការប៉ាន់ប្រមាណស្តីពីការបំភាយនេះ មានតែប្រភពចម្បងប៉ុណ្ណោះ ដែលត្រូវបានយកមក

ពិចារណា។ ការដកដង្ហើមស្រូបយក PM ចូលរយៈពេលយូរអាចបង្កឲ្យមានផលប៉ះពាល់សុខភាពជាអវិជ្ជមាន។

ក្រាហ្វិក ៧៨ បង្ហាញអំពីភាគល្អិតនិចល ត្រូវបានបំភាយចេញពីប្រភពផ្សេងៗ ដូចជាពីមធ្យោបាយដឹកជញ្ជូនតាមដងផ្លូវ ការដ្ឋានសំណង់ ការដ្ឋានរ៉ែផលិតឥដ្ឋ ការដុតសំណល់នៅកន្លែងបើកចំហរ ការដុតសំណល់កសិកម្ម ការចំអិនអាហារ និងឧស្សាហកម្មផ្សេងៗ។ ការបំភាយ $PM_{2.5}$ សរុបក្នុងប្រទេសកម្ពុជាមានប្រមាណ ៨៥ Gg គិតត្រឹមឆ្នាំ២០១៥ ដែលក្នុងនោះការដុតសំណល់កសិកម្មគឺជាប្រភពធំជាងគេក្នុងអត្រា៤៩% បន្ទាប់មក ១៧% ប្រភពមកពីការចម្អិនអាហារតាមលំនៅឋាន ១២% ការដុតសំណល់នៅទីវាល និងប្រមាណ១០% ការផលិតឥដ្ឋបូករួមជាមួយនឹងការដឹកជញ្ជូន។

**ក្រាហ្វិក ៧៨. ប្រភពដែលរួមចំណែកឲ្យមានបំភាយ $PM_{2.5}$ នៅកម្ពុជា ឆ្នាំ២០១៥**




ប្រភព៖ ក្រសួងបរិស្ថាន (២០២០)

### ក២.១.២ អាសូតអុកស៊ីត ( NOx )

NOx គឺជាស័ព្ទទូទៅទាំងសម្រាប់ប្រភេទនីទ្រិចអុកស៊ីត (NOx) និងអាសូតឌីអុកស៊ីត ($NO_2$)។ NOx ត្រូវបានបង្កើតឡើងក្នុងអំឡុងពេលដំណើរការប្រតិកម្មរវាងអាសូតជាមួយអុកស៊ីសែន ជាមួយដំណើរការចំហេះដែលជាចម្បង ដែលមានប្រភពចេញមកពីឥន្ធនៈហ្វូស៊ីល ដូចជា ប្រេង និងឧស្ម័ន

និងសារធាតុសរីរាង្គ។ NOx ប៉ះពាល់សុខភាពមនុស្សយ៉ាងធ្ងន់ធ្ងរ និងចូលរួមចំណែកធ្វើឲ្យមានការបង្កើតភ្លៀងអាស៊ីត និងអូហ្សូននៅលើដី។ ក្រាហ្វិក ៣៤ បង្ហាញអំពីប្រភពរួមចំណែកធ្វើឲ្យមានការបំភាយ NOx នៅកម្ពុជា ឆ្នាំ២០១៥។

ក្នុងប្រទេសកម្ពុជាការដឹកជញ្ជូន និងការដុតសំណល់ដំណាំ គឺជាប្រភពចម្បងនៃការបំភាយ NOx។ ការបំភាយ NOx ត្រូវបានប៉ាន់ប្រមាណមានបរិមាណ ៩៤Gg គិតត្រឹមឆ្នាំ២០១៥ ដែលក្នុងនោះ ៥៣,៦៦% បណ្តាលមកពីវិស័យដឹកជញ្ជូន បន្ទាប់ ១៨,៩២% មកពីការដុតសំណល់កសិកម្ម ១០,៤៧% ពីការផលិតអគ្គិសនី និង ១៦,៩៥% ប្រភពដទៃទៀត (រួមទាំងការដុតសំណល់រឹងនៅទីវាល លំនៅឋាន ឧស្សាហកម្ម និងការផលិតឥដ្ឋថ្ម។ សម្រាប់ការបំភាយចេញពីវិស័យដឹកជញ្ជូន ការប្រើប្រាស់ប្រេងម៉ាស៊ូតរួមចំណែកធំជាងគេបំផុតក្នុងចំនួន៦៥% ហើយ៣០% ទៀត គឺមកពីគ្រឿងម៉ាស៊ីនសាំង និង៥%មកពី LPG។

MME & ERIA បានរាយការណ៍ថាមានការប្រើប្រាស់ប្រេងម៉ាស៊ូត និងប្រេងសាំងកើនឡើងចាប់ពីឆ្នាំ២០១០ដល់២០១៥ ដោយក្នុងអត្រាកំណើនប្រចាំឆ្នាំ គឺប្រមាណ១០,២% សម្រាប់ប្រេងម៉ាស៊ូត និង៦,៤% សម្រាប់ប្រេងសាំង។

**ក្រាហ្វិក ៧៩. ប្រភពដែលរួមចំណែកឲ្យមានបំភាយ NOx នៅកម្ពុជា ឆ្នាំ២០១៥**




ប្រភព៖ ក្រសួងបរិស្ថាន (២០២០

### ក២.១.៣ ស្ពាន់ធ័រឌីអុកស៊ីត ($SO_2$)

$SO_2$ គឺជាឧស្ម័នគ្មានពណ៌ ងាយរលាយក្នុងដំណក់ទឹកបង្កើតបានជា អាស៊ីតស៊ុលហ្វួរិច រួចធ្លាក់ចុះមកជាមួយភ្លៀងអាស៊ីត។ ស្ពាន់ធ័រឌីអុកស៊ីត ជាសារធាតុបំពុលដែលអាចធ្វើឲ្យខូចខាតអគារ កាត់បន្ថយផលិតកម្មដំណាំ បង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ។ ជាចម្បង $SO_2$ កើតចេញពីដំណើរការបង្កឡើងដោយមនុស្ស ដូចជា ឥន្ទនៈហ្វូស៊ីលនៅក្នុងរោងចក្រផលិតថាមពល ការបម្លែងថាមពលផ្សេង ចំហេះម៉ាស៊ីនយានយន្ត និងវិស័យដែលប្រើប្រាស់ប្រេងឥន្ទនៈដទៃទៀត។ នៅទូទាំងពិភពលោក ការដុតធ្យូងថ្មរួមចំណែក ៥០% នៃការបំភាយ $SO_2$ ចំណែកប្រេងឥន្ទនៈរួមមាន ២៥-៣០%។

នៅកម្ពុជា ការបំភាយ $SO_2$ សរុបក្នុងឆ្នាំ២០១៥ មានប្រមាណ ៣៨ Gg ដោយក្នុងនោះប្រភពបំភាយចម្បងគឺការផលិតអគ្គិសនី (៥២%) វិស័យដឹកជញ្ជូន (១៨%) ការដុតសំណល់កសិកម្ម (៨%) ឧស្សាហកម្ម (៨%) និងប្រភពដទៃទៀត (សរុបបញ្ចូលគ្នា ១២,៨%) ។ ទិន្នន័យលំអិតមានបង្ហាញនៅក្នុងក្រាហ្វិក ៣៧ ដូចខាងក្រោម។

**ក្រាហ្វិក ៨០. ប្រភពដែលរួមចំណែកឲ្យមានបំភាយ $SO_2$ នៅកម្ពុជា ឆ្នាំ២០១៥**




ប្រភព៖ ក្រសួងបរិស្ថាន (២០២០)

### ក២.១.៤ មេតាន ($CH_4$)

មេតាន ($CH_4$) គឺជាឧស្ម័នគ្មានពណ៌ គ្មានក្លិន និងងាយឆាប់ឆេះជាខ្លាំង។ មេតានត្រូវបានផលិតចេញមកជាលក្ខណៈធម្មជាតិ និងលក្ខណៈសំយោគផង និងនៅពេលគេដុតមេតានពេលមានអុកស៊ីសែន ឧស្មន័នេះផលិតចេញជាកាបូនឌីអុកស៊ីត ($CO_2$) និងចំហាយទឹក ដោយហេតុនេះសារធាតុនេះគឺជាកត្តារួមចំណែកគួរឲ្យកត់សំគាល់ ធ្វើឲ្យមានការប្រែប្រួលអាកាសធាតុ ក៏ដូចជាការបំពុលខ្យល់។

នៅកម្ពុជា ការបំភាយ $CH_4$ សរុបប្រចាំឆ្នាំ២០១៥ គឺមានបរិមាណប្រមាណ ៧៨១Gg ដោយក្នុងនោះ ភាគច្រើនលើសលប់គឺបណ្តាលមកពីការដាំដុះស្រូវ និងបសុសត្វដែលមានសមាមាត្រ ៥៣% មកពីការដាំដុះស្រូវ និង ២៩% មកបសុសត្វ បន្ទាប់មកគឺការផលិតថ្យូង ៦% និង ការចោលសំណល់ក្នុងទីចាក់សំរាមចំនួន ៥%។ សម្រាប់ការបំភាយចេញមកពីបសុសត្វសត្វគោក្របីទទួលបន្ទុកប្រមាណ ៨០% នៃការបំភាយសរុបក្នុងវិស័យនេះ។ ទិន្នន័យលំអិតមានបង្ហាញនៅក្នុងក្រាហ្វិក ៣៨ ដូចខាងក្រោម។

**ក្រាហ្វិក ៨១. ប្រភពដែលរួមចំណែកឲ្យមានបំភាយ $CH_4$នៅកម្ពុជា ឆ្នាំ២០១៥**




ប្រភព៖ ក្រសួងបរិស្ថាន (២០២០)

### ក២.១.៥ កាបូនម៉ូណូអុកស៊ីត (CO)

កាបូនម៉ូណូអុកស៊ីត (CO) គឺជាឧស្ម័នគ្មានក្លិន គ្មានពណ៌ដែរ និងជាផលិតផលកើតចេញពីចំហេះមិនពេញលេញនៃឥន្ធនៈហ្វូស៊ីល ព្រមទាំងជីវម៉ាសដទៃទៀត។ ប្រភពចម្បងនៃកាបូនម៉ូណូអុកស៊ីតនៅសកលលោកគឺចំហេះម៉ាស៊ីននៅប៊ូហ្ស៊ី (ឧទាហរណ៍ ម៉ាស៊ីនសាំង/ឥន្ធនៈដទៃទៀត ប៉ុន្តែក៏មានចំហេះឥន្ធនៈដទៃទៀតកាន់តែច្រើនឡើងផងដែរដូចជា LPG និង (ជីវៈ) អេតាណុល)។ ស្ថានីយ៍ផលិតថាមពល និងឡដុតកម្ទេចសំណល់ក៏រួមចំណែកធ្វើឲ្យមានការបំភាយ CO ផងដែរ។

នៅកម្ពុជា ការដុតសំណល់កសិកម្ម ជាកត្តារួមចំណែកជាចម្បងធ្វើឲ្យមាន CO ក្នុងសមាមាត្រប្រមាណ ៤០%។ ការផលិតធ្យូងរួមចំណែកចំនួន (២៧%) លំនៅឋាន (១៦%) ការដឹកជញ្ជូន (១៣%) និងសមាមាត្រសេសសល់ ៤% ពីប្រភពដទៃទៀត។ ទិន្នន័យលំអិតមានបង្ហាញនៅក្នុងក្រាហ្វិក ៨២ ដូចខាងក្រោម។

**ក្រាហ្វិក ៨២. ប្រភពដែលរួមចំណែកឲ្យមានបំភាយ CO នៅកម្ពុជា ឆ្នាំ២០១៥**




ប្រភព៖ ក្រសួងបរិស្ថាន (២០២០)

### ក២.១.៦ សមាសធាតុសរីរាង្គងាយប្រែប្រួល ប្រភេទមិនមានមេតាន (NMVOCs)

សមាសធាតុសរីរាង្គងាយប្រែប្រួល ប្រភេទមិនមែនមេតាន (NMVOCs) គឺជាបណ្តុំសមាសធាតុសរីរាង្គដែលប្លែកគ្នាយ៉ាងខ្លាំងនៅក្នុងសមាសធាតុផ្សំគីមីរបស់ខ្លួន ប៉ុន្តែស្តែងចេញនូវលក្ខណៈស្រដៀងគ្នា។ NMVOCs ត្រូវបានបំភាយចេញពីប្រភពផ្សេងៗជាច្រើនរួមទាំងសកម្មភាពចំហេះ ការប្រើប្រាស់សារធាតុលាយ និងដំណើរការផលិតកម្ម។ NMVOCs ចូលរួមឲ្យមានការបង្កើតឲ្យមានអូហ្សូននៅលើដី។ លើសពីនេះទៀត NMVOCs មួយចំនួនដូចជា benzene និង butadiene គឺមានគ្រោះថ្នាក់ចំពោះសុខភាពមនុស្ស។ ប្រភពរួមចំណែកការបំភាយ NMVOCs ត្រូវបានបង្ហាញក្នុងក្រាហ្វិក ៣៨ សរុបប្រចាំឆ្នាំ២០១៥ មានចំនួន ២៣៥ Gg ដោយក្នុងនោះការផលិតថ្យូង គឺជាកត្តាចម្បង (៤៧%) បន្ទាប់មកគឺការចំអិនអាហារតាមលំនៅឋាន (២៤%)។ ការដុតសំណល់រឹងនៅទីវាល និងវិស័យដឹកជញ្ជូនរួមចំណែកជិត១០% ហើយដុតសំណល់ដំណាំកសិកម្ម ៧,៦%។ ទិន្នន័យលំអិតមានបង្ហាញនៅក្នុងក្រាហ្វិក ៨៣ ដូចខាងក្រោម។

**ក្រាហ្វិក ៨៣. ប្រភពដែលរួមចំណែកឲ្យមានបំភាយ NMVOCs នៅកម្ពុជា ឆ្នាំ២០១៥**




ប្រភព៖ ក្រសួងបរិស្ថាន (២០២០)

## ៩៣ ការផ្លាស់ប្តូរអាកាសធាតុ

អាកាសធាតុប្រទេសកម្ពុជាគឺមានការផ្លាស់ប្តូរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ តាមរយៈការសិក្សាអំពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត ហៅកាត់ថា (KAP3) បានរកឃើញថា មានប្រជាជន ៦៩% បានបញ្ជាក់ថា ភ្លៀងធ្លាក់មានការថយចុះក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ។ អ្នកនេសាទ និងកសិករ៧៤% ប្រជាជន ដែលរស់នៅតំបន់ទន្លេសាប៧៥% និងប្រជាជនរស់នៅតំបន់ភ្នំ៧៤% បានឆ្លើយថាចំនួនភ្លៀងធ្លាក់មានការថយចុះ ខណៈដែលប្រជាជនដែលរស់នៅតំបន់ឆ្នេរសមុទ្រ៤៧% បានឆ្លើយថាភ្លៀងធ្លាក់មានការថយចុះ។

ការបញ្ជាក់អំពីការថយចុះនៃទឹកភ្លៀង បានអះអាងស្រដៀងនឹងអ្នកឆ្លើយ (៧៤%) ដែលបានឆ្លើយថាមានការកើនឡើងសីតុណ្ហភាព ក្នុងរយៈពេល១ទសវត្សរ៍កន្លងទៅ។ ប្រជាជនដែលរស់នៅភ្នំពេញ៨៥% និងប្រជាជនដែលរស់នៅតំបន់ទន្លេសាប៨០% ខណៈដែលតំបន់ឆ្នេរសមុទ្រ ៥៦% បានអះអាងដូចខាងលើដែរ។

នៅក្នុងក្រាហ្វិក ៨៤ បានបង្ហាញអំពីការផ្លាស់ប្តូរនៃកម្រិតទឹកភ្លៀង និងការប្រែប្រួលអាកាសធាតុដែលអាចគិតថានាំឲ្យមានគ្រោះរាំងស្ងួតនិង គ្រោះទឹកជំនន់។ ចំនួនអ្នកឆ្លើយជាងបីភាគ (៣៦%) បានគិតថាគ្រោះរាំងស្ងួតនិងបញ្ហាទឹក មានការកើនឡើងគួរឲ្យព្រួយបារម្ភក្នុងរយៈពេល១ទសវត្សរ៍កន្លងទៅនេះជាពិសេសអ្នករស់នៅតំបន់បឹងទន្លេសាប៤៥% និងតំបន់ភ្នំ៤១% ដែលបានបង្ហាញចំណុចទាំងអស់នេះ។ ប្រជាជនក្រីក្រ៤០% និងអ្នកនេសាទ៤៣% បានកត់សំគាល់ឃើញថាគ្រោះរាំងស្ងួតកំពុងកើនឡើង។ លើសពីនេះទៀត ៥៤%នៃអ្នកឆ្លើយទាំងនោះបានបញ្ជាក់ថាគ្រោះទឹកជំនន់មានការថយចុះ និងអ្នកដែលរស់នៅតំបន់ទន្លេសាប៧១%ក៏យល់ស្របដូចគ្នានេះដែរ។ ជារួមអ្នកឆ្លើយជាងពាក់កណ្តាលបានបញ្ជាក់អំពីការកើនឡើងខ្យល់ខ្លាំងនិងព្យុះ(៤៥%) និងផ្គររន្ទះ ៥០% ក្នុងរយៈពេលជាងមួយទសវត្សរ៍នេះ។

## ក្រាហ្វិក ៨៤. ការយល់ដឹងអំពីការផ្លាស់ប្តូរអាកាសធាតុតាមតំបន់




ប្រភព៖ The National Council for Sustainable Development, Ministry of Environment, *A Third Study on Understanding Public Perceptions of Climate Change in Cambodia, Phnom Penh,* The National Council for Sustainable Development, Ministry of Environment, 2020, p.26.

## ក៤. គ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថាន និងសំណល់

### ក៤.១ គ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថាន

ផ្អែកលើទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានីខេត្តឆ្នាំ២០២១ បានបង្ហាញថា ចំនួនគ្រួសារនៅទូទាំងប្រទេសដែលរស់នៅក្នុងតំបន់ការពារឬអភិរក្សមាន ១,៤% គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះមាន១៣,២% គ្រួសារទទួលផលប៉ះពាល់ដោយបរិស្ថានមាន១,១% នៅក្នុងចំណោមគ្រួសារសរុប៣,៨លានគ្រួសារ។ នៅខេត្តកំពង់ចាមគ្រួសារដែលរស់នៅក្នុងតំបន់ការពារឬអភិរក្សមាន ០,០% គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះមាន៣,១% គ្រួសារទទួលផលប៉ះពាល់ដោយបរិស្ថានមាន០,៥% ក្នុងចំណោមគ្រួសារសរុប២៨០ពាន់គ្រួសារ។ នៅក្នុងខេត្តត្បូងឃ្មុំ គ្រួសារដែលរស់នៅក្នុងតំបន់ការពារឬអភិរក្សមាន ០,១% គ្រួសារមានសេវាប្រមូលសំរាមនៅតាមផ្ទះមាន ១,៨% គ្រួសារទទួលផលប៉ះពាល់ដោយបរិស្ថានមាន០,៦% ក្នុងចំណោមគ្រួសារសរុប១៩៩ពាន់គ្រួសារ (តារាង៤៩ និងក្រាហ្វិក៨៥)។

### តារាង ៤៩. ចំនួនគ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថានឆ្នាំ២០២១ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

| អធិប្បាយ | កំពង់ចាម | ត្បូងឃ្មុំ | កម្ពុជា |
|---|---|---|---|
| គ្រួសារដែលរស់នៅក្នុងតំបន់ការពារឬអភិរក្ស | 29 | 244 | 54,741 |
| គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | 8,598 | 3,640 | 505,325 |
| គ្រួសារដែលទទួលរងផលប៉ះពាល់ពីការបំពុលបរិស្ថាន | 1,527 | 1,213 | 41,649 |
| **ចំនួនគ្រួសារសរុប** | **279,677** | **199,113** | **3,816,272** |

ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០២១

### ក្រាហ្វិក ៨៥. ភាគរយគ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះឆ្នាំ២០២១




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០២១

## ក៤.២. សំណល់

ប្រទេសកម្ពុជាបានធ្វើការអភិវឌ្ឍន៍លើគ្រប់វិស័យ ដែលធ្វើឲ្យមានកំណើន GDP ក្នុងប្រជាជនម្នាក់បានកើនឡើងពី ២៥៥ ដុល្លារអាមេរិក ទៅ ១.៦៤៨ ដុល្លារអាមេរិក ពីឆ្នាំ១៩៩៨ ទៅ ២០២១។ ទន្ទឹមនឹងកំណើនសេដ្ឋកិច្ចនេះ ចំនួនប្រជាជនក៏មានកំណើនផងដែរ គឺបានកើនឡើងពីចំនួន ៥,៧លាននាក់ នៅឆ្នាំ១៩៦២ ហើយបានកើនឡើងនៅឆ្នាំ១៩៩៨ មានចំនួន ១១,៤លាននាក់ បន្តកើនឡើងនៅឆ្នាំ ២០០៨ មានចំនួន១៣,៤លាននាក់ និងនៅឆ្នាំ២០១៩ មានចំនួន ១៥,៣ លាននាក់ ហើយបានព្យាករណ៍ឆ្នាំ២០៣៥ អាចកើនឡើងដល់ ១៩,៨ លាននាក់ ដោយផ្អែកលើលទ្ធផលនៃការធ្វើជំរឿនប្រជាជនឆ្នាំ១៩៩២ ១៩៩៨ ២០០៨ ២០១៩ និងការធ្វើចំណោលឆ្នាំ ២០២០ (វិទ្យាស្ថានជាតិស្ថិតិ)។ ការកើនឡើងចំនួនប្រជាជននេះ បានធ្វើឲ្យមានការប្រើប្រាស់វត្ថុធាតុដើម និងធនធានធម្មជាតិមានការកើនឡើងផងដែរ ហើយវាបានធ្វើឲ្យមានការកើនឡើងជាគំហុកនៃការបង្កើតសំណល់ រួមមានទាំងសំណល់រឹង និងសំណល់រាវ ដែលទាមទារឲ្យមានការគ្រប់គ្រងឲ្យបានល្អប្រសើរ។

### ក៤.២.១ សំណល់រាវ

សំណល់រាវ -ទឹកកខ្វក់ ភាគច្រើនបានបញ្ជូនតាមរយៈបំពង់លូទៅកាន់ស្ថានីយប្រព្រឹត្តិកម្ម ដោយក្នុងនោះស្ថានីយ៍បូមទឹកចែកចាយសំណល់រាវ-ទឹកកខ្វក់ដែលបានប្រព្រឹត្តិកម្មរួច បានបង្ហូរទៅកាន់ស្រះទៅកាន់ស្រះដាក់ទឹកឲ្យរង។ សំណល់រាវ -ទឹកកខ្វក់ក្នុងបរិមាណគួរឲ្យកត់សម្គាល់នៅតំបន់ជនបទនៃប្រទេសកម្ពុជា ពុំត្រូវបានរាំងខ្ទប់ឲ្យស្ថិតក្នុងប្រព័ន្ធបិទជិតនោះទេ ប៉ុន្តែផ្ទុយទៅវិញ ទឹកទាំងនោះត្រូវបានបញ្ចេញដោយផ្ទាល់ទៅក្នុងបរិស្ថាន ដោយសារពុំទាន់មានប្រព័ន្ធប្រត្តិកម្មសំណល់រាវ-ទឹកកខ្វក់នៅឡើយ។ ស្ថានីយប្រព្រឹត្តិកម្មសំណល់រាវ-ទឹកកខ្វក់មាននៅក្នុងខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តបាត់ដំបង។ តែទោះយ៉ាងណាក្តី ទីក្រុងកំពុងលូតលាស់នេះបន្តជួបប្រទះបញ្ហាប្រឈមដោយសារសមត្ថភាពរបស់ស្ថានីយទាំងនេះពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការនៅឡើយ។

ក្រាហ្វិក ៨៦. បង្ហាញអំពីសមត្ថភាពប្រព្រឹត្តិកម្មសំណល់រាវ-ទឹកកខ្វក់ នៅក្នុងខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តកែប។ ខេត្តព្រះសីហនុបានកសាងអាងប្រព្រឹត្តិកម្មទឹកកខ្វក់តាំងពីឆ្នាំ២០០៨ ដែលមានសមត្ថភាពសរុបមានចំនួន ៦.៩០០ម$^{៣}$/ថ្ងៃ ហើយបានកើនឡើងសមត្ថភាពប្រព្រឹត្តិកម្មដល់ ២០.០០០ម$^{៣}$/ថ្ងៃ នៅឆ្នាំ២០១៨ ដោយសារមានអនុស្ថានីយចំនួន ៥ កន្លែងបន្ថែមទៀត។ ខេត្តសៀមរាបមានសមត្ថភាពប្រព្រឹត្តិកម្មដំបូងចំនួន ៣.០០០ ម$^{៣}$/ថ្ងៃ បានកើនឡើងដល់

៨.០០០ ម³/ថ្ងៃ នៅឆ្នាំ២០១៤។ ខេត្តបាត់ដំបងបានកសាងអាងប្រព្រឹត្តិកម្មទឹកកខ្វក់នៅក្នុងឆ្នាំ ១៩៩៤ ដែលអាចមានសមត្ថភាពប្រព្រឹត្តិកម្មចំនួន ១.០០០ម³/ថ្ងៃ ប៉ុន្តែបច្ចុប្បន្ននេះបានធ្លាក់ចុះមក ត្រឹម ៤៥០ម³/ថ្ងៃ ដោយសារតែការថមថយចុះរបស់ប្រព័ន្ធ។

**ក្រាហ្វិក ៨៦. សមត្ថភាពប្រព្រឹត្តិកម្មសំណល់រាវ-ទឹកកខ្វក់**




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

### ក២.២.២ សំណល់រឹង

នៅក្នុងក្រាហ្វិក ៨៧ បង្ហាញពីបរិមាណសំណល់រឹងទីប្រជុំជន ដែលចាក់នៅទីលានប្រចាំឆ្នាំ ពី២០០៤ ដល់ឆ្នាំ២០១៧ (ក្រសួងបរិស្ថាន ២០១៧ច) ។ ជាមួយនឹងកំណើនសន្សឹមៗចាប់ពី ៣១៧.៥៥០ តោន នៅឆ្នាំ ២០០៤ រហូតដល់ប្រមាណជាង ៦៣៥.០០០ តោន ក្នុងឆ្នាំ ២០១១ និង មានសន្ទុះខ្លាំងនៅឆ្នាំ បន្ទាប់គឺប្រមាណជាង ៩៣០.០០០តោន ។ ទិន្នន័យឆ្នាំ២០១៧ បង្ហាញថា សំណល់រឹងដែលបានចាក់នៅទីលានសរុបមានប្រមាណ ១.៤៥៤.៦៥៣ តោន ធៀបនឹងឆ្នាំ២០១៦ គឺកើនឡើង ១៨៨.០៣៣តោន ស្មើនឹង ១៤,៨ ភាគរយ និងមានកំណើន ៤៦,៩ភាគរយ ធៀបនឹង ឆ្នាំ២០១៣។

## ក្រាហ្វិក ៨៧. បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលបានចាក់នៅទីលានប្រចាំឆ្នាំនៅទូទាំងប្រទេស




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៣* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០១៩។

ក្រាហ្វិក ៨៨ បង្ហាញអំពីបរិមាណសំណល់រឹងនៅរាជធានីភ្នំពេញ ដែលបានប្រមូលប្រចាំឆ្នាំ គិតជាតោន។ បរិមាណសំណល់រឹង គឺបានបង្ហាញអំពីការកើនឡើងគួរឲ្យកត់សំគាល់ដែលមានចំនួន ២៥០.០០០ តោន/ឆ្នាំ (ឆ្នាំ២០០៤) បានកើនដល់ ៩៥០.០០០ តោន/ឆ្នាំ (២០១៨)។ ជាទូទៅ សំណល់សរីរាង្គមានចំនួនច្រើនជាង ៥០% ខណៈដែលសំណល់ផ្លាស្ទិកមានប្រមាណ ២១% ក្រដាសមានប្រមាណ១០% និងក្រៅពីនោះជាប្រភេទសំណល់រឹងផ្សេងៗ ដូចបង្ហាញជូននៅក្នុង ក្រាហ្វិក២៩ ផ្នែកខាងក្រោម។

## ក្រាហ្វិក ៨៨. បរិមាណសំណល់រឹងនៅរាជធានីភ្នំពេញ (តោន/ឆ្នាំ)



### ក្រាហ្វិក ៨៩. ភាគរយបរិមាណសំណល់រឹងនៅរាជធានីភ្នំពេញឆ្នាំ២០១៥




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

នៅក្នុងក្រាហ្វិក ៩០ និងតារាង ៥០ បង្ហាញអំពីបរិមាណសំណល់រឹងប៉ាន់ប្រមាណនៅឆ្នាំ ២០១៥ នៅទូទាំង ប្រទេសមានចំនួន ៤.០៩០.២០៩ តោន/ឆ្នាំ ដែលក្នុងនោះបរិមាណសំណល់រឹង ដែលបានប្រមូលមានចំនួន ២.៥៧១.២៣៥តោន/ឆ្នាំ ស្មើនឹង ៦៣ ភាគរយ ការបោះសំណល់រឹង ចោលដោយខុសច្បាប់មានចំនួន ១.១៩៤.៤៥៦ តោន/ឆ្នាំ ស្មើនឹង ២៩ ភាគរយ និង បរិមាណ សំណល់ដែលត្រូវកែច្នៃឡើងវិញមានចំនួន ៣២៤.៥១២តោន/ឆ្នាំ ស្មើនឹង ៨ភាគរយ។ តំបន់ទំនាប កណ្តាលមានសំរាមប៉ាន់ប្រមាណ ២.៥១០.៣១៣ តោន/ឆ្នាំ ដែលក្នុងនោះបរិមាណសំណល់រឹង ដែលបានប្រមូលមានចំនួន ១.៦៥៦.៩៧៥តោន/ឆ្នាំ ស្មើនឹង ៦៦ ភាគរយ ការបោះសំណល់រឹង ចោលដោយខុសច្បាប់មានចំនួន ៧២៩.៧០៤ តោន/ឆ្នាំ ស្មើនឹង ២៩ ភាគរយ និង បរិមាណ សំណល់ដែលត្រូវកែច្នៃឡើងវិញមានចំនួន ១២៣.៦២៦តោន/ឆ្នាំ ស្មើនឹង ៥ភាគរយ។ តំបន់ទំនាប ទន្លេសាបមានសំរាមប៉ាន់ប្រមាណ ១.០៥៨.១១៣ តោន/ឆ្នាំ ដែលក្នុងនោះបរិមាណសំណល់រឹង ដែលបានប្រមូលមានចំនួន ៦៤២.០០៣តោន/ឆ្នាំ ស្មើនឹង ៦១ ភាគរយ ការបោះសំណល់រឹងចោល ដោយខុសច្បាប់មានចំនួន ៣២១.៤៦២ តោន/ឆ្នាំ ស្មើនឹង ៣០,៤ ភាគរយ និង បរិមាណសំណល់ ដែលត្រូវកែច្នៃឡើងវិញមានចំនួន ៩៤.៦៤៤តោន/ឆ្នាំ ស្មើនឹង ៩ភាគរយ។ តំបន់ឆ្នេរសមុទ្រមាន

សំរាមប៉ាន់ប្រមាណ ៣៩២.២៩៩ តោន/ឆ្នាំ ដែលក្នុងនោះបរិមាណសំណល់រឹងដែលបានប្រមូលមានចំនួន ១៩៥.៦៤៤តោន/ឆ្នាំ ស្មើនឹង ៥០ ភាគរយ ការបោះសំណល់រឹងចោលដោយខុសច្បាប់មានចំនួន ១១៣.៦៤៦ តោន/ឆ្នាំ ស្មើនឹង ២៩ ភាគរយ និង បរិមាណសំណល់ដែលត្រូវកែច្នៃឡើងវិញមានចំនួន ៨៣.០០៨តោន/ឆ្នាំ ស្មើនឹង ២១,២ភាគរយ។ តំបន់ខ្ពង់រាបនិងភ្នំ មានសំរាមប៉ាន់ប្រមាណ ១២៩.៤៧៨ តោន/ឆ្នាំ ដែលក្នុងនោះបរិមាណសំណល់រឹងដែលបានប្រមូលមានចំនួន ៧៦.៦០៨តោន/ឆ្នាំ ស្មើនឹង ៥៩ ភាគរយ ការបោះសំណល់រឹងចោលដោយខុសច្បាប់មានចំនួន ២៩.៦៣៩ តោន/ឆ្នាំ ស្មើនឹង ២៣ ភាគរយ និង បរិមាណសំណល់ដែលត្រូវកែច្នៃឡើងវិញមានចំនួន ២៣.២២៩តោន/ឆ្នាំ ស្មើនឹង ១៨ភាគរយ។

### ក្រាហ្វិក ៩០. ភាគរយបរិមាណសំណល់រឹងទីក្រុងតាមតំបន់ឆ្នាំ២០១៥




ប្រភព÷ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

**តារាង ៥០. បរិមាណការប្រមូលសំណល់រឹងទីក្រុង ការចោលសំរាមខុសច្បាប់ និងការកែច្នៃឡើងវិញ ឆ្នាំ២០១៥ តាមតំបន់**

| កម្ពុជា/តំបន់ | បរិមាណសំណល់ ប៉ាន់ស្មាន | បរិមាណសំណល់ ដែលបានប្រមូល | ការបោះសំណល់រឹង ចោលដោយ ខុសច្បាប់ | បរិមាណសំណល់ ដែលបានកែច្នៃ ឡើងវិញ |
|---|---|---|---|---|
| **កម្ពុជា** | **4,090,209** | **2,571,235** | **1,194,456** | **324,512** |
| តំបន់ខ្ពង់រាបនិងភ្នំ | 129,478 | 76,608 | 29,639 | 23,229 |
| តំបន់ឆ្នេរសមុទ្រ | 392,299 | 195,644 | 113,646 | 83,008 |
| ទន្លេសាប | 1,058,113 | 642,003 | 321,462 | 94,644 |
| ទំនាបកណ្តាល | 2,510,313 | 1,656,975 | 729,704 | 123,626 |
| តំបន់ខ្ពង់រាបនិងភ្នំ | 129,478 | 76,608 | 29,639 | 23,229 |

ប្រភព÷ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

ក្រាហ្វិក ៩១ បង្ហាញអំពីភាគរយបរិមាណសំណល់រឹងទីក្រុងតាមរាជធានីខេត្តដែលស្ថិតនៅក្នុងតំបន់ទំនាបកណ្តាល។ បរិមាណប្រមូលសំណល់រឹងដែលប្រមូលបាននៅរាជធានីភ្នំពេញមានប្រហែល៨៣% ច្រើនជាងគេខណៈដែលខេត្តស្វាយរៀងមានប្រហែល៤៣% ទាបជាងគេក្នុងចំណោមខេត្តទាំង៧ ដែលស្ថិតនៅក្នុងតំបន់ទំនាបកណ្តាល។ ភាគរយសំណល់រឹងដែលចោលខុសច្បាប់នៅក្នុងខេត្តត្បូងឃ្មុំមានចំនួន ៤៨% ច្រើនជាងគេ និងតិចជាងគេរាជធានីភ្នំពេញ ១២% ខណៈដែលខេត្តស្វាយរៀង និងខេត្តកំពង់ចាមមានភាគរយ (៤៥%)ស្មើគ្នា។ ចំពោះបរិមាណសំណល់រឹងកែច្នៃឡើងវិញ ខេត្តតាកែវមានភាគរយខ្ពស់ជាងគេ ២៨% និងខេត្តត្បូងឃ្មុំពុំមានការកែច្នៃឡើងវិញ។

**ក្រាហ្វិក ៩១. ភាគរយបរិមាណសំណល់រឹងទីក្រុងតាមរាជធានីខេត្តក្នុងតំបន់ទំនាបកណ្តាលឆ្នាំ២០១៥**



**តារាង ៥១. បរិមាណការប្រមូលសំណល់រឹងទីក្រុង ការចោលសំរាមខុសច្បាប់ និងការកែច្នៃឡើងវិញ ឆ្នាំ២០១៥ តាមខេត្តក្នុងតំបន់ទំនាបកណ្ដាល**

| កម្ពុជា/តំបន់ | បរិមាណសំណល់ ប៉ាន់ស្មាន | បរិមាណសំណល់ ដែលបានប្រមូល | ការបោះសំណល់រឹង ចោលដោយខុសច្បាប់ | បរិមាណសំណល់ ដែលបានកែច្នៃឡើងវិញ |
|---|---|---|---|---|
| **ទំនាបកណ្ដាល** | **2,510,313** | **1,656,975** | **729,704** | **123,626** |
| រាជធានីភ្នំពេញ | 1,007,400 | 839,500 | 117,530 | 50,370 |
| កណ្ដាល | 379,600 | 205,495 | 155,125 | 18,980 |
| តាកែវ | 59,427 | 29,066 | 14,002 | 16,358 |
| កំពង់ចាម | 578,890 | 308,060 | 258,420 | 12,410 |
| ត្បូងឃ្មុំ | 214,002 | 110,350 | 102,484 | 1,167 |
| ស្វាយរៀង | 20,239 | 8,654 | 9,143 | 2,441 |
| ព្រៃវែង | 250,755 | 155,850 | 73,000 | 21,900 |

ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

ផ្អែកតាមរបាយការណ៍ស្ថានភាពបរិស្ថានលើកទី៣ ឆ្នាំ២០១៩ បាន បង្ហាញថា ការផ្ដល់សេវាប្រមូលដឹកជញ្ជូនសំរាម សំណល់រឹងនៅទីប្រជុំជន ក្រុង ស្រុក ភាគច្រើនអនុវត្តដោយអ្នកគ្រប់គ្រងផ្សារ ឬ ភាស៊ីផ្សារដែលមានរហូតដល់ ៥៣ ភាគរយ ហើយការផ្ដល់សេវានេះដោយក្រុមហ៊ុនឯកជននៅទីប្រជុំជន ក្រុងមានចំនួនតែ ២០ ភាគរយ ប៉ុណ្ណោះ ។ មូលហេតុមកពីនៅតាមទីប្រជុំជនស្រុកការចូលរួមបង់ថ្លៃសេវាកម្មដឹកជញ្ជូនសំរាម សំណល់រឹងមានតែអាជីវករលក់ដូរតាមតូបក្នុងផ្សារ និងហាងទំនិញ ឬ ផ្ទះប្រជាពលរដ្ឋជុំវិញផ្សារតែប៉ុណ្ណោះ ហើយដែលក្រុមហ៊ុនពិបាកនឹងទទួលយក (ទំហំការងារមិនសមាមាត្រនឹងចំណាយរបស់ក្រុមហ៊ុន) ហើយយោងតាមក្រាហ្វិក ៤៩ បង្ហាញថា ២៤ភាគរយ ទៀតពុំទទួលបានសេវាប្រមូលសំរាម សំណល់រឹង ទីប្រជុំជននៅក្នុងក្រុង សំណល់រឹងទូទាំងប្រទេស។

**ក្រាហ្វិក ៩២. ភាគរយការផ្ដល់សេវា ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន នៅក្រុង ស្រុក ទាំង១៨៥ទូទាំងប្រទេស ឆ្នាំ២០១៧**




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០១៩។

## ក៤. តំបន់ការពារ

តំបន់ការពារនៅក្នុងប្រទេសកម្ពុជាចែកជា៤ផ្នែកធំៗគឺ ១) ឧទ្យានជាតិ(National Park) មានផ្ទៃដី សរុប ៧៤២,៣ ពាន់ហិកតាស្មើនឹង ១៣,៨% ២) តំបន់ការពារសត្វព្រៃ (Wildlife Sanctuary) មានផ្ទៃដីចំនួន៤.១៣៧,៦ ពាន់ហិកតា ស្មើនឹង ៧៦,៩% ៣) តំបន់ប្រាសាទ (Protected Land Scape) មានចំនួន ៩៧ ពាន់ហិកតា ស្មើនឹង ១,៨% និងតំបន់គ្រប់គ្រងប្រើប្រាស់ច្រើនយ៉ាង (Multiple Use Management) មានចំនួន ៤០៣,៩ ពាន់ហិកតា ស្មើនឹង ៧,៥%។

**ក្រាហ្វិក៩៣. តំបន់ការពារ**




ប្រភព៖ ក្រសួងបរិស្ថាន

*សំគាល់: សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ ២០១៧* វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បោះពុម្ពខែមករា ឆ្នាំ ២០១៨។

## ក៥.១. តំបន់ការពារធម្មជាតិ និងព្រៃការពារ

### ក៥.១.១ តំបន់ការពារធម្មជាតិ

តំបន់ការពារធនធានធម្មជាតិ គឺជាដែនដីសម្បត្តិសាធារណៈរបស់រដ្ឋ រួមមានដែនដីគោក ឬដែនទឹក រួមទាំងឆ្នេរសមុទ្រ និងសមុទ្រ ស្ថិតនៅក្នុងតំបន់ដែលទទួលស្គាល់ដោយបញ្ញត្តិនៃច្បាប់ ឬតំបន់ដែលបង្កើតថ្មីក្នុងដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដែលធានាបាននូវការការពារប្រភេទសត្វព្រៃ និងរុក្ខជាតិសំខាន់ៗ ក៏ដូចជាសហគមន៍ធម្មជាតិ។ រហូតមកដល់ឆ្នាំ២០២១នេះ កម្ពុជាមានតំបន់ការពារធនធានធម្មជាតិចំនួន ៧៣ ដែលមានផ្ទៃដីសរុប ៧,២៩៧,៣១៤ ហិកតា ស្មើនឹង

៤១% នៃផ្ទៃដីប្រទេសកម្ពុជាទាំងមូល។ តំបន់ការពារធនធានធម្មជាតិចំនួន៧៣នេះ គឺស្ថិតនៅក្នុងប្រភេទតំបន់ការពារធំៗចំនួន ៨ រួមមាន៖

**ទី១៖ តំបន់ឧទ្យានជាតិ៖** តំបន់ឧទ្យានជាតិនេះមានចំនួន ១១ តំបន់ផ្សេងៗគ្នា និងមានផ្ទៃដីសរុប ១,៧១៧,៦១៤ ហិកតា រួមមាន ឧទ្យានជាតិកែប ឧទ្យានជាតិព្រះមុនីវង្ស «**បូកគោ** » ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ «គិរីរម្យ» ឧទ្យានជាតិសីហនុ-រាម ឧទ្យានជាតិបុទុមសាគរ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ឧទ្យានជាតិវីរជ័យ ឧទ្យានជាតិវើនសៃ-សៀមប៉ាង ឧទ្យានជាតិអូរយ៉ាដាវ ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង។ តំបន់ឧទ្យានជាតិទាំងនេះ សម្បូរទៅដោយសត្វព្រៃកម្រជាច្រើនប្រភេទ និងសម្បត្តិទៅដោយព្រៃស្រោង ព្រៃរបោះ និងជាតំបន់ទាក់ទាញភ្ញៀវទេសចរឱ្យចូលទស្សនាបានយ៉ាងច្រើនផងដែរ។

**ទី២៖ តំបន់ដែនជម្រកសត្វព្រៃ៖** តំបន់ដែនជម្រកសត្វព្រៃនេះត្រូវបែងចែកជា ១៩ តំបន់ផ្សេងៗគ្នា និងមានផ្ទៃដីសរុប ៣,៤៣៣,៣៣៦ ហិកតា រួមមាន ដែនជម្រកសត្វព្រៃឱរ៉ាល់ ដែនជម្រកសត្វព្រៃពាមក្រសោប ដែនជម្រកសត្វព្រៃភ្នំសំកុស ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ដែនជម្រកសត្វព្រៃបឹងពែរ ដែនជម្រកសត្វព្រៃលំផាត់ ដែនជម្រកសត្វព្រៃភ្នំព្រេច ដែនជម្រកសត្វព្រៃភ្នំណាមលៀរ ដែនជម្រកសត្វព្រៃព្រៃឡង់ ដែនជម្រកសត្វព្រៃព្រះរកា ដែនជម្រកសត្វព្រៃឆែប ដែនជម្រកសត្វព្រៃតាតៃ ដែនជម្រកសត្វព្រៃកែវសីមា ដែនជម្រកសត្វព្រៃស្រែពក ដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពក ដែនជម្រកសត្វព្រៃសង្ឃរុក្ខវ័ន្ត ដែនជម្រកសត្វព្រៃព្រែកប្រសព្វ ដែនជម្រកសត្វព្រៃសំបូរ និងដែនជម្រកសត្វព្រៃសៀមប៉ាង។ តំបន់ដែនជម្រកសត្វព្រៃទាំងនេះសម្បូរទៅដោយប្រភេទសត្វព្រៃជិតផុតពូជ សត្វព្រៃកម្រ សត្វព្រៃរងការគំរាមកំហែង ពពួកមច្ឆាជាតិជិតផុតពូជ និងកម្រ ព្រមទាំងជាជម្រកសត្វព្រៃ និងជីវចម្រុះជាច្រើនប្រភេទ ពិសេសសម្បូរទៅដោយធនធានធម្មជាតិ ព្រៃស្រោង និងព្រៃរបោះជាដើម។

**ទី៣៖ តំបន់ទេសភាព៖** តំបន់ទេសភាពនេះត្រូវបែងចែកជា ១៣ តំបន់ផ្សេងៗគ្នា និងមានផ្ទៃដីសរុប ១៥៣,៦០៤ ហិកតា រួមមាន តំបន់រមណីយដ្ឋានអង្គរ តំបន់បន្ទាយឆ្មារ តំបន់ព្រះវិហារ តំបន់អង្គង់ព្រីង តំបន់ទំនាបខាងជើងទន្លេសាប តំបន់បឹងព្រែកល្ពៅ តំបន់អាងត្រពាំងថ្ម តំបន់ប្រាសាទបាកាន ß ព្រះខ័នកំពង់ស្វាយàតំបន់រនាមដូនសំ តំបន់សំបូរព្រៃគុក តំបន់បឹងលំកុដ តំបន់ភ្នំក្រាំងដីមាស និងតំបន់បឹងយ៉ាកអោម-យ៉ាកកាវ៉ា។ សម្រាប់តំបន់ទេសភាពនេះ គឺសម្បូរទៅដោយប្រាង្គប្រាសាទបុរាណ សម្បត្តិបេតិកភណ្ឌវប្បធម៌ ព្រៃឈើ និងធនធានធម្មជាតិជាច្រើនទៀត។

**ទី៤៖ តំបន់ប្រើប្រាស់ច្រើនយ៉ាង៖** តំបន់ប្រើប្រាស់ច្រើនយ៉ាងត្រូវបែងចែកជា ៨ តំបន់ផ្សេងៗគ្នា និងមានផ្ទៃដីសរុប ៤១៥,៧៩៦ ហិកតា រួមមាន តំបន់ដងព្រែក តំបន់សំឡូត តំបន់ទន្លេសាប តំបន់ពញាក្រែក តំបន់ព្រែកទឹកសាបក្បាលឆាយ តំបន់ភ្នំនាងកង្រី-ភ្នំទូកមាស តំបន់សសរស្តម្ភសត្វតោ និងតំបន់បឹងយក្ខឡោម។

**ទី៥៖ តំបន់រ៉ាមសារ៖** តំបន់រ៉ាមសារត្រូវបែងចែកជា ៥ តំបន់ និងមានផ្ទៃសរុប ៦០,៩៩៥ ហិកតា រួមមាន តំបន់ស្ទឹងត្រែង តំបន់កោះកាពិ បឹងទន្លេឆ្មារ តំបន់ព្រែកទាល់ និងតំបន់ស្ទឹងសែន។

**ទី៦៖ តំបន់ស្នូលនៃបបនីយជីវមណ្ឌល៖** តំបន់ស្នូលនៃបបនីយជីវមណ្ឌលនេះត្រូវបែងចែកជា ៣ តំបន់ផ្សេងៗគ្នា និងមានផ្ទៃសរុប ៤២,២៥៧ ហិកតា រួមមាន តំបន់ព្រែកទាល់ តំបន់ស្ទឹងសែន និងតំបន់បឹងទន្លេឆ្មារ។

**ទី៧៖ តំបន់បេតិកភណ្ឌធម្មជាតិ៖** តំបន់បេតិកភណ្ឌធម្មជាតិនេះត្រូវបែងចែកជា ១១ តំបន់ផ្សេងៗគ្នា និងមានផ្ទៃដីសរុប ៣៣,៩៥១ ហិកតា រួមមាន តំបន់ភ្នំត្បែង តំបន់ភ្នំយ៉ាត តំបន់ភ្នំប្រាំពីរ តំបន់ជញ្ជាំង តំបន់គិរីយង់ តំបន់ភ្នំទាក់ទ្រាំង តំបន់ភ្នំព្រះនេត្រព្រះ តំបន់ភ្នំព្រះ-ភ្នំវែង តំបន់ភ្នំយាយសំ តំបន់ភ្នំបាក់ និងតំបន់ភ្នំស្វាយ។

**ទី៨៖ តំបន់ឧទ្យានសមុទ្រ៖** តំបន់ឧទ្យានសមុទ្រនេះមានផ្ទៃដីសរុប ៥២,៤៤៨ ហិកតា គឺតំបន់សមុទ្រកោះរ៉ុង។ ក្រៅពីនេះ ក៏នៅមានតំបន់អភិរក្សទឹកសាបបឹងព្រែកទប់ ដែលមានផ្ទៃដីសរុប ១,៦៣០ ហិកតា និងរបៀងអភិរក្សជីវចម្រុះ ដែលមានផ្ទៃដីសរុប ១៤២,៧៩៤០ ហិកតា។ ការបង្កើតឱ្យមានតំបន់ការពារទាំងអស់នេះ របស់រាជរដ្ឋាភិបាល គឺក្នុងគោលបំណងកែប្រែតំបន់នានាឱ្យក្លាយទៅជាតំបន់បេតិកភណ្ឌធម្មជាតិភ្នំ លើកស្ទួយតម្លៃទៅលើប្រវត្តិសាស្ត្រ វប្បធម៌ ការអភិរក្ស ជីវចម្រុះ លើកស្ទួយជីវភាពប្រជាពលរដ្ឋ និងវិស័យទេសចរណ៍នៅតំបន់ទាំងនោះ។

**តារាង ៥២. ចំនួនផ្ទៃដីតំបន់ការពារធម្មជាតិ**

| លរ | ប្រភេទតំបន់ការពារធម្មជាតិ | ផ្ទៃដីគិតជាហិកតា |
|---|---|---|
| 1 | តំបន់ឧទ្យានជាតិ | 1,717,614 |
| 2 | តំបន់ដែនជម្រកសត្វព្រៃ | 3,433,336 |
| 3 | តំបន់ទេសភាព | 153,604 |
| 4 | តំបន់ប្រើប្រាស់ច្រើនយ៉ាង | 415,796 |
| 5 | តំបន់រ៉ាមសា | 60,994 |
| 6 | តំបន់ស្នូលនៃបបនីយជីវមណ្ឌល | 42,257 |
| 7 | តំបន់បេតិកភណ្ឌធម្មជាតិ | 33,951 |
| 8 | តំបន់ឧទ្យានសមុទ្រ | 52,448 |
| | **សរុប** | **5,910,000** |

សំគាល់៖ផ្ទៃដីតំបន់ឧទ្យានសមុទ្រខាងលើមិនបានរាប់បញ្ចូលផ្ទៃដីតំបន់អភិរក្សទឹកសាបបឹងព្រែកទប់ដែលមានផ្ទៃដី ១.៦៣០ហិកតា និងរបៀងអភិរក្សជីវចម្រុះ ដែលមានផ្ទៃដីសរុប ១.៤២៧.៩៤០ ហិកតា ទេ។

ប្រភព៖ ក្រសួងបរិស្ថាន *តំបន់ការពារធម្មជាតិ* [website], 15 March 2021. https:// www.moe.gov.kh/index/29971. (Accessed 23 August 2023).

ក្រាហ្វិក ៩៤. ភាគរយតាមប្រភេទតំបន់ការពារធម្មជាតិ




## ក៥.១.២ តំបន់ព្រៃការពារ

នៅក្នុងប្រទេសកម្ពុជាមានព្រៃ ៥ ប្រភេទធំៗ ព្រៃជ្រុះស្លឹករួមទាំងព្រៃល្បោះ (១៨,៥%) ព្រៃស្រោង (១៥,៨%) ព្រៃពាក់កណ្តាលស្រោង (៥,៩%) ព្រៃលិចទឹក (២,៦%) និងព្រៃផ្សេងៗ (៥%) ដែលរាប់បញ្ចូលព្រៃដុះឡើងវិញ និងព្រៃលូតលាស់ឡើងវិញ ព្រៃកោងកាង កៅស៊ូ ចម្ការឈើ ចម្ការដូងប្រេង និងឬស្សី ខណៈដែល តំបន់មិនមានព្រៃមានប្រមាណ ៥២%។ នៅចន្លោះឆ្នាំ២០០៦ ដល់ ២០១៨ ប្រទេសកម្ពុជាបាត់បង់ព្រៃឈើចំនួន ២,៧ លានហិកតា នៅក្នុងគ្រប់តំបន់អេកូឡូស៊ីទាំងអស់។ តំបន់មេគង្គខាងកើត និងតំបន់ទំនាបកណ្តាលបាត់បង់ព្រៃឈើក្នុងផ្ទៃដីធំជាងគេបំផុតចំនួន ៧៦០ ០០០ ហិកតា នៅក្នុងមួយតំបន់ ចំណែកឯគម្របព្រៃឈើក្នុងតំបន់ប្រជុំភ្នំក្រវាញ ហាក់បីនៅមានចំនួនថេរ (ក្រសួងបរិស្ថានឆ្នាំ២០១៨)។

## ក្រាហ្វិក ៩៥. ប្រភេទព្រៃឈើ




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ២០២១ ។

### ៩.១.៣ គម្របព្រៃឈើ

ប្រទេសកម្ពុជា គឺជាប្រទេសមួយ ដែលរក្សាបានគម្របព្រៃឈើមានចំនួនខ្ពស់ជាងគេបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះ ។ តែទោះបីយ៉ាងណាក៏ដោយ និន្នាការនៃការប្រែប្រួលគម្របព្រៃឈើពីឆ្នាំ ១៩៦៥ មានចំនួនប្រហែល ៧៣% បានថយចុះមកត្រឹម ៤៧% នៅឆ្នាំ២០១៨ ។

## ក្រាហ្វិក ៩៦. ការប្រែប្រួលគម្របព្រៃឈើ




សំគាល់÷ ព្រៃឈើទូទាំងប្រទេសរួមបញ្ចូលចម្ការកៅស៊ូ និងចម្ការដូងប្រេង។

ប្រភព÷ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

## ក៤.១.៤ តំបន់វាលភក់ និងលក្ខណៈពិសេស

តំបន់វាលភក់មាននៅតាមដងទន្លេដូចជាទន្លេមេគង្គ ទន្លេស្រែពក ទន្លេសេកុង និងតំបន់ដែលមានបឹងធំៗ ជាដើម ដែលមានចំនួន ១៧ គឺ បឹងព្រីង ប្រព័ន្ធទន្លេក្រចេះ ប្រព័ន្ធទន្លេស្រែពក ប្រព័ន្ធទន្លេសេសាន ព្រៃលិចទឹក ទន្លេមេគង្គស្ទឹងត្រែង ប្រព័ន្ធទន្លេមេគង្គពាមជីលាំង បឹងប្រាសាទទុយោ បឹងវាលសំណាប់ បឹងប្រាំង បឹងចាំងរុង ប្រព័ន្ធសុងសែនខាងលើ ភូមិមុតពាម បឹងវាលដំរី ស្ទឹងសែនទាប បឹងឆ្មា និង បឹងវាលពក ។

### ក្រាហ្វិក ៩៧. តំបន់វាលភក់ គិតជាហិកតា




ប្រភព÷ ក្រសួងបរិស្ថាន

*សំគាល់: សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ ២០១៧* វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បោះពុម្ពខែមករា ឆ្នាំ ២០១៨។

## ខ. ទឹកស្អាត និងទឹកកខ្វក់






ទឹកបានដើរតួនាទីយ៉ាងសំខាន់ជាគ្រឹះសម្រាប់ការអភិវឌ្ឍនានានៃប្រទេសមួយ។ ប្រទេសកម្ពុជាពិតជាមានចំណងជាក់លាក់ខ្លាំងទៅនឹងអ្វីដែលត្រូវបានហៅ មាសខៀវ ដូចដែលវាត្រូវបានគេចាត់ទុកថា ជាប្រទេសមួយ ដែលអំណោយទានដ៏ពិសិដ្ឋ ជាពិសេសធនធានទឹក។ ភ្នំគូលែននៃអតីតចក្រភពខ្មែរ មានភាពល្បីល្បាញដោយសារទឹកដ៏ពិសិដ្ឋ ហើយរាជធានីអង្គរវត្ត ក៏បានបង្ហាញពីប្រព័ន្ធធារាសាស្ត្រដ៏ទំនើបបំផុតនៃសម័យនោះផងដែរ។ ប្រជាជនកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងទៅលើទឹកសាបជាជាងតំបន់ឆ្នេរសមុទ្រ ជាពិសេសផលផលទឹកសាប សម្រាប់ទ្រទ្រង់ដល់ជីវភាពរស់នៅ និងសម្រាប់ជាប្រភពប្រូតេអ៊ីនចម្បងរបស់ពួកគេ។ ប្រទេសកម្ពុជាទទួលរងនូវអាកាសធាតុត្រូពិច ដែលនាំឱ្យមានការឆ្លាស់គ្នានៃរដូវខ្វះទឹក និងរដូវទឹកច្រើនហួស។ ប្រភពទឹកសាបសំខាន់ៗរបស់ប្រទេសកម្ពុជាមានដូចជាទន្លេមេគង្គ ទន្លេស្រែពក ទន្លេសេកុង ទន្លេសាប ទន្លេបាសាក់ ស្ទឹង ព្រែក ទឹកបឹង ទឹកត្រពាំង ទឹកចេញពីក្រោមដី និងទឹកភ្លៀងជាដើម។ ទន្លេមេគង្គ និងទន្លេសាបមានសារៈសំខាន់សម្រាប់ប្រព័ន្ធជលសាស្ត្រកម្ពុជា ហើយវាជាប្រភពដ៏សំខាន់សម្រាប់ការផ្គត់ផ្គង់ប្រូតេអ៊ីននៅកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ វាត្រូវបានផ្លាស់ប្តូរ ខណៈពេលដែលចំនួនប្រជាជនកំពុងតែកើនឡើង ហើយតម្រូវការទឹកកំពុងកើនឡើងជាមួយនឹងកង្វះការការពារ ដែលប្រកបដោយប្រសិទ្ធភាព។ កំណើនសេដ្ឋកិច្ចបាននាំឱ្យមានតម្រូវការទឹកខ្លាំងសម្រាប់វិស័យឧស្សាហកម្ម និងកសិកម្ម ដែលធ្វើឱ្យមានការប្រកួតប្រជែងរវាងវិស័យទាំងនេះជាមួយនឹងវិស័យផ្សេងទៀត ហើយវាកំពុងតែធ្វើឱ្យមានការប៉ះពាល់ទាំងបរិមាណ និងគុណភាពទឹក។

គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពទី ៦ មានចំណុចដៅចំនួន ៨ និងសូចនាករចំនួន ១១ ដែលនឹងត្រូវប្រើ ដើម្បីជម្រុញសកម្មភាពឆ្ពោះទៅរកការទទួលបានជាសកលនូវការគ្រប់គ្រងទឹកស្អាត និង អនាម័យដោយសុវត្ថិភាព និងការគ្រប់គ្រងធនធានទឹកសមស្រប។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៦ ទទួលស្គាល់ការគ្រប់គ្រងទឹកប្រកបដោយចីរភាព សំដៅលើការផ្គត់ផ្គង់ទឹកស្អាត (ចំណុចដៅ ៦.១) និង អនាម័យ (ចំណុចដៅ ៦.២) ដែលជាសិទ្ធិមនុស្សជាមូលដ្ឋាន។ គោលដៅនេះ ក៏ផ្តោតលើបញ្ហាដូចជា គុណភាពទឹក និងការគ្រប់គ្រងសំណល់រាវ (ចំណុចដៅ ៦.៣) កង្វះខាតទឹក និងការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព (ចំណុចដៅ ៦.៤) ការគ្រប់គ្រងធនធានទឹក (ចំណុចដៅ ៦.៥) និងការការពារ និងការស្តារប្រព័ន្ធអេកូឡូស៊ីទាក់ទងនឹងទឹក (ចំណុចដៅ ៦.៦)។

## ២១.ទឹកស្អាត

### ២១.១ ទីតាំងប្រភពទឹក

ក្រាហ្វិក ៩៨ បានបង្ហាញថាភាគរយគ្រួសារដែលមានទីតាំងប្រភពទឹកសម្រាប់ទទួលទាននៅក្នុងបរិវេណលំនៅដ្ឋានសម្រាប់នៅទូទាំងប្រទេសនៅឆ្នាំ២០០៨ មានចំនួនគ្រួសារ ៣៦% និងបានកើនដល់ ៦៤% នៅឆ្នាំ២០១៩។ តំបន់ទំនាបកណ្តាលនៅឆ្នាំ២០០៨ មានចំនួនគ្រួសារ ៤៦% បាន

កើនដល់ ៧៥% នៅឆ្នាំ២០១៩។ ខេត្តកំពង់ចាមនៅឆ្នាំ២០០៨ មានចំនួនគ្រួសារ ៣២% បានកើនដល់៦៧% នៅឆ្នាំ២០១៩ និងខេត្តត្បូងឃ្មុំនៅឆ្នាំ២០០៨ មានចំនួនគ្រួសារ ៤២% បានកើនដល់ ៦៨% នៅឆ្នាំ២០១៩។ ចំពោះភាគរយទីតាំងប្រភពទឹកដែលមានចម្ងាយទៅយកទឹកតិចជាង៣០នាទី នៅទូទាំងប្រទេសនៅឆ្នាំ២០០៨ មានចំនួន ៣១ភាគរយ បានធ្លាក់ចុះមក ២៥ភាគរយនៅឆ្នាំ ២០១៩ និងចម្ងាយទៅយកទឹកច្រើនជាង៣០នាទីមានប្រហែល១២ភាគរយ នៅឆ្នាំ២០១៩។ តំបន់ទំនាបកណ្តាលចម្ងាយរយៈពេលទៅយកទឹកតិច៣០នាទីនៅឆ្នាំ២០០៨ មាន២៩% បានថយចុះមកត្រឹម១៨% នៅឆ្នាំ២០១៩ និងចម្ងាយរយៈពេលទៅយកទឹកច្រើនជាង៣០នាទីមាន២៤% នៅឆ្នាំ ២០០៨ បានថយចុះឡើង ៦%នៅឆ្នាំ២០១៩។ ខេត្តកំពង់ចាមមានចម្ងាយទៅយកទឹកតិចជាង៣០នាទីនៅឆ្នាំ២០០៨ មានចំនួន ៣១% បានធ្លាក់ចុះមកត្រឹម ២៥% នៅឆ្នាំ២០១៩ និងចម្ងាយទៅយកទឹកច្រើនជាង៣០នាទីមាន ៣៧% នៅឆ្នាំ២០០៨ បានថយចុះមកត្រឹមតែ៨% នៅឆ្នាំ២០១៩។ ខេត្តត្បូងឃ្មុំចម្ងាយទៅយកទឹកតិចជាង៣០នាទី ឆ្នាំ២០០៨ មានចំនួន ៣៧% បានធ្លាក់ចុះមក ២៦% នៅឆ្នាំ២០១៩ និងចម្ងាយទៅយកទឹកច្រើនជាង៣០នាទីមាន ២១% នៅឆ្នាំ២០០៨ បានថយចុះមកត្រឹមតែ៦%នៅឆ្នាំ២០១៩ (ក្រាហ្វិក៩៨ និងតារាង៤៩)។

**ក្រាហ្វិក ៩៨. ភាគរយគ្រួសារ តាមទីតាំងប្រភពទឹកទទួលទាន**




ប្រភព៖ លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៨ និងឆ្នាំ២០១៩

## តារាង ៥៣. ចំនួនគ្រួសារតាមទីតាំងប្រភពទឹកដែលយកមកប្រើប្រាស់

| កម្ពុជា/តំបន់/ខេត្ត | 2008 | | | 2019 | | |
|---|---|---|---|---|---|---|
| | ទីតាំងបរិវេណផ្ទះ | តិចជាង ៣០នាទី | ច្រើនជាង ៣០នាទី | ទីតាំងបរិវេណផ្ទះ | តិចជាង ៣០នាទី | ច្រើនជាង ៣០នាទី |
| កម្ពុជា | 1,019,955 | 887,696 | 909,986 | 2,261,291 | 870,250 | 421,480 |
| តំបន់ទំនាបកណ្តាល | 646,855 | 415,680 | 336,017 | 1,332,931 | 323,421 | 113,013 |
| កំពង់ចាម | 65,982 | 64,473 | 75,665 | 146,017 | 54,446 | 16,734 |
| ត្បូងឃ្មុំ | 63,780 | 57,373 | 33,211 | 121,163 | 47,151 | 10,628 |

ប្រភព÷ លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៨ និងឆ្នាំ២០១៩

## ១១.២. ការប្រើប្រាស់ទឹកស្អាត

នៅឆ្នាំ១៩៩៨ នៅទូទាំងប្រទេសមានចំនួនគ្រួសារសរុប២,២ លានគ្រួសារ តែគ្រួសារដែលមានទឹកស្អាតប្រើប្រាស់មាន ២៩% និង នៅឆ្នាំ២០០៨ មានគ្រួសារសរុប២,៨លានគ្រួសារ ចំពោះគ្រួសារដែលមានទឹកស្អាតប្រើប្រាស់បានកើនដល់ ៤៧% កើនឆ្នាំ១៩៩៨ជិត២ដង ខណៈដែលឆ្នាំ២០១៩ មានចំនួនគ្រួសារសរុបមានចំនួន៣,៦ លានគ្រួសារ ហើយគ្រួសារដែលមានទឹកស្អាតប្រើប្រាស់កើនដល់៧៣% កើនជាងឆ្នាំ២០០៨ ជិត២ដង។ នៅតំបន់ទំនាបកណ្តាលភាគរយនៃគ្រួសារប្រើប្រាស់ទឹកស្អាតបានកើនឡើងពី៤០% ទៅ៨១% ពីឆ្នាំ១៩៩៨ ដល់២០១៩ ខណៈដែលខេត្តកំពង់ចាមបានកើនឡើងពី២៥% ទៅ៨១% និងខេត្តត្បូងឃ្មុំ បានកើនឡើងពី១១% ទៅ៨៦% ពីឆ្នាំ១៩៩៨ ដល់២០១៩ (តារាង ៥៤ និងក្រាហ្វិក៩៩)។

## តារាង ៥៤. ចំនួនគ្រួសារដែលមានទឹកស្អាតប្រើប្រាស់

| កម្ពុជា/តំបន់/ខេត្ត | 1998 | | 2008 | | 2019 | |
|---|---|---|---|---|---|---|
| | ចំនួនគ្រួសារ | ចំនួនគ្រួសារមានទឹកស្អាតប្រើប្រាស់ | ចំនួនគ្រួសារ | ចំនួនគ្រួសារមានទឹកស្អាតប្រើប្រាស់ | ចំនួនគ្រួសារ | ចំនួនគ្រួសារមានទឹកស្អាតប្រើប្រាស់ |
| កម្ពុជា | 2,162,086 | 627,914 | 2,817,637 | 1,319,472 | 3,553,021 | 2,588,652 |
| តំបន់ទំនាបកណ្តាល | 1,126,660 | 449,167 | 1,398,552 | 821,394 | 1,769,365 | 1,525,634 |
| កំពង់ចាម | 178,438 | 45,233 | 206,120 | 74,024 | 217,197 | 174,967 |
| ត្បូងឃ្មុំ | 132,713 | 14,883 | 161,994 | 67,516 | 178,942 | 153,302 |

### ក្រាហ្វិក ៥៩. ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់




ប្រភព៖ (១)ជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ១៩៩៨ លទ្ធផលជំរឿនសរុបចុងក្រោយ
(២)ជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨ របាយការណ៍ជាតិស្ដីពីលទ្ធផលចុងក្រោយ
(៣)ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ របាយការណ៍ជាតិស្ដីពីលទ្ធផលចុងក្រោយ

សំគាល់៖ ១) ទឹកស្អាតឆ្នាំ១៩៩៨ រួមមានទឹកបណ្ដាញ អណ្ដូងខួង/អណ្ដូងស្នប់ និងទឹកទិញ
២) ទឹកស្អាតឆ្នាំ២០០៨ រួមមានទឹកបណ្ដាញ អណ្ដូងខួង/អណ្ដូងស្នប់ អណ្ដូងជីកមានគម្រប និងទឹកភ្លៀង
៣) ទឹកស្អាតឆ្នាំ២០១៩ រួមមានទឹកបណ្ដាញ ទឹកបំពង់បណ្ដាញក្នុងទីធ្លា/បរិវេណផ្ទះ ទឹកបំពង់សាធារណៈ អណ្ដូងខួង/អណ្ដូងស្នប់ អណ្ដូងជីកមានគម្រប ទឹកភ្លៀង និងទឹកពិសារ(ដប)។

## ១២.ទឹកកខ្វក់

ផ្អែកតាមរបាយការណ៍ស្ថានភាពបរិស្ថានលើកទី ៣ ឆ្នាំ២០១៩ បង្ហាញថា បរិមាណសំណល់រាវបញ្ចេញចោលនៅរាជធានីភ្នំពេញក្នុងឆ្នាំ២០១៣ មានប្រមាណ១០៨.១៩៨.៧២៥ ម$^{៣}$/ឆ្នាំ គឺមានការកើនឡើងប្រមាណ ១៧.៨៩៨.៥៧៤ ម$^{៣}$/ឆ្នាំ បើប្រៀបធៀបឆ្នាំ ២០១២។ មានន័យថា ឆ្នាំ ២០១២ បរិមាណសំណល់រាវដែលបញ្ចេញចោលនៅរាជធានីភ្នំពេញ មាន ៩០.២៩៩.២៣៤ម$^{៣}$/ឆ្នាំ។ បរិមាណបញ្ចេញចោលនេះមានការកើនឡើងជាប្រចាំ ពីមួយឆ្នាំទៅមួយឆ្នាំ ។ ក្រាហ្វិក ៥៧ បង្ហាញពីបរិមាណទឹកកខ្វក់នៅរាជធានីភ្នំពេញ ដែលបានបញ្ចេញចោលនៅក្នុងចន្លោះឆ្នាំ ២០០៦ ដល់ ២០១៧។

## ក្រាហ្វិក ១០០. បរិមាណទឹកកខ្វក់បញ្ចេញពីរាជធានីភ្នំពេញ ឆ្នាំ២០០៦ ដល់ ២០១៧




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៣* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០១៩។

### គ. បង្គន់អនាម័យ

នៅឆ្នាំ១៩៩៨ នៅទូទាំងប្រទេសមានចំនួនគ្រួសារសរុប២,២ លានគ្រួសារ តែគ្រួសារដែលមានទឹកបង្គន់អនាម័យប្រើប្រាស់មាន ១៤% និង នៅឆ្នាំ២០០៨ មានគ្រួសារសរុប២,៨លានគ្រួសារ ចំពោះគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់បានកើនដល់ ៣៤% កើនឆ្នាំ១៩៩៨ ជាង២ដង ខណៈដែលឆ្នាំ២០១៩ មានចំនួនគ្រួសារសរុបមានចំនួន៣,៦ លានគ្រួសារ ហើយគ្រួសារដែលមានទឹកស្អាតប្រើប្រាស់កើនដល់៨៣% កើនជាងឆ្នាំ២០០៨ ជិត៣ដង។ នៅតំបន់ទំនាបកណ្តាលភាគរយនៃគ្រួសារប្រើប្រាស់បង្គន់អនាម័យបានកើនឡើងពី១៨% ទៅ៨៨% ពីឆ្នាំ១៩៩៨ ដល់២០១៩ ខណៈដែលខេត្តកំពង់ចាមបានកើនឡើងពី១១% ទៅ៨៣% និងខេត្តត្បូងឃ្មុំ បានកើនឡើងពី៨% ទៅ៧៣% ពីឆ្នាំ១៩៩៨ ដល់២០១៩ (តារាង ៥៥ និងក្រាហ្វិក១០១)។

## តារាង ៥៥. ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់

| កម្ពុជា/តំបន់/ខេត្ត | 1998 | | 2008 | | 2019 | |
|---|---|---|---|---|---|---|
| | គ្រួសារ | គ្រួសារមាន បង្គន់ប្រើប្រាស់ | គ្រួសារ | គ្រួសារមាន បង្គន់ប្រើប្រាស់ | គ្រួសារ | គ្រួសារមាន បង្គន់ប្រើប្រាស់ |
| កម្ពុជា | 2,162,086 | 312,990 | 2,817,637 | 949,691 | 3,553,021 | 2,943,161 |
| តំបន់ទំនាបកណ្ដាល | 1,126,660 | 203,385 | 1,398,552 | 544,072 | 1,769,365 | 1,560,607 |
| កំពង់ចាម | 178,438 | 19,108 | 206,120 | 58,762 | 217,197 | 180,001 |
| ត្បូងឃ្មុំ | 132,713 | 10,914 | 161,994 | 35,344 | 178,942 | 129,790 |

## ក្រាហ្វិក ១០១. ភាគរយចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់




ប្រភពៈ (១)ជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ១៩៩៨ លទ្ធផលជំរឿនសរុបចុងក្រោយ
(២)ជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨ របាយការណ៍ជាតិស្ដីពីលទ្ធផលចុងក្រោយ
(៣)ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ របាយការណ៍ជាតិស្ដីពីលទ្ធផលចុងក្រោយ

## ៣.១.៤ ស្ថានភាពគ្រោះមហន្តរាយ



គ្រោះមហន្តរាយ គឺបានកើតឡើងស្ទើរគ្រប់ប្រទេសទាំងអស់ដែលរស់នៅលើពិភពលោក មិនថាប្រទេសអភិវឌ្ឍន៍ និងប្រទេសមិនទាន់អភិវឌ្ឍន៍ឡើយ។ គ្រោះមហន្តរាយទាំងអស់នោះបានកើតឡើងដោយធម្មជាតិ ជំងឺឆ្លង និងដោយសារសង្គ្រាម។ គ្រោះមហន្តរាយធម្មជាតិមានដូចជា រញ្ជួយដី បន្ទុះភ្នំភ្លើង បាក់ដី ភ្លើងឆេះព្រៃដោយគ្រោះរាំងស្ងួត រលកយក្សស៊ូណាមី ព្យុះ ទឹកជំនន់។ គ្រោះមហន្តរាយបង្ករដោយសង្គ្រាមបានបន្សល់ទុកនូវគ្រាប់ អាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បំផ្លាញលំនៅដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធ បង្កឲ្យប្រជាជនស្លាប់ និងភ័យខ្លាចជាដើម។

### ក. គ្រោះមហន្តរាយធម្មជាតិ

### ក១. សកលលោក

### ក១.១ ចំនួនគ្រោះមហន្តរាយ

គ្រោះមហន្តរាយធម្មជាតិមានដូចជា រញ្ជួយដី បន្ទុះភ្នំភ្លើង បាក់ដី ភ្លើងឆេះព្រៃដោយគ្រោះរាំងស្ងួត រលកយក្សស៊ូណាមី ព្យុះ ទឹកជំនន់។ យោងតាមរបាយការណ៍វាយតម្លៃអំពីគ្រោះមហន្តរាយធម្មជាតិសកលឆ្នាំ ២០២៤ បានបង្ហាញថាចំនួនករណីគ្រោះមហន្តរាយដែលបានកើតឡើងនៅលើពិភពលោកមានចំនួន ៣៩៣ ដង បានធ្វើឲ្យមនុស្សស្លាប់ ១៦ ៧៥៣នាក់ ធ្វើឲ្យប៉ះពាល់ដល់មនុស្ស ១៦៧,២ លាននាក់ និងធ្វើឲ្យខូចខាតសេដ្ឋកិច្ច ២៤២ ប៊ីលានដុល្លារអាមេរិក។

ក្រាហ្វិក ១០២ បានបង្ហាញអំពីចំនួនគ្រោះមហន្តរាយដែលបានកើតឡើង តាមទ្វីប និងប្រទេសចំនួន១១ ដែលទទួលរងគ្រោះមហន្តរាយធ្ងន់ធ្ងរឆ្នាំ២០២៤។ ក្នុងចំណោមទ្វីទាំង៥ ដែលមានគ្រោះមហន្តរាយច្រើនជាងគឺទ្វីបអាស៊ីមានចំនួន១៦៧ ដង ទ្វីបអាមេរិកមានចំនួន ១១៨ដង ទ្វីបអាហ្វ្រិក ៧៥ដង ទ្វីបអឺរ៉ុបមានចំនួន ២៤ដង និងទ្វីបអូសេអានីមានចំនួន ៩ដង។ នៅក្នុងទ្វីបអាស៊ីចំនួនគ្រោះមហន្តរាយបានកើតឡើងចំនួន១៦៧ដង ក្នុងនោះប្រទេសដែលស្ថិតនៅក្នុងទ្វីអាស៊ីដែលរងគ្រោះធ្ងន់ធ្ងររួមមាន ប្រទេសឥណ្ឌូនេស៊ីមានចំនួន២០ដង ចិន ១៨ដង ហ្វីលីពីន១៨ដង ឥណ្ឌា ១៥ដង វៀតណាម ១០ដង អាហ្គានីស្ថាន ៨ដង និងប្រទេសថៃចំនួន ៧ដង។ នៅក្នុងទ្វីបអាមេរិកសរុបចំនួនគ្រោះមហន្តរាយបានកើតឡើងចំនួន១១៨ដង ក្នុងប្រទេសដែលរងគ្រោះធ្ងន់ធ្ងរជាងគេគឺប្រទេសអាមេរិកចំនួន ២៩ដង ប្រេស៊ីល១១ដង ម៉ិកស៊ិកូ ៨ដង និងប្រទេសកាណាដាចំនួន៧ដង។ នៅក្នុងក្រាហ្វិក៥៨ បង្ហាញអំពីចំនួនគ្រោះមហន្តរាយចាប់តាំងពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០២៤។ តាមក្រាហ្វិកខាងក្រោមបង្ហាញថា នៅលើពិភពលោកចាប់ពីឆ្នាំ១៩៩៣ដល់ឆ្នាំ២០០២ ចំនួនគ្រោះមហន្តរាយដែលបានកើតឡើងក្នុងរយៈពេល៩ឆ្នាំមានចំនួនសរុប៣០៨ដង និងរយៈពេល៩ឆ្នាំពីឆ្នាំ ២០០៣ ដល់២០១២ មានចំនួន៣៧៣ដង កើនឡើង៦៥ដង ហើយក្នុងរយៈពេល៩ឆ្នាំក្រោយទៀតពីឆ្នាំ២០១៣ដល់២០២២ ចំនួនគ្រោះមហន្តរាយសរុប៣២៨ដង ថយចុះ៤៥ដងបើប្រៀបធៀបនឹងឆ្នាំ២០០៣ដល់២០១២។ នៅក្នុងឆ្នាំ២០២៣ ចំនួនគ្រោះមហន្តរាយបានកើតឡើងចំនួន៣២៦ដង ច្រើនជាងចំនួនសរុបពីឆ្នាំ២០២៣ដល់២០២២ ហើយបន្តកើនឡើងនៅឆ្នាំ២០២៤ មានចំនួន ៣៩៣ដង ច្រើនជាងឆ្នាំ២០២៣ចំនួន ៦៧ដង។ តាមទិន្នន័យនេះគេអាចព្យាករណ៍ថាពីឆ្នាំ២០២៥ គ្រោះមហន្តរាយនឹងបន្តកើនឡើងថែមទៀត។

### ក្រាហ្វិក ១០២. ចំនួនគ្រោះមហន្តរាយដែលបានកើតឡើង តាមទ្វីប និងប្រទេសចំនួន១១ ដែលទទួលរងគ្រោះមហន្តរាយធ្ងន់ធ្ងរឆ្នាំ២០២៤







ប្រភព៖ - RELIEFWEB, *2024 Disasters in Number,* [website], 18 April 2025, https://reliefweb.int/report/world/2024-disasters-numbers. (Accessed 18 May 2025).

- UNDRR, *2023 Global Natural Disaster Assessment Report,* [website], 13 October 2024, https://www.preventionweb.net/publication/2023-global-natural-disaster-assessment-report. (Accessed 18 May 2024).

## ក១.២ ប្រភេទគ្រោះមហន្តរាយ

ក្រាហ្វិក១០៣ បង្ហាញអំពីប្រភេទនៃគ្រោះមហន្តរាយ ដែលបានកើតឡើងសរុបពីឆ្នាំ២០០៤ ដល់ឆ្នាំ២០២៣ និងឆ្នាំ២០២៤។ គ្រោះទឹកជំនន់ (Flood) នៅក្នុងឆ្នាំ២០២៤ បានកើតឡើង១៤២ ដង ជិតប្រហែលនឹងចំនួនសរុប១៩ឆ្នាំពីឆ្នាំ២០០៤ដល់២០២៣ មានចំនួន១៦៨ដង។ បន្ទាប់មកគឺ ព្យុះ (Storm) នៅឆ្នាំ២០២៤មានចំនួន១៤៧ដង ច្រើនជាងចំនួនសរុប១៩ឆ្នាំកន្លងទៅ ដល់ទៅ៤១ ដង គឺពីឆ្នាំ២០០៤ដល់២០២៣មានចំនួន ១០៦ដង។ ទិន្នន័យជាភាគនៃប្រភេទគ្រោះមហន្តរាយ ផ្សេងមានបង្ហាញជូនខាងក្រោម។

**ក្រាហ្វិក ១០៣. ប្រភេទគ្រោះមហន្តរាយដែលបានកើតឡើងពីឆ្នាំ២០០៤ដល់២០២៣ និងឆ្នាំ២០២៤ (គិតជាដង)**






### ក្រាហ្វិក១០៤ ប្រភេទនៃគ្រោះមហន្តរាយពីឆ្នាំ២០០៤ ដល់២០២៣ និងឆ្នាំ២០២៤

#### (ក) ប្រភេទនៃគ្រោះមហន្តរាយពីឆ្នាំ២០០៤ ដល់២០២៣




#### (ខ) ប្រភេទនៃគ្រោះមហន្តរាយពីឆ្នាំ២០២៤



## ក១.៣. ការជះឥទ្ធិពលដល់មនុស្សដោយសារគ្រោះមហន្តរាយ

### ក១.៣.១ ចំនួនអ្នកស្លាប់ដោយសារគ្រោះមហន្តរាយ

ក្រាហ្វិក ១០៥ បង្ហាញអំពីអ្នកស្លាប់ដោយសារគ្រោះមហន្តរាយ បានបង្ហាញថាឆ្នាំ២០២៤ ចំនួនអ្នកស្លាប់ដោយសារគ្រោះមហន្តរាយមានចំនួន១៦ ៧៥៣នាក់ ទាបជាងឆ្នាំ២០២៣ ដែលមានចំនួន ៨៦ ៤៧៣នាក់ គឺតិចជាងដល់ទៅ៥ដង តែមានច្រើនជាងចំនួនសរុបពីឆ្នាំ២០១៣ ដល់ ២០២២ ក្នុងរយៈពេល៥ឆ្នាំអ្នកស្លាប់មានចំនួន១៤ ៨៦២នាក់។ បើប្រៀបធៀប៥ឆ្នាំដូចគ្នានៃចំនួនអ្នកស្លាប់សរុបពីឆ្នាំ២០០៣ ដល់ ២០១២ និង ២០១៣ ដល់២០២២ គឺចំនួនអ្នកស្លាប់សរុបពីឆ្នាំ២០០៣ ដល់ ២០១២ ច្រើនជាងពីឆ្នាំ២០១៣ ដល់ ២០២២ រហូតដល់៧ដង។

**ក្រាហ្វិក១០៥. ចំនួនអ្នកស្លាប់ដោយសារគ្រោះមហន្តរាយ**




នៅក្នុងក្រាហ្វិក ១០៦ បានបង្ហាញថានៅក្នុងរយៈពេល៥ឆ្នាំ គឺចាប់ពីឆ្នាំ២០០៤ដល់ឆ្នាំ ២០២៣ គ្រោះមហន្តរាយដែលបានកើតឡើង ហើយបណ្តាលធ្វើឲ្យមនុស្សស្លាប់ច្រើនជាងគេគឺ គ្រោះរញ្ជួយដី (Earthquake) មានភាគរយអ្នកស្លាប់ប្រហែល ៥៦,៣% ខ្ពស់ជាងគេ ព្យុះ ១៦,៤% កម្តៅឡើងខ្លាំង (Extreme Temperature) មាន ១៥,៦% តាមលំដាប់រៀង និងក្រៅពីនោះគ្រោះមហន្តរាយដែលបណ្តាលឲ្យមនុស្សស្លាប់តិចជាង១០% ក្នុងចំណោមអ្នកស្លាប់ទាំងអស់ដោយសារគ្រោះមហន្តរាយ។ នៅឆ្នាំ២០២៤ ភាគរយអ្នកស្លាប់ដោយសារគ្រោះមហន្តរាយទឹកជំនន់មានប្រហែល ៣៥,១% កម្តៅឡើងខ្លាំង ៣១,៣% ព្យុះ១៥,៤% ការប្រែប្រួលចលនាខ្លាំងនៃភាពសើម

(Mass movement (wet)) ១៣,៤% និងក្រៅពីនោះគ្រោះមហន្តរាយដែលបណ្តាលឲ្យមនុស្សស្លាប់តិចជាង១០% ក្នុងចំណោមអ្នកស្លាប់ទាំងអស់ដោយសារគ្រោះមហន្តរាយ។

នៅក្នុងឆ្នាំ២០២៤ ចំនួនអ្នកស្លាប់នៅទ្វីបអាស៊ីមានប្រហែល ៥៨,៦% ទ្វីបអាហ្វ្រិកចំនួន ២១,៤% ទ្វីបអាមេរិក ១៣,៧% ទ្វីបអូសេអានី ៤,៣% និងទ្វីបអឺរ៉ុប២,១%។ ចំនួនអ្នកស្លាប់ពីឆ្នាំ ២០០៤ ដល់២០២៣ ចំនួនអ្នកស្លាប់នៅទ្វីបអាស៊ីមានចំនួន៥៩,៨% ទ្វីបអាមេរិកមានចំនួន២០,១% ទ្វីបអឺរ៉ុប ១៤,៦% ទ្វីបអាហ្រិក ៥,២% និងទ្វីបអូសេអានី ០,២%។

ប្រទេសចំនួន១០ ដែលរងគ្រោះដោយសារគ្រោះមហន្តរាយធ្ងន់ធ្ងរជាងគេគឺអារ៉ាប៊ីសាអូឌីត អាហ្គានីស្ថាន សហរដ្ឋអាមេរិក ឥណ្ឌា ប៉ាពូញ៉ូហ្គីណេ ឆាត ប៉ាគីស្ថាន ជប៉ុន មីយ៉ាន់ម៉ា និងប្រទេសហ្គីណេ។

**ក្រាហ្វិក១០៦. ភាគរយអ្នកស្លាប់តាមប្រភេទគ្រោះមហន្តរាយ**




ប្រភព៖ - RELIEFWEB, *2024 Disasters in Number,* [website], 18 April 2025, https://reliefweb.int/report/world/2024-disasters-numbers. (Accessed 18 May 2025).

- UNDRR, *2023 Global Natural Disaster Assessment Report,* [website], 13 October 2024, https://www.preventionweb.net/publication/2023-global-natural-disaster-assessment-report. (Accessed 18 May 2024).

## ក).ភាគរយអ្នកស្លាប់តាមទ្វីប




## ខ).ចំនួនអ្នកស្លាប់តាមប្រភេទនៃគ្រោះមហន្តរាយ




## គ). ប្រទេស១០ដែលមានអ្នកស្លាប់ច្រើនជាងគេដោយសារគ្រោះមហន្តរាយ

**Table 1** Top 10 Mortality – 2024

| | | | | | |
|---|---|---|---|---|---|
| Saudi Arabia | Heat Wave | 1,301 | Chad | Flood | 576 |
| Afghanistan | Severe Winter Conditions | 1,197 | Pakistan | Heat Wave | 568 |
| USA | Heat Wave | 1,006 | Japan | Earthquake | 551 |
| India | Heat Wave | 733 | Myanmar | Typhoon Yagi | 460 |
| Papua New Guinea | Landslide | 670 | Niger | Flood | 396 |

### ក១.៣.២ ប្រជាជនដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយ

ក្រាហ្វិក ១០៧ បានបង្ហាញថាចំនួនប្រជាជនដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយឆ្នាំ២០២៤ មានចំនួន ១៦៧.២០០លាននាក់ ច្រើនជាងឆ្នាំ២០២៣ រហូតដល់ជិត១៨ដង។ ប្រសិនបើពិនិត្យនិន្នាការ៩ឆ្នាំចាប់ពីឆ្នាំ១៩៩៣ដល់២០០២ ចំនួនប្រជាជនដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយមានចំនួន ២៥.១៤០លាននាក់ បានធ្លាក់ចុះមកត្រឹម ១៩.២៩២លាននាក់ ពីឆ្នាំ២០០៣ដល់២០១២ និងបន្តធ្លាក់ចុះមកត្រឹម១៤.៨២៣លាននាក់ ពីឆ្នាំ២០១៣ដល់២០២២ និងឆ្នាំ២០២៣មានចំនួន៩.៣០៥ លាននាក់។

**ក្រាហ្វិក១០៧. ចំនួនប្រជាជនដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយ (គិតជាលាននាក់)**




**ក). ចំនួនប្រជាជនដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយតាមទ្វីប**



### ខ). ចំនួនប្រជាជនដែលរងផលប៉ះពាល់តាមប្រភេទគ្រោះមហន្តរាយ (គិតជាលាននាក់)

Figure 6
Number of Affected by Disaster Type: 2024 Compared to 2004-2023 Annual Average




### គ). ប្រទេស១០ដែលមានចំនួនប្រជាជនដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយច្រើនជាងគេ

Table 2 Top 10 Total Affected – 2024

| | | | | | |
|---|---|---|---|---|---|
| Bangladesh | Heat Wave | 33 million | Philippines | Typhoon Gaemi and Prapiroon | 6.5 million |
| Zambia | Drought | 9.8 million | Malawi | Drought | 6.1 million |
| Philippines | Typhoon Trami | 9.7 million | Bangladesh | Flood (August) | 5.8 million |
| India | Flood | 8 million | Bangladesh | Flood (June-July) | 5.1 million |
| Zimbabwe | Drought | 7.6 million | Bangladesh | Tropical Cyclone Remal | 4.6 million |

11 Sum of people injured, homeless, and otherwise affected.

ប្រភព៖ - RELIEFWEB, *2021 Disasters in Number*, [website], 18 April 2025, https://reliefweb.int/report/world/2024-disasters-numbers. (Accessed 18 May 2025).

- UNDRR, *2023 Global Natural Disaster Assessment Report,* [website], 13 October 2024, https://www.preventionweb.net/publication/2023-global-natural-disaster-assessment-report. (Accessed 18 May 2024).

## ក១.៣.៤ ការខាតបង់ផ្នែកសេដ្ឋកិច្ចដោយសារគ្រោះមហន្តរាយ

ក្រាហ្វិក ១០៨ បានបង្ហាញថានៅឆ្នាំ២០២៤ ការខាតបង់ផ្នែកសេដ្ឋកិច្ចមានចំនួន ២៤២ ប៊ីនលានដុល្លារសហរដ្ឋអាមេរិកច្រើនជាងឆ្នាំ២០២៣ ដែលមានចំនួន ២០២,៧ ប៊ីនលានដុល្លារសហរដ្ឋអាមេរិក ដែលរងគ្រោះដោយសារគ្រោះមហន្តរាយ។ នៅក្នុងរយៈពេល ៩ ឆ្នាំ ចាប់ពីឆ្នាំ១៩៩៣ដល់២០០២ សរុបមានការខាតបង់ដោយផ្ទាល់ផ្នែកសេដ្ឋកិច្ចមានចំនួន១១១,៣ ប៊ីនលានដុល្លារសហរដ្ឋអាមេរិក ហើយបានកើនឡើងរហូតដល់ ១៨៤,៥ ប៊ីនលានដុល្លារសហរដ្ឋអាមេរិក ក្នុងរយៈពេល៩ឆ្នាំចន្លោះពីឆ្នាំ ២០០៣ ដល់ ២០១២ និងបានធ្លាក់ចុះមកត្រឹម១៦៤,៨ ប៊ីនលានដុល្លារសហរដ្ឋអាមេរិក ក្នុងរយៈពេល ៩ឆ្នាំចន្លោះពីឆ្នាំ ២០១៣ ដល់ ២០២២ ។ ការខាតបង់សេដ្ឋកិច្ចតាមទ្វីប តាមប្រភេទនៃគ្រោះមហន្តរាយ និងបង្ហាញអំពីចំនួន១០ប្រទេស ដែលខាតបង់សេដ្ឋកិច្ចច្រើនជាងគេក្នុងឆ្នាំ២០២៤ មានបង្ហាញជូននៅក្រាហ្វិកខាងក្រោម។

ក្រាហ្វិក១០៨. ការខាតបង់ផ្នែកសេដ្ឋកិច្ចដោយសារគ្រោះមហន្តរាយ (គិតជា ប៊ីលានUS$)




ក). ភាគរយការខាតបង់សេដ្ឋកិច្ចតាមទ្វីប



## ខ). ការខាតបង់សេដ្ឋកិច្ចតាមប្រភេទគ្រោះមហន្តរាយ

**Figure 8**

Economic Losses (US$ billion) by Disaster Type: 2024 Compared to the 2004-2023 Annual Average

**209.6** 2004 to 2023 **<** **242** in 2024




## គ). ប្រទេស១០ដែលខាតបង់សេដ្ឋកិច្ចដោយសារគ្រោះមហន្តរាយច្រើនជាងគេ

**Table 3** Top 10 Economic Losses (US$) - 2024

| | | | | | |
|---|---|---|---|---|---|
| USA | Hurricane Helene | 56 billion | Brazil | Flood | 7 billion |
| USA | Hurricane Milton | 38 billion | USA | Storm (May) | 6.6 billion |
| Japan | Earthquake | 15 billion | Brazil | Drought | 6 billion |
| Spain | Flood | 11 billion | USA | Storm (March) | 5.9 billion |
| USA | Hurricane Beryl | 7.2 billion | USA | Drought | 5.4 billion |

12 Historical figures for economic losses are adjusted using the annual consumer price index (CPI) from OECD.

ប្រភព៖ - RELIEFWEB, *2024 Disasters in Number,* [website], 18 April 2025, https://reliefweb.int/report/world/2024-disasters-numbers. (Accessed 18 May 2025).

- UNDRR, *2023 Global Natural Disaster Assessment Report,* [website], 13 October 2024, https://www.preventionweb.net/publication/2023-global-natural-disaster-assessment-report. (Accessed 18 May 2024).

ក្រាហ្វិក ១០៩ បានបង្ហាញ ការខាតបង់សេដ្ឋកិច្ចនៅឆ្នាំ២០២៤ គឺគ្រោះមហន្តរាយដោយសារព្យុះមានចំនួន ៧១,៤% ច្រើនជាងគេ បន្ទាប់មកទឹកជំនន់ ១៣,៦% និងក្រៅពីនោះតិចជាង១០%។ នៅចន្លោះពីឆ្នាំ២០០៤ ដល់២០២៣ គិតជាមធ្យមប្រចាំឆ្នាំ បានបង្ហាញថាគ្រោះមហន្តរាយដោយសារព្យុះមានចំនួន ៥០,៥% មានចំនួនច្រើនជាងគេ រញ្ជួយដី ២១,៤% ទឹកជំនន់ ២១,០% និងក្រៅពីនោះតិចជាង១០%។

ក្រាហ្វិក១០៩. ភាគរយនៃការខាតបង់ផ្នែកសេដ្ឋកិច្ចតាមប្រភេទគ្រោះមហន្តរាយ




## ក២. គ្រោះមហន្តរាយនៅកម្ពុជា

គ្រោះមហន្តរាយធម្មជាតិដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា គឺគ្រោះទឹកជំនន់ ខ្យល់ព្យុះ រន្ទះបាញ់ គ្រោះរាំងស្ងួត ការបាក់ច្រាំងទន្លេស្ទឹង ការបាក់រលំអគារ ឬ សំណង់ អគ្គីភ័យ ការពុលស្រា និងជំងឺឆ្លងផ្សេងៗ ។ គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាគ្រោះមហន្តរាយដែលប៉ះពាល់ដល់ប្រជាជនច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា ដែលជានិច្ចកាលគ្រោះថ្នាក់ទាំងនេះរមែងនាំឱ្យមានការចំណាយខ្ពស់ជាងគេផងដែរ។ នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅទី១៣ វិធានការចំពោះអាកាសធាតុមានគោលបំណងចាត់វិធានការជាបន្ទាន់ ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយអភិវឌ្ឍសមត្ថភាពរបស់ប្រទេសនីមួយៗ ដើម្បីកាត់បន្ថយហានិភ័យអាកាសធាតុ និងការបន្សាំ។ គ្រោះមហន្តរាយមាននៅក្នុងចំណុចដៅ ៣.១ នៅក្នុងគោលដៅទី ១៣ នៃ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

នៅក្នុងរបាយការណ៍វិភាគនេះ គឺបង្ហាញអំពីគ្រោះមហន្តរាយ ៣ ចំណុចដែលបានកើតឡើងរួមមាន៖

១) គ្រោះមហន្តរាយធម្មជាតិ

២) គ្រោះមហន្តរាយដោយអគ្គីភ័យ

៣) គ្រោះមហន្តរាយដោយជំងឺឆ្លង

៤) គ្រោះមហន្តរាយដោយសារសង្គ្រាម។

នៅទូទាំងប្រទេស ចំនួនជនរងគ្រោះរហូតបាត់បង់ជីវិតដោយសារអគ្គីភ័យនៅឆ្នាំ២០២២ មានចំនួន ១១នាក់ បានកើនឡើងដល់ ៣៥នាក់ នៅឆ្នាំ២០២៥ ខណៈដែលខេត្តកំពង់ចាមមានចំនួន១នាក់នៅក្នុងឆ្នាំ២០២២ បានកើន២នាក់ នៅក្នុងឆ្នាំ២០២៥ និងខេត្តត្បូងឃ្មុំនៅឆ្នាំ២០២២ ពុំមានអ្នកស្លាប់ និងនៅឆ្នាំ២០២៥ ក៏ពុំមានអ្នកស្លាប់ដែរ។ ចំនួនជនរងគ្រោះដោយសាខ្យល់កន្ត្រាក់នៅទូទាំងប្រទេសមានចំនួន១១នាក់ នៅឆ្នាំ២០២២ បានកើនឡើងដល់៣៥នាក់ នៅក្នុងឆ្នាំ២០២៥ ខណៈដែលខេត្តកំពង់ចាមពុំមានចំនួនអ្នកស្លាប់នៅឆ្នាំ២០២២ តែបានកើនឡើងដល់៤នាក់នៅក្នុងឆ្នាំ២០២៥ និងខេត្តត្បូងឃ្មុំពីឆ្នាំ២០២២ដល់ឆ្នាំ២០២៥ ពុំមានអ្នកស្លាប់។ ចំនួនជនរងគ្រោះដោយសាររន្ទះបាញ់នៅទូទាំងប្រទេសឆ្នាំ២០២២មានចំនួន៣២នាក់ បានកើនឡើងដល់៤៥នាក់ នៅឆ្នាំ២០២៥ តែមានចំនួនទាបជាងឆ្នាំ២០២៣និងឆ្នាំ២០២៤ ខណៈដែលខេត្តកំពង់ចាមចំនួនអ្នកស្លាប់នៅក្នុងឆ្នាំ២០២៤ មាន២នាក់ និងឆ្នាំ២០២៥មានចំនួន១នាក់ និងខេត្តត្បូងឃ្មុំចំនួនអ្នកស្លាប់នៅក្នុងឆ្នាំ២០២២ និង២០២៣ ពុំមានអ្នកស្លាប់ តែនៅក្នុងឆ្នាំ២០២៤ មានចំនួន៤នាក់ និងនៅក្នុងឆ្នាំ២០២៥ មានចំនួន១នាក់ (តារាង ៥៦) និងក្រាហ្វិក១១០។

**តារាង ៥៦. ចំនួនអ្នកស្លាប់ដោយសារអគ្គីភ័យ ខ្យល់កន្ត្រាក់ និងរន្ទះបាញ់**

| ឆ្នាំ | កម្ពុជា | | | កំពង់ចាម | | | ត្បូងឃ្មុំ | | |
|---|---|---|---|---|---|---|---|---|---|
| | អគ្គិភ័យ | ខ្យល់កន្ត្រាក់ | រន្ទះបាញ់ | អគ្គិភ័យ | ខ្យល់កន្ត្រាក់ | រន្ទះបាញ់ | អគ្គិភ័យ | ខ្យល់កន្ត្រាក់ | រន្ទះបាញ់ |
| 2022 | 11 | 3 | 32 | 1 | 0 | 0 | 0 | 0 | 0 |
| 2023 | 14 | 6 | 46 | 3 | 1 | 0 | 0 | 0 | 0 |
| 2024 | 15 | 7 | 66 | 0 | 0 | 2 | 0 | 0 | 4 |
| 2025 | 35 | 14 | 45 | 2 | 4 | 1 | 0 | 0 | 1 |

### ក្រាហ្វិក ១១០. ចំនួនអ្នកស្លាប់ដោយសារអគ្គីភ័យ ខ្យល់កន្ត្រាក់ និងរន្ទះបាញ់




ប្រភព៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម)

នៅទូទាំងប្រទេសចំនួនអ្នករងរបួសដោយអគ្គីភ័យមានចំនួន ៣២នាក់ បានកើនឡើងដល់ ៦៣នាក់ អ្នករងរបួសដោយសារខ្យល់កន្ត្រាក់មានចំនួន២៨នាក់បានកើនដល់៤៧នាក់ និងចំនួនអ្នករងរបួសដោយសាររន្ទះបាញ់មានចំនួន២៦នាក់ បានកើនដល់៥៨នាក់ បើប្រៀបធៀបពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៥ ប៉ុន្តែចំនួនជនរងគ្រោះដោយសារខ្យល់កន្ត្រាក់នៅក្នុងឆ្នាំ២០២៣មានរហូតដល់ ១២០នាក់។ ខេត្តកំពង់ចាមចំនួនអ្នករងរបួសដោយសារអគ្គីភ័យមានចំនួន១នាក់នៅក្នុងឆ្នាំ២០២២ និងនៅឆ្នាំ២០២៥ ចំនួនអ្នករបួស១នាក់ ខណៈដែលចំនួនអ្នករងនៅក្នុងឆ្នាំ២០២៣ មានចំនួន២នាក់ និង២០២៤ មាន១នាក់។ ចំនួនអ្នករងរបួសដោយសារខ្យល់កន្ត្រាក់នៅក្នុងឆ្នាំ២០២២ មានចំនួន១នាក់ និងនៅឆ្នាំ២០២៥ពុំមានអ្នករងរបួស ប៉ុន្តែនៅឆ្នាំ២០២៣ មានចំនួន១៣នាក់ និងឆ្នាំ ២០២៤ មានចំនួន៣នាក់។ ចំនួនអ្នករងរបួសដោយសាររន្ទះបាញ់ពីឆ្នាំ២០២២ដល់២០២៥ ពុំមានអ្នករងរបួសលើកលែងតែឆ្នាំ២០២៤ មានអ្នករងរបួសចំនួន១នាក់។ ខេត្តត្បូងឃ្មុំអ្នករងគ្រោះដោយសារអគ្គីភ័យនៅឆ្នាំ២០២៤មានចំនួន៣នាក់ និងនៅឆ្នាំ២០២៥មានចំនួន២នាក់។ ចំនួនអ្នករងរបួសដោយខ្យល់កន្ត្រាក់ពីឆ្នាំ២០២២ដល់ឆ្នាំ២០២៥ ពុំមានអ្នករងរបួសលើកលែងតែឆ្នាំ២០២៣ មានអ្នករងរបួស

ចំនួន៦នាក់។ ចំនួនអ្នករងរបួសដោយសាររន្ទះបាញ់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៥ ពុំមានអ្នករងរបួសទេ លើកលែងតែឆ្នាំ២០២៤មានចំនួន២នាក់ (តារាង៥៧ និងក្រាហ្វិក១១១)។

**តារាង ៥៧. ចំនួនអ្នករងរបួសដោយសារអគ្គីភ័យ ខ្យល់កន្ត្រាក់ និងរន្ទះបាញ់**

| ឆ្នាំ | កម្ពុជា | | | កំពង់ចាម | | | ត្បូងឃ្មុំ | | |
|---|---|---|---|---|---|---|---|---|---|
| | អគ្គីភ័យ | ខ្យល់កន្ត្រាក់ | រន្ទះបាញ់ | អគ្គីភ័យ | ខ្យល់កន្ត្រាក់ | រន្ទះបាញ់ | អគ្គីភ័យ | ខ្យល់កន្ត្រាក់ | រន្ទះបាញ់ |
| 2022 | 32 | 28 | 26 | 1 | 1 | 0 | 0 | 0 | 0 |
| 2023 | 27 | 120 | 39 | 2 | 15 | 0 | 0 | 6 | 0 |
| 2024 | 52 | 38 | 48 | 1 | 3 | 1 | 3 | 0 | 2 |
| 2025 | 63 | 47 | 58 | 1 | 0 | 0 | 2 | 0 | 0 |

**ក្រាហ្វិក ១១១. ចំនួនអ្នករងរបួសដោយសារអគ្គីភ័យ ខ្យល់កន្ត្រាក់ និងរន្ទះបាញ់**




ប្រភព៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម)

## ក២.១. គ្រោះមហន្តរាយធម្មជាតិ

គ្រោះមហន្តរាយធម្មជាតិ សំដៅលើគ្រោះថ្នាក់ធម្មជាតិ ដែលបានកើតឡើង ដូចជា ទឹកជំនន់ ការបាក់ច្រាំងទន្លេ ស្ទឹង ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ និងគ្រោះថ្នាក់រន្ទះបាញ់។

### *១.ទឹកជំនន់*

តាមលទ្ធផល នៃរបាយការណ៍ថ្នាក់ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ដែលបានផ្សព្វផ្សាយឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥ បានឲ្យដឹងថាក្នុងរយៈពេល៥ឆ្នាំមុនធ្វើជំរឿនកសិកម្មឆ្នាំ២០២៣ នៅក្នុងតំបន់បឹងទន្លេសាបមានភាគរយនៃភូមិដែលទទួលរងគ្រោះដោយទឹកជំនន់ និងគ្រោះរាំងស្ងួតច្រើនជាងតំបន់ផ្សេងទៀត។ ភូមិដែលទទួលរងដោយទឹកជំនន់មានប្រហែល៦៦% និងចំនួនភូមិប្រហែល៦៧% ទទួលរងគ្រោះរាំងស្ងួត។ តំបន់ខ្ពង់រាប និងភ្នំមានភូមិប្រហែល២៦% រងគ្រោះដោយទឹកជំនន់ និងភូមិប្រហែល៣៩% រងគ្រោះរាំងស្ងួត។ តំបន់ទំនាបកណ្តាលមានភូមិប្រហែល២៦% រងគ្រោះដោយទឹកជំនន់ និងភូមិប្រហែល៣៨% រងគ្រោះរាំងស្ងួត និងតំបន់ឆ្នេរសមុទ្រមានភូមិប្រហែល២២% រងគ្រោះដោយសារទឹកជំនន់ និងភូមិប្រហែល២៥% រងគ្រោះដោយសារគ្រោះរាំងស្ងួត។

**ក្រាហ្វិក ១១២. ភាគរយនៃភូមិដែលងាយរងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងរយៈពេល ៥ឆ្នាំចុងក្រោយមុនធ្វើជំរឿនកសិកម្មឆ្នាំ២០២៣**




ប្រភព៖ របាយការណ៍ថ្នាក់ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣

តាមរបាយការណ៍ ស្តីពីលទ្ធផលការងារគ្រប់គ្រងគ្រោះមហន្តរាយ គិតត្រឹមថ្ងៃទ២៦ ខែវិច្ឆិកា ឆ្នាំ២០២៥ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានបង្ហាញថាជំនន់ទឹកភ្លៀងរួមជាមួយ

នឹងទឹកជំនន់ទន្លេមេគង្គ បានធ្វើឲ្យប៉ះពាល់ដល់ស្រុកចំនួន៨១ ឃុំ៣៣៧ សម្រាប់ទូទាំងប្រទេស។ ខេត្តកំពង់ចាមបានរងផលប៉ះពាល់ដោយសារជំនន់ទឹកភ្លៀង និងទឹកទន្លេមេគង្គប៉ះពាល់ដល់ស្រុកចំនួន៨ ឃុំចំនួន ៤៧ និងខេត្តត្បូងឃ្មុំប៉ះពាល់ស្រុកចំនួន២ ឃុំចំនួន១៦។ ផលប៉ះពាល់ទាំងនេះបានធ្វើឲ្យប៉ះពាល់ដល់វិស័យសង្គមកិច្ច វិស័យផលិតកម្ម និងហេដ្ឋារចនាសម្ព័ន្ធ (តារាង៥៨)។

**តារាង ៥៨. ទិន្នន័យរងផលប៉ះពាល់ និងខូចខាតដោយជំនន់ទឹកភ្លៀង និងទឹកជំនន់ទន្លេមេគង្គឆ្នាំ២០២៥ (គិតត្រឹមថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥)**

| ប៉ះពាល់និងខូចខាត | កំពង់ចាម | ត្បូងឃ្មុំ | កម្ពុជា |
|---|---|---|---|
| ចំនួនស្រុក/ខណ្ឌ | 8 | 2 | 81 |
| ចំនួនឃុំ/សង្កាត់ | 47 | 16 | 337 |
| ១).វិស័យសង្គមកិច្ច | | | |
| ចំនួនគ្រួសារ | 6,063 | 8,416 | 57,329 |
| ជម្លៀស(គ្រួសារ) | 65 | 2,320 | 1,832 |
| ស្លាប់ | 3 | 2 | 27 |
| សង្គ្រោះនិងរបួស | | | 2 |
| ផ្ទះប៉ះពាល់(ខ្នង) | 2,860 | 1,647 | 19,923 |
| ផ្ទះខូចខាត(ខ្នង) | | | 6 |
| សាលារៀនប៉ះពាល់ | 9 | 2 | 104 |
| សាលារៀនខូចខាត | | | |
| វត្តវិហារប៉ះពាល់ | 10 | 3 | 45 |
| មន្ទីរពេទ្យមណ្ឌលសុខភាពប៉ះពាល់ | | | 8 |
| ២).វិស័យផលិតកម្ម | | | |
| សត្វពាហនៈជម្លៀស | 82 | 2,479 | 11,777 |
| សត្វពាហនៈងាប់ | | | 4 |
| សន្ទូង/ពង្រោះប៉ះពាល់(ហត) | 7,824 | 2,982 | 48,369 |

| ប៉ះពាល់និងខូចខាត | កំពង់ចាម | ត្បូងឃ្មុំ | កម្ពុជា |
|---|---|---|---|
| សន្ទូង/ពង្រោះខូចខាត(ហត) | 4,480 | 2,435 | 25,645 |
| សំណាបប៉ះពាល់(ហត) | | | |
| សំណាបខូចខាត(ហត) | | | 527 |
| ដំណាំរួមផ្សំប៉ះពាល់(ហត) | 748 | 2,745 | 5,125 |
| ដំណាំរួមផ្សំខូចខាត(ហត) | 392 | 1,994 | 1,778 |
| ៣).ហេដ្ឋារចនាសម្ព័ន្ធ | | | |
| ផ្លូវកៅស៊ូ/ផ្លូវបេតុងប៉ះពាល់(ម) | 2,252 | | 91,931 |
| ផ្លូវកៅស៊ូ/ផ្លូវបេតុងខូចខាត(ម) | | | |
| ផ្លូវជនបទប៉ះពាល់(ម) | 163,275 | 28,364 | 738,954 |
| ផ្លូវជនបទខូចខាត(ម) | | | 7,109 |
| ស្ពានប៉ះពាល់(កន្លែង) | 13 | 1 | 41 |
| ទំនប់ប៉ះពាល់(ម) | 6,400 | | 44,106 |
| បាក់ច្រាំងទន្លេ(ម) | 15,468 | 2,411 | 26,286 |

ប្រភព៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ២០២៥។

ក្រាហ្វិក ១១៣ បង្ហាញអំពីចំនួនឃុំ/សង្កាត់ និងស្រុក/ខណ្ឌនៅក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងទូទាំងប្រទេសរងផលប៉ះពាល់ និងខូចខាតលើវិស័យសង្គមកិច្ច ដោយទឹកជំនន់ឆ្នាំ ២០២៥។ ក្រាហ្វិក ១១៤ ដល់ ១១៦ បង្ហាញអំពីផលប៉ះពាល់លើវិស័យសង្គមកិច្ច វិស័យផលិតកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងប្រទេស។ ក្រាហ្វិក ១១៧ ដល់ ១១៩ បង្ហាញអំពីផលប៉ះពាល់លើវិស័យសង្គមកិច្ច វិស័យផលិតកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។

## ក្រាហ្វិក ១១៣. ចំនួនស្រុក/ខណ្ឌ និង ឃុំ/សង្កាត ដែលរងផលប៉ះពាល់ដោយសារជំនន់ទឹកភ្លៀង និងទឹកទន្លេមេគង្គឆ្នាំ២០២៥




## ក្រាហ្វិក ១១៤. ផលប៉ះពាល់ និងខូចខាតលើវិស័យសង្គមកិច្ចដោយទឹកជំនន់ឆ្នាំ២០២៥ ទូទាំងប្រទេស



**ក្រាហ្វិក ១១៥. ផលប៉ះពាល់ និងខូចខាតលើវិស័យផលិតកម្ម ដោយទឹកជំនន់ឆ្នាំ២០២៥ ទូទាំងប្រទេស**




**ក្រាហ្វិក ១១៦. ផលប៉ះពាល់ និងខូចខាតលើហេដ្ឋារចនាសម្ព័ន្ធ ដោយទឹកជំនន់ឆ្នាំ២០២៤ ទូទាំងប្រទេស**




ប្រភព៖ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ឆ្នាំ២០២៤។

## ក្រាហ្វិក ១១៧. ផលប៉ះពាល់ និងខូចខាតលើវិស័យសង្គមកិច្ចដោយទឹកជំនន់ឆ្នាំ២០២៥ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ




## ក្រាហ្វិក ១១៨. ផលប៉ះពាល់ និងខូចខាតលើវិស័យផលិតកម្ម ដោយទឹកជំនន់ឆ្នាំ២០២៥ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ



**ក្រាហ្វិក ១១៩. ផលប៉ះពាល់ និងខូចខាតលើហេដ្ឋារចនាសម្ព័ន្ធ ដោយទឹកជំនន់ឆ្នាំ២០២៥ នៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ**




## ៣.គ្រោះរាំងស្ងួត

នៅក្នុងឆ្នាំ២០២៥ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានបង្ហាញថា នៅទូទាំងប្រទេសមានស្រុក៥៨ និង ឃុំចំនួន១៨៥ រងផលប៉ះពាល់ដោយគ្រោះរាំងស្ងួត ហើយបានធ្វើឲ្យប៉ះពាល់ដំណាំស្រូវប្រហែលចំនួន១៣៨ពាន់ហិកតា ខូចខាតអស់ប្រហែល១៦ពាន់ហិកតា ប៉ះពាល់ដល់ដំណាំរួមផ្សំប្រហែល ១,៥ ពាន់ហិកតា និងបានជួយអន្តរាគមន៍ទាន់ពេលសម្រាប់ដំណាំស្រូវបានប្រហែល១១០ពាន់ហិកតា។ ខេត្តកំពង់ចាមប៉ះពាល់ដល់ស្រុក១ និងឃុំចំនួន៣ ព្រមទាំងប៉ះពាល់ដល់ដំណាំស្រូវចំនួន៣៩៧ ហិកតា ខូចខាតអស់៣ ហិកតា និងអន្តរាគមន៍ទាន់ពេលចំនួន៣១៨ ហិកតា។ ខេត្តត្បូងឃ្មុំប៉ះពាល់ដល់ស្រុក៤ និងឃុំចំនួន១៣ ព្រមទាំងប៉ះពាល់ដល់ដំណាំស្រូវចំនួន១,២ ពាន់ហិកតា ខូចខាតអស់១៤៤ហិកតា និងអន្តរាគមន៍ទាន់ពេល១,០៥៣ពាន់ហិកតា (តារាង ៥៩ និងក្រាហ្វិក១២០)។

នៅក្នុងឆ្នាំ២០២១ តាមប្រភពទិន្នន័យមូលដ្ឋានដែលប្រមូលដោយមន្ទីរផែនការរាជធានីខេត្ត បានបង្ហាញថាចំនួនគ្រួសារប្រហែល៨៥ ពាន់គ្រួសារ និងផ្ទៃដីស្រែប្រហែលចំនួន ១៦១ ពាន់ហិកតា ដែលរងការខូចខាត ដោយគ្រោះរាំងស្ងួត (ក្រាហ្វិក១២១)។

## តារាង ៥៩. ការប៉ះពាល់ និងខូចខាតដោយសារគ្រោះរាំងស្ងួតឆ្នាំ២០២៥

| ខេត្ត កម្ពុជា | ស្រុក | ឃុំ | ដំណាំស្រូវ (ហត) | | | ដំណាំរួមផ្សំ (ហត) |
|---|---|---|---|---|---|---|
| | | | ប៉ះពាល់ | ខូចខាត | អន្តរាគមន៍ | ប៉ះពាល់ |
| កំពង់ចាម | 1 | 3 | 397 | 3 | 318 | |
| ត្បូងឃ្មុំ | 4 | 13 | 1,196 | 144 | 1,052 | 1,550 |
| កម្ពុជា | 58 | 185 | 137,568 | 15,640 | 109,990 | 1,557 |

## ក្រាហ្វិក ១២០. ការប៉ះពាល់ និងអន្តរាគមន៍ដោយសារគ្រោះរាំងស្ងួតឆ្នាំ២០២៥



### ក្រាហ្វិក ១២១. ចំនួនគ្រួសារ និងផ្ទៃដីដែលរងផលប៉ះពាល់ដោយសារគ្រោះរាំងស្ងួត ទូទាំងប្រទេស ឆ្នាំ២០២១




ប្រភព៖ ទិន្នន័យមន្ទីរផែនការខេត្ត២០១៩ ២០២០ និង ២០២១

## *៤. ការបាក់ច្រាំងទន្លេ ស្ទឹង*

នៅក្នុងឆ្នាំ២០២៥នេះ មានករណីបាក់ច្រាំងទន្លេកើតឡើង៣៥ករណី នៅក្នុងខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង ព្រៃវែង កំពង់ធំ និងរាជធានីភ្នំពេញ (តារាង ៦០ ក្រាហ្វិក១២២ និង ក្រាហ្វិក ១២៣)។

### តារាង ៦០ ស្ថានភាពរងគ្រោះដោយការបាក់ច្រាំងទន្លេ ស្ទឹងឆ្នាំ២០២៥

| បរិយាយ | ២០២៥ | ២០២៤ | ប្រៀបធៀប |
|---|---|---|---|
| កើតមាន(ករណី) | 35 | 42 | -7 |
| ផ្ទះបាក់ធ្លាក់ចូលទឹក(ខ្នង) | 31 | 15 | 16 |
| ផ្ទះរំកិលនិងរុះរើ | 52 | 92 | -40 |
| បាក់ស្រុតសាលាឆទាន(ខ្នង) | 1 | 1 | 0 |
| បាក់ស្រុតដីច្រាំងទន្លេ(ម៉ែត្រ) | 31,584 | 16,291 | 15,293 |

## ក្រាហ្វិក ១២២. ស្ថានភាពរងគ្រោះដោយការបាក់ច្រាំងទន្លេ ស្ទឹងឆ្នាំ២០២៥ ទូទាំងប្រទេស




## ក្រាហ្វិក ១២៣. ច្រាំងទន្លេដែលបានបាក់ស្រុត គិតជាម៉ែត្រ ទូទាំងប្រទេស



## ៥.ខ្យល់កន្ត្រាក់ និងខ្យល់ព្យុះ

### ៥.១ ខ្យល់កន្ត្រាក់

នៅក្នុងឆ្នាំ២០២៥ ខ្យល់កន្ត្រាក់កើតមាន៣០០ លើកកើនឡើងជាងឆ្នាំ២០២៤ចំនួន៥លើក ហើយបានបណ្តាលឲ្យមនុស្សស្លាប់ចំនួន១៤នាក់ របួស៤៧នាក់ រលំផ្ទះ៤៦៨ខ្នង ខូចខាតសាលារៀន៥០អគារ និងអគាររដ្ឋបាល២០កន្លែងនៅក្នុងឆ្នាំ២០២៥កន្លងទៅនេះ (តារាង៦១។

តារាង ៦១. ស្ថានភាពរងគ្រោះដោយសារខ្យល់កន្ត្រាក់ឆ្នាំ២០២៥ ទូទាំងប្រទេស

| បរិយាយ | 2024 | 2025 | ប្រៀបធៀប |
|---|---|---|---|
| កើតមាន(ករណី) | 295 | 300 | 5 |
| ស្លាប់មនុស្ស(នាក់) | 7 | 14 | 7 |
| របួសមនុស្ស(នាក់) | 39 | 47 | 8 |
| ផ្ទះរលំនិងខូចខាតធ្ងន់ធ្ងរ(ខ្នង) | 548 | 468 | -80 |
| ខូចខាតផ្ទះមធ្យម(ខ្នង) | 4,637 | 9,029 | 4,392 |
| សាលារៀន(អគារ) | 51 | 50 | -1 |
| អគាររដ្ឋបាល(កន្លែង) | 23 | 20 | -3 |

ក្រាហ្វិក ១២៤. ស្ថានភាពរងគ្រោះដោយសារខ្យល់កន្ត្រាក់ឆ្នាំ២០២៥ទូទាំងប្រទេស



## ៥.២. ផលប៉ះពាល់វិស័យសេដ្ឋកិច្ច ដោយខ្យល់ព្យុះកេតសាណា (Ketsana)

ការប្រែប្រួលអាកាសធាតុបានបណ្តាលឲ្យមាន គ្រោះមហន្តរាយកើតឡើង នៅលើពិភពលោក ដូចជា រលកយក្សស៊ូណាមី ទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះ ហើយធ្វើឲ្យប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចជាតិនៃប្រទេសដែលបានទទួលរងគ្រោះដោយសារគ្រោះមហន្តរាយ។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា បានធ្វើការវាយតម្លៃអំពីផលប៉ះពាល់អំពីការខូចខាត និងការបាត់បង់ដោយសារឥទ្ធិពលនៃព្យុះកេតសាណា (Ketsana) ។ ការវាយតម្លៃត្រូវបានធ្វើឡើងនៅឆ្នាំ ២០១០ ទៅលើខេត្តចំនួន១៤ ក្នុងចំណោមខេត្តទាំង២៤ របស់ប្រទេសកម្ពុជា។ ការសិក្សាបានប៉ាន់ប្រមាណ ខ្យល់ព្យុះបានបំផ្លាញមុខរបរការចិញ្ចឹមជីវិត និ ផ្ទះសម្បែង របស់ប្រជាជនកម្ពុជាចំនួន ១,៤% នៃចំនួនប្រជាជនសរុប។

តារាង ៦២ បង្ហាញអំពីការខាតបង់ផ្នែកសេដ្ឋកិច្ចបែងចែកតាមវិស័យឆ្នាំ២០០៩។ តាមទិន្នន័យបានបង្ហាញថាសរុបនៃការខូខាត និងការបាត់បង់មានទំហំទឹកប្រាក់សរុបចំនួន ១៣១.៩៩៦.៤១៥ ដុល្លារសហរដ្ឋអាមេរិក ដែលនៅក្នុងនោះផលប៉ះពាល់ខ្លាំង លើវិស័យផលិតកម្មមានទំហំទឹកប្រាក់រហូតដល់ ៦០.០៥៩.២៨៦ ដុល្លារសហរដ្ឋអាមេរិក វិស័យសង្គមកិច្ចមានទំហំទឹកប្រាក់៤២.៨៨២.៣៧៦ ដុល្លារសហរដ្ឋអាមេរិក វិស័យហេដ្ឋារចនាសម្ព័ន្ធមានទំហំទឹកប្រាក់សរុប ២៨.៧៤៧.៦២៨ ដុល្លារសហរដ្ឋអាមេរិក និង អន្តរវិស័យមានចំនួន ៣០៨.១២៥ ដុល្លារសហរដ្ឋអាមេរិក។

ក្រាហ្វិក ១២៥ បង្ហាញអំពីភាគរយនៃការខាតបង់ផ្នែកសេដ្ឋកិច្ច បែងចែកតាមវិស័យឆ្នាំ ២០០៩។ វិស័យដែលទទួលរងការខូចខាតធំជាងគេ គឺវិស័យផលិតកម្មមានចំនួន ៤៥,៥% វិស័យសង្គមកិច្ចមានចំនួន៣២,៥% វិស័យហេដ្ឋារចនាសម្ពន្ធ័មានចំនួន ២១,២% និងអន្តរវិស័យមានចំនួន ០,២%។

## តារាង ៦២. ការខាតបង់ផ្នែកសេដ្ឋកិច្ចបែងចែកតាមវិស័យ ឆ្នាំ២០០៩

| វិស័យនិងអនុវិស័យ | ផលប៉ះពាល់ដោយគ្រោះមហន្តរាយគិតជាដុល្លារ (US$) | | |
|---|---|---|---|
| | ការខូចខាត | ការបាត់បង់ | សរុប |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | **17,259,051** | **11,487,577** | **28,746,628** |
| ផ្លូវ | 14,388,832 | 11,076,698 | 25,465,530 |
| ការផ្គត់ផ្គង់ទឹកនិងអនាម័យ | 64,339 | 392,689 | 457,028 |
| ការគ្រប់គ្រងទឹកនិងប្រព័ន្ធស្រោចស្រព | 2,779,000 | 13,000 | 2,792,000 |
| ថាមពល | 26,880 | 5,190 | 320,170 |
| **វិស័យសង្គមកិច្ច** | **39,548,563** | **3,333,813** | **42,882,376** |
| ផ្ទះនិងទីជម្រក | 15,281,952 | 3,294,398 | 18,576,350 |
| សុខាភិបាល | 57,072 | 39,415 | 96,487 |
| អប់រំ | 24,209,539 | - | 24,209,539 |
| **វិស័យផលិតកម្ម** | **1,051,124** | **59,008,162** | **60,059,286** |
| កសិកម្មចិញ្ចឹមសត្វនិងនេសាទ | 91,270 | 56,420,846 | 56,512,116 |
| ឧស្សាហកម្មនិងនេសាទ | 959,854 | 2,587,316 | 3,547,170 |
| **អន្តរវិស័យ** | **205,358** | **102,767** | **308,125** |
| បរិស្ថាន | 31,073 | 98,367 | 129,440 |
| គ្រប់គ្រងសាធារណៈ | 174,285 | 4,400 | 178,685 |
| **សរុប** | **58,064,096** | **73,932,319** | **131,996,415** |

ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ២០២១។

### ក្រាហ្វិក ១២៥. ភាគរយនៃការខាតបង់ផ្នែកសេដ្ឋកិច្ចបែងចែកតាមវិស័យ ឆ្នាំ២០០៩




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។

## ៦.គ្រោះថ្នាក់រន្ទះបាញ់

ស្ថានភាពរងគ្រោះដោយសាររន្ទះបាញ់នៅក្នុងឆ្នាំ២០២៥ បានកើតឡើងមានចំនួន១២៥ លើក ថយចុះ៣២លើកពើប្រៀបធៀបនឹងឆ្នាំ២០២៤។ នៅក្នុងឆ្នាំ២០២៥ ចំនួនអ្នកស្លាប់មានចំនួន មានចំនួន៤៥នាក់ ថយចុះ២៣នាក់ របួសមនុស្សមានចំនួន៥៨នាក់ កើនឡើង៣នាក់ និងខូចខាត ផ្ទះ២០ខ្នងថយចុះ១១ខ្នង បើធៀបនឹងឆ្នាំ២០២៤ (តារាង៦៣ និងក្រាហ្វិក១២៦)។

**តារាង ៦៣. ស្ថានភាពរងគ្រោះដោយសាររន្ទះបាញ់ទូទាំងប្រទេស**

| បរិយាយ | 2024 | 2025 | ប្រៀបធៀប |
|---|---|---|---|
| កើតមាន (ករណី) | 125 | 93 | -32 |
| ស្លាប់មនុស្ស (នាក់) | 68 | 45 | -23 |
| របួសមនុស្ស (នាក់) | 55 | 58 | 3 |
| ខូចខាតផ្ទះ (ខ្នង) | 20 | 31 | 11 |

**ក្រាហ្វិក ១២៦. ស្ថានភាពរងគ្រោះដោយសាររន្ទះបាញ់ទូទាំងប្រទេស**



## ក២.២. គ្រោះថ្នាក់ផ្សេង

### *១.អគ្គីភ័យ*

នៅក្នុងឆ្នាំ២០២៥ ចំនួនអគ្គីភ័យបានកើតឡើងចំនួន ៨១២លើក ថយចុះ១១លើ បើធៀបទៅនឹងឆ្នាំ២០២៤ សម្រាប់នៅទូទាំងប្រទេស។ ស្ថានភាពរងគ្រោះដោយសារអគ្គីភ័យនៅទូទាំងប្រទេសមានលម្អិតនៅក្នុងតារាង ៦៤ និង ក្រាហ្វិក១២៧។

**តារាង ៦៤. ស្ថានភាពរងគ្រោះដោយសារអគ្គីភ័យទូទាំងប្រទេស**

| បរិយាយ | 2024 | 2025 | ប្រៀបធៀប |
|---|---|---|---|
| កើតមាន(លើក) | 823 | 812 | -11 |
| ឆេះផ្ទះកុដិឃ្លាំងអគារ (ខ្នងកន្លែងអគារ) | 1,155 | 836 | -319 |
| រោងចក្រនិងសិប្បកម្ម(កន្លែង) | 25 | 16 | -9 |
| រោងមហោស្រប(កន្លែង) | 0 | ១ | 1 |
| ក្លឹបកម្សាន្តនិងកាស៊ីណូ | 0 | 3 | 3 |
| ស្ថានីយប្រេងឥន្ធនៈ(កន្លែង) | 0 | 4 | 4 |
| ឆេះខូចខាតស្រូវពូជនិងស្រូវជង្រុក(តោន) | 0 | 50 | 50 |
| ចំការដំណាំនិងចំការកៅស៊ូ(ហិកតា) | 211 | 729 | 518 |
| ថ្នាំពេទ្យ(កេស) | 0 | 10 | 10 |
| កៅស៊ូក្រែប(តោន) | 0 | 10 | 10 |
| ព្រៃឈើនិងព្រៃរនាមលិចទឹក(ហិតកតា) | 684 | 0 | -684 |
| ព្រៃស្មៅនិងជញ្ជ្រាំងស្រូវ(ហិកតា) | 78 | 1040 | 962 |
| កសិកដ្ឋានចិញ្ចឹមមាន់(កន្លែង) | 1 | 0 | -1 |
| ម៉ាស៊ីនដេរ(គ្រឿង) | 0 | 30 | 30 |
| ឆេះខូចខាតរថយន្ត(គ្រឿង) | 21 | 28 | 7 |
| ម៉ូតូ(គ្រឿង) | 68 | 11 | -57 |
| ត្រាក់ទ័រនោងគោយន្ត(គ្រឿង) | 11 | 0 | -11 |
| រងគ្រោះស្លាប់(នាក់) | 20 | 36 | 16 |
| របួស(នាក់) | 59 | 63 | 4 |

**ក្រាហ្វិក ១២៧. ស្ថានភាពរងគ្រោះដោយសារអគ្គីភ័យឆ្នាំ២០២៥ ទូទាំងប្រទេស**




### *២.ជំងឺឆ្លង*

នៅលើពិភពលោកយើងនេះ មានជំងឺឆ្លងជាច្រើនបានឆ្លងមកលើមនុស្ស។ ជំងឺឆ្លងទាំងនោះ រួមមានដូចជាជំងឺកូវីដ១៩ ជំងឺផ្តាសាយបក្សី និងជំងឺឆ្លងអេប៊ូឡា ជាដើម ប៉ុន្តែជំងឺឆ្លងដែលប្រជាជនលើពិភពលោកបានចាប់អារម្មណ៍នោះគឺជំងឺឆ្លងកូវីដ១៩។

#### *ក.ស្ថានភាពជំងឺកូវីដ១៩ទូទាំងពិភពលោកឆ្នាំ២០២៥*

តាមទិន្នន័យគេហទំព័ររបស់អង្គការសុខភាពពិភពលោកគិតរយៈពេល៧ថ្ងៃមកត្រឹមថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៥ មានអ្នកឆ្លងជំងឺកូវីដ១៩ ចំនួន ៥.៧៥៩នាក់ ដែលក្នុងនោះតំបន់អាហ្វ្រិកមានចំនួន១៦ករណី តំបន់អាមេរិកមានចំនួន១.៦០១ករណី តំបន់មេឌីទែរ៉ាណេខាងកើតមានចំនួន៦៣៨ករណី តំបន់អឺរ៉ុបមានចំនួន៣.៤៣៦ករណី និងតំបន់អាស៊ីប៉ែកអាគ្នេយ៍មានចំនួន១៨ករណី និងសរុបអ្នកស្លាប់មានចំនួន២២៧នាក់។ នៅក្នុងប្រទេសកម្ពុជាយើង តាមទិន្នន័យរបស់ក្រសួងសុខាភិបាលកម្ពុជា ការឆ្លងជំងឺកូវីដ១៩ក្នុងខែតុលា គិតពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទ២៥ ខែតុលា ឆ្នាំ២០២៤ មានអ្នកឆ្លងថ្មីចំនួន១ករណី ឆ្លងក្នុងសហគមន៍ចំនួន១ករណី គ្មានករណីនាំចូល និងអ្នកស្លាប់ទេ។

ក្រាហ្វិក ១២៨. ចំនួនអ្នកឆ្លងកូវីដ១៩ ឆ្នាំ២០២៥ (គិតរយៈពេល៧ថ្ងៃត្រឹមថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៥)




ប្រភព៖ World Health Organization (WHO), WHO COVID-19 dashboard 4th May 2025, https://data.who.int/dashboards/covid19/cases?n=c. (Accessed 19 October 2023).

### *ក១.ស្ថានភាពជំងឺកូវីដ១៩ទូទាំងពិភពលោកពេលចាប់ផ្តើមរហូតដល់ឆ្នាំ២០២៣*

ក្រាហ្វិក ១២៩ បង្ហាញអំពីស្ថានភាពជំងឺកូវីដ១៩ តាមរយៈគេហទំព័ររបស់អង្គការសុខភាពពិភពលោក (WHO) ។ តាមទិន្នន័យបង្ហាញថាចំនួនអ្នកឆ្លងជំងឺកូវីដ១៩ ប្រហែលចំនួន ៧៧១លាននាក់ ស្មើនឹង ៩,៦% នៃប្រជាជនពិភពលោកចំនួន ៨,១ ពាន់លាននាក់ និងបានស្លាប់បានកើនដល់ជិត ៧លាននាក់គិតត្រឹមថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២៣។ វ៉ាក់សាំងដែលបានចាក់ទៅលើប្រជាជននៅលើពិភពលោកគិតជាចំនួនដូសមានចំនួនប្រហែល ១៣,៥ ពាន់លានដូស ក្នុងចំណោមប្រជាជនជិត ៨,១ ពាន់លាននាក់ ។

### ក្រាហ្វិក ១២៩. ស្ថានភាពជំងឺកូវីដ១៩ទូទាំងពិភពលោកគិតត្រឹមថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២៣




ប្រភព ÷ (1) World Health Organization (WHO), *WHO Coronavirus (COVID-19) Dashboard,* [website], 19 October 2023, https:// covid19.who.int/?mapFilter=vaccinations. (Accessed 19 October 2023).

(2) Worldometer, *Current World Population Clock: 8.1 Billion People (LIVE, 2023),* [website], 19 October 2023, www.worldometers.info/worldpopulation/#:~:text=World%20Population%20Clock%3A%208.1%20Billion, (LIVE%2C%202023)%20-%20Worldometer. (Accessed 19 October 2023).

ក្រាហ្វិក ១៣០. បង្ហាញអំពីស្ថានភាពនៃការចាក់វ៉ាក់សាំងជំងឺកូវីដ១៩ តាមរយៈគេហទំព័ររបស់អង្គការសុខភាពពិភពលោក (WHO)។ តាមទិន្នន័យបានបង្ហាញថា ក្នុងចំណោមប្រជាជន ១០០នាក់ បានចាក់វ៉ាក់សាំង ១៧៣,៤១ដូស មានន័យថាមានប្រជាជនភាគច្រើនចាក់បាន២ដូស ខណៈដែលវ៉ាក់សាំងខ្លះតម្រូវឲ្យចាក់តែ១ដូស។ ប្រជាជននៅលើពិភពលោកចំនួន ៦៦នាក់បានចាក់វ៉ាក់សាំងពេញលេញតាមស៊េរីនៃវ៉ាក់សាំង ដែលកំណត់ឲ្យចាក់ក្នុងប្រជាជន ១០០នាក់ និងបានចាក់វ៉ាក់សាំងដូសជំរុញមានប្រជាជនប្រហែល ៣១,៧១នាក់ ក្នុងចំណោមប្រជាជន១០០នាក់។

**ក្រាហ្វិក ១៣០. ស្ថានភាពនៃចាក់វ៉ាក់សាំងជំងឺកូវីដ១៩ទូទាំងពិភពលោកគិតត្រឹមថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២៣**




ប្រភព÷ World Health Organization (WHO), *WHO Coronavirus (COVID-19) Dashboard,* [website], 19 October 2023, https:// covid19.who.int/?mapFilter=vaccinations. (Accessed 19 October 2023).

### *ក២. ស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា*

នៅក្នុងប្រទេសកម្ពុជាយើង តាមទិន្នន័យរបស់ក្រសួងសុខាភិបាលកម្ពុជា ការឆ្លងជំងឺកូវីដ១៩ក្នុងខែតុលា គិតពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទ២៥ ខែតុលា ឆ្នាំ២០២៤ មានអ្នកឆ្លងថ្មីចំនួន១ករណី ឆ្លងក្នុងសហគមន៍ចំនួន១ករណី គ្មានករណីនាំចូល និងអ្នកស្លាប់ទេ។យោងតាមរបាយការណ៍ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងឆ្នាំ២០២៣ គិតត្រឹមរយៈពេល៦ខែ បានបង្ហាញថាជំងឺឆ្លង ដែលបានកើតឡើងរួមមាន៖ ជំងឺផ្តាសាយបក្សី ជំងឺគ្រុនឈាម និងជំងឺកូវីដ១៩។

នៅក្នុងរបាយការណ៍នេះ បើទោះបីជំងឺកូវីដ១៩ បានផុតរល់ក្តី ប៉ុន្តែទិន្នន័យនេះមានសារៈសំខាន់នឹងជាបទពិសោធន៍ ដែលប្រទេសកម្ពុជាដោះស្រាយបញ្ហាលំបាកនេះប្រកបដោយជោគជ័យ គួរឲ្យកត់សំគាល់តាមរយៈការអនុវត្តវិធានការណ៍ចាំបាច់មួយចំនួន។ វិធានការណ៍ទាំងនោះគឺរាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសុខាភិបាល បានអំពាវនាវឲ្យប្រជាពលរដ្ឋអនុវត្តវិធានការណ៍ « ៣ការពារ និង៣កុំ » ដោយប្រុងប្រយ័ត្ន ទោះបីជាអង្គការសុខភាពពិភពលោកប្រកាសជំងឺកូវីដ១៩លែងជាភាពអាសន្នសុខភាពសាធារណៈក៏ដោយ ប៉ុន្តែការបំប្លែងខ្លួនជាបន្តបន្ទាប់នៃវីរុសកូវីដ១៩ ធ្វើឲ្យនៅតែមានការឆ្លងនៅបណ្តាប្រទេសមួយចំនួនរួមទាំងកម្ពុជាផង ដែលអាចមានលទ្ធភាពក្នុងការផ្ទុះឡើងជាថ្មីក្នុងសហគមន៍។

- ការឆ្លងថ្មីក្នុងឆមាសទី១ឆ្នាំ ២០២៣ មានចំនួន ៣០៦នាក់
- ការឆ្លងក្នុងសហគមន៍ ៣០០នាក់ ករណីនាំចូល៦នាក់ និងការព្យាបាលជាសះស្បើយ ៣៤១នាក់
- ការចាក់វ៉ាក់ការពារសរុបលើចំនួនប្រជាជន ១៥.២៩៨.០០៩ នាក់។

**ក្រាហ្វិក ១៣១. ស្ថានភាពជំងឺកូវីដ១៩នៅកម្ពុជាគិតត្រឹមថ្ងៃទី ២០ ខែ១០ឆ្នាំ២០២៣**




ប្រភព៖ - World Health Organization (WHO), *WHO Coronavirus (COVID-19) Dashboard,* [website], 19 October 2023, https:// covid19.who.int/?mapFilter=vaccinations. (Accessed 19 October 2023).
- របាយការណ៍ស្តីពី លទ្ធផលការងារគ្រប់គ្រងគ្រោះមហន្តរាយឆមាសទី១ ឆ្នាំ ២០២៣ និងទិសដៅឆមាសទី២ ឆ្នាំ ២០២៣
- ចំណោលប្រជាជនឆ្នាំ ២០២០ ផ្អែកតាមទិន្នន័យជំរឿនទូទៅប្រជាជនឆ្នាំ២០១៩។

ក្រាហ្វិក ១៣២ បង្ហាញថាចំនួនប្រជាជនកម្ពុជា ១០០នាក់ដែលបានចាក់វ៉ាក់សាំង គឺបានប្រើប្រាស់វ៉ាក់សាំងអស់ចំនួន ២៨៤,៧២ដូស (២៨៥ដូស) មានន័យថា ប្រជាជនកម្ពុជាម្នាក់បានចាក់វ៉ាក់សាំងដូសទី៣ភាគច្រើន ខណៈដែលភាគច្រើនវ៉ាក់សាំងដែលបានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាចាក់បាន២ដូសទើបកំណត់ថាពេញលេញ។ ស្ថានភាពចាក់វ៉ាក់សាំងប្រជាជនពិភពលោកលើ

ចំនួនប្រជាជន១០០នាក់ ដែលបានចាក់វ៉ាកសាំង គឺបានប្រើប្រាស់វ៉ាក់សាំងចំនួន ១៧៣,៤១ ដូស (១៧៣ដូស) មានន័យថាភាគច្រើនចាក់បានដូសទី២ ខណៈដែលភាគច្រើនវ៉ាក់សាំងតម្រូវឲ្យចាក់តែ១ដូស។ ប្រជាជនកម្ពុជាដែលបានចាក់វ៉ាក់សាំងពេញលេញមានចំនួន៨៨នាក់ និងបានចាក់ដូសជំរុញចំនួន ៦៤នាក់ ក្នុងចំណោមប្រជាជនដែលបានចាក់វ៉ាក់សាំង១០០ នាក់ ខណៈប្រជាជនពិភពលោកបានចាក់វ៉ាក់សាំងពេញលេញមានចំនួន ៦៦នាក់ និងចាក់ដូសជំរុញមានចំនួន ៣២នាក់ ក្នុងចំណោមប្រជាជនដែលបានចាក់វ៉ាក់សាំង ១០០នាក់ ផ្អែកតាមគេហទំព័ររបស់អង្គការសុខភាពពិភពលោក គិតត្រឹមថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣។

**ក្រាហ្វិក ១៣២. ស្ថានភាពចាក់វ៉ាក់សាំងជំងឺកូវីដ១៩នៅកម្ពុជា និងពិភពលោក គិតត្រឹមថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២៣**




ប្រភព៖ - World Health Organization (WHO), *WHO Coronavirus (COVID-19) Dashboard,* [website], 19 October 2023, https:// covid19.who.int/?mapFilter=vaccinations. (Accessed 19 October 2023).

នៅក្នុងឆ្នាំ២០២៥ ស្ថានភាពជំងឺកូវីដ១៩ មានករណីឆ្លងថ្មីមានចំនួន៣៣៤នាក់ ថយចុះពីឆ្នាំ២០២៤ ចំនួន៤៩នាក់ ករណីឆ្លងក្នុងសហគមន៍ចំនួន៣៣៤នាក់ ថយចុះ៤៣នាក់ និងព្យាបាលជាសះស្បើយ៣៣៤នាក់ (តារាង ៦៥ និងក្រាហ្វិក ១៣១)។

**តារាង ៦៥. ស្ថានភាពកូវីដ១៩ ក្នុងឆ្នាំ២០២៥**

| បរិយាយ | 2024 | 2025 | ប្រៀបធៀប |
|---|---|---|---|
| ករណីឆ្លងថ្មី | 383 | 334 | -49 |
| ករណីឆ្លងក្នុងសហគមន៍ | 377 | 334 | -43 |
| ករណីនាំចូល | 6 | | -6 |
| ព្យាបាលជាសះស្បើយ | 418 | 334 | -84 |

**ក្រាហ្វិក ១៣៣. ស្ថានភាពកូវីដ១៩ ២០២៥**



## *ក៣. ស្ថានភាពជំងឺឆ្លងផ្សេងៗនៅកម្ពុជា*

### ក៣.១ ស្ថានភាពគ្រោះជំងឺផ្តាសាយបក្សី H1N1

នៅក្នុងឆ្នាំ២០២៥ ជំងឺរាតត្បាតមានដូចជា ជំងឺផ្តាសាយបក្សី H1N1 មានករណីកើតមានឡើងលើមនុស្សចំនួន១៨ករណី (ក្មេង) នៅក្នុងខេត្តកំពង់ចាម កំពត ត្បូងឃ្មុំ រាជធានីភ្នំពេញ កំពង់ឆ្នាំង ក្រចេះ តាកែវ កំពង់ស្ពឺ ស្វាយរៀង និងខេត្តសៀមរាប។

**តារាង ៦៦. ស្ថានភាពគ្រោះជំងឺផ្តាសាយបក្សី H1N1**

| បរិយាយ | 2024 | 2025 | ប្រៀបធៀប |
|---|---|---|---|
| កើតមាន | 10 | 18 | 8 |
| រងគ្រោះស្លាប់ | 2 | 9 | 7 |
| ជាសះស្បើយ | 8 | 9 | 1 |

**ក្រាហ្វិក ១៣៤. ស្ថានភាពគ្រោះជំងឺផ្តាសាយបក្សី H1N1**



### ក៣.២ ជំងឺគ្រុនឈាម

នៅក្នុងឆ្នាំ២០២៥ ស្ថានភាពជំងឺគ្រុនឈាមបានកើតឡើង៦១.៤៨៣ ករណីកើនឡើងជាងឆ្នាំ២០២៤ រហូតដល់ ៤៣.៦៧៣ ករណី និងបានស្លាប់មនុស្សចំនួន ៧៥នាក់ លើសឆ្នាំ២០២៤ រហូតដល់៣១នាក់។

**តារាង ៦៧. ស្ថានភាពជំងឺគ្រុនឈាម**

| បរិយាយ | 2024 | 2025 | ប្រៀបធៀប |
|---|---|---|---|
| កើតមាន (ករណី) | 17,810 | 61,483 | 43,673 |
| ស្លាប់មនុស្ស (នាក់) | 44 | 75 | 31 |

**ក្រាហ្វិក ១៣៥. ស្ថានភាពជំងឺគ្រុនឈាម**




### *៣. គ្រោះមហន្តរាយដោយសារសង្គ្រាម*

#### *ក. សកលលោក*

មុននឹងបង្ហាញជូនអំពីទិន្នន័យដែលខូចខាតដោយសារសង្គ្រាមលោកលើកទី១ និង លើកទី២ ខាងក្រោម សូមបង្ហាញជូនអំពីចំណុចមួយចំនួន ដែលមាននៅក្នុងរបាយការណ៍ហានិយភ័យសកលឆ្នាំ២០២៥ របស់វេទិកាសេដ្ឋកិច្ចពិភពលោកដូចខាងក្រោម។

តាមរបាយការណ៍ហានិយភ័យសកលឆ្នាំ២០២៥ របស់វេទិកាសេដ្ឋកិច្ចពិភពលោក បានបង្ហាញថា នៅក្នុងរយៈពេលខ្លី (២ឆ្នាំ)គឺកម្រិតខ្យល់ព្យុះ៖ ហានិភ័យមហន្តរាយសកលកំពុងកើតមាន

(Stormy: Global catastrophic risks looming) មានចំនួន ៥% និងនៅក្នុងរយៈពេលវែង (១០ឆ្នាំ) នឹងកើនដល់១៧% អាចជាជម្លោះប្រើប្រាស់កម្លាំងយោធា។ ភាពច្របូកច្របល់៖ ភាពចលាចល និងហានិភ័យខ្ពស់នៃគ្រោះមហន្តរាយសកល (Turbulent: Upheavals and elevated risk of global catastrophes) នៅក្នុងរយៈពេលខ្លី (២ឆ្នាំ) មាន៣១% និងនៅក្នុងរយៈពេលវែង (១០ឆ្នាំ) នឹងកើនដល់៤៥%។ មិនបានដោះស្រាយ៖ អស្ថិរភាពខ្លះ ហានិភ័យកម្រិតមធ្យមនៃគ្រោះមហន្តរាយសកល (Unsettled: Some instability, moderate risk of global catastrophes) នៅក្នុងរយៈពេលខ្លី (២ឆ្នាំ) មាន៥២% និងនៅក្នុងរយៈពេលវែង (១០ឆ្នាំ) នឹងថយចុះមកត្រឹម ៣០%។ ស្ថិរភាព៖ ការរំខានឲ្យនៅឯកោ ហានិភ័យទាបនៃគ្រោះមហន្តរាយសកល (Stable: Isolated disruptions, low risk of global catastrophes) នៅក្នុងរយៈពេលខ្លី (២ឆ្នាំ) មាន១១% និងនៅក្នុងរយៈពេលវែង (១០ឆ្នាំ) នឹងថយចុះមកត្រឹម ៨%។ ភាពស្ងប់ស្ងាត់៖ ហានិភ័យតិចតួចនៃគ្រោះមហន្តរាយពិភពលោក (Calm: Negligible risk of global catastrophes) នៅក្នុងរយៈពេលខ្លី (២ឆ្នាំ) មាន១% និងនៅក្នុងរយៈពេលវែង (១០ឆ្នាំ) មិនមានតទៅទៀត។ ទិន្នន័យលំអិតមានបង្ហាញជូននៅក្នុងក្រាហ្វិក១៣៦ ខាងក្រោម។

**ក្រាហ្វិក ១៣៦.ទស្សនវិស័យសកលរយៈពេលខ្លី និងរយៈពេលវែង**

(Short- and long-term global outlook)




ប្រភព៖ World Economic Forum, *Global Risks Report 2025,* Geneva, Switzerland, World Economic Forum, 2025, p.6.

តាមរបាយការណ៍ហានិយភ័យសកលឆ្នាំ២០២៥ របស់វេទិកាសេដ្ឋកិច្ចពិភពលោក បានបង្ហាញថា គឺជម្លោះប្រដាប់អាវុធតាមប្រទេសមានរហូត២៣% បញ្ហាអាកាសធាតុមាន១៤% បញ្ហាប្រឈមសេដ្ឋកិច្ចមាន៨% ពត៌មានមិនពិត និងក្លែងក្លាយមាន៧% បញ្ហាសង្គមកិច្ច វិបត្តិសេដ្ឋកិច្ចមាន៥% ការផ្លាស់ប្តូរដ៏សំខាន់ចំពោះប្រព័ន្ធផែនដី មាន ៤% កង្វះឱកាសសេដ្ឋកិច្ច ឬអត់ការងារធ្វើមាន៣% ការបំផ្លាញសិទ្ធិមនុស្ស និង/ឬសេរីភាពពលរដ្ឋ២% និង វិសមភាពមាន២%។ ទិន្នន័យលំអិតមានបង្ហាញជូននៅក្នុងក្រាហ្វិក៨៥ ខាងក្រោម។

**ក្រាហ្វិក ១៣៧. ស្ថានភាពហានិភ័យសកលលោកបច្ចុប្បន្ន**




ប្រភព៖ World Economic Forum, *Global Risks Report 2025,* Geneva, Switzerland, World Economic Forum, 2025, p.13.

សង្គ្រាមបានបង្កឲ្យមានគ្រោះមហន្តរាយយ៉ាងធំធេងដល់ជីវិតមនុស្ស និងបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិជាច្រើន ព្រមទាំងបន្សល់ទុកនូវដីធ្លី ដែលមានគ្រាប់មីន និងអាវុធផ្សេងៗទៀត សម្រាប់ការប្រើប្រាស់ដាំដំណាំកសិកម្ម និងដីសម្រាប់ការសាងសង់លំនៅដ្ឋានសម្រាប់ប្រជាជនរស់នៅ។ សង្គ្រាមធំៗ២ ដែលបានកើតឡើង គឺសង្គ្រាមលោកលើកទី១ ចាប់ពីឆ្នាំ១៩១៤ ដល់ ឆ្នាំ១៩២១ និង សង្គ្រាមលោកលើកទី២ ពីឆ្នាំ១៩៣៩ ដល់ឆ្នាំ១៩៤៥។ សរុបចំនួនទាហាន ដែលប្រយុទ្ធស្លាប់សរុបនៅក្នុងសង្គ្រាមលោកលើកទី១ និងទី២ មានចំនួនសរុប២៤,៧លាននាក់ និងទាហានរងរបួសមានចំនួនសរុប៤៦,២លាននាក់ និងជនស៊ីវិលស្លាប់មានចំនួនសរុប៥១,៨លាននាក់។ គ្រោះមហន្តរាយនេះ មិនទាន់គិតអំពីការខូចខាតសម្ភារៈផ្សេងៗទៀតផង។

## ក្រាហ្វិក ១៣៨. ចំនួនអ្នកស្លាប់ និង រងរបួសក្នុងសង្គ្រាមលោកលើកទី១ និងលើកទី២




ប្រភព÷ 1) https://www.census.gov/history/pdf/reperes112018.pdf. *(Accessed 24 October 2023).*

2) https://www.nationalww2museum.org/students-teachers/student-resources/research-starters/research-starters-worldwide-deaths-world-war. *(Accessed 24 October 2023).*

*សំគាល់÷ *Worldwide casualty estimates vary widely in several sources. The number of civilian deaths in China alone might well be more than 50,000,000.*

### *ក១. សង្គ្រាមលោកលើកទី១ ពីឆ្នាំ១៩១៤ ដល់ ឆ្នាំ១៩២១*

សង្គ្រាមលោកលើកទី១បានចាប់ផ្តើមពីឆ្នាំ១៩១៤ និងបានបញ្ចប់នៅឆ្នាំ ១៩២១។ ចំនួនទាហាន និងជនស៊ីវិលដែលស្លាប់នៅក្នុងសង្គ្រាមលោកលើកទី១មានប្រហែល៤០លាននាក់ ក្នុងនោះ២០លាននាក់ ស្លាប់ និង ២១លាននាក់រងរបួស។ ចំនួនអ្នកស្លាប់សរុបត្រូវបានរាប់បញ្ចូលបុគ្គលិកទាហាន ៩លាននាក់ និងជនស៊ីវិលប្រហែល១០លាននាក់ផងដែរ។ ក្រុម Allies ឬ The Entente Powers គឺជាទាហានអន្តរជាតិដែលដឹកនាំដោយបារាំង ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក រុស្ស៊ី អ៊ីតាលី និងជប៉ុន បាត់បង់កងទ័ពប្រហែល ៥,៧លាននាក់ ខណៈដែលក្រុម The Central Power (Central Empire) ដែលមានប្រទេសអាល្លឺម៉ង់ អូទ្រីស-ហុងគ្រី ចក្រភពអូតូម៉ង់ និងប៊ុលហ្គារីដែលគេស្គាល់ថាជាក្រុម Quadruple Alliance។ ចំណាត់ថ្នាក់នៃស្ថិតិអ្នកស្លាប់បានប៉ាន់

ប្រមាណសម្រាប់សង្គ្រាមលោកលើកទី១ គឺជាទាហានដែលបានចុះបញ្ជីរួមបញ្ចូលការប្រយុទ្ធព្រមទាំងស្លាប់ដោយសារគ្រោះថ្នាក់ ជំងឺ និងស្លាប់នៅក្នុងគុកនៃសង្គ្រាម។ ការស្លាប់ភាគច្រើនគឺអត់អាហារ និងជំងឺ។ ជនស៊ីវិលស្លាប់ដោយសារផ្ដាសាយនៅអេស្ប៉ាញមិនរាប់បញ្ចូលទេ តែជនស៊ីវិលស្លាប់ដោយការសម្លាប់រង្គាលនៅប្រទេសអាមេនីត្រូវបានរាប់បញ្ចូល[3]។ គ្រោះមហន្តរាយនេះ មិនទាន់គិតអំពីការខូចខាតសម្ភារៈ ផ្ទះសម្បែង និងផ្ទៃដីកសិកម្មដែលបន្សល់ទុកនូវអាវុធជាតិផ្ទុះផ្សេងៗទៀត។

## តារាង ៦៨. ចំនួនប្រជាជន និង ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១

| No. | Country Name | Population (Millions) | Military deaths | Civilian deaths | Total deaths | Deaths as % of population | Military wounded |
|---|---|---|---|---|---|---|---|
| 1 | Australia | 4.5 | 61,928 | | 61,928 | 1.38 | 152,171 |
| 2 | Canada | 7.2 | 64,944 | 2,000 | 66,944 | 0.92 | 149,732 |
| 3 | India Empire | 315.1 | 74,187 | | 74,187 | 0.02 | 69,214 |
| 4 | New Zealand | 1.1 | 18,050 | | 18,050 | 1.64 | 41,317 |
| 5 | New Found land | 0.2 | 1,204 | | 1,204 | 0.60 | 2,314 |
| 6 | South Africa | 6.0 | 9,463 | | 9,463 | 0.16 | 12,029 |
| 7 | United Kingdom | 45.4 | 885,138 | 109,000 | 994,138 | 2.19 | 1,663,435 |
| | Sub-total for British Imperial Forces | - | 1,114,914 | 111,000 | 1,225,914 | - | 2,090,212 |
| 8 | Belgium | 7.4 | 58,637 | 62,000 | 120,637 | 1.63 | 44,686 |
| 9 | France | 39.6 | 1,397,800 | 300,000 | 1,697,800 | 4.29 | 4,266,000 |
| 10 | Greece | 4.8 | 26,000 | 150,000 | 176,000 | 3.67 | 21,000 |
| 11 | Italy | 35.6 | 651,000 | 589,000 | 1,240,000 | 3.48 | 953,886 |
| 12 | Empire of Japan | 53.6 | 415 | - | 415 | - | 907 |
| 13 | Luxembourg | 0.3 | | - | - | - | |
| 14 | Montenegro | 0.5 | 3,000 | - | 3,000 | 0.60 | 10,000 |
| 15 | Portugal | 6.0 | 7,222 | 82,000 | 89,222 | 1.49 | 13,751 |
| 16 | Romania | 7.5 | 250,000 | 430,000 | 680,000 | 9.07 | 120,000 |
| 17 | Russian Empire | 175.1 | 1,811,000 | 1,500,000 | 3,311,000 | 1.89 | 4,950,000 |
| 18 | Serbia | 4.5 | 275,000 | 450,000 | 725,000 | 16.11 | 133,148 |
| 19 | United States | 92.0 | 116,708 | 757 | 117,465 | 0.13 | 205,690 |
| | Total (Entente Powers) | 806.4 | 5,711,696 | 3,674,757 | 9,386,453 | 1.19 | 12,809,280 |
| 1 | Austria-Hungary | 51.4 | 1,100,000 | 467,000 | 1,567,000 | 3.05 | 3,620,000 |
| 2 | Bulgaria | 5.5 | 87,500 | 100,000 | 187,500 | 3.41 | 152,390 |

[3] REPERES, *World War I Casualty*, [website], 2011, https://www.census.gov/history/pdf/reperes112018.pdf. (Accessed 24 October 2023).

| No. | Country Name | Population (Millions) | Military deaths | Civilian deaths | Total deaths | Deaths as % of population | Military wounded |
|---|---|---|---|---|---|---|---|
| 3 | German Empire | 64.9 | 2,050,897 | 426,000 | 2,476,897 | 3.82 | 4,247,143 |
| 4 | Ottoman Empire | 21.3 | 771,844 | 2,150,000 | 2,921,844 | 13.72 | 400,000 |
| | Total (Central Powers) | 143.1 | 4,010,241 | 3,143,000 | 7,153,241 | 5.00 | 8,419,533 |
| 1 | Denmark | 2.7 | | 722 | 722 | 0.03 | |
| 2 | Norway | 2.4 | | 1,892 | 1,892 | 0.08 | |
| 3 | Sweden | 5.6 | | 877 | 877 | 0.02 | |
| | Neutral nations | 10.7 | - | 3,491 | 3,491 | | |
| | Grand total | 960.2 | 9,721,937 | 6,821,248 | 16,543,185 | 1.75 | 21,228,813 |

ក្រាហ្វិក១៣៩ បង្ហាញអំពីចំនួនប្រជាជនតាមប្រទេស ដែលមានការទាក់ទងការស្លាប់ទាហាន ជនស៊ីវិល និង រងរបួសអំឡុងពេលសង្គ្រាមលោកលើកទី១។ ក្រុមប្រទេសដែលស្ថិតក្នុងចំណាត់ថ្នាក់ Ententes Powers ដែលមានចំនួនប្រជាជនច្រើនជាងគេគឺចក្រភពឥណ្ឌាមានប្រជាជនជាង៣០០លាននាក់ ហើយប្រទេសដែលមានចំនួនប្រជាជនតិចជាងគេ គឺប្រទេស New Found land មានចំនួនប្រជាជនប្រហែល ២០ម៉ឺននាក់។ នៅក្នុងក្រុមប្រទេស Central Powers ចក្រភពអាល្លឺម៉ង់មានចំនួនប្រជាជនប្រហែល ៦៥លាននាក់ និងប្រទេសដែលមានប្រជាជនតិចជាងគេគឺប្រទេសប៊ុលហ្គារី មានប្រជាជនប្រហែល ៥,៥លាននាក់។ ចំពោះក្រុមប្រទេស Neutral nations ប្រទេស Norway មានចំនួនប្រជាជនតិចជាងគេប្រហែល ២,៤លាននាក់ និងច្រើនជាងគេប្រទេសស៊ុយអែតមានចំនួនប្រជាជនប្រហែល ៥,៦លាននាក់។

**ក្រាហ្វិក ១៣៩. ចំនួនប្រជាជនសរុបក្នុងអំឡុងពេល WWI**



ក្រាហ្វិក១៤០ បង្ហាញថាចំនួនអ្នកស្លាប់ក្នុងនោះមានទាហាននិងជនស៊ីវិលស្លាប់ និង ទាហានដែលរងរបួសច្រើនជាងគេគឺចក្រភពរុស្ស៊ី។ ចក្រភពរុស្ស៊ីមានអ្នកស្លាប់ (ទាហាននិងជនស៊ីវិល) មានចំនួនប្រហែល ៣,៣លាននាក់ និងទាហានរងរបួសមានចំនួនប្រហែល ៤,៩ លាននាក់ និងចក្រភពជប៉ុនមានមានអ្នកស្លាប់ ៤១៥នាក់ និងទាហានរងរបួសមានចំនួន ៩០៧នាក់តិចជាងគេ ខណៈដែលប្រទេស Luxembourg ពុំមានអ្នកស្លាប់ និងរងរបួស សម្រាប់ក្រុមប្រទេស Ententes Powers។ ចំពោះក្រុមប្រទេស Central Powers ចក្រភព Ottoman មានអ្នកស្លាប់២,៩លាននាក់ និង ទាហានរងរបួសប្រហែល៤០ម៉ឺន ខណៈដែលចក្រភពអាល្លឺម៉ង់ មានអ្នកស្លាប់ប្រហែល ២,៥ លាននាក់ និងទាហានរងរបួស ៤,២លាននាក់។ ចំពោះក្រុមប្រទេស Neutral nations មានប្រជាជនស៊ីវិលស្លាប់ចំនួន៣៤៩១នាក់។

**ក្រាហ្វិក ១៤០. ចំនួនអ្នកស្លាប់ និងទាហានរងរបួសសរុបក្នុងអំឡុងពេល WWI**




សំគាល់÷ 1) ក្រុមប្រទេស Entente Powers (Australia, Canada, India Empire, New Zealand, New Found Land, South Africa, United Kingdom, Belgium, France, Greece, Italy, Empire of Japan, Luxembourg, Montenegro, Portugal, Romania, Russian Empire, Serbia and United States.

2) ក្រុមប្រទេស Central Powers (Austria-Hungary, Bulgaria, German Empire, and Ottoman Empire).

3) ក្រុមប្រទេស Neutral nations (Denmark, Norway, and Sweden).

4) Total deaths (Military death and Civilians deaths)

ក្រាហ្វិក ១៤១. ភាគរយចំនួនអ្នកស្លាប់តាមចំណាត់ថ្នាក់ក្នុង WWI (1914-1921)




ក្រាហ្វិក ១៤២. ភាគរយចំនួនទាហានសម្រាប់ក្រុម Entente Powers ក្នុង WWI



ក្រាហ្វិក ១៩៣. ភាគរយចំនួនទាហានសម្រាប់ក្រុម Central Powers ក្នុង WWI




### *ក.២ សង្គ្រាមលោកលើកទី២ ពីឆ្នាំ១៩៣៩ ដល់ ឆ្នាំ១៩៤៥*

សង្គ្រាមលោកលើកទី២គឺជាជម្លោះសកលដែលបានចាប់ផ្តើមពីឆ្នាំ ១៩៣៩ ដល់ឆ្នាំ ១៩៤៥។ ប្រទេសធំៗនៅលើពិភពលោករួមបញ្ចូលទាំងប្រទេស ដែលមានអំណាចធំៗ បានប្រយុទ្ធគ្នាដែលមានទាហានជាសម្ព័ន្ធភាពនឹងគ្នាបានបែងចែកជាពីរក្រុមធំៗគឺ ក្រុមប្រទេស Allies និងក្រុមប្រទេស Axis។ ក្រុមប្រទេស Allies មានប្រទេសធំៗចំនួន៤គឺ ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក សហភាពសូវៀត និងប្រទេសចិន។ ក្រុមប្រទេស Axis មាន Nazi Germany, Empire of Japan, និង Kingdom of Italy។

តារាង ៦៩. បង្ហាញអំពីចំនួនទាហានស្លាប់ ជនស៊ីវិលស្លាប់ និង ទាហានរងរបួសនៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ ពីឆ្នាំ១៩៣៩ ដល់ ឆ្នាំ១៩៤៥។ ចំនួនអ្នកស្លាប់ច្រើនជាងគេ គឺសហភាពសូវៀតមានចំនួនប្រហែល ២៤លាននាក់ ក្នុងនោះមានទាហានស្លាប់ប្រហែល ១០លាននាក់ ក្រៅពីនោះជាជនស៊ីវិល។ ប្រទេសចិនមានចំនួនអ្នកស្លាប់ប្រហែល២០លាននាក់ ក្នុងនោះមានទាហានស្លាប់ពី៣ទៅ៤លាននាក់ ប្រទេសអាល្លឺម៉ង់មានអ្នកស្លាប់ចំនួនចន្លោះពី ៦ ដល់៨លាននាក់ ក្នុងនោះមានទាហានស្លាប់ប្រហែល ៥,៥លាននាក់ ប្រទេសជប៉ុន មានអ្នកស្លាប់ប្រហែល៣លាននាក់ ក្នុងនោះមានទាហានចំនួន២,១លាននាក់ និងប្រទេសប៉ូឡូញមានអ្នកស្លាប់ចំនួន ៥,៦លាននាក់ ក្នុងនោះទាហានស្លាប់ប្រហែល២៤ម៉ឺននាក់។

## តារាង ៦៩. ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី២

| Country | Military Deaths | Total Civilian and Military Deaths |
|---|---:|---:|
| Albania | 30,000 | 30,200 |
| Australia | 39,800 | 40,500 |
| Austria | 261,000 | 384,700 |
| Belgium | 12,100 | 86,100 |
| Brazil | 1,000 | 2,000 |
| Bulgaria | 22,000 | 25,000 |
| Canada | 45,400 | 45,400 |
| China | 3-4,000,000 | 20,000,000 |
| Czechoslovakia | 25,000 | 345,000 |
| Denmark | 2,100 | 3,200 |
| Dutch East Indies | -- | 3-4,000,000 |
| Estonia | -- | 51,000 |
| Ethiopia | 5,000 | 100,000 |
| Finland | 95,000 | 97,000 |
| France | 217,600 | 567,600 |
| French Indochina | -- | 1-1,500,000 |
| Germany | 5,533,000 | 6,600,000-8,800,000 |
| Greece | 20,000-35,000 | 300,000-800,000 |
| Hungary | 300,000 | 580,000 |
| India | 87,000 | 1,500,000-2,500,000 |
| Italy | 301,400 | 457,000 |
| Japan | 2,120,000 | 2,600,000-3,100,000 |
| Korea | -- | 378,000-473,000 |
| Latvia | -- | 227,000 |
| Lithuania | -- | 353,000 |
| Luxembourg | -- | 2,000 |
| Malaya | -- | 100,000 |
| Netherlands | 17,000 | 301,000 |
| New Zealand | 11,900 | 11,900 |
| Norway | 3,000 | 9,500 |
| Papua New Guinea | -- | 15,000 |
| Philippines | 57,000 | 500,000-1,000,000 |
| Poland | 240,000 | 5,600,000 |
| Romania | 300,000 | 833,000 |
| Singapore | -- | 50,000 |
| South Africa | 11,900 | 11,900 |
| Soviet Union | 8,800,000-10,700,000 | 24,000,000 |
| United Kingdom | 383,600 | 450,700 |
| United States | 416,800 | 418,500 |
| Yugoslavia | 446,000 | 1,000,00 |

### ក្រាហ្វិក ១៤៤. ចំនួនអ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី២




ប្រភព÷ 1) https://www.census.gov/history/pdf/reperes112018.pdf. *(Accessed 24 October 2023).*

2) https://www.nationalww2museum.org/students-teachers/student-resources/research-starters/research-starters-worldwide-deaths-world-war. *(Accessed 24 October 2023).*

*សំគាល់÷ *Worldwide casualty estimates vary widely in several sources. The number of civilian deaths in China alone might well be more than 50,000,000*

## ខ. កម្ពុជា

### ខ១. ស្ថានភាពគ្រាប់មីន និងអាវុធជាតិផ្ទុះ

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមជាច្រើន នៅក្នុងដំណាក់កាលនៃសម័យកាលនីមួយៗ ជាពិសេស ជាមួយនឹងប្រទេសជិតខាង។ បន្ទាប់មានបញ្ចប់ជម្លោះជាមួយនឹងប្រទេស កម្ពុជាមានសង្គ្រាមផ្ទៃក្នុងរវាងខ្មែរ និងខ្មែរ។ សង្គ្រាមនេះបានធ្លាក់ចូលក្នុងគ្រោះមហន្តរាយយ៉ាងធំធេង ដូចជាការបាត់បង់ជីវិតមនុស្ស និងបន្សល់ទុកគ្រាប់មីនជាច្រើននៅក្នុងប្រទេសកម្ពុជា។

ក្រោយថ្ងៃរំដោះ៧មករាឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានរួចផុតពីរបបប្រល័យពូជសាសន៍ ប្រជាជាតិខ្មែរទាំងមូលបានរស់ឡើងវិញ ហើយក្រសួងស្ថាប័នរដ្ឋត្រូវបានបង្កើតឡើងវិញ។ ពេលនោះ ក្រសួងផែនការ មិនទាន់បានបង្កើតនៅឡើយ តែការងារផែនការបានបញ្ចូលនៅក្នុងក្រសួងសេដ្ឋកិច្ច

និងជីវភាព។ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ១៩៨១ ការបោះក្រដាសប្រាក់រៀល និងចរាចរប្រាក់រៀលត្រូវបានដាក់ឲ្យប្រើប្រាស់ឡើងវិញ បន្ទាប់ពីត្រូវបានលុបចោលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ក្រសួងសេដ្ឋកិច្ច និងជីវភាពត្រូវបានបែកជាៈ ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ និង ក្រសួងផ្សេងៗទៀត។ ចាប់ពីពេលនោះមក ក្រសួងផែនការមានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំផែនការ និងលើកទិសដៅអនុវត្តដល់គ្រប់បណ្ដាក្រសួងទាំងអស់សម្រាប់គ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ចជាតិតាមបែបសេដ្ឋកិច្ចផែនការ។ នៅក្នុងដំណាក់កាលនោះ ប្រទេសកម្ពុជាពុំទាន់បានទទួលសន្តិភាពទាំងស្រុងនៅឡើយទេ តែក្រោមការដឹកនាំប្រកបដោយភាពវៃឆ្លាត និងគតិបណ្ឌិត **សម្ដេចនាយករដ្ឋមន្ត្រី** បានដាក់ចេញនូវគោលនយោបាយបង្រួបបង្រួមជាតិ ដែលបានឈានដល់ការជួបសន្ទនា ឬ ហៅកាត់ថាការចរចា **សីហនុ ហ៊ុនសែន** នៅហ្វែរអង់តាដឺន័រ នៅប្រទេសបារាំងថ្ងៃទី ២ ខែធ្នូ ឆ្នាំ ១៩៨៧ រហូតដល់ការបង្កើតបានកិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃទី ២៣ ខែ តុលា ឆ្នាំ១៩៩១ ។ អនុវត្តកិច្ចព្រមព្រៀងនេះ ការបោះឆ្នោតនៅឆ្នាំ ១៩៩៣ ដែលបានរៀបចំឡើងដោយអាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិ (UNTAC) នៅកម្ពុជាត្រូវបានធ្វើឡើង របបរាជានិយមត្រូវបានបង្កើតជាថ្មី។ ប៉ុន្តែសង្គ្រាមនៅតែអូសបន្លាយ ដោយកើតមានឡើងនៅតាមតំបន់មួយចំនួនរហូតដល់ចុងឆ្នាំ១៩៩៨ ទើបសង្គ្រាមត្រូវបានបញ្ចប់ទាំងស្រុងតាមរយៈគោលនយោបាយ «**ឈ្នះៗ**» ដឹកនាំដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ បើទោះបីសង្គ្រាមបានបញ្ចប់មែន តែគ្រាប់មីន និងអាវុធជាតិផ្ទុះបានកប់នៅក្នុងដី។ ដូច្នេះនៅក្នុងគោលដៅអភិវឌ្ឍន៍សហវត្សរ៍សកលមាន ៨គោលដៅ តែសម្រាប់ប្រទេសកម្ពុជាបានបន្ថែមតែ១គោលដៅទៀតគឺការដោះមីន និងអាវុធជាតិផ្ទុះ សរុបទាំងអស់៩គោលដៅ។

**ក្រាហ្វិក ១៤៥. ចំនួនគ្រាប់មីន និងអាវុធជាតិផ្ទុះដែលបានកម្ទេច (១៩៩២-២០២៣)**



## ក្រាហ្វិក ១៤៦. ចំនួនជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ (១៩៩២-២០២៣)




## ក្រាហ្វិក ១៤៧. ប្រភេទជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់ (១៩៩២ -២០២៣)




ប្រភព៖ អាជ្ញាធរមីនកម្ពុជា

**ក្រាហ្វិក ១៤៨. ចំនួនជនរងគ្រោះដោយគ្រាប់មីន និង ដោយសារគ្រាប់**
**ពីឆ្នាំ១៩៩២ -២០២៣ តាមរាជធានី ខេត្ត**




ប្រភព៖ អាជ្ញាធរមីនកម្ពុជា

## ១២. ឧប្បត្តិហេតុប្រដាប់អាវុធនៅតំបន់ព្រំដែនកម្ពុជា និង ថៃ

នៅក្នុងឆ្នាំ២០២៥នេះ ក្រៅពីគ្រោះមហន្តរាយដោយធម្មជាតិ អគ្គីភ័យ និងការបាក់ច្រាំងទន្លេ ក៏មានគ្រោះមហន្តរាយដ៏ធំមួយទៀត គឺឧប្បត្តិហេតុប្រដាប់អាវុធនៅតំបន់ព្រំដែនកម្ពុជា និងថៃ ដែលមានការប៉ះទង្គិចគ្នារហូតដល់២លើក គឺលើទី១ចំនួន៥ថ្ងៃនៅក្នុងខែកក្កដា និងលើកទី២នៅក្នុងខែធ្នូ ដែលមានរយៈពេល២១ថ្ងៃ នៅក្នុងឆ្នាំ២០២៥ ដែលបង្កឡើងដោយទង្វើឈ្លានពានរបស់ថៃ។ យោធាថៃបានប្រើអាវុធយុទ្ធោបករណ៍ធុនធ្ងន់ និងមានកម្រិតបំផ្លាញខ្ពស់ដូចជាការប្រើប្រាស់យន្តហោះ F-16 នាវាចម្បាំង កាំភ្លើងធំគ្រប់ប្រភេទ រថក្រោះ និងរថពាសដែក គ្រាប់បែកចង្កោម ដ្រូនទម្លាក់គ្រប់បែកគ្រប់ប្រភេទ និងការបាញ់ផ្សែងពុលមកលើមូលដ្ឋានទ័ព ភូមិឋានប្រជាជន រួមនឹងតំបន់បេតិកភណ្ឌវប្បធម៌ដែលជាសម្បត្តិមនុស្សជាតិ ដោយបង្កឲ្យមានវិនាសកម្មយ៉ាងធ្ងន់ធ្ងរលើគ្រប់វិស័យ លើមូលដ្ឋានរងគ្រោះខេត្តចំនួន៨ ដែលរងផលប៉ះពាល់រួមមានខេត្តព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន សៀមរាប ពោធិ៍សាត់ និងខេត្តកោះកុង។ ក្នុងនេះប្រជាជនភៀសសឹកក្រៅពីមូលដ្ឋានខេត្តចំនួន១០ ទៀតគឺខេត្តកំពត កំពង់ស្ពឺ កណ្ដាល កំពង់ចាម កំពង់ធំ កែប

មណ្ឌលគិរី ព្រះសីហនុ និងខេត្តក្រចេះ។ ការខូចខាត និងបាត់បង់ក្នុងការប៉ះទង្គិចគ្នាទាំង២លើក បានធ្វើឲ្យប៉ះពាល់ដល់វិស័យសង្គមកិច្ច វិស័យអប់រំ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ លើសពីនេះ ក៏មានការបាត់បង់វីរៈកងទ័ព និងជនស៊ីវិលផងដែរ។

### ខ២.១ វិស័យសង្គមកិច្ច

ឧប្បត្តិហេតុប្រដាប់អាវុធនៅតំបន់ព្រំដែនកម្ពុជា និងថៃ ដែលមានការប៉ះទង្គិចគ្នារហូតដល់២ លើក គឺលើទី១ចំនួន៥ថ្ងៃនៅក្នុងខែកក្កដា និងលើកទី២នៅក្នុងខែធ្នូ ដែលមានរយៈពេល២១ថ្ងៃ នៅក្នុងឆ្នាំ២០២៥ បានធ្វើឲ្យប្រជាជនបានរត់ភៀសសឹកចំនួន ៧៨៩.៧២៩នាក់ ស្មើនឹង ២៤៤.៤៣៣ គ្រួសារ ព្រមទាំងបាត់បង់ជីវិតមនុស្ស ៤០ នាក់ និងរងរបួសធ្ងន់ស្រាលចំនួន៣៩៣។ ក្រៅពីការនេះទៀត ក៏មានការខូចខាតលំនៅដ្ឋាន វត្តអារាម មន្ទីរពេទ្យ សាលារៀនជាដើម។ ទិន្នន័យលម្អិតមាន បង្ហាញជូននៅក្នុងតារាង ៧០ និងក្រាហ្វិក ១៤៩ ដូចខាងក្រោម។

**តារាង ៧០. ផលប៉ះពាល់ដល់វិស័យសង្គមកិច្ច**

| បរិយាយ | ចំនួន |
|---|---|
| គ្រួសារដែលបានភៀសសឹក(គ្រួសារ) | 244,433 |
| ប្រជាជនដែលបានភៀសសឹក(នាក់) | 789,729 |
| លំនៅដ្ឋាន(ខ្នង) | 717 |
| មណ្ឌលសុខភាព | 23 |
| វត្តអារាម | 12 |
| អគាររដ្ឋបាលនិងអគារកងទ័ព | 14 |
| បេតិកភ័ណ្ឌវប្បធម៌ | 4 |
| សណ្ឋាគារនិងអគារកាស៊ីណូ(កន្លែង) | 10 |
| ស្ថានីយ៍ប្រេង(កន្លែង) | 5 |
| ផ្សារ(កន្លែង) | 2 |
| ប្រជាជនរងគ្រោះស្លាប់(នាក់) | 40 |
| របួសធ្ងន់ស្រាល(នាក់) | 393 |
| ប្រជាជនដែលរងផ្សែងពុល(នាក់) | 392 |

ក្រាហ្វិក ១៤៩. ចំនួនអ្នកស្លាប់ របួស និងរងផ្សែងពុល




## ៦២.២ វិស័យអប់រំ

ផលប៉ះពាល់ដល់វិស័យអប់រំដោយសារឧប្បត្តិហេតុប្រដាប់អាវុធនៅតំបន់ព្រំដែនកម្ពុជា និងថៃ ដែលមានការប៉ះទង្គិចគ្នារហូតដល់២លើក គឺលើទី១ចំនួន៥ថ្ងៃនៅក្នុងខែកក្កដា និងលើកទី២នៅក្នុងខែធ្នូ ចំនួន ២១ថ្ងៃ បានធ្វើឲ្យសាលារៀនចំនួន ១.០៤២ កន្លែង គ្រូបង្រៀន ៩.៨៦៥ នាក់ និងសិស្សសាលាចំនួន ២៤៥.០០១ នាក់ ក្នុងនោះខូចខាតសាលាចំនួន២៥កន្លែង និងមូលដ្ឋានរងគ្រោះនៅក្នុងខេត្តចំនួន ៧ (តារាង៧១ និងក្រាហ្វិក១៥០)។

តារាង ៧១. ផលប៉ះពាល់ដល់វិស័យអប់រំ

| បរិយាយ | ចំនួន |
|---|---|
| មូលដ្ឋានរងគ្រោះនៅក្នុងខេត្ត | 7 |
| សាលារៀនគ្រប់កម្រិតបិទទ្វារ(សាលា) | 1,042 |
| ប៉ះពាល់សិស្ស(នាក់) | 245,001 |
| ប៉ះពាល់ដល់គ្រូបង្រៀន(នាក់) | 9,865 |
| សាលារៀនខូចខាត(កន្លែង) | 25 |
| សាលារៀនដែលរងការខូចខាតដោយការទម្លាក់គ្រាប់បែកពីលើយន្តហោះ(កន្លែង) | 5 |

## ក្រាហ្វិក ១៥០. ចំនួនសាលារៀនបានបិទទ្វារ និងប៉ះពាល់ដល់គ្រូបង្រៀន




### ១២.៣ វិស័យហេដ្ឋារចនាសម្ព័ន្ធ

ផលប៉ះពាល់ដល់វិស័យអប់រំដោយសារឧប្បត្តិហេតុប្រដាប់អាវុធនៅតំបន់ព្រំដែនកម្ពុជា និងថៃ ដែលមានការប៉ះទង្គិចគ្នារហូតដល់២លើក គឺលើទី១ចំនួន៥ថ្ងៃនៅក្នុងខែកក្កដា និងលើកទី២នៅក្នុងខែធ្នូ ចំនួន ២១ថ្ងៃ បានធ្វើឲ្យខូចខាតផ្លូវថ្នល់ចំនួន ៧៣ទីតាំង ខូចខាតបណ្តាញអគ្គិសនីនៅក្នុងខេត្តឧត្តរមានជ័យចំនួន ៤កន្លែង និងខូចខាតស្ពានចំនួន ៥កន្លែង ព្រមទាំងមានបន្សល់ទុកគ្រាប់បែកចង្កោមរាប់ពាន់គ្រាប់នៅតាមដីលំនៅដ្ឋាន ប្រាសាទបុរាណ និងដីស្រែចម្ការរបស់ប្រជាជន (តារាង ៧២ និងក្រាហ្វិក១៥១)។

**តារាង ៧២. ផលប៉ះពាល់ដល់វិស័យហេដ្ឋារចនាសម្ព័ន្ធ**

| បរិយាយ | ចំនួន |
|---|---|
| ផ្លូវថ្នល់ខូចខាត(ទីតាំង) | 73 |
| ខូចខាតបណ្តាញអគ្គិសនីក្នុងខេត្តឧត្តរមានជ័យ | 4 |
| ផ្ទៃដីលំនៅឋានតំបន់ប្រាសាទបុរាណនិងវាលស្រែចម្ការរាយប៉ាយដោយគ្រាប់បែកចង្កោមនិងគ្រាប់មិនទាន់ផ្ទុះ(គ្រាប់) | 1,000-50,000 |
| ខូចខាតស្ពាន(កន្លែង) | 5 |

## ក្រាហ្វិក ១៥១. ផលប៉ះពាល់ដល់វិស័យហេដ្ឋារចនាសម្ព័ន្ធ



## ៣.១.៥ ការប្រែប្រួលអាកាសធាតុ



នៅគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ បានកំណត់គោលដៅចំនួន ១៧ ដែលក្នុងនោះ នៅក្នុងគោលដៅទី ១៣ គឺ វិធានការលើការប្រែប្រួលអាកាសធាតុ (Climate Action) ។ នៅក្នុងគោលដៅទី ១៣ នេះ មានចំណុចដៅចំនួន ៥ គឺ ១៣.១, ១៣.២, ១៣.៣, ១៣.A និង ១៣.B ។

ការប្រែប្រួលអាកាសធាតុ គឺជាដំណើរការប្រែប្រួលបន្តិចម្តងៗនៃអាកាសធាតុ ក្នុងរយៈពេលវែង ក្នុងនោះរួមមាន សីតុណ្ហភាព និង ស្ថានភាពទឹកភ្លៀង របបខ្យល់ ឬ គម្របទឹកកក ជាដើម។ ការប្រែប្រួលនេះ កើតឡើងដោយសារ កត្តាធម្មជាតិ និងសកម្មភាពមនុស្សផងដែរ។ មូលហេតុ នៃការប្រែប្រួលអាកាសធាតុ អាចកើតឡើងដោយធម្មជាតិ ឬដោយសារសកម្មភាពមនុស្សរួមមាន៖

- សកម្មភាពមនុស្ស ដូចជាការដុតប្រេងឥន្ធនៈហ្វូស៊ីល ការកាប់បំផ្លាញព្រៃឈើ កសិកម្ម ។ល។ បានបញ្ចេញឧស្ម័នផ្ទះកញ្ចក់យ៉ាងច្រើន ទៅក្នុងបរិយាកាសផែនដី
- កំណើនកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសរាំងស្កាត់កំដៅដែលផ្លាតចេញពីផ្ទៃផែនដី ឱ្យនៅក្នុងបរិយាកាសកាន់តែច្រើន ដែលជាមូលហេតុនៃកំណើនកំដៅសកល
- បាតុភូត "ផលផ្ទះកញ្ចក់" សំដៅលើកំណើនសីតុណ្ហភាពបរិយាកាស ដោយសារកំដៅដែលចាំងផ្លាតពីផ្ទៃផែនដី ហើយត្រូវរាំងស្កាត់មិនឱ្យភាយចេញទៅ ក្នុងលំហអវកាសបាន
- ឧស្ម័នផ្ទះកញ្ចក់(GHGs)សំខាន់ៗ នៅក្នុងបរិយាកាសរួមមាន ៖ ចំហាយទឹក(water vapor), ឧស្ម័នកាបូនិច CO2, មេតាន CH4, ឌីអាសូតម៉ូណូអុកស៊ីត N2O, អ៊ីដ្រូហ្លួយអរ៉ូកាបូន HFCs, ពែរហ្លួយអរ៉ូកាបូន PFCs, ស៊ុលភួអិចសាភ្លួរ SF6 ។

ការប្រែប្រួលអាកាសធាតុបានធ្វើឲ្យមានគ្រោះធម្មជាតិផ្សេងៗដូចជាខ្យល់ព្យុះ គ្រោះទឹកជំនន់ និងភាពរាំងស្ងួតជាដើម។ គ្រោះធម្មជាតិទាំងនេះ បានធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅខ្លាំងចំពោះប្រជាជននៅតាមជនបទជាពិសេសប៉ះពាល់ដល់ការធ្វើកសិកម្ម។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ក្នុងឆ្នាំ១៩៩៥ ។

ប្រទេសកម្ពុជាមានផ្ទៃដី ១៨១.០៣៥ គីឡូម៉ែត្រក្រឡា ស្ថិតនៅភាគនិរតីនៃឧបទ្វីបអាស៊ីបូព៌ា ហើយផ្ទៃដីប្រមាណ ២០ ភាគរយត្រូវបានប្រើប្រាស់សម្រាប់ដំណាំកសិកម្ម ។ ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់ត្រូពិកទាំងស្រុង និងស្ថិតនៅចំណុចខាងត្បូងច្រើនជាង១០អង្សា នៅលើអេក្វាទ័រ។ សីតុណ្ហភាពអតិបរមាខ្ពស់ជាង៣៣អង្សាសេ ជាទូទៅចាប់ផ្តើមរដូវវស្សានៅខែមីនា និងខែមេសា ហើយអាចកើនឡើងដល់ ៣៨ អង្សាសេ។ សីតុណ្ហភាពអប្បបរមាធ្លាក់នៅក្រោម១០ អង្សាសេ។ នៅខែមករា ជាខែត្រជាក់បំផុត និង ខែមេសាជាខែដែលក្តៅបំផុត។ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ គឺរវាង ១៤២ និង ២០០សង់ទីម៉ែត្រ ។ ភ្លៀងធ្លាក់ពីខែ មេសាដល់ខែកញ្ញា ក្នុងតំបន់ដីទំនាបបឹងទន្លេសាប

មេគង្គ ជាមធ្យមប្រចាំឆ្នាំពី ១១០ ទៅ ១៩០សង់ទីម៉ែត្រ ប៉ុន្តែបរិមាណនេះប្រែប្រួលដែលគួរឲ្យកត់សំគាល់ពីមួយឆ្នាំទៅមួយឆ្នាំ ។ តែទោះបីយ៉ាងណាក៏ដោយ តំបន់ទឹកភ្លៀងដ៏ធំបំផុតនេះភាគច្រើនហូរទៅសមុទ្រ ហើយមានបរិមាណតិចតួចប៉ុណ្ណោះ ដែលហូរតាមស្ទឹងទន្លេចូលក្នុងបឹងទន្លេសាប។ សំណើមនៅប្រទេសកម្ពុជា គឺខ្ពស់នៅពេលយប់ពេញមួយឆ្នាំ និងនៅពេលរដូវប្រាំងសំណើមមធ្យមប្រមាណ ៥០ភាគរយ ឬ ទាបជាងបន្តិច ប៉ុន្តែវាអាចមានប្រមាណ ៦០ ភាគរយ នៅរដូវវស្សា។

### ក. ការយល់ដឹងពីការប្រែប្រួលអាកាសធាតុ

យោងតាមរបាយការណ៍របស់ក្រសួងបរិស្ថាន ដែលបានសិក្សាអំពីឥរិយាបថនៃការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងអាកាសធាតុសកលតាមរយៈការសម្ភាសន៍ពីប្រជាជន សិស្ស និសិត្ស និងកម្មករជាដើម។ តាមលទ្ធផលបានបង្ហាញថា ភាគរយអ្នកដែលបានយល់ដឹងពីការប្រែប្រួលអាកាសធាតុមានចំនួន ៧២% ក្នុងនោះអ្នកយល់ដឹងអំពីអត្ថន័យការប្រែប្រួលមានចំនួន ៣៣% និងមិនយល់ដឹងអំពីអត្ថន័យការប្រែប្រួលមានចំនួន ៣៩% និងមិនដែលដឹងអំពីការប្រែប្រួលមានចំនួន ២៨%។ ចំពោះការយល់ដឹងអំពីអាកាសធាតុសកលមានចំនួន ៧១% ក្នុងនោះ៣១% យល់ដឹងពីអត្ថន័យនៃអាកាសធាតុសកល និងដឹងតែមិនយល់ពីអត្ថន័យមានចំនួន៤០% និងមិនដឹងចំនួន ២៩%។ ក្រាហ្វិក ១៥២ បង្ហាញអំពីការយល់ដឹងអំពីអត្ថន័យការប្រែប្រួលអាកាសធាតុ និង អាកាសធាតុសកល។

**ក្រាហ្វិក១៥២. ការយល់ដឹងអំពីអត្ថន័យការប្រែប្រួលអាកាសធាតុ និង អាកាសធាតុសកលនៅកម្ពុជា**




ប្រភព÷ Ministry of Environment, *A Third Study Understanding Public Perception of Climate Change in Cambodia, Knowledge, Attitude, and Practice (KAP3),* Ministry of Environment, 2020.

ក្រាហ្វិក១៥៣ អំពីការយល់ដឹងអំពីស្ថានភាពអាកាសធាតុតាមប្រភេទ និងតាមតំបន់នៅកម្ពុជា។ តាមទិន្នន័យខាងក្រោមដែលបានមកពីការសម្ភាសន៍នៅតាមតំបន់ផ្សេងៗពីគ្នា ហើយបានឆ្លើយថា ការប្រែប្រួលអាកាសធាតុអាចឲ្យមានភ្លៀងធ្លាក់ មានសីតុណ្ហភាពប្រែប្រួល ទឹកជំនន់ គ្រោះរាំងស្ងួត និងបណ្តាលឲ្យមានខ្យល់ព្យុះ ។ ទិន្នន័យលំអិតមានបង្ហាញក្នុងក្រាហ្វិកខាងក្រោម។

**ក្រាហ្វិក ១៥៣. ការយល់ដឹងអំពីស្ថានភាពអាកាសធាតុតាមប្រភេទ និងតាមតំបន់នៅកម្ពុជា**




ប្រភព៖ Ministry of Environment, *A Third Study Understanding Public Perception of Climate Change in Cambodia, Knowledge, Attitude, and Practice (KAP3),* Ministry of Environment, 2020.

## ខ. កត្តាចម្បងនៃការប្រែប្រួលអាកាសធាតុ

ក្រាហ្វិក១៥៤ បង្ហាញអំពីកត្តាដែលនាំឲ្យមានការប្រែប្រួលអាកាសធាតុ តាមរយៈការសម្ភាសន៍ប្រជាជនកម្ពុជា។ តាមទិន្នន័យបានបង្ហាញថា មូលហេតុដែលនាំឲ្យមានការប្រែប្រួលអាកាសធាតុដែលបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើមានចំនួន៧៦% អត្រាភាគរយខ្ពស់ជាងគេលំដាប់ទី១ បន្ទាប់មកសកម្មភាពមនុស្សលំដាប់ទី២មានចំនួន ៥៣% កត្តាធម្មជាតិ៥២% ការបំផ្លាញស្រទាប់អូហ្សូន ៥០% កំណើនប្រជាជន ៤៩% បំលាស់ទីទៅទីក្រុង៣៤% និងពិធីសាសនាដូចជាដុតក្រដាស បណ្តែតសពក្នុងទន្លេ ជាដើមមានចំនួន ៣២% តាមលំដាប់រៀង។

## ក្រាហ្វិក ១៥៤. កត្តាចម្បងដែលនាំឱ្យមានការប្រែប្រួលអាកាសធាតុនៅកម្ពុជា




ប្រភព÷ Ministry of Environment, *A Third Study Understanding Public Perception of Climate Change in Cambodia, Knowledge, Attitude, and Practice (KAP3),* Ministry of Environment, 2020.

### គ. ការបំភាយឧស្ម័នផ្ទះកញ្ចក់តាមវិស័យ

យោងតាមរបាយការណ៍ស្ថានភាពបរិស្ថានលើកទី៤ របស់ក្រសួងបរិស្ថានបានបង្ហាញថា ការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយការប្រែប្រួលដី និងព្រៃឈើមានចំនួនច្រើនជាងគេ។ នៅឆ្នាំ១៩៩៤ មានចំនួនប្រហែល ៨១,១% ហើយព្យាករណ៍ថា ឆ្នាំ២០២០ មានការថយចុះមកត្រឹម៦៣%។ វិស័យកសិកម្មគឺមានការបំភាយផ្ទះកញ្ចក់លំដាប់ទី២ គឺនៅឆ្នាំ១៩៩៤ មានចំនួន១៥,៥% ហើយបានកើនឡើងនៅឆ្នាំ២០២០ មានចំនួន ២៧,៥%។ វិស័យថាមពលនិងឧស្សាហកម្ម មានចំនួន ២,៩% នៅឆ្នាំ១៩៩៤ នឹងអាចកើនឡើងដល់ ៩,០% នៅឆ្នាំ២០២០។

### ក្រាហ្វិក ១៥៥. ការបំភាយឧស្ម័នផ្ទះកញ្ចក់តាមវិស័យ




ប្រភព៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី៤* អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានឆ្នាំ ២០២១។
សំគាល់៖ ទិន្នន័យឆ្នាំ ២០១០ និងឆ្នាំ ២០២០ គឺជាទិន្នន័យធ្វើចំណោលផ្អែកលើទិន្នន័យឆ្នាំ ២០០២។

## ឃ. ស្ថានភាពទឹកភ្លៀង

ក្រាហ្វិក១៥៤ បង្ហាញអំពីកម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំតាមស្ថានីយ គិតជាមីលីម៉ែត្រ សម្រាប់ទូទាំងប្រទេសកម្ពុជា ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ពីឆ្នាំ ២០១៦ ដល់ ២០២៥។ នៅក្នុងប្រទេសកម្ពុជា កម្ពស់ទឹកភ្លៀងអប្បបរមា ១.៦៣៥ មីលីម៉ែត្រ កម្ពស់អតិបរមា ២.១៥០ មីលីម៉ែត្រ និងកម្ពស់ជាមធ្យម ១.៨២៩ មីលីម៉ែត្រ គិតពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២៥។ នៅក្នុងខេត្តកំពង់ចាម កម្ពស់ទឹកភ្លៀងអប្បបរមា ១.០៦៣ មីលីម៉ែត្រ កម្ពស់អតិបរមា ១.៩៧៤ មីលីម៉ែត្រ និង កម្ពស់គិតជាមធ្យម ១.៤៨១ មីលីម៉ែត្រ គិតពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២៥។ ខេត្តត្បូងឃ្មុំ កម្ពស់ទឹកភ្លៀងអប្បបរមា ១.២២៦ មីលីម៉ែត្រ កម្ពស់អតិបរមា ២.២០៤ មីលីម៉ែត្រ និង កម្ពស់គិតជាមធ្យម ១.៧៨៤ មីលីម៉ែត្រ គិតពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២៥ (ក្រាហ្វិក ១៥២)។ ចំនួនថ្ងៃភ្លៀងក្នុង១ឆ្នាំ នៅក្នុងប្រទេសកម្ពុជាគិតជាមធ្យម ១៣៣ ថ្ងៃ និងខេត្តកំពង់ចាម-ត្បូងឃ្មុំ មានចំនួន១២៦ថ្ងៃ។ នៅទូទាំងប្រទេស ចំនួនថ្ងៃភ្លៀងអប្បបរមាមានចំនួន ១០៩ថ្ងៃ និងកំពង់ចាម-ត្បូងឃ្មុំ ៩៨ថ្ងៃ។ ចំនួនថ្ងៃភ្លៀងអតិបរមា មានចំនួនសម្រាប់ទូទាំងប្រទេសមានចំនួន១៤៧ថ្ងៃ និង កំពង់ចាម-ត្បូងឃ្មុំ ១៤៧ថ្ងៃដូចគ្នាគិតពីឆ្នាំ ២០០៣ដល់២០១៨ (ក្រាហ្វិក១៥៦)។

**ក្រាហ្វិក ១៥៦. កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ តាមស្ថានីយគិតជាមីលីម៉ែត្រ**




ប្រភព: នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

ក្រាហ្វិក ១៥៧. បង្ហាញអំពីចំនួនថ្ងៃដែលមានភ្លៀងក្នុងមួយឆ្នាំគិតជាមធ្យម តាមស្ថានីយសម្រាប់ទូទាំងប្រទេស និងខេត្តកំពង់ចាម/ខេត្តត្បូងឃ្មុំ។ តាមនិន្នាការបានបង្ហាញថា នៅទូទាំងប្រទេសចំនួនថ្ងៃដែលមានភ្លៀងធ្លាក់ពីឆ្នាំ២០០៣ ដល់ ២០១៨ គឺស្ថិតនៅចន្លោះពី ១០៩ថ្ងៃ ដល់ ១៤៧ថ្ងៃ នៅក្នុងរយៈពេល១ឆ្នាំ។ ខេត្តកំពង់ចាម/ខេត្តត្បូងឃ្មុំ ចំនួនថ្ងៃដែលមានភ្លៀងធ្លាក់ពីឆ្នាំ២០០៣ ដល់ ២០១៨ គឺស្ថិតនៅចន្លោះពី ៩៨ថ្ងៃ ដល់ ១៤៧ ថ្ងៃ និង គិតជាមធ្យមមាន១២៦ថ្ងៃ នៅក្នុងរយៈពេល១ឆ្នាំ ដែលក្នុងនោះឆ្នាំដែលមានចំនួនថ្ងៃមានចំនួនថ្ងៃដែលភ្លៀងធ្លាក់ច្រើនជាងគេ គឺឆ្នាំ២០០៩ ឆ្នាំ ២០១០ និងឆ្នាំ២០១៧ ។ សូមបញ្ជាក់ថា ដោយសារខេត្តត្បូងឃ្មុំពុំមានទិន្នន័យអំពីចំនួនភ្លៀង ដូច្នេះសន្មត់ថា មានលក្ខណៈដូចខេត្តកំពង់ចាមដែរ ព្រោះខេត្តទាំងពីរនេះជាខេត្តតែមួយ។

### ក្រាហ្វិក ១៥៧. ចំនួនថ្ងៃមានភ្លៀងក្នុងមួយឆ្នាំគិតជាមធ្យមតាមស្ថានីយ




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

## ខ. សីតុណ្ហភាព

សីតុណ្ហភាពអប្បបរមានៅទូទាំងប្រទេស ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំពីឆ្នាំ២០០២៣ ដល់ ២០២៥។ នៅទូទាំងប្រទេស សីតុណ្ហភាពអប្បបរមា ១៥,៥ អង្សាសេ(°C) អតិបរមា ២៤ អង្សាសេ (°C) និងគិតជាមធ្យម ២០,២អង្សាសេ (°C)។ ខេត្តកំពង់ចាមសីតុណ្ហភាពអប្បបរមា ១៦ អង្សាសេ (°C) អតិបរមាមាន២៤,៥ អង្សាសេ (°C) និងគិតជាមធ្យមភាគ ២០,៤ អង្សាសេ (°C)។ ខេត្តត្បូងឃ្មុំ សីតុណ្ហភាពអប្បបរមា ១៧ អង្សាសេ (°C) អតិបរមាមាន២៤,៥ អង្សាសេ (°C) និងគិតជាមធ្យមភាគ ២០,៥ អង្សាសេ (°C)។ ទិន្នន័យខេត្តត្បូងឃ្មុំពីឆ្នាំ២០០៣ ដល់ ២០១៦ ដូចខេត្តកំពង់ចាមដែរ (តារាង ៧៣ និង ក្រាហ្វិក១៥៨)។

### តារាង ៧៣. សីតុណ្ហភាពអប្បបរមា (អប្បបរមា អតិបរមា និងមធ្យមភាគ) ពីឆ្នាំ២០០៣ដល់២០២៥

| បរិយាយ | កម្ពុជា | កំពង់ចាម | ត្បូងឃ្មុំ |
|---|---|---|---|
| អប្បបរមា | 15.5 | 16.0 | 17.0 |
| អតិបរមា | 24.0 | 24.5 | 24.5 |
| មធ្យមភាគ | 20.2 | 20.4 | 20.5 |

### ក្រាហ្វិក ១៥៨. សីតុណ្ហភាពអប្បបរមា គិតជាអង្សាសេ




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

## ខ. សីតុណ្ហភាព

សីតុណ្ហភាពអតិបរមានៅទូទាំងប្រទេស ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំពីឆ្នាំ២០០២៣ ដល់ ២០២៥។ នៅទូទាំងប្រទេស សីតុណ្ហភាពអប្បបរមា ៣២,០ អង្សាសេ(°C) អតិបរមា ៤០,២ អង្សាសេ (°C) និងគិតជាមធ្យម ៣៥,៨ អង្សាសេ (°C)។ ខេត្តកំពង់ចាមសីតុណ្ហភាពអប្បបរមា ៣២,១ អង្សាសេ (°C) អតិបរមាមាន ៤១,០ អង្សាសេ (°C) និងគិតជាមធ្យមភាគ ៣៥,៩ អង្សាសេ (°C)។ ខេត្តត្បូងឃ្មុំ សីតុណ្ហភាពអប្បបរមា ៣២,១ អង្សាសេ (°C) អតិបរមា ៤១,០ អង្សាសេ (°C) និងគិតជាមធ្យមភាគ ៣៥,៩ អង្សាសេ (°C)។ ទិន្នន័យខេត្តត្បូងឃ្មុំពីឆ្នាំ២០០៣ ដល់ ២០១៦ ដូចខេត្តកំពង់ចាមដែរ (តារាង ៧៤ និង ក្រាហ្វិក១៥៧)។

### តារាង ៧៤. សីតុណ្ហភាពអតិបរមា (អប្បបរមា អតិបរមា និងមធ្យមភាគ) ពីឆ្នាំ២០០៣ដល់២០២៥

| បរិយាយ | កម្ពុជា | កំពង់ចាម | ត្បូងឃ្មុំ |
|---|---|---|---|
| អប្បបរមា | 32.0 | 32.1 | 32.1 |
| អតិបរមា | 40.2 | 41.0 | 41.0 |
| មធ្យមភាគ | 35.8 | 35.9 | 35.9 |

### ក្រាហ្វិក ១៥៩. សីតុណ្ហភាព អតិបរមា គិតជាអង្សាសេ




ប្រភព: នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

## ច. កម្ពស់ទឹក

### ច១. កម្ពស់ទឹកអតិបរមា

ស្ថានភាពទូទៅនៃកម្ពស់ទឹកអតិបរមា នៅទន្លេមេគង្គគិតជាម៉ែត្រពីឆ្នាំ១៩៩០ ដល់ ២០២៥ តាមស្ថានីយជលសាស្ត្រដែលរួមមាន ស្ទឹងត្រែង ក្រចេះ កំពង់ចាម ចតុមុខ (បាសាក់) អ្នកលឿង កោះខែល និងព្រែកក្តាម។ និន្នាជារួមនៃកម្ពស់ទឹកអតិបរមានៅទូទាំងប្រទេសពីឆ្នាំ១៩៩០ ដល់ ២០២៥ ដោយផ្អែកតាមស្ថានីយជលសាស្ត្រខាងលើមានការប្រប្រួលខ្លាំង គឺកម្ពស់ទឹកអតិបរមា ស្ថិតនៅចន្លោះទាបបំផុតពី៧ ម៉ែត្រ និងខ្ពស់បំផុត ១៥,៦ ម៉ែត្រ។ បើប្រៀបធៀបអំពីកម្ពស់ទឹកអតិបរមារវាងឆ្នាំ១៩៩០ និងឆ្នាំ២០២៥ គឺបានថយពីឆ្នាំ១៩៩០ រហូតដល់ជិត៣ម៉ែត្រ និងបានថយចុះចុះជិត ៥ ម៉ែត្រ បើប្រៀបធៀបជាមួយឆ្នាំ២០១៤។ កម្ពស់ទឹកអតិបរមាដែលទាបបំផុតគឺនៅឆ្នាំ២០២០ និងនៅឆ្នាំ២០២៥ បានកើនឡើងចំនួន០,៣ម៉ែត្របើប្រៀបធៀបនឹងឆ្នាំ២០២៥។ នៅក្នុងរយៈពេល១០ឆ្នាំ គិតពីឆ្នាំ២០១៦ ដល់ ២០២៥ កម្រិតទឹកអតិបរមាដែលទាបបំផុតគឺ ៦,៤ម៉ែត្រ ខ្ពស់បំផុតគឺ ២០,៨ម៉ែត្រ និងគិតជាមធ្យម ១០,៧ម៉ែត្រ (តារាង ៧០ ក្រាហ្វិក១៦០ និងក្រាហ្វិក១៦១)។

## ក្រាហ្វិក ១៦០. ស្ថានភាពកម្ពស់ទឹកអតិបរមានៅទន្លេមេគង្គពីឆ្នាំ ១៩៩០ ដល់ ២០២៥ គិតជាម៉ែត្រ




## តារាង ៧៥. កម្ពស់ទឹកអតិបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២៥ គិតជាម៉ែត្រ

| ស្ថានីយ៍ | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 | គិតជាមធ្យម10ឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|
| ស្ទឹងត្រែង | 9.6 | 10.7 | 11.0 | 12.0 | 8.8 | 8.3 | 9.9 | 9.52 | 10.44 | 10.1 | 10.1 |
| ក្រចេះ | 20.0 | 21.3 | 22.3 | 22.7 | 19.1 | 18.5 | 20.5 | 20.05 | 21.64 | 20.8 | 20.8 |
| កំពង់ចាម | 13.3 | 14.6 | 15.6 | 15.8 | 12.5 | 11.9 | 13.8 | 13 | 14.3 | 13.9 | 13.9 |
| បាសាក់ | 8.1 | 8.9 | 10.0 | 9.5 | 7.7 | 7.6 | 9.2 | 8.26 | 9.1 | 8.8 | 8.8 |
| អ្នកលឿង | 5.9 | 6.4 | 7.5 | 7.0 | 5.7 | 5.5 | 6.7 | 5.97 | 6.53 | 6.4 | 6.4 |
| កោះខែល | 6.9 | 7.5 | 7.8 | 7.7 | 6.9 | 6.7 | 7.7 | 7.14 | 7.71 | 7.4 | 7.4 |
| ព្រែកក្តាម | 7.1 | 7.8 | 9.1 | 8.0 | 6.6 | 6.6 | 8.5 | 7.43 | 7.82 | 7.8 | 7.8 |
| **ជាមធ្យមទាំង7 ស្ថានីយ** | **10.1** | **11.0** | **11.9** | **11.8** | **9.6** | **9.3** | **10.9** | **10.2** | **11.1** | 12.3 | 10.8 |
| **អតិបរិមាទាំង7 ស្ថានីយ** | **20.0** | **21.3** | **22.3** | **22.7** | **19.1** | **18.5** | **20.5** | **20.05** | **21.64** | 20.8 | 20.8 |
| **អប្បរមាទាំង7 ស្ថានីយ** | **5.9** | **6.4** | **7.5** | **7.0** | **5.7** | **5.5** | **6.7** | **5.97** | **6.53** | 6.4 | 6.4 |

ក្រាហ្វិក ១៦១. កម្ពស់ទឹកអតិបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២៥ គិតជាម៉ែត្រ




## ច២. កម្ពស់ទឹកអប្បបរមា

ស្ថានភាពទូទៅនៃកម្ពស់ទឹកអប្បបរមា នៅទន្លេមេគង្គគិតជាម៉ែត្រពីឆ្នាំ២០០៦ ដល់ ២០២៥ តាមស្ថានីយជលសាស្ត្រដែលរួមមាន ស្ទឹងត្រែង ក្រចេះ កំពង់ចាម ចតុមុខ (បាសាក់) អ្នកលឿង កោះខែល និងព្រែកក្ដាម។ និន្នាជារួមនៃកម្ពស់ទឹកអប្បបរមានៅទូទាំងប្រទេសពីឆ្នាំ២០០៦ ដល់ ២០២៥ ដោយផ្អែកតាមស្ថានីយជលសាស្ត្រខាងលើមានការប្រែប្រួលតិចតួច គឺកម្ពស់ទឹកអប្បបរមា មានកម្ពស់ទាបបំផុតពី២,១ ម៉ែត្រ និងខ្ពស់បំផុត ៣,១ ម៉ែត្រ។ បើប្រៀបធៀបអំពីកម្ពស់ទឹកអប្បបរមារវាងឆ្នាំ ២០០៦ និងឆ្នាំ២០២៥ គឺបានកើនពីឆ្នាំ២០០៦ មានប្រហែល ០,២ម៉ែត្រ និងបានថយចុះចុះជិត ០,៦ ម៉ែត្រ បើប្រៀបធៀបជាមួយឆ្នាំ២០១៤។ កម្ពស់ទឹកអប្បបរមាដែលទាបបំផុតគឺនៅឆ្នាំ២០២០ និងឆ្នាំ ២០២៤ មានកម្ពស់២,១ម៉ែត្រ និងឆ្នាំ ២០១៤ មានកម្ពស់៣,១ម៉ែត្រ។ កម្ពស់ទឹកតាមស្ថានីយ៍ពីឆ្នាំ ២០១១ ដល់២០២៥ រយៈ១៥ឆ្នាំ កម្ពស់ទឹកទាបបំផុតគិតជាមធ្យមស្មើនឹង២,៥ម៉ែត្រ ខ្ពស់បំផុត ៦,៩ ម៉ែត្រ និងគិតជាមធ្យមភាគ ១,០ម៉ែត្រ ក្នុងចំណោមស្ថានីយ៍ទាំង៧ (តារាង ៧៦ ក្រាហ្វិក១៦០ ក្រាហ្វិក១៦២ និងក្រាហ្វិក១៦៣)។

## ក្រាហ្វិក ១៦២. ស្ថានភាពកម្ពស់ទឹកអប្បរមានៅទន្លេមេគង្គពីឆ្នាំ ២០០៦ ដល់ ២០២៥ គិតជាម៉ែត្រ




## តារាង ៧៦. កម្ពស់ទឹកអប្បបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២៥ គិតជាម៉ែត្រ

| | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 | គិតជាមធ្យម 15ឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្ទឹងត្រែង | 2.3 | 2.5 | 2.4 | 2.7 | 2.5 | 2.27 | 2.64 | 2.67 | 2.54 | 2.27 | 2.5 | 2.56 | 1.32 | 1.44 | 2.55 | 2.3 |
| ក្រចេះ | 6.5 | 7 | 6.8 | 7.3 | 6.9 | 6.42 | 7.2 | 7.34 | 7.19 | 5.59 | 6.86 | 7 | 6.92 | 6.82 | 7.05 | 6.9 |
| កំពង់ចាម | 2.4 | 2.9 | 2.9 | 3.2 | 2.6 | 2.25 | 2.83 | 2.81 | 2.94 | 2.25 | 2.26 | 2.5 | 2.16 | 2.3 | 2.48 | 2.6 |
| បាសាក់ | 1.9 | 2.1 | 2.1 | 2.2 | 1.6 | 1.59 | 1.85 | 1.99 | 1.77 | 1.44 | 1.73 | 1.84 | 1.62 | 1.3 | 1.61 | 1.8 |
| អ្នកលឿង | 1.3 | 1.3 | 1.4 | 1.5 | 1 | 0.96 | 1.33 | 1.25 | 1.18 | 1.1 | 1.18 | 1.22 | 1.03 | 0.88 | 0.94 | 1.2 |
| កោះខែល | 1.8 | 1.9 | 2 | 2.3 | 1.7 | 1.23 | 1.78 | 1.77 | 1.03 | 1.43 | 1.65 | 1.7 | 1.53 | 1.2 | 1.59 | 1.6 |
| ព្រែកក្តាម | 1 | 1.2 | 1.2 | 2.2 | 1 | 0.8 | 1.05 | 1.03 | 1.03 | 0.76 | 0.62 | 1.05 | 0.74 | 0.72 | 1.03 | 1.0 |
| **ជាមធ្យមទាំង7 ស្ថានីយ** | **2.5** | **2.7** | **2.7** | **3.1** | **2.5** | **2.2** | **2.7** | **2.7** | **2.5** | **2.1** | **2.4** | **2.6** | **2.2** | **2.1** | **2.5** | **2.5** |
| **អតិបរិមាទាំង7 ស្ថានីយ** | **6.5** | **7** | **6.8** | **7.3** | **6.9** | **6.42** | **7.2** | **7.34** | **7.19** | **5.59** | **6.86** | **7** | **6.92** | **6.82** | **7.05** | **6.9** |
| **អប្បរមាទាំង7 ស្ថានីយ** | **1** | **1.2** | **1.2** | **1.5** | **1** | **0.8** | **1.1** | **1** | **1** | **0.8** | **0.6** | **1.1** | **0.74** | **0.72** | **0.94** | **1.0** |

ប្រភព៖ នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

### ក្រាហ្វិក ១៦៣. កម្ពស់ទឹកអប្បបរមាប្រចាំឆ្នាំតាមស្ថានីយ៍ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០២៥ គិតជាម៉ែត្រ




### ក្រាហ្វិក ១៦៤. កម្ពស់ទឹកអប្បបរមា អតិបរមា ពីឆ្នាំ២០០៦ ដល់ ២០២៥




ប្រភព៖ នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

## ៣.១.៦ ការព្យាករណ៍ទិន្នផលស្រូវ បរិមាណផលស្រូវ ចំណូលជាមធ្យមសម្រាប់មនុស្ស និងផលិតផលក្នុងស្រុកសរុបដោយប្រើប្រាស់ម៉ូដែល Linear Relation or Regression Analysis Model

នៅក្នុងរបាយការណ៍នេះ នឹងបង្ហាញជូនអំពីការព្យាករណ៍ទិន្នផលស្រូវ បរិមាណផលស្រូវ ចំណូលជាមធ្យមសម្រាប់មនុស្ស (GDP Per Capita) និងផលិតផលក្នុងស្រុកសរុប (GDP) ដោយប្រើប្រាស់ម៉ូដែល Linear Relation or Regression Analysis Model។ នៅក្នុងការវិភាគនេះ អថេរទិន្នផលស្រូវ បរិមាណផលិតផលស្រូវ ចំណូលសម្រាប់មនុស្សម្នាក់ និងផលិតផលក្នុងស្រុកសរុប (GDP) ត្រូវបានកំណត់ជាអថេរមិនឯករាជ្យ (ពឹងផ្អែកលើ) ដែលរងឥទ្ធិពលដោយសារ សីតុណ្ហភាព កម្ពស់ទឹកភ្លៀង និងកម្ពស់ទឹក ដែលជាអថេរឯករាជ្យ។ លទ្ធផលដែលបានតាមរយៈម៉ូដែលអនុគមន៍ទំនាក់ទំនង (Regression Analysis Model) ជាមូលដ្ឋានដើម្បីធ្វើការព្យាករណ៍បរិមាណផលិតផលស្រូវ និងផលិតផលក្នុងស្រុកសរុប (GDP) នៅពេលដែលមានការប្រែប្រួលសីតុណ្ហភាព កម្ពស់ទឹកភ្លៀង និងកម្ពស់ទឹក។

អនុគមន៍ទំនាក់ទំនង (Linear Relation ឬ Regression) គឺជាអនុគមន៍ដែលមានទំនាក់ទំនងរវាងអថេរមិនឯករាជ្យមួយ ជាមួយនឹងអថេរឯករាជ្យមួយឬច្រើន។ ការវិភាគអនុគមន៍ទំនាក់ទំនង (Regression Analysis) គឺអាចឲ្យគេធ្វើការណ៍ព្យាករណ៍នូវលទ្ធផលអថេរមិនឯករាជ្យបានដោយផ្អែកលើការប្រែប្រួលទិន្នន័យនៃអថេរឯករាជ្យ។ អនុគមន៍ទំនាក់ទំនង (Linear Relation ឬ Regression) ត្រូវបានបែងចែកជា៣ប្រភេទគឺ៖

(1) Simple Linear Regression

$$\hat{y} = b.x + a$$

(2) Multiple Linear Regression

$$\hat{y} = b_1.x_1 + b_2.x_2 + b_3.x_3 + \dots\dots b_k.x_k + a$$

(3) Logistic Linear Regression

$$f(z) = \frac{1}{1+e^{-z}} = \frac{1}{1+e^{-(b_1x_1+\dots+b_kx_k+a)}}$$

$$z = \hat{y} = b_1.x_1 + b_2.x_2 + b_3.x_3 + \dots\dots b_k.x_k + a$$

## ក. ការព្យាករណ៍អំពីទិន្នផលស្រូវផ្អែកលើកត្តាសីតុណ្ហភាព កម្ពស់ទឹកភ្លៀង និង កម្ពស់ទឹក

### ក១. ស្ថានភាពសីតុណ្ហភាប កម្ពស់ទឹកភ្លៀង និង កម្ពស់ទឹក

### ក១.១. ស្ថានភាពសីតុណ្ហភាព

នៅទូទាំងប្រទេស ស្ថានភាពសីតុណ្ហភាពអតិបរមាពីឆ្នាំ២០០៣ ដល់ ២០២៥ ស្ថិតនៅចន្លោះពី៣២°C ដល់ ៤០,២°C ។ សីតុណ្ហភាពខ្ពស់ខ្លាំង៤០,២°C គឺនៅឆ្នាំ២០១៦ និងទាបជាងគេនៅក្នុងឆ្នាំ២០០៥ មានសីតុណ្ហភាព ៣២ °C និងនៅក្នុងឆ្នាំ២០២៤ មានកម្រិត៣៩,៥°C ។ សីតុណ្ហភាពអប្បបរមាពីឆ្នាំ២០០៣ ដល់២០២៥ ស្ថិតនៅចន្លោះពី កម្រិត១៥,៥°C ដល់ ២៤°C និងនៅឆ្នាំ២០២៥មានកម្រិត១៨,៧ °C។

**ក្រាហ្វិក ១៦៥. និន្នាការសីតុណ្ហភាពអតិបរមា និងអប្បបរមា ពីឆ្នាំ២០០៣ ដល់ ២០២៥**




ការព្យាករណ៍សីតុណ្ហភាពអតិបរមាពីឆ្នាំ២០២៦ ដល់២០៣៥ ត្រូវបានគណនាផ្អែកលើទិន្នន័យពីឆ្នាំ២០០៦ ដល់ ២០២៥។ ការគណនារកអត្រាកំណើនប្រចាំឆ្នាំដែលមានប្រហែល ១,០២% ក្នុងមួយឆ្នាំ សម្រាប់កំណើនសីតុណ្ហភាពអតិបរមាពីឆ្នាំ ២០២៦ ដល់ ឆ្នាំ២០៣៥។ អត្រាកំណើនប្រចាំឆ្នាំនៃសីតុណ្ហភាពអប្បបរមាគឺថយចុះ -១,២៥%ប្រចាំឆ្នាំ ចាប់ពីឆ្នាំ២០២៦ ដល់ ២០៣៥ សម្រាប់ទូទាំងប្រទេស។ រូបមន្តគណនាអំពីសីតុណ្ហភាពអតិបរមា និងអប្បបរមា ឆ្នាំ២០២៦ មានបង្ហាញជូនខាងក្រោម។

Annual Exponetial Growth Rate[4]

$$r = \frac{log_e P_t - log_e P_o}{t}$$

$$P_t = P_o e^{rt}$$

ដែល $P_o$ សីតុណ្ហភាពឆ្នាំគោល

$P_t$ សីតុណ្ហភាពឆ្នាំ $t$

$t$ ឆ្នាំរវាងសីតុណ្ហភាពឆ្នាំគោល និងសីតុណ្ហភាពឆ្នាំ $t$

តាមលទ្ធផលដែលបានអនុវត្តរូបមន្តខាងលើ ឆ្នាំ២០២៦ សីតុណ្ហភាពអតិបរមាមានកម្រិត ៤០,១ អង្សាសេ (ºC) និងតុណ្ហភាពអប្បរមាមានកម្រិត ១៨,៥អង្សាសេ (ºC) និងឆ្នាំបន្តបន្ទាប់អនុវត្តដូចគ្នានេះដែរ។

## ក១.២. ស្ថានភាពកម្ពស់ទឹកភ្លៀង

ស្ថានភាពកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំពីស្ថិតនៅចន្លោះពី ១.៤០០ មីលីម៉ែត្រ ដល់ ២.១៦៤ ពីឆ្នាំ ១៩៩៤ ដល់២០២៥។ កម្ពស់ទឹកភ្លៀងប្រចាំឆ្នាំទាបជាងគេនៅក្នុងឆ្នាំ១៩៩៨ មានកម្ពស់១.៤០០ មីលីម៉ែត្រ និងខ្ពស់ជាងគេនៅក្នុងឆ្នាំ២០២៤ មានកម្ពស់២.១៦៤ មីលីម៉ែត្រ និងឆ្នាំ២០២៥ មានកម្ពស់ ១.៨៦៥ មីលីម៉ែត្រ សម្រាប់ទូទាំងប្រទេស។

**ក្រាហ្វិក ១៦៦ និន្នាការកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំ**




ប្រភព៖ ក្រសួងធនធានទឹក និងឧតុនិយម

[4] H.Shryock, et al., *The Methods and Materials of Demography,* Condensed Edition. Bowling Green University, USA, 1976,. P412.

តាមការព្យាករណ៍ដោយផ្អែករូបមន្ត Annual Exponetial Growth Rate ខាងលើ កម្រិតកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំ២០២៦ មានចំនួន១.៨៦១ មីលីម៉ែត្រ ដោយអត្រាកំណើនប្រចាំឆ្នាំពីឆ្នាំ ២០២៦ ដល់ ២០៣៥ គឺមានចំនួនថយចុះ -០,២២% ផ្អែកលើការគណនាអត្រាកំណើននៃកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំពីឆ្នាំ២០០៦ ដល់ ២០២៥។

### ក១.៣. ស្ថានភាពកម្ពស់ទឹក

ស្ថានភាពកម្ពស់ទឹកអតិបរមាពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០២៥ ស្ថិតនៅចន្លោះពី ៧ម៉ែត្រ ដល់ ១៥,៦ម៉ែត្រ។ ស្ថានភាពកម្ពស់ទឹកអតិបរមា ពីឆ្នាំ២០០៦ ដល់ ២០២៥ មានអត្រាកំណើនប្រចាំឆ្នាំគិតជាមធ្យមស្មើនឹង -១,៥%។ ស្ថានភាពកម្ពស់ទឹកអប្បបរមាពីឆ្នាំ២០០៦ ដល់ ២០២៥ ស្ថិតនៅចន្លោះពី២,១ម៉ែត្រ ដល់ ៣,១ម៉ែត្រ និងមានអត្រាកំណើនប្រចាំឆ្នាំគិតជាមធ្យមស្មើនឹង ០,៤៤%។

**ក្រាហ្វិក ១៦៧. និន្នាការកម្ពស់ទឹកអតិបរមា និងអប្បរមា**




ប្រភព៖ ក្រសួងធនធានទឹក និងឧតុនិយម

## *ក២). ការព្យាករណ៍*

### *ក២.១). ការព្យាករណ៍ទិន្នផលស្រូវពីឆ្នាំ២០២៦ ដល់ ២០៣៥*

ក្រាហ្វិក១៦៨ បង្ហាញអំពីនិន្នាការទិន្នផលស្រូវ គឺបានកើនឡើងពីជាង១តោន រហូតកើនដល់ជិត៤តោនក្នុង១ហិកតា ចាប់ពីឆ្នាំ១៩៩៨០ ដល់ ២០២៥។ ការព្យាករណ៍ពីទិន្នផលស្រូវពីឆ្នាំ ២០២៥ ដល់ ២០៣៥ ជាមួយនឹងសីតុណ្ហភាព កម្ពស់ទឹកភ្លៀង និងកម្ពស់ទឹកដែលអាចមានពីឆ្នាំ ២០០៦ ដល់២០២៥ ដោយប្រើប្រាស់ម៉ូដែលអនុគមន៍ទំនាក់ទំនង (Linear Relation or Regression Model) ប្រភេទ Multiple Linear Regression។

រូបមន្ត Multiple Linear Regression គឺ៖

$$\hat{y} = b_1.x_1 + b_2.x_2 + b_3.x_3 + b_4.x_4 + b_5.x_5 + a$$

ដែល $\hat{y}$ ទិន្នផលស្រូវ

$x_1$ កម្ពស់ទឹកភ្លៀង

$x_2$ សីតុណ្ហភាពអតិបរមា

$x_3$ សីតុណ្ហភាពអប្បបរមា

$x_4$ កម្ពស់ទឹកអតិបរមា

$x_5$ កម្ពស់ទឹកអប្បបរមា

**ក្រាហ្វិក ១៦៨. និន្នាការទិន្នផលស្រូវ**




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## តារាង ៧៧. កំណត់អថេរឯករាជ្យ និងអថេរមិនឯករាជ្យសម្រាប់ព្យាករណ៍ទិន្នផលស្រូវ

| Year | Dependent Variable | Independent variable | | | | |
|---|---|---|---|---|---|---|
| | Yield (t/ha) | Rain water high (ml) | Maximum Temperature (°C) | Minimum Temperature (°C) | Maximum High Water (m) | Minimum High Water (m) |
| 2006 | 2.50 | 1,944 | 32.7 | 23.7 | 14.1 | 2.3 |
| 2007 | 2.60 | 1,740 | 32.6 | 23.8 | 13.6 | 2.2 |
| 2008 | 2.70 | 1,704 | 32.5 | 23.3 | 13.5 | 2.4 |
| 2009 | 2.80 | 1,542 | 32.9 | 23.3 | 14.3 | 2.4 |
| 2010 | 3.00 | 1,584 | 35.5 | 22.0 | 12.6 | 2.3 |
| 2011 | 3.17 | 1,767 | 34.5 | 20.8 | 15.3 | 2.5 |
| 2012 | 3.12 | 1,632 | 35.1 | 20.9 | 11.9 | 2.7 |
| 2013 | 3.16 | 1,781 | 34.2 | 21.8 | 15.2 | 2.7 |
| 2014 | 3.08 | 1,659 | 35.0 | 21.9 | 15.6 | 3.1 |
| 2015 | 3.09 | 1,408 | 35.9 | 22.1 | 11.5 | 2.3 |
| 2016 | 3.21 | 1,862 | 40.2 | 15.5 | 9.1 | 2.2 |
| 2017 | 3.30 | 1,856 | 36.4 | 18.6 | 9.9 | 2.7 |
| 2018 | 3.35 | 1,717 | 36.4 | 15.7 | 10.7 | 2.7 |
| 2019 | 3.34 | 1,635 | 38.7 | 17.0 | 10.6 | 2.5 |
| 2020 | 3.35 | 1,684 | 37.8 | 19.4 | 7.0 | 2.1 |
| 2021 | 3.49 | 1,966 | 38.2 | 16.0 | 8.9 | 2.4 |
| 2022 | 3.52 | 2,150 | 36.4 | 17.4 | 10.9 | 2.6 |
| 2023 | 3.56 | 1,856 | 38.4 | 18.2 | 10.2 | 2.2 |
| 2024 | 3.64 | 1,697 | 39.5 | 18.8 | 11.1 | 2.1 |
| 2025 | 3.72 | 1,865 | 39.7 | 18.7 | 10.7 | 2.5 |

*សំគាល់៖ ទិន្នផលស្រូវឆ្នាំ២០២៥ ត្រូវបានគិតតាមអត្រាកំណើនពីឆ្នាំ២០០៦ដល់២០២៤*

ផ្អែកតាមតារាងខាងលើ និង Run Multiple Linear Regression បានបង្ហាញលទ្ធផលដែលមានដូចខាងក្រោមសម្រាប់ធ្វើការព្យាករណ៍ទិន្នផលស្រូវពីឆ្នាំ២០២៦ ដល់ ២០៣៥។

| SUMMARY OUTPUT | |
|---|---|
| | |
| Regression Statistics | |
| Multiple R | 0.894021237 |
| R Square | 0.799273971 |
| Adjusted R Squ | 0.727586104 |
| Standard Error | 0.177024389 |
| Observations | 20 |

ANOVA

| | df | SS | MS | F | Significance F |
|---|---|---|---|---|---|
| Regression | 5 | 1.746973119 | 0.34939462 | 11.14936182 | 0.000175012 |
| Residual | 14 | 0.438726881 | 0.03133763 | | |
| Total | 19 | 2.1857 | | | |

| | Coefficients | Standard Error | t Stat | P-value | Lower 95% | Upper 95% | Lower 95% | Upper 95% |
|---|---|---|---|---|---|---|---|---|
| Intercept | -2.159762307 | 2.260243169 | -0.955544225 | 0.35551237 | -7.007501751 | 2.68797714 | -7.00750175 | 2.68797714 |
| Rain_water | 0.000184985 | 0.000284066 | 0.65120524 | 0.52545950 | -0.000424276 | 0.00079425 | -0.00042428 | 0.00079425 |
| Max_Temp | 0.119358064 | 0.034616183 | 3.448042315 | 0.00391987 | 0.045113735 | 0.19360239 | 0.04511374 | 0.19360239 |
| Min_Temp | -0.002548534 | 0.036471163 | -0.069878061 | 0.94527904 | -0.080771398 | 0.07567433 | -0.0807714 | 0.07567433 |
| Max_Water | 2.27931E-05 | 0.032470611 | 0.000701962 | 0.99944982 | -0.06961974 | 0.06966533 | -0.06961974 | 0.06966533 |
| Min_Water | 0.310322596 | 0.210552804 | 1.47384689 | 0.16265072 | -0.141268255 | 0.76191345 | -0.14126825 | 0.76191345 |

តាមលទ្ធផលខាងលើ បានបង្ហាញ Multiple R = 0.894021237 បញ្ជាក់ថាទំនាក់ទំនងរវាងអថេរមិនឯករាជ្យ (ទិន្នផលស្រូវ) មានទំនាក់ទំនងខ្លាំងជាមួយនឹងអថេរឯករាជ្យ (កម្ពស់ទឹកភ្លៀង,សីតុណ្ហភាព, និងកម្ពស់ទឹក)។ សីតុណ្ហភាពអតិបរមាជះឥទ្ធិពលខ្លាំងជាងគេទៅលើទិន្នផលស្រូវដោយបង្ហាញតម្លៃ P(0.0039) < 0.05)។

តាមរយៈរូបមន្ត $\hat{y} = b_1.x_1 + b_2.x_2 + b_3.x_3 + b_4.x_4 + b_5.x_5 + a$ យើងអាចព្យាករណ៍ទិន្នផលស្រូវដូចខាងក្រោម៖

ទិន្នផលស្រូវព្យាករណ៍ឆ្នាំ២០២៦ គឺ

= 0.00018498529133848*1,861 + 0.119358063723773*40.1 -0.00254853411487233*18.5 +0.0000227931238789836*10.5 + 0.31032259599661*2.5 -2.15976230652132 =**3.70 t/ha**

## តារាង ៧៨. ការព្យាករណ៍ទិន្នផលស្រូវពីឆ្នាំ២០២៦ ដល់ ២០៣៥

| ឆ្នាំ | ទិន្នផលស្រូវ (តោន/ហត) | កម្ពស់ទឹកភ្លៀង (មីលីម៉ែត្រ) | សីតុណ្ហភាព អតិបរមា (°C) | សីតុណ្ហភាព អប្បបរមា (°C) | កម្ពស់ទឹក អតិបរមា (ម) | កម្ពស់ទឹក អប្បបរមា(ម) |
|---|---|---|---|---|---|---|
| 2026 | 3.70 | 1,861 | 40.1 | 18.5 | 10.5 | 2.5 |
| 2027 | 3.76 | 1,857 | 40.5 | 18.2 | 10.4 | 2.5 |
| 2028 | 3.81 | 1,853 | 40.9 | 18.0 | 10.2 | 2.5 |
| 2029 | 3.86 | 1,849 | 41.4 | 17.8 | 10.1 | 2.5 |
| 2030 | 3.92 | 1,845 | 41.8 | 17.6 | 10.0 | 2.6 |
| 2031 | 3.97 | 1,841 | 42.2 | 17.4 | 9.8 | 2.6 |
| 2032 | 4.03 | 1,837 | 42.6 | 17.1 | 9.7 | 2.6 |
| 2033 | 4.08 | 1,833 | 43.1 | 16.9 | 9.5 | 2.6 |
| 2034 | 4.14 | 1,829 | 43.5 | 16.7 | 9.4 | 2.6 |
| 2035 | 4.19 | 1,825 | 44.0 | 16.5 | 9.3 | 2.6 |

## *ក២.២). ការព្យាករណ៍បរិមាណផលស្រូវពីឆ្នាំ២០២៦ ដល់ ២០៣៥*

ក្រាហ្វិក១៦៩ បង្ហាញអំពីនិន្នាការបរិមាណផលស្រូវ គឺបានកើនឡើងពីជិត២លានតោន បានកើនឡើងជាង១៤លានតោន ពីឆ្នាំ១៩៩៨០ ដល់ ២០២៥។ ការព្យាករណ៍ពីបរិមាណផលស្រូវ ពីឆ្នាំ២០២៦ ដល់ ២០៣៥ ជាមួយនឹងសីតុណ្ហភាព កម្ពស់ទឹកភ្លៀង និងកម្ពស់ទឹកដែលអាចមានពីឆ្នាំ២០០៦ ដល់២០២៥ ដោយប្រើប្រាស់ម៉ូដែលអនុគមន៍ទំនាក់ទំនង (Linear Relation or Regression Model) ប្រភេទ Multiple Linear Regression។

រូបមន្ត Multiple Linear Regression គឺ៖

$$\hat{y} = b_1.x_1 + b_2.x_2 + b_3.x_3 + b_4.x_4 + b_5.x_5 + a$$

ដែល $\hat{y}$ បរិមាណផលស្រូវ

$x_1$ កម្ពស់ទឹកភ្លៀង

$x_2$ សីតុណ្ហភាពអតិបរមា

$x_3$ សីតុណ្ហភាពអប្បបរមា

$x_4$ កម្ពស់ទឹកអតិបរមា

$x_5$ កម្ពស់ទឹកអប្បបរមា

តារាង ៧៩ បង្ហាញអំពីការកំណត់អថេរឯករាជ្យ និងអថេរមិនឯករាជ្យសម្រាប់ព្យាករណ៍ បរិមាណផលស្រូវពីឆ្នាំ២០២៥ ដល់ ឆ្នាំ២០៣៥ ដែលកំណត់ជាអថេរមិនឯករាជ្យ ជាមួយនឹងកត្តា កម្ពស់ទឹកភ្លៀង សីតុណ្ហភាពអតិបរមា សីតុណ្ហភាពអប្បរមា កម្ពស់តឹកអតិបរមា និងកម្ពស់ទឹកអប្បរមា ដែលត្រូវបានកំណត់ជាអថេរឯករាជ្យ។

**តារាង ៧៩. កំណត់អថេរឯករាជ្យ និងអថេរមិនឯករាជ្យសម្រាប់ព្យាករណ៍បរិមាណផលស្រូវ**

| Year | Dependent Variable | Independent variable | | | | |
|---|---|---|---|---|---|---|
| | Yield (t/ha) | Rain water high (ml) | Maximum Temperature (°C) | Minimum Temperature (°C) | Maximum High Water (m) | Minimum High Water (m) |
| 2006 | 6,264,000 | 1,944 | 32.7 | 23.7 | 14.1 | 2.3 |
| 2007 | 6,727,100 | 1,740 | 32.6 | 23.8 | 13.6 | 2.2 |
| 2008 | 7,175,500 | 1,704 | 32.5 | 23.3 | 13.5 | 2.4 |
| 2009 | 7,585,900 | 1,542 | 32.9 | 23.3 | 14.3 | 2.4 |
| 2010 | 8,249,500 | 1,584 | 35.5 | 22.0 | 12.6 | 2.3 |

| Year | Dependent Variable | Independent variable | | | | |
|---|---|---|---|---|---|---|
| | Yield (t/ha) | Rain water high (ml) | Maximum Temperature (°C) | Minimum Temperature (°C) | Maximum High Water (m) | Minimum High Water (m) |
| 2011 | 8,779,400 | 1,767 | 34.5 | 20.8 | 15.3 | 2.5 |
| 2012 | 9,290,940 | 1,632 | 35.1 | 20.9 | 11.9 | 2.7 |
| 2013 | 9,389,961 | 1,781 | 34.2 | 21.8 | 15.2 | 2.7 |
| 2014 | 9,324,416 | 1,659 | 35.0 | 21.9 | 15.6 | 3.1 |
| 2015 | 9,335,284 | 1,408 | 35.9 | 22.1 | 11.5 | 2.3 |
| 2016 | 9,952,270 | 1,862 | 40.2 | 15.5 | 9.1 | 2.2 |
| 2017 | 10,518,339 | 1,856 | 36.4 | 18.6 | 9.9 | 2.7 |
| 2018 | 10,891,735 | 1,717 | 36.4 | 15.7 | 10.7 | 2.7 |
| 2019 | 10,985,733 | 1,635 | 38.7 | 17.0 | 10.6 | 2.5 |
| 2020 | 10,935,619 | 1,684 | 37.8 | 19.4 | 7.0 | 2.1 |
| 2021 | 12,206,988 | 1,966 | 38.2 | 16.0 | 8.9 | 2.4 |
| 2022 | 11,623,872 | 2,150 | 36.4 | 17.4 | 10.9 | 2.6 |
| 2023 | 12,497,232 | 1,856 | 38.4 | 18.2 | 10.2 | 2.2 |
| 2024 | 13,889,562 | 1,697 | 39.5 | 18.8 | 11.1 | 2.1 |
| 2025 | 14,484,066 | 1,865 | 39.7 | 18.7 | 10.7 | 2.5 |

## ក្រាហ្វិក ១៦៧ ស្ថានភាពបរិមាណផលស្រូវ




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ផ្អែកតាមតារាងខាងលើ និង Run Multiple Linear Regression បានបង្ហាញលទ្ធផលដែលមានដូចខាងក្រោមសម្រាប់ធ្វើការព្យាករណ៍បរិមាណផលស្រូវពីឆ្នាំ២០២៦ ដល់ ២០៣៥។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| SUMMARY OUTPUT | | | | | | | | |
| | | | | | | | | |
| Regression Statistics | | | | | | | | |
| Multiple R | 0.895205827 | | | | | | | |
| R Square | 0.801393473 | | | | | | | |
| Adjusted R Squar | 0.73046257 | | | | | | | |
| Standard Error | 1171207.648 | | | | | | | |
| Observations | 20 | | | | | | | |
| | | | | | | | | |
| ANOVA | | | | | | | | |
| | df | SS | MS | F | Significance F | | | |
| Regression | 5 | 7.74904E+13 | 1.5498E+13 | 11.29822747 | 0.000163026 | | | |
| Residual | 14 | 1.92042E+13 | 1.3717E+12 | | | | | |
| Total | 19 | 9.66946E+13 | | | | | | |
| | Coefficients | Standard Error | t Stat | P-value | Lower 95% | Upper 95% | Lower 95% | Upper 95% |
| Intercept | -34789144.04 | 14953951.25 | -2.3264182 | 0.035522907 | -66862179.51 | -2716109 | -66862179.5 | -2716109 |
| Rain_water | 2055.074804 | 1879.403826 | 1.09347165 | 0.292645051 | -1975.845491 | 6085.995 | -1975.84549 | 6085.995 |
| Max_Temp | 935175.9719 | 229023.4608 | 4.08331954 | 0.001117977 | 443969.5034 | 1426382 | 443969.503 | 1426382 |
| Min_Temp | 166707.2851 | 241296.1551 | 0.69088248 | 0.500934857 | -350821.4947 | 684236.1 | -350821.495 | 684236.1 |
| Max_Water | -34250.14012 | 214828.1815 | -0.1594304 | 0.875607022 | -495010.7627 | 426510.5 | -495010.763 | 426510.5 |
| Min_Water | 1834586.821 | 1393034.35 | 1.3169717 | 0.208998506 | -1153174.699 | 4822348 | -1153174.7 | 4822348 |

តាមលទ្ធផលខាងលើ បានបង្ហាញ Multiple R = 0.895205827 បញ្ជាក់ថាទំនាក់ទំនងរវាងអថេរមិនឯករាជ្យ (បរិមាណផលស្រូវ) មានទំនាក់ទំនងខ្លាំងជាមួយនឹងអថេរឯករាជ្យ (កម្ពស់ទឹកភ្លៀង,សីតុណ្ហភាព, និងកម្ពស់ទឹក)។ សីតុណ្ហភាពអតិបរមាជះឥទ្ធិពលខ្លាំងជាងគេទៅលើបរិមាណផលស្រូវដោយបង្ហាញតម្លៃ P(0.0011) < 0.05)។

តាមរយៈរូបមន្ត $\hat{y} = b_1.x_1 + b_2.x_2 + b_3.x_3 + b_4.x_4 + b_5.x_5 + a$ យើងអាចព្យាករណ៍ទិន្នផលស្រូវដូចខាងក្រោម៖

បរិមាណផលស្រូវព្យាករណ៍ឆ្នាំ២០២៦ គឺ

= 2055.07480369315*1,861 + 935175.971922711 *40.1 + 166707.285112165 *18.5 -34250.1401214301 *10.5 + 1834586.82120574 *2.5 -34789144.0371642 =**13,866,909 t**

**តារាង ៨០. ការព្យាករណ៍បរិមាណផលស្រូវពីឆ្នាំ២០២៦ ដល់ ២០៣៥**

| ឆ្នាំ | បរិមាណផលស្រូវ(តោន) | កម្ពស់ទឹកភ្លៀង (មីលីម៉ែត្រ) | សីតុណ្ហភាព អតិបរមា (ºC) | សីតុណ្ហភាព អប្បបរមា (ºC) | កម្ពស់ទឹក អតិបរមា (ម) | កម្ពស់ទឹក អប្បបរមា(ម) |
|---|---|---|---|---|---|---|
| 2026 | 13,866,909 | 1,861 | 40.1 | 18.5 | 10.5 | 2.5 |
| 2027 | 14,230,763 | 1,857 | 40.5 | 18.2 | 10.4 | 2.5 |
| 2028 | 14,599,072 | 1,853 | 40.9 | 18.0 | 10.2 | 2.5 |
| 2029 | 14,971,872 | 1,849 | 41.4 | 17.8 | 10.1 | 2.5 |
| 2030 | 15,349,199 | 1,845 | 41.8 | 17.6 | 10.0 | 2.6 |
| 2031 | 15,731,091 | 1,841 | 42.2 | 17.4 | 9.8 | 2.6 |
| 2032 | 16,117,584 | 1,837 | 42.6 | 17.1 | 9.7 | 2.6 |
| 2033 | 16,508,718 | 1,833 | 43.1 | 16.9 | 9.5 | 2.6 |
| 2034 | 16,904,530 | 1,829 | 43.5 | 16.7 | 9.4 | 2.6 |
| 2035 | 17,305,059 | 1,825 | 44.0 | 16.5 | 9.3 | 2.6 |

## *ក២.៣). ការព្យាករណ៍ចំណូលសម្រាប់មនុស្សម្នាក់ (GDP Per Capita) ពីឆ្នាំ២០២៦ ដល់ ២០៣៥*

ក្រាហ្វិក១៦៨ បង្ហាញអំពីនិន្នាការចំណូលសម្រាប់មនុស្សម្នាក់ (GDP Per Capita) គឺបានកើនឡើងពីក្រោម៣០០ បានកើនឡើងដល់ជិត៣.០០០ ដុល្លារសហរដ្ឋអាមេរិក ពីឆ្នាំ១៩៩៣ទៅឆ្នាំ២០២៥។ ការព្យាករណ៍ពីចំណូលសម្រាប់មនុស្សម្នាក់ (GDP Per Capita)ពីឆ្នាំ២០២៥ ដល់ ២០៣៥ ជាមួយនឹងសីតុណ្ហភាព កម្ពស់ទឹកភ្លៀង និងកម្ពស់ទឹកដែលអាចមានពីឆ្នាំ២០០៦ ដល់ ២០២៥ ដោយប្រើប្រាស់ម៉ូដែលអនុគមន៍ទំនាក់ទំនង (Linear Relation or Regression Model) ប្រភេទ Multiple Linear Regression។ រូបមន្ត Multiple Linear Regression គឺ៖

$$\hat{y} = b_1.x_1 + b_2.x_2 + b_3.x_3 + b_4.x_4 + b_5.x_5 + a$$

ដែល $\hat{y}$ ចំណូលសម្រាប់មនុស្សម្នាក់ (GDP Per Capita)

$x_1$ កម្ពស់ទឹកភ្លៀង

$x_2$ សីតុណ្ហភាពអតិបរមា

$x_3$ សីតុណ្ហភាពអប្បបរមា

$x_4$ កម្ពស់ទឹកអតិបរមា

$x_5$ កម្ពស់ទឹកអប្បបរមា

**ក្រាហ្វិក ១៦៨ ស្ថានភាពចំណូលសម្រាប់មនុស្សម្នាក់ (GDP Per Capita) គិតជា US$**




ប្រភព៖ - វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

- ថវិកាសង្ខេបឆ្នាំ២០២៦ នាយកដ្ឋានថវិកានីយកម្ម អគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង ៨១. កំណត់អថេរឯករាជ្យ និងអថេរមិនឯករាជ្យសម្រាប់ព្យាករណ៍ចំណូលជាមធ្យម សម្រាប់មនុស្សម្នាក់ (GDP Per Capita)

| Year | Dependent Variable | Independent variable | | | | |
|---|---|---|---|---|---|---|
| | GDP Per Capita (US$) | Rain water high (ml) | Maximum Temperature (°C) | Minimum Temperature (°C) | Maximum High Water (m) | Minimum High Water (m) |
| 2006 | 639 | 1,944 | 32.7 | 23.7 | 14.1 | 2.3 |
| 2007 | 761 | 1,740 | 32.6 | 23.8 | 13.6 | 2.2 |
| 2008 | 907 | 1,704 | 32.5 | 23.3 | 13.5 | 2.4 |
| 2009 | 914 | 1,542 | 32.9 | 23.3 | 14.3 | 2.4 |
| 2010 | 1,025 | 1,584 | 35.5 | 22.0 | 12.6 | 2.3 |
| 2011 | 1,143 | 1,767 | 34.5 | 20.8 | 15.3 | 2.5 |
| 2012 | 1,241 | 1,632 | 35.1 | 20.9 | 11.9 | 2.7 |
| 2013 | 1,350 | 1,781 | 34.2 | 21.8 | 15.2 | 2.7 |
| 2014 | 1,489 | 1,659 | 35.0 | 21.9 | 15.6 | 3.1 |
| 2015 | 1,616 | 1,408 | 35.9 | 22.1 | 11.5 | 2.3 |
| 2016 | 1,747 | 1,862 | 40.2 | 15.5 | 9.1 | 2.2 |
| 2017 | 1,879 | 1,856 | 36.4 | 18.6 | 9.9 | 2.7 |
| 2018 | 2,081 | 1,717 | 36.4 | 15.7 | 10.7 | 2.7 |
| 2019 | 2,260 | 1,635 | 38.7 | 17.0 | 10.6 | 2.5 |
| 2020 | 2,132 | 1,684 | 37.8 | 19.4 | 7.0 | 2.1 |
| 2021 | 2,213 | 1,966 | 38.2 | 16.0 | 8.9 | 2.4 |
| 2022 | 2,345 | 2,150 | 36.4 | 17.4 | 10.9 | 2.6 |
| 2023 | 2,520 | 1,856 | 38.4 | 18.2 | 10.2 | 2.2 |
| 2024 | 2,675 | 1,697 | 39.5 | 18.8 | 11.1 | 2.1 |
| 2025 | 2,858 | 1,865 | 39.7 | 18.7 | 10.7 | 2.5 |

ប្រភព៖ - វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

- ថវិកាសង្ខេបឆ្នាំ២០២៥ នាយកដ្ឋានថវិកានីយកម្ម អគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្អែកតាមតារាងខាងលើ និង Run Multiple Linear Regression បានបង្ហាញលទ្ធផលដែលមានដូចខាងក្រោមសម្រាប់ធ្វើការព្យាករណ៍ អំពីចំណូលសម្រាប់មនុស្សម្នាក់ (GDP Per Capita) ពីឆ្នាំ ២០២៦ ដល់ ២០៣៥។

ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ (GDP Per Capita) ត្រូវបានគណនាចេញពីផលិតផលក្នុងស្រុកសរុប (GDP) ហើយ GDP មានវិស័យសំខាន់បីចូលរួមចំណែកគឺ វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។ វិស័យកសិកម្មអាចរងឥទ្ធិពលដោយសីតុណ្ហភាព កម្ពស់ទឹកភ្លៀង និងកម្ពស់ទឹកខ្លាំងជាងវិស័យពីរទៀត។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| SUMMARY OUTPUT | | | | | | | | |
| | | | | | | | | |
| Regression Statistics | | | | | | | | |
| Multiple R | 0.903250182 | | | | | | | |
| R Square | 0.815860891 | | | | | | | |
| Adjusted R Squar | 0.750096923 | | | | | | | |
| Standard Error | 338.788767 | | | | | | | |
| Observations | 20 | | | | | | | |
| | | | | | | | | |
| ANOVA | | | | | | | | |
| | df | SS | MS | F | Significance F | | | |
| Regression | 5 | 7119608.58 | 1423921.72 | 12.40589522 | 9.8223E-05 | | | |
| Residual | 14 | 1606889.6 | 114777.829 | | | | | |
| Total | 19 | 8726498.18 | | | | | | |
| | | | | | | | | |
| | Coefficients | Standard Erro | t Stat | P-value | Lower 95% | Upper 95% | Lower 95% | Upper 95% |
| Intercept | -9102.684399 | 4325.64688 | -2.1043522 | 0.053897295 | -18380.274 | 174.9054 | -18380.2742 | 174.9054 |
| Rain_water | 0.517129204 | 0.54364476 | 0.95122631 | 0.357623783 | -0.6488728 | 1.683131 | -0.64887284 | 1.683131 |
| Max_Temp | 238.4876335 | 66.2483515 | 3.59990291 | 0.00289904 | 96.3990515 | 380.5762 | 96.3990515 | 380.5762 |
| Min_Temp | 26.2435087 | 69.798406 | 0.37599009 | 0.712560439 | -123.45918 | 175.9462 | -123.459183 | 175.9462 |
| Max_Water | -43.4360179 | 62.1421615 | -0.6989782 | 0.496014627 | -176.7177 | 89.84566 | -176.717698 | 89.84566 |
| Min_Water | 515.4642282 | 402.955352 | 1.27920929 | 0.22161939 | -348.78904 | 1379.718 | -348.789044 | 1379.718 |

តាមលទ្ធផលខាងលើ បានបង្ហាញ Multiple R = 0.903250182 បញ្ជាក់ថាទំនាក់ទំនងរវាងអថេរមិនឯករាជ្យ (GDP Per Capita) មានទំនាក់ទំនងខ្លាំងជាមួយនឹងអថេរឯករាជ្យ (កម្ពស់ទឹកភ្លៀង, សីតុណ្ហភាព, និងកម្ពស់ទឹក)។ សីតុណ្ហភាពអតិបរមាជះឥទ្ធិពលខ្លាំងជាងគេទៅលើបរិមាណផលស្រូវដោយបង្ហាញតម្លៃ P(0.0028) < 0.05)។

តាមរយៈរូបមន្ត $\hat{y} = b_1.x_1 + b_2.x_2 + b_3.x_3 + b_4.x_4 + b_5.x_5 + a$ យើងអាចព្យាករណ៍ GDP Per Capita ដូចខាងក្រោម៖

ចំណូលសម្រាប់មនុស្សម្នាក់ឆ្នាំ២០២៦គឺ

= 0.517129204440234*1,861 +238.487633468157 *40.1 + 26.2435086983223*18.5 -43.4360179029809*10.5 + 515.464228231547*2.5 -9102.6843986581= **US$ 2,746**

តារាង ៨២. ការព្យាករណ៍ចំណូលសម្រាប់មនុស្សម្នាក់ (GDP Per Capita) ពីឆ្នាំ២០២៦ ដល់ ២០៣៥

| ឆ្នាំ | GDP Per Capita (US$) | កម្ពស់ទឹកភ្លៀង (មីលីម៉ែត្រ) | សីតុណ្ហភាពអតិបរមា (°C) | សីតុណ្ហភាពអប្បបរមា (°C) | កម្ពស់ទឹកអតិបរមា (ម) | កម្ពស់ទឹកអប្បបរមា(ម) |
|---|---|---|---|---|---|---|
| 2026 | 2,746 | 1,861 | 40.1 | 18.5 | 10.5 | 2.5 |
| 2027 | 2,848 | 1,857 | 40.5 | 18.2 | 10.4 | 2.5 |
| 2028 | 2,951 | 1,853 | 40.9 | 18.0 | 10.2 | 2.5 |
| 2029 | 3,056 | 1,849 | 41.4 | 17.8 | 10.1 | 2.5 |
| 2030 | 3,161 | 1,845 | 41.8 | 17.6 | 10.0 | 2.6 |
| 2031 | 3,268 | 1,841 | 42.2 | 17.4 | 9.8 | 2.6 |
| 2032 | 3,375 | 1,837 | 42.6 | 17.1 | 9.7 | 2.6 |
| 2033 | 3,484 | 1,833 | 43.1 | 16.9 | 9.5 | 2.6 |
| 2034 | 3,594 | 1,829 | 43.5 | 16.7 | 9.4 | 2.6 |
| 2035 | 3,704 | 1,825 | 44.0 | 16.5 | 9.3 | 2.6 |

### *ក២.៤). ការព្យាករណ៍ផលិតផលក្នុងស្រុកសរុប (GDP) ពីឆ្នាំ២០២៥ ដល់ ២០៣៥*

ក្រាហ្វិក១៦៩ បង្ហាញអំពីនិន្នាការផលិតផលក្នុងស្រុកសរុប (GDP) គឺបានកើនឡើងពីក្រោម១០ពាន់លានដុល្លារសហរដ្ឋអាមេរិក បានកើនឡើងជាង៥០ពាន់លានដុល្លារសហរដ្ឋអាមេរិក ពីឆ្នាំ១៩៩៣ទៅឆ្នាំ២០២៥។ ការព្យាករណ៍ពី GDP ពីឆ្នាំ២០២៦ ដល់ ២០៣៥ ជាមួយនឹង សីតុណ្ហភាព កម្ពស់ទឹកភ្លៀង និងកម្ពស់ទឹកដែលអាចមានពីឆ្នាំ២០០៦ ដល់២០២៥ ដោយប្រើប្រាស់ម៉ូដែលអនុគមន៍ទំនាក់ទំនង (Linear Relation or Regression Model) ប្រភេទ Multiple Linear Regression។

រូបមន្ត Multiple Linear Regression គឺ៖

$$\hat{y} = b_1.x_1 + b_2.x_2 + b_3.x_3 + b_4.x_4 + b_5.x_5 + a$$

ដែល $\hat{y}$ GDP
$x_1$ កម្ពស់ទឹកភ្លៀង
$x_2$ សីតុណ្ហភាពអតិបរមា
$x_3$ សីតុណ្ហភាពអប្បបរមា
$x_4$ កម្ពស់ទឹកអតិបរមា
$x_5$ កម្ពស់ទឹកអប្បបរមា

## ក្រាហ្វិក ១៦៩ ស្ថានភាពផលិតផលក្នុងស្រុកសរុប (GDP) គិតជាលានUS$




ប្រភព៖ - វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

- ថវិកាសង្ខេបឆ្នាំ២០២៦ នាយកដ្ឋានថវិកានីយកម្ម អគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង ៨៣. កំណត់អថេរឯករាជ្យ និងអថេរមិនឯករាជ្យសម្រាប់ព្យាករណ៍ GDP

| Year | Dependent Variable | Independent variable | | | | |
|---|---|---|---|---|---|---|
| | GDP (Millions in US$) | Rain water high (ml) | Maximum Temperature (ºC) | Minimum Temperature (ºC) | Maximum High Water (m) | Minimum High Water (m) |
| 2006 | 8,326.90 | 1,944 | 32.7 | 23.7 | 14.1 | 2.3 |
| 2007 | 10,087.45 | 1,740 | 32.6 | 23.8 | 13.6 | 2.2 |
| 2008 | 12,208.59 | 1,704 | 32.5 | 23.3 | 13.5 | 2.4 |
| 2009 | 12,508.71 | 1,542 | 32.9 | 23.3 | 14.3 | 2.4 |
| 2010 | 14,248.21 | 1,584 | 35.5 | 22.0 | 12.6 | 2.3 |
| 2011 | 16,154.35 | 1,767 | 34.5 | 20.8 | 15.3 | 2.5 |

| Year | Dependent Variable | Independent variable | | | | | |
|---|---|---|---|---|---|---|---|
| | GDP (Millions in US$) | Rain water high (ml) | Maximum Temperature (ºC) | Minimum Temperature (ºC) | Maximum High Water (m) | Minimum High Water (m) |
| 2012 | 17,829.84 | 1,632 | 35.1 | 20.9 | 11.9 | 2.7 |
| 2013 | 19,707.28 | 1,781 | 34.2 | 21.8 | 15.2 | 2.7 |
| 2014 | 22,082.48 | 1,659 | 35.0 | 21.9 | 15.6 | 3.1 |
| 2015 | 24,354.79 | 1,408 | 35.9 | 22.1 | 11.5 | 2.3 |
| 2016 | 26,764.63 | 1,862 | 40.2 | 15.5 | 9.1 | 2.2 |
| 2017 | 29,251.39 | 1,856 | 36.4 | 18.6 | 9.9 | 2.7 |
| 2018 | 32,931.05 | 1,717 | 36.4 | 15.7 | 10.7 | 2.7 |
| 2019 | 36,344.14 | 1,635 | 38.7 | 17.0 | 10.6 | 2.5 |
| 2020 | 34,835.44 | 1,684 | 37.8 | 19.4 | 7.0 | 2.1 |
| 2021 | 36,725.66 | 1,966 | 38.2 | 16.0 | 8.9 | 2.4 |
| 2022 | 39,490.79 | 2,150 | 36.4 | 17.4 | 10.9 | 2.6 |
| 2023 | 43,074.45 | 1,856 | 38.4 | 18.2 | 10.2 | 2.2 |
| 2024 | 46,379.85 | 1,697 | 39.5 | 18.8 | 11.1 | 2.1 |
| 2025 | 50,240.99 | 1,865 | 39.7 | 18.7 | 10.7 | 2.5 |

ផ្អែកតាមតារាងខាងលើ និង Run Multiple Linear Regression បានបង្ហាញលទ្ធផលដែលមានដូចខាងក្រោមសម្រាប់ធ្វើការព្យាករណ៍ អំពី GDP ពីឆ្នាំ ២០២៦ ដល់ ២០៣៥។

GDP មានវិស័យសំខាន់បីចូលរួមចំណែកគឺ វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។ វិស័យកសិកម្មអាចរងឥទ្ធិពលដោយសីតុណ្ហភាព កម្ពស់ទឹកភ្លៀង និងកម្ពស់ទឹកខ្លាំងជាងវិស័យពីរទៀត។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| SUMMARY OUTPUT | | | | | | | | |
| | | | | | | | | |
| Regression Statistics | | | | | | | | |
| Multiple R | 0.893128923 | | | | | | | |
| R Square | 0.797679273 | | | | | | | |
| Adjusted R Square | 0.72542187 | | | | | | | |
| Standard Error | 6718.935036 | | | | | | | |
| Observations | 20 | | | | | | | |
| | | | | | | | | |
| ANOVA | | | | | | | | |
| | df | SS | MS | F | Significance F | | | |
| Regression | 5 | 2491821043 | 498364209 | 11.0394125 | 0.000184511 | | | |
| Residual | 14 | 632017232.2 | 45144088 | | | | | |
| Total | 19 | 3123838275 | | | | | | |
| | | | | | | | | |
| | Coefficients | Standard Error | t Stat | P-value | Lower 95% | Upper 95% | Lower 95% | Upper 95% |
| Intercept | -194430.2804 | 85787.20192 | -2.2664252 | 0.03980074 | -378425.5285 | -10435.032 | -378426 | -10435.0323 |
| Rain_water | 13.33831743 | 10.78168524 | 1.23712733 | 0.2363897 | -9.786097489 | 36.4627323 | -9.7861 | 36.4627323 |
| Max_Temp | 4713.532045 | 1313.852209 | 3.5875664 | 0.00297089 | 1895.599326 | 7531.46476 | 1895.599 | 7531.46476 |
| Min_Temp | 799.964205 | 1384.257688 | 0.57790122 | 0.57250934 | -2168.973248 | 3768.90166 | -2168.97 | 3768.90166 |
| Max_Water | -749.4476031 | 1232.417324 | -0.6081119 | 0.55285148 | -3392.719866 | 1893.82466 | -3392.72 | 1893.82466 |
| Min_Water | 8322.048699 | 7991.501181 | 1.04136238 | 0.3153578 | -8818.016598 | 25462.114 | -8818.02 | 25462.114 |

តាមលទ្ធផលខាងលើ បានបង្ហាញ Multiple R = 0.893128923 បញ្ជាក់ថាទំនាក់ទំនងរវាងអថេរមិនឯករាជ្យ GDP មានទំនាក់ទំនងខ្លាំងជាមួយនឹងអថេរឯករាជ្យ (កម្ពស់ទឹកភ្លៀង, សីតុណ្ហភាព, និងកម្ពស់ទឹក)។ សីតុណ្ហភាពអតិបរមាជះឥទ្ធិពលខ្លាំងជាងគេទៅលើបរិមាណផលស្រូវដោយបង្ហាញតម្លៃ P(0.00297) < 0.05)។

តាមរយៈរូបមន្ត $\hat{y} = b_1.x_1 + b_2.x_2 + b_3.x_3 + b_4.x_4 + b_5.x_5 + a$ យើងអាចព្យាករណ៍ GDP Per Capita ដូចខាងក្រោម៖

ចំណូលសម្រាប់មនុស្សម្នាក់ឆ្នាំ២០២៦គឺ៖

= 13.3383174258129*1,861 + 4713.53204497647 *40.1 + 799.964204996358*18.5

-749.447603112436*10.5 + 8322.04869936476*2.5 -194430.280409206= **US$ 47,205.95**

### តារាង ៨៤. ការព្យាករណ៍ផលិតផលសរុប (GDP) ពីឆ្នាំ២០២៦ ដល់ ២០៣៥

| ឆ្នាំ | GDP in Million (US$) | កម្ពស់ទឹកភ្លៀង (មីលីម៉ែត្រ) | សីតុណ្ហភាព អតិបរមា (°C) | សីតុណ្ហភាព អប្បបរមា (°C) | កម្ពស់ទឹក អតិបរមា (ម) | កម្ពស់ទឹក អប្បបរមា(ម) |
|---|---|---|---|---|---|---|
| 2026 | 47,205.95 | 1,861 | 40.1 | 18.5 | 10.5 | 2.5 |
| 2027 | 49,114.48 | 1,857 | 40.5 | 18.2 | 10.4 | 2.5 |
| 2028 | 51,044.07 | 1,853 | 40.9 | 18.0 | 10.2 | 2.5 |
| 2029 | 52,994.92 | 1,849 | 41.4 | 17.8 | 10.1 | 2.5 |
| 2030 | 54,967.23 | 1,845 | 41.8 | 17.6 | 10.0 | 2.6 |
| 2031 | 56,961.20 | 1,841 | 42.2 | 17.4 | 9.8 | 2.6 |
| 2032 | 58,977.05 | 1,837 | 42.6 | 17.1 | 9.7 | 2.6 |
| 2033 | 61,014.98 | 1,833 | 43.1 | 16.9 | 9.5 | 2.6 |
| 2034 | 63,075.21 | 1,829 | 43.5 | 16.7 | 9.4 | 2.6 |
| 2035 | 65,157.94 | 1,825 | 44.0 | 16.5 | 9.3 | 2.6 |

តារាង៨០ បង្ហាញអំពីលទ្ធផលនៃការព្យាករណ៍ទៅលើ ទិន្នផលស្រូវ ផលិតផលស្រូវ ផលិតផលក្នុងស្រុកសរុប និងចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ពីឆ្នាំ២០២៦ ដល់ ២០៣៥ តាមរយៈនៃការ Run Multiple Linear Regession Model ដែលផ្អែកលើកត្តាសីតុណ្ហភាព កម្ពស់ទឹកភ្លៀង និងកម្ពស់ទឹក។ លទ្ធផលលំអិតមានក្នុងតារាងខាងក្រោម។

**តារាង ៨៥. លទ្ធផលព្យាករណ៍ពីឆ្នាំ២០២៥ ដល់២០៣៥ ផ្អែកលើ**

Multiple Linear Regression Model

| ឆ្នាំ | ទិន្នផលស្រូវ (តោន/ហត) | ផលិតផលស្រូវ (តោន) | GDP in Millions US$ | GDP Per Capita in US$ |
|---|---|---|---|---|
| 2026 | 3.70 | 13,866,909 | 47,205.95 | 2,746 |
| 2027 | 3.76 | 14,230,763 | 49,114.48 | 2,848 |
| 2028 | 3.81 | 14,599,072 | 51,044.07 | 2,951 |
| 2029 | 3.86 | 14,971,872 | 52,994.92 | 3,056 |
| 2030 | 3.92 | 15,349,199 | 54,967.23 | 3,161 |
| 2031 | 3.97 | 15,731,091 | 56,961.20 | 3,268 |
| 2032 | 4.03 | 16,117,584 | 58,977.05 | 3,375 |
| 2033 | 4.08 | 16,508,718 | 61,014.98 | 3,484 |
| 2034 | 4.14 | 16,904,530 | 63,075.21 | 3,594 |
| 2035 | 4.19 | 17,305,059 | 65,157.94 | 3,704 |

## ៣.២ ស្ថានភាពទូទៅផ្អែកលើទិន្នន័យទី៣ ( ផ្កាយរណប )

យោងតាមការចែករំលែកទិន្នន័យពីអង្គការ NASA របស់សហរដ្ឋអាមេរិកតាមរយៈផ្កាយរណប Sentinel 2 បានផ្តល់ទិន្នន័យទាក់ទងផ្ទៃដីគ្របដណ្តប់តាមប្រទេសនីមួយៗ។ ប្រទេសកម្ពុជាយើងគឺត្រូវបានផ្តល់ទិន្នន័យតាមរយៈផ្កាយរណប Sentinel 2 ពីឆ្នាំ ២០១៧ ដល់ ២០២៤ ។ ស្ថានភាពទូទៅនៃផ្ទៃដីគ្របដណ្តប់ (Land Cover) នឹងបង្ហាញជូននៅខាងក្រោម។

### ៣.២.១ ផ្ទៃដីគ្របដណ្តប់ ( Land Cover ) ប្រទេសកម្ពុជា

នៅក្នុងផែនទី ៨ បង្ហាញអំពីស្ថានភាពផែនទីផ្ទៃដីគ្របដណ្តប់ (Land Cover) សម្រាប់ប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀត ដែលមានព្រំប្រទល់ជាប់ប្រទេសកម្ពុជា ហើយក្នុងនោះក៏បានបង្ហាញអំពីពណ៌មានបៃតង(Tree) ខៀវ (Water) ក្រហម(Built Area) លឿង(Crop) បៃតងស្រាល (Flood vegetable) ទឹកក្រូចស្រាល(Bare Ground) ទឹកក្រូចក្រាសបន្តិច (Rangeland) B ពណ៌ស (Snow) និងពណ៌ប្រផេះ(Cloud) តាមរយៈផ្កាយរណប Sentinel 2 របស់អង្គការ NASA បានផ្តល់ឲ្យ។

**ផែនទី ៨. ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាឆ្នាំ ២០២៤**




ប្រភព៖Esri Sentinel2 Land Cover, [website], 2024, https://livingatlas.arcgis.com/landcoverexplorer/#mapCenter=106.91689%2C12.56482%2C7&mode=step&timeExtent=2017%2C2022&year=2024&renderingRule=0. (Accessed 29 May 2024)

ផែនទី ៩. ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាគ្របដណ្តប់ដោយផ្ទៃទឹក (Water) ឆ្នាំ ២០២៤




ផែនទី ១០. ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាគ្របដណ្តប់ដោយព្រៃឈើ (Tree) ឆ្នាំ ២០២៤



ផែនទី ១១. ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាគ្របដណ្តប់ដោយ
ទឹកជំនន់ដំណាំ (Flood Vegetation) ឆ្នាំ ២០២៤




ផែនទី ១២. ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាគ្របដណ្តប់ដោយដំណាំ (Crop) ឆ្នាំ ២០២៤



## ផែនទី ១៣. ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាគ្របដណ្តប់ដោយ អគារ ឬ សំណង់ផ្សេងៗ (Built) ឆ្នាំ ២០២៤




## ផែនទី ១៤. ផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជាគ្របដណ្តប់ដោយ វាលស្មៅ (Rangeland) ឆ្នាំ ២០២៤



តាមប្រព័ន្ធ Sattellite Sentinel-2 បានបង្ហាញអំពីផ្ទៃដីគ្របដណ្តប់ (Land Cover) ពីឆ្នាំ២០១៧ ដល់២០២៤។ ផ្ទៃដីដែលបានគ្របដណ្តប់ដោយទឹក (Water) មានប្រហែល ១៥% នៅឆ្នាំ២០១៧ និងនៅឆ្នាំ២០២៤ នៅតែរក្សាបាន១៥%ដដែល។ ផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ (Tree) នៅឆ្នាំ២០១៧ មាន៤៣% បានថយចុះមកត្រឹម៣៤%នៅឆ្នាំ២០២៤។ ផ្ទៃដីដែលទទួលរងគ្រោះដោយទឹកជំនន់បណ្តាលឲ្យខូចដំណាំ (Flood Vegetation) នៅឆ្នាំ២០១៧ មានប្រហែល ១,0% បានថយចុះ0,៨% នៅឆ្នាំ២០២៤។ ផ្ទៃដីដែលគ្របដណ្តប់ដោយដំណាំ (Crop) នៅឆ្នាំ២០១៧ មានប្រហែល២៤% បានកើនឡើង២៩% នៅឆ្នាំ២០២៤។ ចំពោះផ្ទៃដីដែលគ្របដណ្តប់ដោយអគារមានប្រហែល៥%នៅឆ្នាំ២០១៧ បានកើនឡើង៧%នៅឆ្នាំ២០២៤។ ផ្ទៃដីដែលគ្របដណ្តប់ដោយវាលស្មៅ (Rangeland) មានប្រហែល ១១,១% នៅឆ្នាំ២០១៧ បានកើនឡើង ១៣,៨% នៅឆ្នាំ២០២៤ (ក្រាហ្វិក១៧០)។

**ក្រាហ្វិក ១៧០. ផ្ទៃដីគ្របដណ្តប់ (Land Cover) ប្រទេសកម្ពុជា ពីឆ្នាំ២០១៧ ដល់២០២៤**



### ៣.២.២ ផ្ទៃដីគ្របដណ្តប់ ( Land Cover ) ខេត្តកំពង់ចាម

នៅក្នុងផែនទី ១៥ បង្ហាញអំពីស្ថានភាពផែនទីផ្ទៃដីគ្របដណ្តប់ (Land Cover) សម្រាប់ខេត្តកំពង់ចាម និងខេត្តដែលមានព្រំប្រទល់ជាប់ខេត្តកំពង់ចាម បានបង្ហាញអំពីពណ៌មានបៃតង(Tree) ខៀវ (Water) ក្រហម(Built Area) លឿង(Crop) បៃតងស្រាល (Flood vegetable) ទឹកក្រូចស្រាល(Bare Ground) ទឹកក្រូចក្រាសបន្តិច (Rangeland) Bពណ៌ស (Snow) និងពណ៌ប្រផេះ(Cloud) តាមរយៈផ្កាយរណប Sentinel 2 របស់អង្គការ NASA បានផ្តល់ឲ្យនៅឆ្នាំ២០២៤។

**ផែនទី ១៥. ផ្ទៃដីគ្របដណ្តប់ខេត្តកំពង់ចាមឆ្នាំ ២០២៤**




**ផែនទី ១៦. ផ្ទៃដីគ្របដណ្តប់ដោយទឹក ខេត្តកំពង់ចាមឆ្នាំ ២០២៤**



ផែនទី ១៧. ផ្ទៃដីគ្របដណ្តប់ខេត្តកំពង់ចាមគ្របដណ្តប់ដោយព្រៃឈើឆ្នាំ ២០២៤




ផែនទី ១៨. ផ្ទៃដីគ្របដណ្តប់ខេត្តកំពង់ចាមគ្របដណ្តប់ដោយទឹកជំនន់ឆ្នាំ ២០២៤



ផែនទី ១៩. ផ្ទៃដីគ្របដណ្តប់ខេត្តកំពង់ចាមគ្របដណ្តប់ដោយដំណាំឆ្នាំ ២០២៤




ផែនទី ២០. ផ្ទៃដីគ្របដណ្តប់ខេត្តកំពង់ចាមគ្របដណ្តប់ដោយអគារឆ្នាំ ២០២៤



## ផែនទី ២១. ផ្ទៃដីគ្របដណ្តប់ខេត្តកំពង់ចាមគ្របដណ្តប់ដោយវាលស្មៅឆ្នាំ ២០២៤




ក្រាហ្វិក ១៧១ បង្ហាញថា នៅឆ្នាំ២០២៤ ផ្ទៃដីគ្របដណ្តប់ដោយទឹកនៅខេត្តកំពង់ចាមគ្របដណ្តប់ដោយផ្ទៃទឹកមានប្រហែល១៧% នៅឆ្នាំ២០១៧ បានថយចុះបន្តិចមកត្រឹម១៦,៣% នៅឆ្នាំ២០២៤។ ផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើនៅឆ្នាំ២០១៧ មានប្រហែល៧% បានថយចុះមកត្រឹម៦% នៅឆ្នាំ២០២៤។ ទឹកជំនន់បានគ្របដណ្តប់ផ្ទៃដីប្រហែល១៤% នៅឆ្នាំ២០១៧ បានថយចុះមកត្រឹម៤% នៅឆ្នាំ២០២៤។ ផ្ទៃដីដែលបានគ្របដណ្តប់នៅឆ្នាំ២០១៧ មានប្រហែល ១១% បានកើឡើងដល់១៧%នៅឆ្នាំ២០២៤។ ផ្ទៃដីដែលនៅទំនេរនៅឆ្នាំ២០១៧ មានប្រហែល ០,៥% បានកើនឡើង០,៩% នៅឆ្នាំ២០២៤។ ផ្ទៃដីដែលគ្របដណ្តប់ដោយវាលស្មៅមានប្រហែល ១៥% នៅឆ្នាំ២០១៧ បានថយចុះមកត្រឹម១១% នៅឆ្នាំ២០២៤ (ក្រាហ្វិក ១៧១)។

ក្រាហ្វិក ១៧១. ផ្ទៃដីគ្របដណ្តប់ (Land Cover) ខេត្តកំពង់ចាម ពីឆ្នាំ២០១៧ ដល់២០២៤




### ៣.២.៣ ផ្ទៃដីគ្របដណ្តប់ ( Land Cover ) ខេត្តត្បូងឃ្មុំ

នៅក្នុងផែនទី ១៥ បង្ហាញអំពីស្ថានភាពផែនទីផ្ទៃដីគ្របដណ្តប់ (Land Cover) សម្រាប់ខេត្តត្បូងឃ្មុំ និងខេត្តដែលមានព្រំប្រទល់ជាប់ខេត្តត្បូងឃ្មុំនៅក្នុងឆ្នាំ២០២៤ បានបង្ហាញអំពីពណ៌មានបៃតង(Tree)មាន ២២% ខៀវ (Water) ៣% ក្រហម(Built Area) ៧% លឿង(Crop) ៦១% បៃតងស្រាល (Flood vegetable) ១% ទឹកក្រូចស្រាល(Bare Ground) 0,២% ទឹកក្រូចក្រាសបន្តិច (Rangeland) ៦% Bពណ៌ស (Snow) និងពណ៌ប្រផេះ(Cloud) តាមរយៈផ្កាយរណប Sentinel 2 របស់អង្គការ NASA បានផ្តល់ឲ្យនៅឆ្នាំ២០២៤។

## ផែនទី២២. ផ្ទៃដីគ្របដណ្តប់ខេត្តត្បូងឃ្មុំឆ្នាំ២០២៤




## ផែនទី២៣. ផ្ទៃដីគ្របដណ្តប់ដោយទឹក ខេត្តត្បូងឃ្មុំឆ្នាំ២០២៤



## ផែនទី២៤. ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤




## ផែនទី២៥. ផ្ទៃដីគ្របដណ្តប់ដោយទឹកជំនន់ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤



ផែនទី២៦. ផ្ទៃដីគ្របដណ្តប់ដោយដំណាំ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤




ផែនទី២៧. ផ្ទៃដីគ្របដណ្តប់ដោយអគារ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤



## ផែនទី២៨. ផ្ទៃដីគ្របដណ្តប់ដោយដីទំនេរ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤




## ផែនទី២៩. ផ្ទៃដីគ្របដណ្តប់ដោយវាលស្មៅ ខេត្តត្បូងឃ្មុំឆ្នាំ២០២៤



ក្រាហ្វិក ១៧២. ផ្ទៃដីគ្របដណ្តប់ (Land Cover) ខេត្តត្បូងឃ្មុំ ពីឆ្នាំ២០១៧ ដល់២០២៤







## ៣.២.៤ ផ្ទៃដីគ្របដណ្ដប់ (Land Cover) ប្រទេសមួយចំនួនមានព្រំប្រទល់ជាប់ប្រទេសកម្ពុជា

ស្ថានភាពផ្ទៃដីគ្របដណ្ដប់នៅក្នុងប្រទេសអាស៊ានមួយចំនួន នឹងបង្ហាញជូននៅក្នុងផែនទីខាងក្រោមដែលរួមមាន ផ្ទៃដីគ្របដណ្ដប់ដោយទឹក ផ្ទៃដីគ្របដណ្ដប់ដោយព្រៃឈើ ផ្ទៃដីគ្របដណ្ដប់ដោយទឹកជំនន់ ផ្ទៃដីគ្របដណ្ដប់ដោយដំណាំ ផ្ទៃដីគ្របដណ្ដប់ដោយអគារ ឬ សំណង់លំនៅដ្ឋានផ្សេងៗ ផ្ទៃដីនៅទំនេរ និងផ្ទៃដីដែលគ្របដណ្ដប់ដោយវាលស្មៅ។

## ផែនទី ៣០. ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួន ឆ្នាំ២០២៤




## ផែនទី ៣១. ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដោយផ្ទៃទឹកសាប ឆ្នាំ២០២៤



## ផែនទី ៣២. ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដោយព្រៃឈើ ឆ្នាំ២០២៤




## ផែនទី ៣៣. ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដោយទឹកជំនន់ ឆ្នាំ២០២៤



## ផែនទី ៣៤. ស្ថានភាពផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជា និងប្រទេសស្ថិត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្ដប់ដោយដំណាំ ឆ្នាំ២០២៤




## ផែនទី ៣៥. ស្ថានភាពផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជា និងប្រទេសស្ថិត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្ដប់ដោយអគារ ឆ្នាំ២០២៤



## ផែនទី ៣៦. ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដីទំនេរ ឆ្នាំ២០២៤




*បញ្ជាក់៖ រូបភាពដីទំនេរជាដីដែលមានពណ៌លឿងស្រាល*

## ផែនទី ៣៧. ស្ថានភាពផ្ទៃដីគ្របដណ្តប់ប្រទេសកម្ពុជា និងប្រទេសស្ថិត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួនគ្របដណ្តប់ដោយវាលស្មៅ ឆ្នាំ២០២៤



ក្រាហ្វិក ១៧៣ បានបង្ហាញថាភាគរយផ្ទៃដីគ្របដណ្ដប់ប្រទេសកម្ពុជាប្រៀបធៀបនឹងប្រទេសវៀតណាម ឡាវ ភូមា និងប្រទេសថៃ។ ភាគរយផ្ទៃដីដែលគ្របដណ្ដប់ដោយផ្ទៃទឹករបស់ប្រទេសកម្ពុជាមានប្រហែល១០% នៅឆ្នាំ២០២៤ តិចជាងប្រទេសវៀតណាមប្រហែល៨% និងប្រទេសថៃចំនួនជាង ៤% តែខ្ពស់ជាងប្រទេសឡាវ និងភូមាជិត១%។

**ក្រាហ្វិក ១៧៣. ប្រៀបធៀបភាគរយផ្ទៃដីគ្របដណ្ដប់ (Land Cover) ប្រទេសកម្ពុជា និងប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយចំនួន ឆ្នាំ២០២៤**



# ជំពូក ៤
# របកគំហើញ និង សន្និដ្ឋាន

## ៤.១ របកគំហើញ

តាមរយៈការសិក្សាស្រាវជ្រាវ នៅក្នុងគម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២៥នៅតាមខេត្តគោលដៅទាំង២គឺ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ផ្អែកលើទិន្នន័យ៣ប្រភេទគឺ ទិន្នន័យទី១ ទិន្នន័យទី២ និងទិន្នន័យទី៣ (ផ្កាយរណប)។ ទិន្នន័យទី១ គឺជាប្រភេទទិន្នន័យ ដែលប្រមូលបានតាមរយៈការសម្ភាសន៍នៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំដែលមានចំនួន៦០០គ្រួសារ។ ទិន្នន័យទី២ គឺទិន្នន័យដែលក្រសួងស្ថាប័នផ្សេងៗបានផលិតចេញ។ ទិន្នន័យពីផ្កាយរណប គឺទិន្នន័យដែលបានតាមរយៈការចែករំលែកពីអង្គការ NASA តាមរយៈផ្កាយរណប Sentinel2។ ដូច្នេះលទ្ធផលនៃការសិក្សាស្រាវខាងលើបានបង្ហាញនូវរបកគំហើញតាមរយៈនៃទិន្នន័យនីមួយៗ ដូចខាងក្រោម៖

### ៤.១.១ របកគំហើញផ្អែកលើទិន្នន័យទី១

#### ក. តាមរយៈការសម្ភាសន៍មេភូមិ

តាមលទ្ធផលនៃការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំបានរកឃើញនូវទាក់ទងនឹងបញ្ហាប្រជាសាស្ត្រតាមរយៈការសម្ភាសន៍មេភូមិ១០នាក់ និងមេគ្រួសារទាំងចំនួន៦០០នាក់ មានដូចខាងក្រោម៖

- ភាគរយមេភូមិដែលបានសម្ភាសន៍ភាគច្រើនជាបុរសមានរហូតដល់៩០% និងស្ត្រី១០%។ មេភូមិទាំងនោះគឺមានអាយុចាប់ពី៦០ឆ្នាំឡើង។ មេធ្យានអាយុរបស់មេភូមិពីឆ្នាំ២០២០ ដល់ ២០២៥ ស្ថិតនៅចន្លោះចាប់ពី ៤៧ឆ្នាំ ដល់ ៦៧ឆ្នាំ និងអាយុមេភូមិគិតជាមធ្យមពីឆ្នាំ ២០២០ ដល់ ២០២៥ ចាប់៥១,៧ឆ្នាំ ដល់ ៦៤,៥ឆ្នាំ។

- ភាគរយប្រជាជនដែលប្រើប្រាស់ទឹកស្អាតមានប្រហែល៧៨% នៅឆ្នាំ២០២៥

- ភាគរយគ្រួសារមានបង្គន់អនាម័យមានប្រហែល ៨៤% និងគ្រួសារមានអគ្គិសនីប្រើប្រាស់ មានជិត៩១%

- ភាគរយសមាជិកគ្រួសារធ្វើការតាមវិស័យសេដ្ឋកិច្ចក្នុងភូមិភាគច្រើនធ្វើការក្នុងវិស័យ កសិកម្មមានមាន៥៤% វិស័យឧស្សាហកម្ម៣១% និងវិស័យសេវាកម្ម១៥%

- ចំនួនគ្រួសារដែលរងផលប៉ះពាល់ការបង្ហូរទឹកកខ្វក់មានចំនួន១០ គ្រួសារ ស្មើនឹង០,២% ក្នុងចំណោមគ្រួសារជាង៥ពាន់ និង រងផលប៉ះពាល់ដោយការចាក់សំរាមមានចំនួន ៥៤គ្រួសារ ស្មើនឹង ១%។

- ប្រភពព័ត៌មានគ្រោះមហន្តរាយដែលមេភូមិទទួលបានពីព័ត៌មានផ្សេងៗមាន៨០% ទូរទស្សន៍ ៧០% អាជ្ញាធរ និង សារតាមទូរស័ព្ទមានចំនួនដូចគ្នាគឺ ៦០% ការជូនដំណឹងតាមទូរស័ព្ទផ្ទាល់៥០% និងតាមវិទ្យុមានតែ៣០%

- គ្រោះមហន្តរាយដែលបានកើតឡើងក្នុងភូមិដែលបានសម្ភាសន៍មានខ្យល់ព្យុះ និងគ្រោះរាំងស្ងួត ក្នុងនោះគ្រោះរាំងស្ងួតបានធ្វើឲ្យខូចខាតផលដំណាំមានទឹកប្រាក់ប្រហែល ២១.០០០ ដុល្លារ និង ខ្យល់ព្យុះខូចខាតគិតជាប្រាក់អស់ប្រហែល ១០.០០០ ដុល្លារ ក្នុងចំណោម១០ភូមិដែលបានសម្ភាសន៍។

- អាកាសធាតុមានការប្រែប្រួលតាមការកត់សំគាល់របស់មេភូមិបានសម្ភាសន៍ គឺមាន ១០០% និង ទឹកភ្លៀងមិនទៀងទាត់មាន ៩០% នៃមេភូមិបានឆ្លើយថាអាកាសធាតុប្រែប្រួលខ្លាំង។

## ខ. តាមរយៈការសម្ភាសន៍មេគ្រួសារ

### ខ១. ប្រជាសាស្ត្រ

- ភាគរយមេគ្រួសារជាបុរសមានរហូតដល់៧៤% និងមេគ្រួសារជាស្ត្រីមាន២៦%។ មេគ្រួសារទាំងបុរស និងស្ត្រីគឺភាគច្រើនស្ថិតនៅក្នុងអាយុ៤០ដល់៥៩ឆ្នាំ

- មេដ្យានអាយុមេគ្រួសារ ៥២ឆ្នាំ ក្នុងនោះមេគ្រួសារជាបុរស ៥១ឆ្នាំ និង មេគ្រួសារជាស្ត្រី៥៥ឆ្នាំ

- អាយុមេគ្រួសារគិតជាមធ្យម ៥១,៥ឆ្នាំ ក្នុងនោះមេគ្រួសារជាបុរស ៥០,៦ឆ្នាំ និង មេគ្រួសារជាស្ត្រី៥៤,៣ឆ្នាំ

- ទំហំសមាជិកគ្រួសារជាមធ្យមទាំង៦០០ គ្រួសារដែលបានសម្ភាសន៍ក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ មានទំហំ៤,៧នាក់ ក្នុងមួយគ្រួសារ។

- ភាគរយនៃសមាជិកក្នុងគ្រួសារដែលចំណាកស្រុកមាន១១% នៃសមាជិកសរុប។ ចំណាកស្រុកភាគច្រើននៅក្នុងប្រទេសមាន៨៧% និងចំណាកស្រុកក្រៅប្រទេសមាន១៣% ក្នុងចំណោមចំណាកស្រុកសរុប។ មូលហេតុនៃចំណាកស្រុក គឺស្វែងរកការងារធ្វើមានរហូតដល់៦០%

- ផ្នែកការងារដែលសមាជិកគ្រួសារបានធ្វើភាគជាក្រុមហ៊ុនឯកជនខ្មែរមាន៨០,៧%និងក្រុមហ៊ុនឯកជនបរទេស ១៦,៣% រដ្ឋាភិបាលប្រហែល៣% និងផ្សេងៗតិចជាង១%

- មុខរបរចម្បងរបស់សមាជិកគ្រួសារភាគច្រើនជាកសិករដាំស្រូវ និងដាំដំណាំមាន៣៩% កម្មកររោងចក្រមាន២៥% ធ្វើការងារជាសន្តិសុខ២៥% និងក្រៅពីនោះមុខរបរផ្សេងៗមាន១១%

- ភាគរយនៃការចូលរួមកម្លាំងពលកម្មក្នុងវិស័យសេដ្ឋកិច្ច គឺភាគរយនៃការចូលរួមកម្លាំងពលកម្មក្នុងវិស័យសេដ្ឋកិច្ចដែលនៅក្នុងនោះវិស័យកសិកម្ម ៤០% វិស័យឧស្សាហកម្ម២៥% និងវិស័យឧស្សាហកម្ម៣៥%។

## ១២. បរិស្ថាន

តាមលទ្ធផលនៃការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំបានរកឃើញនូវទាក់ទងនឹងបញ្ហាបរិស្ថានតាមរយៈការសម្ភាសន៍មេគ្រួសារមានដូចខាងក្រោម៖

- ភាគរយនៃគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់មានជាង៩០%

- សេវាប្រមូលសំរាមនៅក្នុងខេត្តទាំង២ឆ្នាំ២០២៥មានប្រហែល ១៨,២% និងទីតាំងទុកសំរាមនៅក្នុងបរិវេណផ្ទះមានប្រហែល៨៧%

- ភាគរយនៃគ្រួសារដែលរងផលប៉ះពាល់ដោយការចាក់សំរាមមាន៨%

- ភាគរយនៃគ្រួសារដែលរងផលប៉ះពាល់ដោយការបាញ់ថ្នាំពុល១៣%

- ភាគរយនៃគ្រួសារដែលរងផលប៉ះពាល់ដោយការប្រើប្រាស់ជីគីមីមាន៨%។

## ១៣. គ្រោះមហន្តរាយ

តាមលទ្ធផលនៃការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំមានចំនួន៦០០ គ្រួសារ បានរកឃើញទាក់ទងនឹងបញ្ហាគ្រោះមហន្តរាយតាមរយៈការសម្ភាសន៍មេគ្រួសារមានដូចខាងក្រោម៖

- គ្រោះមហន្តរាយដែលបានកើតឡើងនិងរងផលប៉ះពាល់ដល់គ្រួសារដែលបានសម្ភាសន៍មានខ្យល់កន្ត្រាក់/ខ្យល់ព្យុះ ទឹកជំនន់ និងគ្រោះរាំងស្ងួត

- ភាគរយគ្រួសារប្រហែល២៩% ទទួលរងគ្រោះមហន្តរាយ ហើយបានទទួលព័ត៌មានពីគ្រោះមហន្តរាយមានរហូតដល់៨៩%។ ប្រភពព័ត៌មានដែលទទួលបានមានភាគរយខ្ពស់ជាងគេពីប្រភពផ្សេងៗមានភាគរយច្រើនជាងគេប្រហែល៨៨%។ ទទួលព័ត៌មានពីប្រភពអាជ្ញាធរ ទូរទស្សន៍ និងទូរស័ព្ទដៃ មានភាគរយពី១៩% ដល់៣១%

- ភាគរយនៃគ្រួសារដែលរងគ្រោះដោយគ្រោះរាំងស្ងួតមាន៩០% ច្រើនជាងគេ ខ្យល់ព្យុះមាន ១៣% និងទឹកជំនន់មាន២%

- សរុបទឹកប្រាក់ដែលខូចខាតទ្រព្យសម្បត្តិ និងផលដំណាំ ដោយសារគ្រោះមហន្តរាយដែលបានកើតឡើងលើគ្រួសារ១៧៦ គ្រួសារមានទឹកប្រាក់សរុបចំនួន ៩៧.៦២២ ដុល្លារ ក្នុងនោះខូចខាតដោយគ្រោះរាំងស្ងួតមានទឹកប្រាក់ចំនួន ៩៣.៨៥៧ ដុល្លារ (៩៦,១%) ខូចខាតដោយខ្យលព្យុះមានទឹកប្រាក់ចំនួន ២.៤០០ ដុល្លារ (២,៥%) និងខូចខាតដោយទឹកជំនន់មាន ១.៣៦៥ដុល្លារ (១,៤%)

- ក្នុងរបាយការណ៍នេះបានបង្ហាញអំពីការព្យាករណ៍ផលប៉ះពាល់គ្រោះមហន្តរាយដែលអាចកើតឡើងតាមរយៈ Logistic Regression Model។ លទ្ធផលនៃការព្យាករណ៍ចំពោះគ្រួសារទាំង ១៧៦គ្រួសារ ដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយ ផ្អែកលើអថេរឯករាជ្យ (ភេទ អាយុ

ប្រភពទទួលព័ត៌មានគ្រោះមហន្តរាយ ខ្យល់ព្យុះ ទឹកជំនន់ និងគ្រោះរាំងស្ងួត) កម្រិតអតិបរមាមាន ៨៩% កម្រិតគិតជាមធ្យម ៣០% និង កម្រិតអប្បបរមា ៣%។

**ខ៤. ការប្រែប្រួលអាកាសធាតុ**

តាមលទ្ធផលនៃការចុះស្រង់ទិន្នន័យនៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំបានរកឃើញនូវទាក់ទងនឹងបញ្ហាប្រែប្រួលអាកាសធាតុដែលទទួលបានតាមរយៈការសម្ភាសន៍មេគ្រួសារចំនួន៦០០នាក់ មានដូចខាងក្រោម៖

- ភាគរយមេគ្រួសារដែលបានឆ្លើយថា ភ្លៀងធ្លាក់មិនទៀងទាត់មានភាគរយច្រើនជាងគេមាន ៨៤% ភ្លៀងធ្លាក់ទៀងទាត់មាន៧% និងមិនប្រាកដ ៩% ក្នុងចំណោមមេគ្រួសារសរុប៦០០នាក់
- ភាគរយមេគ្រួសារដែលបានឆ្លើយថា ស្ថានភាពសីតុណ្ហភាពក្តៅខ្លាំងមានភាគរយខ្ពស់មាន ៨៥% ក្តៅល្មមមាន១១% និង ត្រជាក់ខ្លាំង៤%។ តាមលទ្ធផលនៃការគណនា (Chi-square) បានបញ្ជាក់ថាអាកាសធាតុឆ្នាំ២០២៥ មានសីតុណ្ហភាពក្តៅខ្លាំងជាងគេ បើគិតពីឆ្នាំ២០២២ដល់ ២០២៥។

## ៤.១.២ របកគំហើញផ្អែកលើទិន្នន័យទី២

តាមរយៈការសិក្សាស្រាវជ្រាវ នៅក្នុងគម្រោងអង្កេតកសិកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥ ដោយផ្អែកលើទិន្នន័យទី២ ដូចខាងក្រោម៖

**ក. ស្ថានភាពប្រជាសាស្ត្រ**

- កំណើនប្រជាជនទូទាំងពិភពលោកបានកើនឡើងជាង៣ដងពីឆ្នាំ១៩៦២ ដល់ ២០៥០។ ចំនួនប្រជាជននៅឆ្នាំ១៩៦០ មានចំនួន ៣.០១៥ លាននាក់បានកើនឡើងនៅឆ្នាំ ២០៣៥ មានចំនួន៨.២៣២ លាននាក់ និងនៅឆ្នាំ ២០៥០ បានកើនឡើងដល់ ៩.៦៦៤ លាននាក់។
- កំណើនប្រជាជនកម្ពុជាបានកើនឡើងជិត ៤ដងពីឆ្នាំ១៩៦២ ដល់ ២០៥០។ ចំនួនប្រជាជននៅឆ្នាំ១៩៦២ មានចំនួន ៥.៧លាននាក់បានកើនឡើងនៅឆ្នាំ២០៣៥ មានចំនួន ១៩.៨លាននាក់។ ចំនួនប្រជាជនក្នុងតំបន់ទំនាបកណ្តាលនឹងកើនឡើងជិត២ដងពីឆ្នាំ១៩៩៨ មានចំនួន ៥,៩ លាននាក់ បានកើនដល់ ៩,៧លាននាក់ ឆ្នាំ ២០៣៥។ ចំនួនប្រជាជននៅខេត្តកំពង់ចាមបានកើនឡើងជិត៣ដង ពីចំនួន៤៤០,៥៣ពាន់នាក់ នៅឆ្នាំ១៩៦២តាមការប៉ាន់ស្មាន បានកើនដល់១,២លាននាក់នៅឆ្នាំ ២០៣៥ និងខេត្តត្បូងឃ្មុំបានកើនឡើងជិត៣ដង ពីចំនួន៣៧៩,២៣ពាន់នាក់នៅឆ្នាំ១៩៦២ តាមការប៉ាន់ស្មានបានកដល់ជាង១លាននាក់នៅឆ្នាំ២០៣៥។

- ដង់ស៊ីតេប្រជាជននៅលើពិភពលោកនៅឆ្នាំ១៩៩៨ មានចំនួនបានកើនពីចំនួន៤៦នាក់ក្នុង១គីឡូម៉ែត្រក្រឡា អាចកើនដល់ចំនួន៦៤នាក់ក្នុង១គីឡូម៉ែត្រក្រឡានៅឆ្នាំ២០៣៥។

- ដង់ស៊ីតេប្រជាជននៅទូទាំងប្រទេសឆ្នាំ ១៩៩៨ មានចំនួន ៦៤នាក់ក្នុង១គីឡូម៉ែត្រក្រឡា នឹងកើនឡើងដល់ចំនួន ១១១នាក់ក្នុង១គីឡូម៉ែត្រក្រឡានៅឆ្នាំ ២០៣៥។ ខេត្តកំពង់ចាម បានកើនពីចំនួន២០៣នាក់ក្នុង១គីឡូម៉ែត្រក្រឡានៅឆ្នាំ១៩៩៨ កើនដល់ចំនួន ២៥៣នាក់ក្នុង១គីឡូម៉ែត្រក្រឡានៅឆ្នាំ២០៣៥ និងខេត្តត្បូងឃ្មុំបានកើនឡើងពីចំនួន១៣៩នាក់ក្នុង១គីឡូម៉ែត្រក្រឡា នៅឆ្នាំ១៩៩៨ កើនដល់ ២០៣នាក់ក្នុង១គីឡូម៉ែត្រក្រឡានៅឆ្នាំ២០៣៥។

- ប្រជាជនប្រហែល ៣,៦% នៃប្រជាជនពិភពលោកដែលបានធ្វើចំណាកស្រុក។ ចំនួនជនអន្តោប្រវេសន៍អន្តរជាតិនៅឆ្នាំ១៩៧០មានចំនួន៨៤,៤លាននាក់ ស្មើនឹង២,៣នៃប្រជាជនពិភពលោកបានកើនដល់២៨១លាននាក់ ស្មើនឹង៣,៦% នៅឆ្នាំ២០២០។ ចំនួនជនអន្តោប្រវេសន៍អន្តរជាតិភាគច្រើនជាកម្មករលក់កម្លាំងពលកម្មមានចំនួន១៦៩លាននាក់នៅឆ្នាំ២០១៩។ ជនអន្តោប្រវេសន៍អន្តរជាតិបានផ្ញើប្រាក់មកក្រុមគ្រួសារនៅក្នុងប្រទេសកំណើត មានចំនួន៨៣១ប៊ីលានដុល្លារនៅឆ្នាំ២០២២ ក្នុងនោះប្រទេសឥណ្ឌាទទួលបានប្រាក់ច្រើនជាងគេ មានចំនួន១១១,២២ប៊ីលានដុល្លារ។ មូលហេតុនៃការធ្វើចំណាកស្រុកជាអន្តរជាតិនេះបណ្តាលមកគ្រោះមហន្តរាយ ៨,៧លាននាក់ នៅក្នុងឆ្នាំ២០២២ និងក្រៅពីនោះក៏បណ្តាលមកពីសង្គ្រាម និងគ្រោះធម្មជាតិផ្សេងៗ។

- ការផ្លាស់ប្តូលំនៅឋានរបស់ប្រជាជនកម្ពុជាបានថយចុះពី៣១%នៅឆ្នាំ១៩៩៨ មកត្រឹម ២២% នៅឆ្នាំ២០១៩។ ខេត្តកំពង់ចាមបានថយចុះពី២២%នៅឆ្នាំ១៩៩៨ ថយមកត្រឹម៩%នៅឆ្នាំ ២០១៩ និងខេត្តត្បូងឃ្មុំបានថយចុះពី២៧%នៅឆ្នាំ១៩៩៨ថយមកត្រឹម១១%នៅឆ្នាំ២០១៩ បើប្រៀបធៀបជាមួយប្រជាជនសរុប។ មូលហេតុចម្បងនៃការផ្លាស់ប្តូរលំនៅឋានដោយសារការស្វែងរកការងារធ្វើ និងគ្រួសារផ្លាស់ប្តូរលំនៅឋានមានចំនួនច្រើន។

- និន្នាការនៃការចូលរួមកម្លាំងពលកម្ម នៅក្នុងវិស័យសេដ្ឋកិច្ចបានថយចុះពីផ្នែកកសិកម្ម និងបានកើនឡើងផ្នែកឧស្សាហកម្ម និងសេវាកម្មទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងខេត្តទាំង២ខាងលើ។

## ខ. តំបន់ទីប្រជុំជន និងលំនៅឋាន

### ខ១. តំបន់ទីប្រជុំជន

- ចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជននៅលើពិភពលោកនៅឆ្នាំ២០៣៥ អាចកើនលើស ៦០% និងចំនួនប្រជាជនកម្ពុជាដែលរស់នៅទីប្រជុំជននៅឆ្នាំ២០៣៥ អាចកើនលើសពី ៤០%។

- ចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជន នៅក្នុងខេត្តកំពង់ចាម បានកើនឡើងពី៨%នៅឆ្នាំ១៩៩៨ កើនដល់ ១៥%នៅឆ្នាំ២០១៩ និងខេត្តត្បូងឃ្មុំបានកើនឡើងពី ៧%នៅឆ្នាំ១៩៩៨ កើនដល់ជិត៩% នៅឆ្នាំ២០១៩។

### ខ២. អគារ និងលំនៅឋាន

- នៅក្នុងប្រទេសកម្ពុជាចំនួនអគារនៅឆ្នាំ១៩៩៨ មានចំនួន២,២ លានអគារ និងមានផ្ទះផ្ទាល់ខ្លួនមានចំនួន ២,១ លានផ្ទះស្មើនឹង៩៤% បានកើនដល់ ៣,៦លានអគារ និងមានផ្ទះផ្ទាល់ខ្លួន ៣,២លានផ្ទះស្មើនឹង៩១% នៅឆ្នាំ២០១៩។ ខេត្តកំពង់ចាមគ្រួសារដែលមានផ្ទះផ្ទាល់ខ្លួន៩៤% នៅឆ្នាំ១៩៩៨ បានកើនឡើង ៩៥% នៅឆ្នាំ២០១៩ និងខេត្តត្បូងឃ្មុំគ្រួសារដែលមានផ្ទះផ្ទាល់ខ្លួនមាន ៩១% នៅឆ្នាំ១៩៩៨ និងបានថយចុះមកត្រឹម៨៨% នៅឆ្នាំ២០១៩។

- លំនៅឋាននៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០២១ មានចំនួនប្រហែល ២៣៧ ពាន់លំនៅឋាន ខេត្តកំពង់ចាមមានលំនៅឋានចំនួន២៦០ ពាន់ និងខេត្តត្បូងឃ្មុំមានចំនួន១៨៥ ពាន់ លំនៅដ្ឋាន។

## គ. បរិស្ថាន

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ ដែលបានរកឃើញនូវបញ្ហាទាក់ទងនឹងបរិស្ថានមានដូចខាងក្រោម៖

### គ១. គុណភាពខ្យល់

តាមរបាយការណ៍របស់ក្រសួងបរិស្ថានឆ្នាំ២០២១ បានឲ្យដឹងថាគុណភាពខ្យល់ $PM_{2.5}$ នៅរាជធានីភ្នំពេញបានកើនពី១៣,៥៩($\mu g/m^3$) នៅឆ្នាំ២០១៧ បានកើនដល់២០,០២($\mu g/m^3$) ដែលកម្រិតស្តង់ដារកំណត់ ២៥($\mu g/m^3$) ។

### គ២. ការប្រមូលសំរាម និងកាកសំណល់

- សេវាប្រមូលសំរាមទូទាំងប្រទេសមានគ្រួសារប្រហែល ៥០៥.៣២៥ គ្រួសារ (១៣,១%) ដែលទទួលសេវាប្រមូលសំរាមក្នុងចំណោមគ្រួសារ ៣,៨លាននៅឆ្នាំ២០២១ ខណៈដែលខេត្តកំពង់ចាមមានប្រហែល ៣% និងខេត្តត្បូងឃ្មុំមានប្រហែល២% ដែលបានទទួលសេវាប្រមូលសំរាមក្នុងចំណោមគ្រួសារសរុបនៅឆ្នាំ២០២១។

- កាកសំណល់រឹង និងសំណល់រាវនឹងមានការកើនឡើងដោយសារកំណើនប្រជាជនអាចកើនដល់ ១៩,៨លាននាក់នៅឆ្នាំ២០៣៥ ជាពិសេសនៅរាជធានីភ្នំពេញ។

- តំបន់ការពារធម្មជាតិមានផ្ទៃដីប្រមាណ ៥,៩ លានហិកតា ខណៈដែលគម្របព្រៃឈើបានធ្លាក់ចុះពី ៧៣%នៅឆ្នាំ ១៩៦៥ មកត្រឹម ៤៧% នៅឆ្នាំ ២០១៨។

- ភាគរយនៃគ្រួសារដែលមានបង្គន់អនាម័យនៅទូទាំងប្រទេសមានចំនួន១៤% នៅឆ្នាំ១៩៩៨ បានកើនឡើង ៨៣% ខេត្តកំពង់ចាមមាន១១% នៅឆ្នាំ១៩៩៨ បានកើនឡើង ៨៣% នៅឆ្នាំ ២០១៩ និងខេត្តត្បូងឃ្មុំមាន៨% នៅឆ្នាំ១៩៩៨ បានកើនឡើងដល់៧៣% នៅឆ្នាំ២០១៩។

### គ៣. តំបន់ការពារ

- ផ្ទៃដីនៃតំបន់ការពារសត្វព្រៃមានប្រហែល ៧៨% នៃផ្ទៃដីតំបន់ការពារសរុបដែលមានជាង ៥,៩ លានហិកតារបស់ប្រទេសកម្ពុជា។

- គម្របព្រៃឈើបានថយចុះពី៧៣,៥% មកត្រឹម ៤៦,៨៦% ពីឆ្នាំ ១៩៦៥ ដល់ឆ្នាំ២០១៨។

**គ៤. ទឹកស្អាត**

និន្នាការនៃការប្រើប្រាស់ទឹកស្អាតមានការកើនឡើងពី២៩%នៅឆ្នាំ១៩៩៨ ទៅ ៧៣% ឆ្នាំ ២០១៩ សម្រាប់ទូទាំងប្រទេស ហើយខេត្តកំពង់ចាមបានកើនឡើងពី២៥% នៅឆ្នាំ១៩៩៨ កើនដល់៨១%នៅឆ្នាំ ២០១៩ និងខេត្តត្បូងឃ្មុំបានកើនពី ១១% នៅឆ្នាំ១៩៩៨ កើនដល់ ៨៦%នៅឆ្នាំ ២០១៩។

## ឃ. គ្រោះមហន្តរាយ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ បានរកឃើញទាក់ទងនឹងគ្រោះមហន្តរាយមានដូចខាងក្រោម៖

**ឃ១. សកលលោក**

- ចំនួនគ្រោះមហន្តរាយធំៗដែលបានកើតឡើងទូទាំងពិភពលោកនៅឆ្នាំ២០២៤ មានចំនួន ៣៩៣ដងក្នុងនោះនៅក្នុងទ្វីបអាស៊ីមានចំនួន១៦៧ដង ទ្វីបអាមេរិក១១៨ដង ទ្វីបអាហ្វ្រិក ៧៥ដង ទ្វីបអឺរ៉ុប ២៤ដង និងទ្វីបអូសេអានី៩ដង ក្នុងនោះរួមមាន៖ ព្យុះ ១៤៧ដង ទឹកជំនន់ ១៤២ដង ផ្ទៃដីមានទឹកយូរ (Mass Movement (wet)) ៣២ដង ភ្លើងឆេះព្រៃ ២១ដង កម្តៅខ្លាំង១៨ដង រញ្ជួយដី១៤ដង និងរាំងស្ងួត១២ដង។

- ចំនួនអ្នកស្លាប់ដោយសារគ្រោះមហន្តរាយឆ្នាំ២០២៤ មានចំនួន ១៦.៧៥៣ នាក់ និងរងផលប៉ះពាល់ដល់ប្រជាជនចំនួន១៦៧,២លាននាក់ នៅលើពិភពលោក ដែលក្នុងនោះគ្រោះមហន្តរាយដោយសារដែលប្រជាជនរងផលប៉ះពាល់គឺ ទឹកជំនន់មាន ខ្យល់ព្យុះ កម្តៅខ្លាំង គ្រោះរាំងស្ងួត និងគ្រោះមហន្តរាយផ្សេងៗទៀត តាមលំដាប់ពីធំទៅតូច។

- ការខាតបង់សេដ្ឋកិច្ចដោយសារគ្រោះមហន្តរាយដែលបានកើតឡើងនៅក្នុងឆ្នាំ២០២៤ មានចំនួន ២៤២ ប៊ីលានដុល្លារ ក្នុងនោះទ្វីបអាមេរិកមានចំនួនធំជាងគេ ១៨៦,៦ ប៊ីលានដុល្លារ ហើយគ្រោះមហន្តរាយខ្យល់ព្យុះធ្វើខាតបង់សេដ្ឋកិច្ចធំជាងគេ។

- ក្រៅពីគ្រោះមហន្តរាយធម្មជាតិក៏មានគ្រោះមហន្តរាយផ្សេងៗទៀត ដូចជាជំងឺឆ្លង និងសង្គ្រាមដែលបានកើតឡើបច្ចុប្បន្ន តែដោយសារពុំមានទិន្នន័យច្បាសលាស់ក្នុងរបាយការណ៍ពុំបានបង្ហាញទេ តែបានលើកឡើងពីការខូចខាត និងបាត់ជីវិតមនុស្សក្នុងសង្គ្រាមលោកលើកទី១ និងទី២។ ការបាត់បង់ទាហានក្នុងពេលប្រយុទ្ធក្នុងសង្គ្រាមលោកទាំង២លើកមានចំនួនសរុប២៤,៧លាននាក់ រងរបួស ៤២,២លាននាក់ និងជនស៊ីវិលដែលបានស្លាប់ចំនួន៥១,៨លាននាក់។

- ជំងឺឆ្លងជាពិសេសជំងឺកូវីដ១៩ បានបញ្ចប់ទៅហើយ និងបណ្តាលឲ្យមនុស្សស្លាប់ជិត ៧លាននាក់ និងធ្វើឲ្យខាតបង់សេដ្ឋកិច្ចពិភពលោកយ៉ាងធ្ងន់ធ្ងរ ដែលមិនអាចបំភ្លេចបាន។

## ឃ២. កម្ពុជា

### ឃ១. គ្រោះមហន្តរាយធម្មជាតិ

- នៅក្នុងប្រទេសកម្ពុជាគ្រោះមហន្តរាយធម្មជាតិដែលមានដូចជា គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត បាក់ច្រាំងឬដីចូលទន្លេ រន្ទះបាញ់ និងខ្យល់កន្ត្រាក់ពិតជាបានកើតឡើង ប៉ុន្តែនៅក្នុងឆ្នាំ២០២៥ គ្រោះមហន្តរាយដោយសាររន្ទះបាញ់បានធ្វើឲ្យប្រជាជនស្លាប់ច្រើនជាងគេ។ ក្រៅពីនេះទៀត ក៏មានគ្រោះថ្នាក់ដែលបានបង្កដោយអគ្គីភ័យ និងគ្រោះថ្នាក់ខ្យល់ព្យុះ។

